# ព្រះ
# ត្រៃបិដកបាលី
និង
សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ ជាតក
ទ្វាទសមភាគ
# ៦៣

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៥០៣

សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

ទ្វាទសមភាគ

៦៣

# សុត្តន្តបិដកេ
## ខុទ្ទកនិកាយស្ស ជាតកំ
## ទ្វាទសមោ ភាគោ

---

## មហានិបាតជាតកំ

### មហានារទកស្សបជាតកំ

(១) អហុ រាជា វិទេហានំ អង្គតិ នាម ខត្តិយោ
បហុតយោគ្គោ ធនិមា អនន្តពលបោរិសោ ។
សោ ច បណ្ណរសេ រត្តិំ បុរិមេ យាមេ អនាគតេ
ចាតុមាសា កោមុទិយា អមច្ចេ សន្និបាតយិ ។
បណ្ឌិតេ សុតសម្បន្នេ មិតបុព្វេ វិចក្ខណេ
វិជយញ្ច សុនាមញ្ច សេនាបតិំ អលាតកំ ។
តមនុបុច្ឆិ វេទេហោ បច្ចេកំ ព្រូថ សំ រុចិំ
ចាតុមាសា កោមុទជ្ជ ជុណ្ហំ ព្យបហតំ តមំ
កាយជ្ជ រតិយា រត្តិំ វិហរេមុ ឥមំ ឧតុំ ។

# សុត្តន្តបិដក
## ខុទ្ទកនិកាយ ជាតក
## ទ្វាទសមភាគ

---

## មហានិបាតជាតក

### មហានារទកស្សបជាតក

(១) (ព្រះសម្ពុទ្ធត្រាស់) ព្រះរាជារបស់ពួកជនអ្នកដែនវិទេហៈ ជាក្សត្រទ្រង់ព្រះនាមអង្គតិ មានយានច្រើន មានទ្រព្យច្រើន មានពួកពល មិនមានទីបំផុត ។ នៅពេលបឋមយាម ដែលមិនទាន់កន្លងនៃរាត្រី ជាថ្ងៃ ១៥ ជាទីបំផុតនៃខែទាំង ៤ ជាទីកើតនៃផ្កាកុមុទ ព្រះអង្គ ទ្រង់ប្រជុំអាមាត្យទាំងឡាយ ជាបណ្ឌិត បរិបូណ៌ដោយការស្តាប់ ជាអ្នកញញឹមមុននិយាយ ជាអ្នកមានប្រាជ្ញា ឈ្មោះវិជយៈ១ ឈ្មោះសុនាមៈ១ និងសេនាបតីឈ្មោះអលាតកៈ១ ។ ព្រះបាទវិទេហៈ ទ្រង់សួរអាមាត្យនោះជាលំដាប់ថា អ្នកទាំងឡាយ ចូរពោលតាមសេចក្តីពេញចិត្តរៀងៗខ្លួន ថ្ងៃនេះជារាត្រីជាទីបំផុតនៃខែទាំង ៤ ជាទីកើតនៃផ្កាកុមុទ មណ្ឌលព្រះចន្ទភ្លឺស្វាង កំចាត់បង់នូវងងឹត ថ្ងៃនេះយើងទាំងឡាយ គប្បីនៅដោយសេចក្តីត្រេកអរដូចម្តេច ក្នុងរាត្រីនេះ ។

(២) តតោ សេនាបតិ រញ្ញោ អលាតោ ឯតទព្រវិ
ហដ្ឋំ យោគ្គំ ពលំ សព្វំ សេនំ សន្នាហយាមសេ ។
និយ្យាម ទេវ យុទ្ធាយ អនន្តពលបោរិសា
យេ តេ វសំ ន អាយន្តិ វសំ ឧបនយាមសេ
ឯសា មយ្ហំ សកា ទិដ្ឋិ អជិតំ ឱជិនាមសេ[១] ។
(ខមស្សុ ទេវ យុទ្ធាយ ឯតំ ចិត្តមតំ មម)
(៣) អលាតស្ស វចោ សុត្វា សុនាមោ ឯតទព្រវិ
សព្វេ តុយ្ហំ មហារាជ អមិត្តា វសមាគតា ។
និក្ខិត្តសត្ថា បច្ចត្ថា និវាតមនុវត្តរេ
ឧត្តមោ ឧស្សវោ អជ្ជ ន យុទ្ធំ មម រុច្ចតិ ។
អន្នបានញ្ច ខជ្ជញ្ច ខិប្បំ អភិហរន្តុ តេ
រមស្សុ ទេវ កាមេហិ នច្ចគីតេសុ វាទិតេ ។

១ ម. ឱជិនាមសេ ។



(២) លំដាប់នោះ សេនាបតីរបស់ព្រះរាជា ឈ្មោះអលាតៈ បានក្រាបទូលថ្វាយព្រះរាជា យើងខ្ញុំនឹងតាក់តែងយាន ពល នឹងសេនាទាំងអស់ ដែលមានចិត្តរីករាយហើយ ។ បពិត្រព្រះសម្មតិទេព យើងខ្ញុំមានពួកពលមិនមានទីបំផុត នឹងចេញទៅដើម្បីច្បាំង ពួកព្រះរាជាណាមិនមកចុះអំណាច យើងនឹងនាំទូលមកចុះអំណាចព្រះអង្គ នេះជាសេចក្តីយល់ផ្ទាល់ខ្លួន របស់ទូលព្រះបង្គំជាខ្ញុំ ពួកទូលព្រះបង្គំជាខ្ញុំ នឹងផ្ចាញ់សត្រូវដែលមិនទាន់ផ្ចាញ់ ។ (បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងចម្បាំង នេះជាសេចក្តីចូលចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ) ។

(៣) អាមាត្យឈ្មោះសុនាមៈ បានស្តាប់ពាក្យអលាតសេនាបតីហើយ ក៏ក្រាបទូលថ្វាយព្រះរាជា បពិត្រមហារាជ ពួកសត្រូវទាំងអស់ មកចុះអំណាចព្រះអង្គស្រាប់ហើយតើ ។ ពួកសត្រូវ មានគ្រឿងសស្ត្រាដាក់ចុះហើយ តែងប្រព្រឹត្តបន្ទន់បន្ទាប មហាស្រពដ៏ឧត្តមនឹងមានក្នុងថ្ងៃនេះ ការច្បាំងទូលព្រះបង្គំជាខ្ញុំ មិនពេញចិត្តទេ ។ ជនទាំងឡាយ ចូរនាំយកបាយ ទឹក នឹងខាទនីយ៍ឆាប់មកថ្វាយព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរ ក្នុងការរាំច្រៀង នឹងគ្រឿងប្រគំ ដោយកាមទាំងឡាយចុះ ។

(៦) សុនាមស្ស វចោ សុត្វា វិជយោ ឯតទព្រវិ
សព្វេ កាមា មហារាជ និច្ចំ តវ ឧបដ្ឋិតា ។
ន ហេតេ ទុល្លភា ទេវ តវ កាមេហិ មោទិតុំ
សទាបិ កាមា សុលត្តិ[១] នេតំ ចិត្តមតំ មម ។
សមណំ ព្រាហ្មណំ វាបិ ឧបាសេម ពហុស្សុតំ
យោ នជ្ជ វិនយេ កង្ខំ អត្ថធម្មវិទូ ឥសេ ។

(៧) វិជយស្ស វចោ សុត្វា អង្គតិ ឯតទព្រវិ
យថា វិជយោ ភណតិ មយ្ហំ បេតំវ រុច្ចតិ ។
សមណំ ព្រាហ្មណំ វាបិ ឧបាសេម ពហុស្សុតំ
យោ នជ្ជ វិនយេ កង្ខំ អត្ថធម្មវិទូ ឥសេ ។
សព្វេវ សន្តា ករោថ មតឹ កំ ឧបាសេម បណ្ឌិតំ
យោ នជ្ជ វិនយេ កង្ខំ អត្ថធម្មវិទូ ឥសេ ។

១ ម. សុលភា ។



(៦) វិជយាមាត្យ បានស្តាប់ពាក្យសុនាមអាមាត្យហើយ ក៏ក្រាបទូលថ្វាយថា បពិត្រមហារាជ កាមគុណទាំងអស់ប្រាកដដល់ព្រះអង្គជានិច្ចហើយតើ ។ បពិត្រព្រះសម្មតិទេព កាមគុណទាំងនេះ ព្រះអង្គមិនមែនបានដោយក្រ ។ កាលបើព្រះអង្គ (ប្រាថ្នា) រីករាយដោយកាមគុណទាំងឡាយ កាមគុណទាំងឡាយ ព្រះអង្គបានសព្វ ៗ កាល នេះមិនមែនជាសេចក្តីពេញចិត្តរបស់ទូលព្រះបង្គំទាំងឡាយ ។ សមណព្រាហ្មណ៍ណា អ្នកដឹងនូវអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ គប្បីកាត់បង់នូវសេចក្តីសង្ស័យនៃយើងទាំងឡាយ ក្នុងថ្ងៃនេះបាន យើងទាំងឡាយនឹងចូលទៅរកសមណព្រាហ្មណ៍ ជាពហុស្សូតនោះ ។

(៧) ព្រះរាជា ទ្រង់ព្រះនាមអង្គតិ ទ្រង់ព្រះសណ្តាប់ពាក្យនៃវិជយាមាត្យហើយ ទ្រង់ត្រាស់ថា ការណ៍នេះពេញចិត្តដល់យើង ដូចវិជយាមាត្យពោល ៗ សមណព្រាហ្មណ៍ណា ជាអ្នកដឹងអត្ថនិងធម៌ជាអ្នកស្វែងរកគុណ គប្បីកាត់បង់សេចក្តីសង្ស័យនៃយើងទាំងឡាយបានក្នុងថ្ងៃនេះ យើងទាំងឡាយនឹងចូលទៅរកសមណព្រាហ្មណ៍ ជាពហុស្សូតនោះ ។ អ្នកទាំងអស់គ្នា ចូរធ្វើសេចក្តីយល់ ថា យើងគួរចូលទៅរកបណ្ឌិតណា ដែលជាអ្នកដឹងអត្ថ និងធម៌ ជាអ្នកស្វែងរកគុណ កាត់បង់សេចក្តីសង្ស័យនៃពួកយើងបានក្នុងថ្ងៃនេះ ។

[៦] វេទេហស្ស វចោ សុត្វា អលាតោ ឯតទព្រវិ
អត្ថាយំ មិគទាយស្មិំ អចេលោ ធីរសម្មតោ ។
គុណោ កស្សបគោត្តាយំ សុតោ ចិត្រកថី គណី
តំ ទេវ បយិរុបាសេមុ សោ នោ កង្ខំ វិនេស្សតិ ។

[៧] អលាតស្ស វចោ សុត្វា រាជា ចោទេសិ សារថឹ
មិគទាយំ គមិស្សាម យុត្តំ យានំ ឥធានយ ។

[៨] តស្ស យានំ អយោជេសុំ ទន្តំ រូបិយបក្ខរំ
សុក្កមដ្ឋបរិវារំ បណ្ឌរំ ទោសិនា មុខំ ។
តត្រាសុំ កុមុទា យុត្តា ចត្តារោ សិន្ធវា ហយា
អនិលូបមសមុប្បាតា[១] សុទន្តា សុវណ្ណមាលិនោ ។
សេតច្ឆត្តំ សេតរថំ សេតស្សា សេតពីជនី
វេទេហោ សហមច្ចេហិ និយំ ចន្ទោវ សោភតិ ។

១ ឱ. ម. អនិលុព្ភសមុប្បាតា ។



[៦] អលាតសេនាបតី បានស្តាប់ព្រះបន្ទូល នៃព្រះបាទវិទេហៈហើយ ក៏ក្រាបបង្គំទូលថា មានអចេលក១ អង្គនេះ ដែលគេសន្មតថាជាអ្នកប្រាជ្ញ នៅក្នុងមិគទាយវ័ន ។ អចេលកៈនេះ ឈ្មោះគុណៈ ជាកស្សបគោត្រ ជាអ្នកចេះដឹង ជាអ្នកពោលពាក្យវិចិត្រ ជាគណាចារ្យ បពិត្រព្រះសម្មតិទេព យើងខ្ញុំគួរចូលទៅគាល់អចេលកៈនោះ លោកនឹងបន្ទោបង់សេចក្តីសង្ស័យ នៃពួកយើងបាន ។

[៧] ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនៃអលាតសេនាបតីហើយ ទ្រង់បង្គាប់នាយសារថីថា យើងនឹងទៅកាន់មិគទាយវ័ន អ្នកចូរនាំយកនូវយានដែលទឹមហើយ មកក្នុងទីនេះ ។

[៨] ពួកនាយសារថី បានទឹមថ្វាយព្រះរាជានោះ នូវយានជាវិការៈនៃភ្លុក មានគ្រឿងជាវិការៈនៃប្រាក់ មានប្រដាប់ជាបរិវារដ៏សរលីង ហាក់ដូចមុខនៃរាត្រី ដែលប្រាសចាកទោស គឺដូចព្រះចន្ទ្រ (ពេញវង់) ក្នុងរថនោះ នាយសារថីបានទឹម សេះសិន្ធព ៤ មានសម្បុរដូចផ្កាកុមុទ មានសន្ទុះលឿនប្រៀបហៀលនឹងសន្ទុះខ្យល់ ដែលបង្ហាត់ល្អហើយ ប្រដាប់ដោយកម្រងផ្កាជាវិការៈនៃមាស ។ មានព្រះឆត្រស រថស សេះស ផ្លិតស ព្រះបាទវិទេហៈយាងទៅ (ដោយរថនោះ) ជាមួយនឹងពួកអាមាត្យ ក៏ល្អដូចជាព្រះចន្ទ្រ ។

គមទុយាយិំសុ ពហាកេ  វត្ថិទត្តក ពលី
អស្សប៉ិដ្ឋិគតា វីរា  នរា នរវរាធិបំ
សោ មុហុត្តំ យាយិត្វា  យានា ឱរុយ្ហ ខត្តិយោ
វេទេហោ សហាមច្ចេហិ  បត្តិ គុណមុបាគមិ ។
យេបិ តត្ថ តទា អាសុំ  ព្រាហ្មណិព្ភា សមាគតា
ន តេ អបនយិ រាជា  អកតំ ភូមិមាគតេ ។

(៥) តតោ សោ មុទុកា ភិសិយា  មុទុចិត្តកសន្ថតេ
មុទុប្បច្ចត្ថតេ រាជា  ឯកមន្តំ ឧបាវិសិ ។
និសជ្ជ រាជា សម្មោទិ  កថំ សារណិយំ តតោ
កច្ចិ យាបនិយំ ភន្តេ  វាតានមវិយគ្គតា[១] ។
កច្ចិ អកសិរា វុត្តិ  លភសិ បិណ្ឌយាបនំ
អប្បាពាធោ ចសិ កច្ចិ  ចក្ខុំ ន បរិហាយតិ ។

១ ម. វាតានមវិសគ្គតា ។ ឧ. វាតានមវិយគ្គតា ។



ពលដ៏ច្រើន ជាអ្នកទ្រទ្រង់លំពែងដ៏វិចិត្រ ជាអ្នកក្លាហាន ក៏ជិះលើខ្នងសេះ ហើយតាមសេ្ដចព្រះរាជានោះ ដែលជាធិបតីប្រសើរជាងនរៈ ។ ព្រះបាទវិទេហៈ ជាក្សត្រនោះ ក៏យាងទៅកាន់ទីខ្លួន ដោយមួយរំពេច ទ្រង់ចុះអំពីយាន យាងចូលគាល់ព្រះគុណ ជាមួយនឹងអាមាត្យ ក៏យាងទៅរកអចេលក ឈ្មោះគុណៈ ។ គ្រានោះ ព្រាហ្មណ៍និងគហបតីទាំងឡាយណា ដែលមកប្រជុំគ្នាក្នុងទីនោះ ព្រះរាជាក៏មិនបណ្ដេញព្រាហ្មណ៍និងគហបតីទាំងនោះ ដែលមកកាន់ទីដែលមិនបានធ្វើទុកសោះ ។

(៥) លំដាប់នោះ ព្រះរាជានោះ ចូលទៅគង់ទីដ៏សមគួរ (ប្រថាប់) លើពូកមានសម្ផស្សទន់ លើក្រាលដ៏វិចិត្រ មានសម្ផស្សទន់ លើទីដែលគេក្រាលដោយគម្រាលដ៏ទន់ ព្រះរាជាលុះគង់ហើយ ក៏រីករាយ (ជាមួយ) អចេលកៈ លំដាប់នោះ ទ្រង់ត្រាស់នូវពាក្យគួររលឹកជាបដិសណ្ឋារកិច្ចថា បពិត្រលោកដ៏ចំរើន សរីរៈរបស់លោក គាប់ប្រព្រឹត្តទៅបានទេឬ ពពួកខ្យល់ មិនប្រព្រឹត្តទៅ (ស្រួលក្នុងសរីរៈ) ទេឬ ។ ការប្រព្រឹត្តិ (ចិញ្ចឹមជីវិត) របស់លោក មិនលំបាកទេឬ លោកបានដុំបាយទូទៅឬ លោកមិនមានអាពាធទេឬ ចក្ខុរបស់លោកមិនសាបសូន្យទេឬ ។

[១០] តំ តត្ថ បដិសម្មោទិ    វេទេហំ វិនយេ រតំ

យាបនីយំ មហារាជ    សព្វមេតំ តទូភយំ ។

កច្ចិ កុហិញ្ចិ វេទេហ    បច្ចន្តា ន ពលីយរេ

កច្ចិ អរោគំ យោគ្គន្តេ    កច្ចិ វហតិ វាហនំ

កច្ចិ តេ ព្យាធយោ នត្ថិ    សរីរស្សុបតាបិយា ។

[១១] បដិសម្មោទិតោ រាជា    តតោ បុច្ឆិ អនន្តរា

អត្ថំ ធម្មញ្ច ញាយញ្ច    ធម្មកាមោ រថេសភោ ។

កថំ ធម្មំ ចរេ មច្ចោ    មាតាបិតូសុ កស្សប

កថញ្ចរេ អាចរិយេ    បុត្តទារេ កថញ្ចរេ ។

កថញ្ចរេយ្យ វុឌ្ឍេសុ    កថំ សមណព្រាហ្មណេ

កថញ្ច ពលកាយស្មឹ    កថំ ជនបទេ ចរេ ។

កថំ ធម្មំ ចរិត្វាន    មច្ចា គច្ឆន្តិ សុគ្គតឹ

កថញ្ចេកេ អធម្មដ្ឋា    បតន្តិ និរយំ អថោ ។



[១០] កាលនោះ ព្រះនារទៈ បានរីករាយតបនឹងព្រះបាទវិទេហៈ ដែលទ្រង់ត្រេកអរក្នុងវិន័យដោយពាក្យថា បពិត្រមហារាជ អាត្មាភាពល្មមញ៉ាំងសរីរៈឲ្យប្រព្រឹត្តទៅបាន ការដើមអំណើរទាំងអស់នុ៎ះ ដំណើរទាំងពីរដែលព្រះអង្គត្រាស់សួរហើយនោះ (ក៏ស្រួលដែរ) ។ បពិត្រព្រះបាទវិទេហៈ បច្ចន្តប្រទេសទាំងឡាយរបស់ព្រះអង្គមិនបះបោរទេឬ យានរបស់ព្រះអង្គ មិនខូចខាតទេឬ វាហនៈនៅប្រព្រឹត្តទៅបានទេឬ ព្យាធិទាំងឡាយដែលដុតកំដៅសរីរៈរបស់ព្រះអង្គ មិនមានទេឬ ។

[១១] លំដាប់នោះ ព្រះរាជាព្រះអង្គប្រសើរក្នុងរថ ទ្រង់ប្រាថ្នាធម៌ ក៏រីករាយតប រួចសួរអត្ថផង ធម៌ផង ហេតុដែលគួរដឹងផង ថា បពិត្រកស្សបគោត្រ សត្វគប្បីប្រព្រឹត្តធម៌ក្នុងមាតាបិតា តើដូចម្ដេច គប្បីប្រព្រឹត្តធម៌ក្នុងអាចារ្យ តើដូចម្ដេច គប្បីប្រព្រឹត្តធម៌ក្នុងកូននិងប្រពន្ធ តើដូចម្ដេច ។ គប្បីប្រព្រឹត្តធម៌ក្នុងមនុស្សចាស់ តើដូចម្ដេច ក្នុងសមណព្រាហ្មណ៍ តើដូចម្ដេច ក្នុងពួកពល តើដូចម្ដេច គប្បីប្រព្រឹត្តក្នុងជនបទ តើដូចម្ដេច ។ សត្វទាំងឡាយប្រព្រឹត្តធម៌ដូចម្ដេច លុះលះលោកនេះហើយ ទៅកាន់សុគតិ សត្វពួកខ្លះ ឋិតនៅក្នុងអធម៌ មានក្បាលសំយុងចុះធ្លាក់ទៅកាន់នរក តើដូចម្ដេច ។

[១៦] វេទេហស្ស វចោ សុត្វា   កស្សបោ ឯតទព្រវិ

សុណោហិ មេ មហារាជ   សច្ចំ អវិតថំ បទំ ។

នត្ថិ ធម្មចរិតស្ស   ផលំ កល្យាណបាបកំ

នត្ថិ ទេវ បរោ លោកោ   កោ តតោ ហិ ឥធាគតោ ។

នត្ថិ ទេវ បិតរោ វា   កុតោ មាតា កុតោ បិតា

នត្ថិ អាចរិយោ នាម   អទន្តំ កោ ទមេស្សតិ ។

សមតុល្យានិ ភូតានិ   នត្ថិ ជេដ្ឋាបចាយិកា

នត្ថិ ពលំ វីរិយំ វា   កុតោ ឧដ្ឋានពោរិសោ ។

និយតានិ ហិ ភូតានិ   យថា គោដវិសោ រថា

លទ្ធេយ្យំ លភតេ មច្ចោ   តត្ថ ទានផលំ កុតោ ។

នត្ថិ ទានផលំ ទេវ   អវសោ ទេវ វីរិយោ

ពាលេហិ ទានំ បញ្ញត្តំ   បណ្ឌិតេហិ បដិច្ឆិតំ

អវសា ទេន្តិ ធីរានំ   ពាលា បណ្ឌិតមានិនោ ។



(១៦) អចេលកៈជាកស្សបគោត្រ បានស្ដាប់ព្រះបន្ទូលព្រះបាទវិទេហៈ ហើយ ក៏ទូលថាថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវបទដែលពិត មិនឃ្លៀងឃ្លាតរបស់អាត្មាភាពចុះ ។ ផលល្អនិងអាក្រក់ របស់បុគ្គលអ្នកប្រព្រឹត្តធម៌មិនមានទេ បពិត្រព្រះសម្មតិទេព បរលោកក៏មិនមានដែរ ព្រោះថាក្នុងលោកនេះ មាននរណាមកពីបរលោក ។ បពិត្រព្រះសម្មតិទេព មួយទៀត មាតាបិតាមិនមានទេ មាតានឹងមានពីណា បិតានឹងមានពីណា បុគ្គលដែលឈ្មោះថាអាចារ្យមិនមានទេ បុគ្គលណានឹងទូន្មានបុគ្គលដែលទូន្មានមិនបាន ។ សត្វទាំងឡាយមានគុណស្មើ ៗ គ្នា សត្វទាំងឡាយ ជាអ្នកគោរពកោតក្រែងបុគ្គលចាស់ មិនមានទេ កំឡាំងក្ដី ព្យាយាមក្ដី ក៏មិនមានដែរ បុរសអ្នកព្យាយាមនឹងមានពីណា ។ ព្រោះថា សត្វទាំងឡាយទៀត ដូចទូកតូចចងភ្ជាប់នឹងទូកធំ សត្វរមែងបានរបស់ដែលត្រូវបាន ផលទាននឹងបានក្នុងលោកនោះ នឹងមានពីណា ។ បពិត្រព្រះសម្មតិទេព ផលទានមិនមានទេ បពិត្រព្រះសម្មតិទេព សេចក្ដីព្យាយាម មិនមានអំណាចទេ ទានគឺពួកជនពាលទេតើបញ្ញត្តមក ពួកបណ្ឌិត ចាំតែទទួលយកនូវទាននោះ ពួកជនពាលជាអ្នកមិនមានអំណាច សំគាល់ខ្លួនថាជាបណ្ឌិត រមែងឲ្យទានដល់បណ្ឌិតទាំងឡាយ ។

(១៣) សត្តិមេ សស្សតា កាយា អច្ឆេជ្ជា អវិកោបិនោ
តេជោ បឋវី អាបោ ច វាយោ សុខទុក្ខញ្ចិមេ ។
ជីវេ ច សត្តិមេ កាយា យេសំ ឆេត្តា ន វិជ្ជតិ
នត្ថិ ហន្តា វ ឆេត្តា វា ហញ្ញេ យេវាបិ កោចិ នំ ។
អន្តរេនេវ កាយានំ សត្ថានិ វីតិវត្តរេ
យោ ចាបិ សិរមាទាយ បរេសំ និសិតាសិនា
ន សោ ឆិន្ទតិ តេ កាយេ តត្ថ កា បរិទេវនា ។
ចុល្លាសីតិមហាកប្បេ សព្វេ សុជ្ឈន្តិ សំសរំ
អនាគតេ តម្ហិ កាលេ សញ្ញតោបិ ន សុជ្ឈតិ ។
ចរិត្វាបិ ពហុំ ភទ្រំ នេវ សុជ្ឈន្តិនាគតេ
បាបញ្ចេបិ ពហុំ កត្វា តំ ខណំ នាតិវត្តរេ ។
អនុបុព្វេន នោ សុទ្ធិ កប្បានំ ចុល្លាសីតិយា
និយតឹ នាតិវត្តាម វេលន្តមិវ សាគរោ ។
(១៤) កស្សបស្ស វចោ សុត្វា អលាតោ ឯតទព្រវិ
យថា ភទន្តោ ភណតិ មយ្ហមេតំ រុច្ចតិ ។
អហម្បិ បុរិមំ ជាតឹ សរេ សំសរិតត្តនោ



(១៣) ភ្លើង ដី ទឹក ខ្យល់ សុខ ទុក្ខ និងជីវិត ពាំង ៧ នេះឈ្មោះថាពួកទៀង ជាសភាវៈឲ្យដាច់មិនបាន ឲ្យកំរើកមិនបាន ។ ពួកទៀងពាំង ៧ នេះតែងរស់នៅជាដរាប ដែលបុគ្គលកាត់ហើយមិនឈ្មោះជាកាត់ បុគ្គលអ្នកសម្លាប់ក្តី បុគ្គលអ្នកកាត់ក្តីមិនមាន អ្នកណាឈ្មោះថា សម្លាប់អ្នកណាបាន ។ គ្រឿងសស្ត្រាពាំងឡាយ គ្រាន់តែចូលទៅកន្លងចន្លោះនៃពួក(ទៀង)ប៉ុណ្ណោះ បុគ្គលណាយកដាវដែលសំលៀងហើយ កាត់ក្បាលជនដទៃ បុគ្គលនោះមិនឈ្មោះថាកាត់ពួក (ទៀង) ពាំងនោះទេ ផលនៃបាបកម្មការកាត់នោះមិនមានក៏ណា ។ សត្វពាំងអស់ កាលអន្ទោលអស់មហាកប្ប ៨៤ ទើបបរិសុទ្ធបាន កាលបើមិនទាន់ដល់កាលនោះបុគ្គលសង្រួមស្រួមក៏មិនបរិសុទ្ធ ។ កាលបើមិនទាន់ដល់កំណត់នោះ ពួកសត្វសូម្បីប្រព្រឹត្តល្អច្រើន ក៏មិនបរិសុទ្ធ ចុះជាធ្វើបាបច្រើនក៏មិនកន្លងហួសនូវខណៈនោះដែរ ។ សេចក្តីបរិសុទ្ធនៃយើងពាំងឡាយតាមលំដាប់នៃកប្ប ៨៤ យើងពាំងឡាយមិនកន្លងហួស (កំណត់) ដ៏ទៀងនោះទេ ដូចសាគរមិនកន្លងហួសច្រាំង ។

(១៤) អលាតសេនាបតី លុះស្តាប់ពាក្យនៃលោកៈជាកស្សបគោត្រហើយក៏ពោលដូច្នេះថា លោកដ៏ចំរើនពោលយ៉ាងណា ពាក្យនោះគាប់ចិត្តខ្ញុំដែរ ។ ខ្ញុំរលឹកជាតិរបស់ខ្លួនក្នុងកាលមុន ដែលអន្ទោលទៅហើយថា

បិង្គលោ នាមហំ អាសឹ លុទ្ទោ គោឃាតកោ បុរេ ។
ពារាណសិយំ ឥទ្ធាយំ ពហុំ បាបំ កតំ មយា
ពហូ មយា ហតា បាណា មហឹសា សូករា អជា ។
តតោ ចុតោ ឥធ ជាតោ ឥទ្ធេ សេនាបតិកុលេ
នត្ថិ នូន ផលំ បាបេ យោហំ ន និរយំ គតោ ។
(១៥) អថេត្ថ វីជកោ នាម ទាសោ អាសិ បដច្ចរី[១]
ឧបោសថំ ឧបវសន្តោ គុណសន្តិកុបាគមិ ។
កស្សបស្ស វចោ សុត្វា អលាតស្ស ច ភាសិតំ
បស្សសន្តោ មុហុំ ឧណ្ហំ រុទំ អស្សូនិ វត្តយិ ។
(១៦) តមបុច្ឆិ វេទេហោ កិមត្ថំ សម្ម រោទសិ
កិំ តេ សុតំ វា ទិដ្ឋំ វា កិំ មំ វេទេសិ វេទនំ ។
(១៧) វេទេហស្ស វចោ សុត្វា វីជកោ ឯតទព្រវិ
នត្ថិ មេ វេទនា ទុក្ខា មហារាជ សុណោហិ មេ ។
អហម្បិ បុរិមំ ជាតិំ សរាមិ សុខមត្តនោ
សាកេតាហំ បុរេ អាសឹ ភាវសេដ្ឋី គុណេ រតោ ។

១ ឱ. បលច្ចា ។ ម. បដិច្ចរី ។



ក្នុងកាលមុន ខ្ញុំកើតជាមនុស្សប្រព្រឹត្តអាក្រក់ ឈ្មោះបិង្គលៈ ជាអ្នកសម្លាប់គោ ។ ខ្ញុំបានធ្វើបាបដ៏ច្រើន ក្នុងក្រុងពារាណសី ជាក្រុងសម្បូរ ខ្ញុំបានសម្លាប់សត្វដ៏ច្រើន គឺក្របី ជ្រូក ពពែ ។ លុះខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានមកកើតក្នុងត្រកូលសេនាបតី ដ៏ស្តុកស្តម្ភក្នុងទីនេះ ផលបាបរបស់ខ្ញុំមិនមានពិត បានជាខ្ញុំមិនទៅនរក ។

(១៥) ព្រោះនោះ ក្នុងក្រុងមិថិលា មានបុគ្គលម្នាក់ ជាទាសៈឈ្មោះ វីជកៈ រក្សាឧបោសថហើយ ចូលទៅកាន់សំណាក់នៃអាជីវកៈ ឈ្មោះគុណៈ ។ វីជកៈលុះស្តាប់ពាក្យរបស់គុណៈ ជាកស្សបគោត្រ និងពាក្យដែលអលាតសេនាបតីពោលហើយ ក៏ដកដង្ហើមចេញដ៏ក្តៅរឿយៗ យំស្រក់ទឹកភ្នែក ។

(១៦) ព្រះបាទវិទេហៈ ទ្រង់ត្រាស់សួរវីជកៈនោះថា ម្នាលសំឡាញ់ អ្នកយំ ដើម្បីអ្វី អ្នកបានឮ ឬបានឃើញអ្វី អ្នកដល់នូវទុក្ខវេទនា ដូចម្តេច ចូរប្រាប់ឲ្យយើងដឹងផង ។

(១៧) វីជកៈ បានស្តាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយ ក្រាបបង្គំទូលថា បពិត្រមហារាជ ទុក្ខវេទនារបស់ទូលព្រះបង្គំជាខ្ញុំ មិនមានទេ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ចុះ ។ ទូលព្រះបង្គំជាខ្ញុំ រលឹកឃើញនូវសេចក្តីសុខរបស់ទូលព្រះបង្គំជាខ្ញុំ ក្នុងជាតិមុន កាលដែលបានកើតជាភាវសេដ្ឋី ជាអ្នកត្រេកអរក្នុងគុណធម៌ ក្នុងបុរីឈ្មោះសាកេត ។

សម្មោ ព្រាហ្មណិក្ខនំ សិរិកាគរោ សុចិ
ន ចាបិ ចាបកំ កម្មំ សករ៉ិ កាគមត្តនោ ។
ករោ ធុតាហំ វេធយា ឥង ជាតោ ឆុត្តិយា
កត្តម្ហិ ក្ខត្តជាសំយា យតោ ជាតោ សុខុត្តតោ ។
សំវេឡ្យំ ឆុត្តតោ សង្ខោ សមខាំយមជិដ្ឋោ
ឱបឡ្យកាតំ កត្តស្ស ឆធាមិ យោ មេ ឥទ្ធតំ ។
ធាតុឆ្ឆសិ បញ្ចសិ សធា ឧបរំសាមហំ
ន ចាបិ ចាណោហិសាមិ វេយ្យញ្ញាចំ វិវជ្ជយិ ។
សព្វមេវ ហំ ធ្មុធតំ សុចិណ្ណំ ករំតំ ចិច្ចលំ
ឆិនិត្តំ ឧញ្ញិធំ សំលំ អឈោតោ កាសតិ យជា ។
កាលិមេវចុឆ កណ្ហាមំ អសិមេឡា ឆុត្តកោ យជា
កាជំ អឈោតោ ឥណ្ហាតិ ក៏ឥកេ សិក្ខាតោ យជា ។
ទ្វារំ ឧបឡ្ឌីឋសព្វាមិ យោឆ ឥញ្ញាមំ សុត្តតិ
ឥស្មា រាជ ឧកេធាមំ សុត្វា កស្សបកាសំតំ ។



ខ្ញុំព្រះបង្គំជាខ្ញុំ ក្រៅពួកព្រាហ្មណ៍ទាំងតាមតី សារសៀកហើយ ជាជាអ្នកប្រព្រឹត្ត ក្នុងការតែងការវែកពាន ជាអ្នកមានការតេជះស្អាត នៃខ្ញុំព្រះបង្គំជាខ្ញុំ មិនហើនធ្វើកនាខ្ញុំនាំកើតក្រក់របស់ខ្លួនផែលធ្វើហើយនេះ ។ បពិត្រព្រះមហារាជ: ខ្ញុំព្រះបង្គំជាខ្ញុំលុះស្បែកតាកអត្តភាពនោះ ក៏មានកើតក្នុងត្រកូលក្ខត្តិយៈ ជាស្រីខត្តិយ ក្នុងក្រេងមិនឈ្លោះ ពាក់ពីកើតមក ខ្ញុំព្រះបង្គំជាខ្ញុំ ចុតិចាកក្រោលោក ។ ស្ដេចខ្ញុំព្រះបង្គំជាខ្ញុំចុតិអយាក់នេះ ក៏តាំងនៅក្នុងការប្រព្រឹត្តិស្មើ តែងខ្សែក្ដីតាក់គណ្ដាលផល់បុគ្គលអ្នកក្រោការ ។ តែងតែក្សា(១០ព្រះសប់)អស់ថ្ងៃទី១៤ ទាំងថ្ងៃទី១៥ សព្វកាល ទាំងមិនបៀតបៀនសត្វផងចុងនៀវបង់ការលួចលាក់ផង ។ អំពើផែលសន្សំល្អហើយទាំងអស់នេះ ជាបេសអំផលរបាំយកិត ខ្ញុំព្រះបង្គំជាខ្ញុំសំគាល់ថា សីលនេះ មិនមានប្រយោជន៍ទេ ដូចជាអណ្ដាតសេតាបតីពាលផែ ។ ផែលខ្ញុំព្រះបង្គំជាខ្ញុំទទួលទុក្ខទោស ដោយជាក់ស្ដែងនេះ ដូចជាអ្នកលេងផែលមិនមានសិល្បៈ ឬដូចជាអណ្ដាតសេតាបតីជាអ្នកលេងស្កាបុកនៀនហើយ ក៏បុគ្គលទទួលការឈ្នះ ។ ខ្ញុំព្រះបង្គំមិនឃើញការសម្រាប់ទៅសុគតិនោះ បពិត្រព្រះរាជា ព្រោះហេតុនោះបុគ្គលខ្ញុំព្រះបង្គំជាខ្ញុំយំខ្លួន ព្រោះបានស្ដាប់ពាក្យសិកនៃអបលក: ជាកស្សបគោត្រ ។

(១៨) វីជកស្ស វចោ សុត្វា គុណោ អង្គតិមព្រវិ
នត្ថិ ទ្វារំ សុគតិយា និយតំ កង្ខ វីជក ។
សុខំ វា យទិ វា ទុក្ខំ និយតិយា កិរ លព្ភតិ
សំសារសុទ្ធិ សព្វេសំ មា តុរិត្ថោ អនាគតេ ។
អហញ្ច បុព្វេ កល្យាណោ ព្រាហ្មណេសុ ព្យាវដោ[១]
វោហារមនុសាសន្តោ រតិហីនោ តទន្តរា ។
(១៩) បុនបិ ភន្តេ ទក្ខេមុ សង្គតិ ចេ ភវិស្សតិ
ឥទំ វត្វាន វេទេហោ បច្ចគា សនិវេសនំ ។
(២០) តតោ រត្យា វិវសានេ ឧបដ្ឋានម្ហិ អង្គតិ
អមច្ចេ សន្និបាតេត្វា ឥទំ វចនមព្រវិ ។
ចន្ទកេ មេ វិមានស្មឹ សទា កាមេ វិធេន្តុ មេ
មា ឧបគច្ឆុំ អត្ថេសុ គុយ្ហប្បកាសិយេសុ ច ។

១. ឱ. ព្យាវដោ ។ ម. វ្យាវដោ ។



(១៨) ព្រះរាជាព្រះនាមអង្គតិ ទ្រង់ព្រះសណ្ដាប់ពាក្យវីជកៈ ហើយទ្រង់ត្រាស់ថា ម្នាលវីជកៈ ទ្វារនៃសុគតិមិនមានទេ អ្នកចូរសង្ឃឹមការជឿ ទៀងចុះ ។ បានឮថា សុខឬទុក្ខ ជារបស់ទៀង ដែលពួកសត្វតែងនឹងបាន សេចក្ដីបរិសុទ្ធិ ព្រោះសង្សារ របស់សត្វទាំងអស់ (រមែងមាន) អ្នកកុំប្រញាប់ចង់ឃើញ ក្នុងកាលដែលមិនទាន់ដល់ (កំណត់នោះ) ឡើយ ។ ក្នុងកាលមុន យើងជាបុគ្គលល្អ បានខ្វល់ខ្វាយ (ចំពោះ) នូវពួកព្រាហ្មណ៍ និងគហបតី កាលប្រៀនប្រដៅនូវវោហារ (រាជកិច្ច) ក៏សាបសូន្យចាកសេចក្ដីត្រេកអរ (ក្នុងកាមគុណ) ជាលំដាប់ ។

(១៩) ព្រះរាជា ទ្រង់ត្រាស់នឹងនារទៈ ជាកស្សបគោត្រថា បពិត្រលោកដ៏ចំរើន ប្រសិនបើមានការប្រជុំ យើងនឹងជួបគ្នានូវអ្នកទៀត ។ ព្រះបាទវិទេហៈ ទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទ្រង់ត្រឡប់ទៅកាន់ព្រះនិវេសន៍របស់ព្រះអង្គវិញ ។

(២០) លំដាប់នោះ លុះកន្លងរាត្រីហើយ ព្រះបាទអង្គតិ ទ្រង់ប្រជុំពួកអាមាត្យក្នុងទីជាទីបម្រើ ហើយត្រាស់ព្រះតម្រាស់ដូច្នេះថា អាមាត្យទាំងឡាយ ចូរចាត់ចែងកាមទាំងឡាយ ក្នុងវិមានចន្ទកៈ របស់យើង សព្វៗកាល នាកាលសេចក្ដីកំបាំង និងសេចក្ដីដែលគួរបើកឡើងហើយ អាមាត្យឯណានីមួយ កុំមកកាន់យើងឡើយ ។

វិជយោ ច សុនាមោ ច សេនាបតិ អលាតកោ
ឯតេ អត្ថេ និសីទន្តុ វោហារកុសលា តយោ ។
ឥតិ វត្វាន វេទេហោ កាមេវ ពហុ មញ្ញថ
ន ចាបិ ព្រាហ្មណិព្ភេសុ អត្ថេ កិស្មិញ្ចិ តាវទេ ។

(៦១) តតោ ទ្វេសត្តរត្តស្ស វេទេហស្សត្រជា បិយា
រាជកញ្ញា រុចា[១] នាម ធាតិមាតរមព្រវិ ។
អលង្ករោថ មំ អម្ម សខិយោ ច អលង្ករោន្តុ មេ
សុវេ បណ្ណរសោ ទិព្យោ គច្ឆំ បិតុស្ស សន្តិកេ ។
តស្សា មាល្យំ អភិហរឹសុ ចន្ទនញ្ច មហារហំ
មណិសង្ខមុត្តារតនំ នានារត្តេ ច អម្ពរេ ។
តញ្ច សោវណ្ណមយេ បីឋេ និសិន្នំ ពហុកិត្តិយោ
បរិកិរិយ អសោភិំសុ រុចំ រុចិរវណ្ណិនឹ ។

(៦២) សា ច សខិមជ្ឈគតា សព្វាភរណភូសិតា
សតេរិតា អព្ភមិវ ចន្ទកំ បាវិសី រុចា ។

១ ម. រុជា នាម ។



អាមាត្យឈ្មោះវិជយៈ១ ឈ្មោះសុនាមៈ១ អលាតសេនាបតី១ ទាំង ៣ នេះ ជាអ្នកឈ្លាសវៃក្នុងវោហារ (រាជកិច្ច) ចូរអង្គុយកាត់ក្តីវិនិច្ឆ័យសេចក្តីនេះចុះ ។ ព្រះបាទវេទេហៈ លុះត្រាស់ព្រះតម្រាស់នេះហើយ ក៏សំគាល់កាមគុណទាំងឡាយដ៏ច្រើន ឈប់ខ្វល់ខ្វាយចំពោះព្រាហ្មណ៍គហបតីនិងសេចក្តីណានីមួយ ។

(៦១) តាំងពីកាលនោះមក រហូតដល់គ្រប់១៤ ថ្ងៃ រាជកញ្ញា របស់ព្រះបាទវេទេហៈ ព្រះនាមរុចា ជាទីគាប់ចិត្ត ជាទីស្រឡាញ់ បានពោលចំពោះមេដោះថា ម៉ែ សូមម៉ែប្រដាប់ស្អិតស្អាងខ្ញុំ ទាំងពួកស្រីជាសំឡាញ់របស់ខ្ញុំ ក៏ចូរប្រដាប់ស្អិតស្អាងដែរ ស្អែក ជាថ្ងៃ ទី ១៥ ជាថ្ងៃទិព្វ ខ្ញុំនឹងទៅកាន់សំណាក់បិតា ។ ស្រីទាំងឡាយបាននាំមកនូវផ្កាកម្រងនិងខ្លឹមចន្ទន៍ កែវមណី ស័ង្ខ កែវមុក្តា ដែលមានថ្លៃដ៏ច្រើននិងសំពត់អម្ពរណ៍មានពណ៌ក្រហមផ្សេងៗ ថ្វាយព្រះរាជកញ្ញានោះ ។ ពួកស្រីដ៏ច្រើន បានហែហមរោមព្រះរាជកញ្ញាព្រះនាមរុចានោះ ដែលមានសម្បុរដ៏រុងរឿង កំពុងគង់លើតាំងជាវិការៈនៃមាស ។

(៦២) ឯព្រះនាងរុចានោះ ស្អិតស្អាង ដោយគ្រឿងអាភរណៈទាំងពួង ឋិតនៅកណ្តាល នៃពួកស្រីជាសំឡាញ់ បានចូលទៅកាន់វិមានចន្ទក៍ ដូចជាផ្លេកបន្ទោរ ចាក់ស្រើយមេឃ ។

ឧបសង្កមិត្វា វេទេហំ   វន្ទិត្វា វិនយេ រតំ
សុវណ្ណចិតកេ បីឋេ   ឯកមន្តំ ឧបាវិសិ ។

(២៣) តញ្ច ទិស្វាន វេទេហោ   អច្ឆរានំវ សង្គមំ
រុចំ សខិមជ្ឈគតំ   ឥទំ វចនមព្រវិ ។

កច្ចិ រមសិ បាសាទេ   អន្តោ បោក្ខរណឹ បតិ
កច្ចិ ពហុវិធំ ខជ្ជំ   សទា អភិហរន្តិ តេ ។

កច្ចិ ពហុវិធំ មាល្យំ   ឱចិនិត្វា កុមារិយោ
ឃរកេ ករោថ បច្ចេកំ   ទិវា រតិរតា អហុ ។

កេន វា វិកលំ តុយ្ហំ   កឹ ខិប្បំ អាហរន្តុ តេ
មនោ ករស្សុ កុដ្ឋមុខី   អបិ ចន្ទសមំ ហិ តេ ។

(២៤) វេទេហស្ស វចោ សុត្វា   រុចា បិតរមព្រវិ
សព្វមេតំ មហារាជ   លព្ភតិស្សរសន្តិកេ ។

សុវេ បណ្ណរសោ ទិព្យោ   សហស្សំ អាហរន្តុ មេ
យថា ទិន្នញ្ច ទស្សាមិ   ទានំ សព្វវណីស្វហំ ។



លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបាទវេទេហៈ ដែលត្រេកត្រេកអរក្នុងវិន័យ ហើយយាងចូលទៅគង់លើតាំង ដែលវិចិត្រដោយមាស ក្នុងទីសមគួរ ។

(២៣) ព្រះបាទវេទេហៈ ទ្រង់ទតឃើញកាប្រជុំនោះ ដូចជាទីប្រជុំនៃពួកស្រីទេពអប្សរ ទើបត្រាស់ព្រះតម្រាស់នេះនឹងនាងរុចា ដែលឋិតនៅត្រង់កណ្តាល នៃពួកស្រីជាសំឡាញ់ថា នាងត្រេកអរក្នុងប្រាសាទស្រះបោក្ខរណីខាងក្នុងដែរឬ ពួកជនបាននាំមកនូវវត្ថុមានប្រការដ៏ច្រើន ដល់នាងសព្វកាលដែរឬ ។ នាងទាំងឡាយជាកុមារី បានក្រងកម្រងផ្កាដ៏ច្រើន ជាស្រីនៅលេងនឹងល្បែង ត្រេកអរដោយសេចក្តីសប្បាយ បានធ្វើផ្ទះតូចៗទាំងឡាយផ្សេងៗគ្នានូវដែរឬ ។ មួយទៀត នាងខ្វះខាត ដោយវត្ថុ ដែលទាំងឡាយបាននាំមក យ៉ាងណាដល់នាងដែរឬ ម្ចាស់នាងមានភក្ត្រជាក់លាបល្អ នាងចូរធ្វើតាមចិត្តចុះ សូម្បីរបស់ស្មើដោយព្រះចន្ទ ក៏ពុកផ្តល់ឲ្យនាងដែរ ។

(២៤) នាងរុចា បានស្តាប់ព្រះរាជឱង្ការព្រះបាទវេទេហៈហើយ ទូលតបព្រះបិតាថា បពិត្រមហារាជ របស់ទាំងអស់នុ៎ះ ខ្ញុំម្ចាស់តែងបានក្នុងសំណាក់របស់ព្រះអង្គជាឥស្សរៈ ។ ស្អែកជាថ្ងៃ ទី ១៥ ជាទិព្វ សូមឲ្យពួកជននាំកហាបណៈមួយពាន់ ដល់ខ្ញុំម្ចាស់ៗ នឹងឲ្យទានចំពោះវណិពកៈទាំងអស់ តាមទំនងដែលខ្ញុំម្ចាស់ធ្លាប់ឲ្យហើយ ។

(២៥) រញ្ញោយ វេឧំ សុត្វា     ភជា អត្តត្ថមព្រវិ
កហុំ វិលាសិតំ វិត្តំ     និរត្ថំ អជលំ គយា ។
ទ្វេ តោសមេ វសំ និច្ចំ     អន្ធកានំ ធ កុញ្ចសំ
និយតេតំ អក្កត្តំ     ធត្ថំ បុញ្ញំ អកុញ្ញតោ
វិជានាមិ ហំ សុត្វាន     គតា កាសរូបកាសិតំ
ចស្សសាវេត្តា ឥមុំ ឡណ្ហំ     វុធំ អស្សុធិ វត្តយំ ។
យាវ រុមេ ធីរមោហា     មា ភត្តមបតាមយិ
ធត្ថិ កាវេត្ត បកោ លោកោ     កំ និរត្ថំ វិហញ្ញសិ ។
(២៦) កេធហស្ស វតោ សុត្វា     រុចា រុចិរវណ្ណិនី
ជាធិ បុញ្ញមេវំ ធម្មំ     ចិតវំ ឯតធព្រវិ ។
សុតមេវំ ឲ្យ កាសិ     បច្ចាតំ និទ្ទិនិ ឋយា
កាល្យមេសេវិ យោ ហោតិ     ការោវ សមបដ្ឋធ ។
ឥមុទ្ធេ ហំ ឥមុទ្ធមាតម្ម     គិយេហ្ស ភោហំ និតក្ខតំ
បដិរូបំ អហរេន     វិជានេធ ធម្មុត្តិ ។



(២៥) ព្រះរាជាអង្គតិ ទ្រង់ព្រះសណ្ដាប់ពាក្យនាងរុចាហើយ ទ្រង់ត្រាស់ថា ទូលព្រះច្រើនឈ្មោះជានាងធ្វើឲ្យវិនាស ធ្វើឲ្យឥតប្រយោជន៍ធ្វើឲ្យឥតផលហើយ ។ នាងក្មេងមួយសំ មិនបរិភោគបាយទឹក ជាទិដ្ឋ ឯបាយនឹងទឹកដែលនាងមិនបរិភោគនេះ ជារបស់ទៀត បុណ្យមិនមានដល់បុគ្គលដែលមិនបរិភោគទេ ដូចយ៉ាងឥតសារៈឈ្មោះវីជកៈបានស្ដាប់ពាក្យគេលេខការៈ ជាកស្សបគោត្រ គុណសារសារ កំពង់ផ្អើមចេញដីក្ដៅរឿយៗ យំសម្រែកទឹកភ្នែក ។ ម្នាលនាងរុចា នាងការរស់នៅដោយបណា កុំអត់បាយឡើយ ម្នាលនាងដ៏ចំរើន បរលោកមិនមានទេ ព្រោះហេតុអ្វីនាងច្រើនឲ្យលំបាក ឥតប្រយោជន៍ ។

(២៦) នាងរុចា មានសម្បុរដ៏ល្អរឿង បានស្ដាប់ព្រះបន្ទូលព្រះបាទវិទេហៈកាលដ៏ឥតមិនដែលមើលនឹងនាងរុជ ទើបពោលពាក្យនេះនឹងបិតាថាពីដើម ខ្ញុំម្ចាស់ត្រាច់នៅក្នុង (ថ្ងៃនេះ) រឿងនេះខ្ញុំម្ចាស់ឃើញជាក់ច្បាស់ហើយថា បុគ្គលណា សេពគប់នឹងជនពាល បុគ្គលនោះទៅជាបុគ្គលពាលដែរ ។ ដូចជា បុគ្គលវង្វេង អាស្រ័យនឹងបុគ្គលវង្វេងរមែងដល់សេចក្ដីវង្វេងដ៏លើសលុប អលាតសេនាបតី នឹងគុណៈឈ្មោះវីជកៈ គួរវង្វេងទៅចុះ (តែព្រះអង្គកុំវង្វេងឡើយ) ។

[៤៧] ត្វញ្ច នេកំ សព្ពញ្ញោ ឯកេ អត្ថស្ស កោវិទោ
ការំ ពាលេហិ សង្គោ(១) ហីនមិច្ឆមុទាគមិ ។
សចេ ហិ សំសារបថេន សុជ្ឈតិ
និរត្ថិយា បព្ពជ្ជា គុណស្ស
កីដោវ អគ្គិំ ជលិតំ អបាបតំ
អាបជ្ជតិ(២) មោហមុឡ្ហោ នគ្គភាវំ ។
សំសារសុទ្ធីតិ បុរេ និវិដ្ឋា
កម្មំ វិទ្ធំសេន្តិ ពហូ អជានំ(៣)
បុព្វេ កលិ ទុគ្គហិតោវ អត្ថោ
ទុម្មោចយា ពលិសា អម្ពុជោវ ។

[៤៨] ឧបមន្តេ ការិស្សាមិ មហារាជ តវត្ថិយា
ឧបមាយមិធេកច្ចេ អត្ថំ ជានន្តិ បណ្ឌិតា ។
វាណិជានំ យថា នាវា អប្បមាណភរា គរុ
អតិភារំ សមាទាយ អណ្ណវេ អវសីទតិ ។
ឯវមេវ នរោ បាបំ ថោកំ ថោកម្បិ អាចិនំ
អតិភារំ សមាទាយ និរយេ អវសីទតិ ។

១ ឱ. ម. សង្គំ ។ ២ ឱ. ឧបបជ្ជតិ ។ ម. ឧបបជ្ជតិ ។ ៣ ម. ពហូ បជា ។



[៤៧] បពិត្រព្រះសម្មតិទេព ព្រះអង្គប្រកបដោយបញ្ញា ជាអ្នកប្រាជ្ញ ឈ្លាសក្នុងសេចក្តីចំរើន ហេតុអ្វី ព្រះអង្គប្រហែលនឹងពួកជនពាល ហើយលុះទៅផ្លូវថោកទាប ។

ប្រសិនបើ សត្វបរិសុទ្ធ ដោយគន្លងនៃសំសារ បព្វជ្ជានៃអចេលកៈឈ្មោះគុណៈ ក៏មិនមានប្រយោជន៍ដែរ អចេលកៈឈ្មោះគុណៈ ជាអ្នកល្ងង់ដោយមោហៈ ដល់នូវភាពជាអ្នកអាក្រាត ដូចជាសត្វកណ្ដូប ធ្លាក់ចូលក្នុងភ្លើងកំពុងឆេះ ។ ជនទាំងឡាយច្រើននាក់ កាលមិនដឹង ត្រូវអចេលកៈឈ្មោះគុណៈទូន្មានហើយ ក្នុងកាលមុនថា សេចក្តីបរិសុទ្ធិព្រោះសំសារដូច្នេះ ក៏បដិសេធនូវកម្មចេញ ប្រយោជន៍ដែលជនកាន់មិនល្អហើយក្នុងកាលមុន ក៏នាំទៅជាទោស ដូចត្រីដែលរួចអំពីសន្ទូច បានដោយក្រ ។

[៤៨] បពិត្រមហារាជ ខ្ញុំម្ចាស់នឹងធ្វើឧបមាថ្វាយព្រះអង្គ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ព្រោះថាបណ្ឌិតពួកខ្លះក្នុងលោកនេះ រមែងដឹងសេចក្តីដោយពាក្យឧបមា ។ ទូកនៃរបស់ពួកឈ្មួញ ផ្ទុកភារៈធ្ងន់ហួសប្រមាណ នាំទៅនូវភារៈធ្ងន់លើសលុប រមែងលិច ក្នុងសមុទ្រយ៉ាងណា នរជនកាលសន្សំបាបបន្តិចម្តង ៗ ឈ្មោះថាជាអ្នកកាន់យកនូវភារៈដ៏លើសលុប រមែងលិចក្នុងនរក យ៉ាងនោះដែរ ។

ន តាវ កាលោ បរិបុរោ អលាតស្ស មហីបតិ
បចិនាតិ ច តំ តានិ យេន គច្ឆតិ ទុគ្គតិំ ។
បុព្វេវស្ស កតំ បុញ្ញំ អលាតស្ស មហីបតិ
តស្សេវ ទេវ និស្សន្ទោ យញ្ចេសោ លភតេ សុខំ ។
ខីយតេវស្ស តំ បុញ្ញំ តថាហិ អគុណេ រតោ
ឧជុមគ្គំ អវហាយ កុម្មគ្គំ អនុធាវតិ ។
តុលា យថា បគ្គហិតា ឱហិតេ តុលមណ្ឌលេ
ឧន្នមេតិ តុលាសីសំ ភារេ ឱរោបិតេ សតិ ។
ឯវមេវ នរោ បុញ្ញំ ថោកំ ថោកម្បិ អាចិនំ
សគ្គាតិមានោ ទាសោវ ពីជកោ សាតវេ[១] រតោ ។
យមជ្ជ ពីជកោ ទាសោ ទុក្ខំ បស្សតិ អត្តនិ
បុព្វេវស្ស[២] កតំ បាបំ តមេសោ បដិសេវតិ ។
ខីយតេវស្ស តំ បាបំ តថាហិ វិនយេ រតោ
កស្សបញ្ច សមាបជ្ជ មាហេវុប្បថមាគមា ។

១ ម. សាធវេ ។ ២ ម. បុព្វ កស្ស ។



បពិត្រព្រះអង្គជាម្ចាស់ផែនដី ការៈដ៏ល្អរបស់អលាតសេនាបតី មិនទាន់ពេញប្រៀបនៅឡើយ អលាតសេនាបតីទៅកាន់ទុគ្គតិព្រោះបាបណា គាត់នៅតែសន្សំបាបនោះ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី អលាតសេនាបតី បានធ្វើបុណ្យហើយក្នុងកាលមុន បពិត្រព្រះសម្មតិទេព ឯអលាតសេនាបតីនុ៎ះបានសុខ ព្រោះអានិសង្សបុណ្យ ដែលគាត់ធ្វើហើយក្នុងកាលមុននោះឯង ។ បុណ្យនោះរបស់គាត់អស់ហើយ បានជាគាត់ត្រេកអរក្នុងអកុសលកម្ម លះបង់ផ្លូវត្រង់ ហើយដើរទៅតាមផ្លូវវៀចវិញ ។ កាលធ្ងន់ ដែលគេដាក់ក្នុងមណ្ឌលនៃជញ្ជីង ជញ្ជីងក៏ធ្លាក់ កាលបើភារៈគេដាក់ចេញហើយ ក្បាលជញ្ជីងក៏ងើបឡើង យ៉ាងណាមិញ ។ នរជនកាលសន្សំបុណ្យ សូម្បីបន្តិចម្តងៗ ដូចជាទាសៈឈ្មោះពីជកៈ កាលប្រាថ្នាឋានសួគ៌ ត្រេកអរក្នុងកុសលកម្ម មានផលល្អ ក៏យ៉ាងនោះដែរ ។ បាបណា ដែលពីជកៈនោះបានធ្វើក្នុងកាលមុន ទាសៈឈ្មោះពីជកៈឃើញទុក្ខណា ចំពោះខ្លួនក្នុងថ្ងៃនេះ ព្រោះតែបានធ្វើបាបក្នុងជាតិមុន បានជាគាត់ទទួលទុក្ខនោះ ។ បាបរបស់គាត់នោះអស់ បានជាគាត់ត្រេកអរក្នុងវិន័យ សូមព្រះអង្គកុំគប់គេអចេលកៈឈ្មោះគុណៈ ជាកស្សបគោត្រ ហើយមកកាន់ផ្លូវខុសឡើយ ។

[៤៩] យំ យំ ហិ រាជ ភជតិ សន្តំ វា យទិ វា អសំ
សីលវន្តំ វិសីលំ វា វសំ តស្សេវ គច្ឆតិ ។
យាទិសំ កុរុតេ មិត្តំ យាទិសញ្ចូបសេវតិ
សោបិ តាទិសកោ ហោតិ សហវាសោ ហិ តាទិសោ ។
សេវមានោ សេវមានំ សម្ផុដ្ឋោ សម្ផុសំ បរំ
សរោ ទិទ្ធោ កលាបំវ អលិត្តមុបលិម្បតិ
ឧបលេបភយា ធីរោ នេវ បាបសខា សិយា ។
បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ
កុសាបិ បូតី វាយន្តិ ឯវំ ពាលូបសេវនា ។
តគរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ
បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ។
តស្មា បត្តបុដស្សេវ ញត្វា សម្បាកមត្តនោ
អសន្តេ នុបសេវេយ្យ សន្តេ សេវេយ្យ បណ្ឌិតោ
អសន្តោ និរយំ នេន្តិ សន្តោ បាបេន្តិ សុគ្គតិំ ។





[៤៩] បពិត្រព្រះរាជា បុគ្គលគប់រកបុគ្គលណា ៗ ជាសប្បុរស ឬជាអសប្បុរស មានសីលឬមិនមានសីល រមែងលុះនូវអំណាចនៃបុគ្គលនោះៗ ឯង ។ បុគ្គលធ្វើបុគ្គលបែបណាឲ្យជាមិត្រផង សេពបុគ្គលបែបណាផង បុគ្គលនោះ រមែងប្រាកដដូចបុគ្គលនោះដែរ ព្រោះថាការនៅរួមគ្នា រមែងប្រាកដដូច្នោះ ។ កាលបើដែលកូនសិស្សពាល់ត្រូវហើយ រមែងប្រឡាក់កូនសិស្ស ដែលមិនទាន់ប្រឡាក់ កាលកូនសិស្សពាល់ត្រូវតាមយ៉ាងនេះ រមែងប្រឡាក់ ដូចព្រួញលាបថ្នាំពិស ប្រឡាក់បំពង់ព្រួញដូច្នោះ អ្នកប្រាជ្ញមិនគួរមានសំឡាញ់អាក្រក់ ព្រោះខ្លាចតែការប្រឡាក់ ។ ជនណាខ្ចប់ត្រីស្អុយដោយស្លឹកស្បូវ ស្លឹកស្បូវរបស់ជននោះ នៅជាមានក្លិនស្អុយផ្សាយទៅ យ៉ាងណាមិញ ការសេពគប់បុគ្គលពាល ក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់គ្រឿងស្លាដោយស្លឹកឈើ ស្លឹកឈើរបស់ជននោះ នៅជាមានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បណ្ឌិតកាលបើដឹងច្បាស់នូវការផលនៃខ្លួនដែលប្រែប្រួលបាន ដូចជាកញ្ចប់នៃស្លឹកឈើ មិនគួរសេពអសប្បុរសទេ គួរសេពតែពួកសប្បុរស ព្រោះថាពួកអសប្បុរស តែងនាំទៅកាន់នរក ពួកសប្បុរសតែងឲ្យដល់សុគតិ ។

(៣០) អហញ្ហិ ជាតិយោ សត្ត សរេ សំសរិតាគតោ

អនាគតេបិ សត្តេវ  យា គមិស្សំ ឥតោ ចុតោ ។

យា មេ សា សត្តមី ជាតិ  អហុ បុព្វេ ជនាធិប

កម្មារបុត្តោ មគធេសុ  អហុ រាជគហេ បុរេ ។

បាបំ សហាយមាគម្ម  ពហុ បាបំ កតំ មយា

បរទារស្ស ហេឋេន្តា  ចរិម្ហា អមរា វិយ ។

តំ កម្មំ និហិតំ អដ្ឋា  ភស្មាច្ឆន្នោវ បាវកោ

អថ អញ្ញេហិ កម្មេហិ  អជាយឹ វំសភូមិយំ ។

កោសម្ពិយំ សេដ្ឋិកុលេ  ឥទ្ធេ ផីតេ មហទ្ធនេ

ឯកបុត្តោ មហារាជ  និច្ចំ សក្កតបូជិតោ ។

តត្ថ មិត្តំ អសេវិស្សំ  សហាយំ សាតកេ រតំ

បណ្ឌិតំ សុតសម្បន្នំ  សោ មំ អត្ថេ និវេសយិ ។

ចាតុទ្ទសឹ បញ្ចទសឹ  ពហុំ រត្តិមុបាវិសឹ

តំ កម្មំ និហិតំ អដ្ឋា  និធីវ ឧទកន្តិកេ ។





(៣០) ខ្ញុំម្ចាស់បានរលឹកឃើញនូវជាតិនៃខ្លួន ដែលអន្ទោលទៅមកអស់ ៧ ជាតិមកហើយ នឹង ៧ ជាតិ(ទៀត)ដែលខ្ញុំម្ចាស់នឹងច្យុតចាកអត្តភាពនេះ ទៅក្នុងអនាគត ។ បពិត្រព្រះអង្គជាធំជាងជន ក្នុងកាលមុន ជាតិណារបស់ខ្ញុំម្ចាស់ជាគំរប់ ៧ (ក្នុងជាតិនោះ) ខ្ញុំម្ចាស់បានកើតជាកូនជាងមាស ក្នុងក្រុងរាជគ្រឹះ ក្នុងដែនមគធៈ ។ បាបដ៏ច្រើនខ្ញុំម្ចាស់បានធ្វើហើយ ព្រោះអាស្រ័យសំឡាញ់ដ៏លាមក ខ្ញុំម្ចាស់ទាំងពីរនាក់ កាលបៀតបៀនប្រពន្ធនៃបុគ្គលដទៃ ប្រព្រឹត្ត(ខ្លួន) ដូចមិនស្លាប់ ។ អំពើនោះកប់នៅ ដូចភ្លើងដែលកប់ក្នុងផេះ បពិត្រមហារាជ តទៅខ្ញុំម្ចាស់បានកើតក្នុងវំសភូមិ ក្រុងកោសម្ពី ជាកូនប្រុសតែមួយ មានគេធ្វើសក្ការបូជាជានិច្ច ក្នុងត្រកូលសេដ្ឋី ជាត្រកូលស្តុកស្តម្ភ សម្បូរ មានទ្រព្យច្រើន ដោយកម្មដទៃ ។ ក្នុងកាលនោះ ខ្ញុំម្ចាស់បានសេពគប់មិត្រសំឡាញ់ អ្នកត្រេកអរក្នុងកុសល ជាបណ្ឌិតអ្នកចេះដឹងច្រើនដោយការរៀនដឹង មិត្រនោះបានតម្កល់ខ្ញុំម្ចាស់ក្នុងគំនើតជាប្រយោជន៍ ។ ខ្ញុំម្ចាស់បានរក្សាឧបោសថអស់រាត្រីទី ១៤ នឹងទី ១៥ ដ៏ច្រើន កម្មនោះនៅកប់ ដូចកំណប់ក្នុងទឹក ។

អជ ទានាហំ កម្មានិ  យំ មេ មគធេ កតំ

ផលំ បរិយាគតំ មជ្ជា  ភុត្វា ទុដ្ឋវិសំ យថា ។

តតោ ចុតាហំ វេទេហ  រោរុវេ និរយេ ចិរំ

សកម្មុនា អបច្ចិស្សំ  តំ សរំ ន សុខំ លភេ ។

ពហុវស្សគណេ តត្ថ  ខេបយិត្វា តហិំ ទុក្ខំ

ភិន្នាគតេ អហុំ រាជ  ឆគលោ ឧទ្ធតប្ផលោ ។

(៣១) សាតបុត្តា មយា វូឡ្ហា  បិដ្ឋិយា ច រថេន ច

តស្ស កម្មស្ស និស្សន្ទោ  បរទារគមនស្ស មេ ។

តតោ ចុតាហំ វេទេហ  កបិ អាសឹ ព្រហាវនេ

និលុញ្ចិតផលោយេវ  យូថបេន បគព្ភិនា

តស្ស កម្មស្ស និស្សន្ទោ  បរទារគមនស្ស មេ ។

តតោ ចុតាហំ វេទេហ  ទសណ្ណេសុ បសុ អហុំ

និលុញ្ចិតោ ជវោ ភទ្រោ  យោគ្គំ វូឡ្ហំ ចិរំ មយា

តស្ស កម្មស្ស និស្សន្ទោ  បរទារគមនស្ស មេ ។



កំបណ្តាបាបកម្មទាំងឡាយ បាបកម្មណា ដែលខ្ញុំម្ចាស់បានធ្វើហើយក្នុងដែនមគធៈ ផល(នៃបាបកម្ម)នោះ ផ្តល់ក្នុងកាលជាខាងក្រោយ ដូចបុគ្គលអ្នកបរិភោគភោជន ដែលលាយដោយពិសដ៏កាចដូច្នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកត្រកូលសេដ្ឋីនោះមក ធ្លាក់ទៅក្នុងរោរុវនរក អស់កាលដ៏យូរ ដោយកម្មរបស់ខ្លួន ខ្ញុំម្ចាស់កាលរលឹកឃើញទុក្ខ ក្នុងនរកនោះ រមែងមិនបានសេចក្តីសុខ ។ ខ្ញុំម្ចាស់ញុំាងសេចក្តីទុក្ខដ៏ច្រើនឲ្យអស់ទៅក្នុងនរកនោះ អស់ពួកនៃឆ្នាំដ៏ច្រើន បានមកកើតជាពពែ គេក្រៀវស្ពុះ ក្នុងក្រុងភិន្នាគតៈ ។

(៣១) ខ្ញុំម្ចាស់បាននាំពួកកូនអាមាត្យដោយខ្នងផង ដោយរថផង (កាលនេះក្នុងកំណើតជាពពែនោះ) ជាផលកម្មគឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយក៏កើតជាស្វាក្នុងព្រៃធំ ត្រូវស្វាជាម្ចាស់ហ្វូងដ៏ជាសត្វឃ្លើសឃ្លង ទាំកាត់ពូជចេញ នេះជាផលកម្មគឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានកើតជាគោក្នុងដែនទសណ្ណៈ ជាគោដ៏ចំរើន មានសន្ទុះលឿន ត្រូវគេក្រៀវ ខ្ញុំម្ចាស់បានអូសរទេះ អស់កាលដ៏យូរ នេះជាផលកម្ម គឺការគប់រកប្រពន្ធអ្នកដទៃ នៃខ្ញុំម្ចាស់នោះ ។

តតោ ចុតាហំ វេទេហ វជ្ជីសុ កុលមាគតា
នេវិត្ថី ន បុមា អាសឹ មនុស្សត្តេ សុទុល្លភេ
តស្ស កម្មស្ស និស្សន្ទោ បរទារិកស្ស មេ ។
តតោ ចុតាហំ វេទេហ អជាយឹ នន្ទនេ វនេ
ភវនេ តាវតឹសាហំ អច្ឆរា កាមវណ្ណិនី ។
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា
កុសលា នច្ចគីតស្ស សក្កស្ស បរិចារិកា ។
តត្ថ ឋិតាហំ វេទេហ សរាមិ ជាតិយោ ឥមា
អនាគតេបិ សត្តេវ យា គមិស្សំ ឥតោ ចុតា ។
បរិយាគតំ តំ កុសលំ យំ មេ កោសម្ពិយំ កតំ
ទេវេ ចេវ មនុស្សេ ច សន្ធាវិស្សំ ឥតោ ចុតា ។
សត្ត ជច្ចា មហារាជ និច្ចំ សក្កតបូជិតា
ឥត្ថីភាវា ន មុច្ចិស្សំ ឆដ្ឋា និគតិយោ[1] ឥមា ។
សត្តមី ច គតិ ទេវ ទេវបុត្តោ មហិទ្ធិកោ
បុមា ទេវោ ភវិស្សាមិ ទេវកាយស្មិមុត្តមោ ។

១ ម. ឆ. ឆដ្ឋា គតិយោ ។



បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានមក (កើត) ក្នុងត្រកូលក្នុងដែនវជ្ជី ក្នុងកាលជាមនុស្សដែលគេបានដោយក្រ កើតមិនមែនស្រីមិនមែនប្រុស (ខ្ទើយ) នេះជាផលកម្មគឺការគប់គេប្រពន្ធបុគ្គលដទៃ នៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានកើតជាស្រីអប្សរ មានវណ្ណៈគួរប្រាថ្នាក្នុងឧទ្យាននន្ទនវ័ន ក្នុងឋានតាវត្តិង្ស ។ មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈនៃកែវមណី ជាស្រីឈ្លាសក្នុងការរាំនិងច្រៀង ជាស្រីបម្រើទេវរាជឈ្មោះសក្កៈ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ឋិតនៅក្នុងឋានតាវត្តិង្សនោះ រលឹកឃើញជាតិ ៧ ដែលខ្ញុំម្ចាស់នឹងទៅក្នុងអនាគត ។ កុសលណាដែលខ្ញុំម្ចាស់បានធ្វើហើយ ក្នុងក្រុងកោសម្ពី កុសលនោះ តាមមកឲ្យផល ខ្ញុំម្ចាស់ច្យុតចាកអត្តភាព ជាទេពអប្សរនេះ នឹងអន្ទោលទៅហើយក្នុងទេវលោក នឹងមនុស្សលោក ។ បពិត្រមហារាជ ខ្ញុំម្ចាស់ដែលគេធ្វើសក្ការបូជាជានិច្ច អស់ជាតិទាំងឡាយ ៧ តែខ្ញុំម្ចាស់នឹងមិនរួចហើយចាកភាពជាស្រី អស់គតិ ៦ នេះ ។ បពិត្រព្រះសម្មតិទេព ក្នុងគតិជាគំរប់ ៧ ខ្ញុំម្ចាស់នឹងកើតជាទេវតាប្រុស ជាទេវបុត្រមានឫទ្ធិច្រើន ដ៏ឧត្តម ក្នុងពួកទេវតា ។

អដ្ឋាសិ សត្តាហមយំ   អាលោ កម្មន្តិ ឆព្ពរេ
ទេវបុត្តោ ជវោ នាម   យោ មេ ភាសំ បដិច្ឆតិ ។
មុហុត្តោ វិយ សោ ទិព្យោ   ឥធ វស្សានិ សោឡស
រត្តិន្ទិវោ ច សោ ទិព្យោ   មានុសិំ សរទោសតំ ។
ឥតិ កម្មានិ អន្វេន្តិ   អសង្ខេយ្យាបិ ជាតិយោ
កល្យាណំ យទិ វា បាបំ   ន ហិ កម្មំ វិនស្សតិ ។
(៣៦) យោ ឥច្ឆេ បុរិសោ ហោតុំ   ជាតិំ ជាតិំ បុនប្បុនំ
បរទារំ វិវជ្ជេយ្យ   ធោតបាទោវ កទ្ទមំ ។
យា ឥច្ឆេ បុរិសោ ហោតុំ   ជាតិំ ជាតិំ បុនប្បុនំ
សាមិកំ អបចាយេយ្យ   ឥន្ទំវ បរិចារិកា ។
យោ ឥច្ឆេ ទិព្វភោគញ្ច   ទិព្វមាយុំ យសំ សុខំ
បាបានិ បរិវជ្ជេត្វា   តិវិធំ ធម្មមាចរេ ។
កាយេន វាចា មនសា   អប្បមត្តោ វិចក្ខណោ
អត្តនោ ហោតិ អត្ថាយ   ឥត្ថី វា យទិ វា បុមា ។
យេ កេចិមេ មានុជា ជីវលោកេ
យសស្សិនោ សព្វសមន្តភោគា
អសំសយំ តេហិ បុរេ សុចិណ្ណំ
កម្មស្សកាសេ[1] បុថុ សព្វសត្តា ។

---
១ ម. កម្មស្សកា យេ ។



ក៏កន្លងនៅនេះ ខាងទេពកញ្ញាទាំងឡាយ នៅក្នុងតែក្រងផ្កាជាផ្កាំង ក្នុងឧទ្យានទៃ ទេវបុត្រឈ្មោះជវៈ (ជាស្វាមីខ្ញុំម្ចាស់នោះ) កំពុងទទួលកម្រងផ្កាដើម្បីខ្ញុំម្ចាស់ ។ ១៦ឆ្នាំ ក្នុងជាតិរបស់ខ្ញុំម្ចាស់នេះ ហាក់ដូចជាកាលទិព្វនោះ មួយពេល មួយយប់ មួយថ្ងៃទិព្វនោះ ជា ១០០ ឆ្នាំរបស់មនុស្ស ។ កម្មទាំងឡាយតែងតែតាមទៅតាមអស់ជាតិជាអសង្ខេយ្យដូច្នេះឯង ព្រោះថា កម្មល្អក្តី លាមកក្តី មិនវិនាសទេ ។

(៣៦) ប្រុសណាប្រាថ្នាឲ្យបានជាភេទប្រុសរាល់ៗជាតិ គួរវៀរប្រពន្ធបុគ្គលដទៃ ដូចជាបុគ្គលអ្នកមានជើងលាងហើយ វៀរចេញចាកភក់ដូច្នោះ ។ ស្ត្រីណាប្រាថ្នាឲ្យបានជាប្រុសរាល់ៗជាតិ គួរគោរពប្តី ដូចជាពួកស្រីអប្សរ ជាអ្នកបំរើ គោរពព្រះឥន្ទដូច្នោះ ។ បុគ្គលណាចង់បានភោគៈជាទិព្វ អាយុ យស នឹងសុខជាទិព្វ គួរវៀរចេញអំពើបាបទាំងឡាយ ប្រព្រឹត្តសុចរិតធម៌ ៣ យ៉ាង ។ ស្ត្រីក្តី ប្រុសក្តី ជាអ្នកមិនធ្វេសប្រហែសដោយកាយវាចាចិត្ត មានប្រាជ្ញាជាគ្រឿងពិចារណា ឈ្មោះថាកើតមកដើម្បីប្រយោជន៍របស់ខ្លួន ។

ពួកមនុស្សណានីមួយ ក្នុងជីវលោក ជាអ្នកមានយស
មានភោគៈបរិបូណ៌ទាំងអស់ ពួកមនុស្សទាំងនោះ បាន
សន្សំកម្មល្អហើយ ក្នុងកាលមុន ដោយឥតសង្ស័យ
សត្វទាំងអស់ ជាច្រើន សុទ្ធតែមានកម្មជារបស់ខ្លួន ។

ឥន្ទ្យាចុ [illegible] សយមេវ ទេវ

[illegible] តេ ឥមា ជនិន្ទ

យោ តេ ឥមា អច្ឆរសង្កាសា

អលង្កតា កាញ្ចនជាលឆន្នា ។

ឥច្ចេវំ បិតរំ កញ្ញា      រុចា តោសេសិ អង្គតិំ

មុឡ្ហស្ស មគ្គមាចិក្ខិ      ធម្មមក្ខាសិ សុព្វតា ។

(៣៣) អថាគមា ព្រហ្មលោកា នារទោ មានុសឹ បជំ

ជម្ពុទីបំ អវេក្ខន្តោ      អទ្ទស រាជានមង្គតិំ ។

តតោ បតិដ្ឋ បាសាទេ      វេទេហស្ស បុរត្ថតោ

តញ្ច ទិស្វា អនុប្បត្តំ      រុចា ឥសិមវន្ទយិ ។

(៣៤) អថាសនម្ហា ឱរុយ្ហ      រាជា ព្យថិតមានសោ

នារទំ បរិបុច្ឆន្តោ      ឥទំ វចនមព្រវិ ។



បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ក្រេវក្រវៀវរាដោយ
ព្រះអង្គឯងចុះ បពិត្រព្រះអង្គជាធំជាងជន ស្រ្តីទាំងឡាយ
ណារបស់ព្រះអង្គ ប្រាកដស្មើដោយស្រីអប្សរ មានខ្លួនប្រដាប់
ហើយ បិទបាំងដោយបណ្តាញមាស តើស្រ្តីទាំងនេះ របស់
ព្រះអង្គ មានឡើងជាហេតុ ។

ព្រះរាជកញ្ញាព្រះនាមរុចា ញ៉ាំងព្រះបាទអង្គតិ ជាព្រះបិតាឲ្យត្រេកអរយ៉ាងនេះដូច្នេះឯង នាងជាអ្នកមានវត្តល្អ បានប្រាប់ផ្លូវ (សុគតិ) ដល់ព្រះបិតា (ដូចបុគ្គលប្រាប់ផ្លូវ) ដល់មនុស្សវង្វេង នាងបានសំដែងសុចរិតធម៌ ។

(៣៣) គ្រានោះ នារទព្រហ្ម មកពីព្រហ្មលោក មកកាន់ពួកសត្វជារបស់មនុស្ស ប្រមើលមើលជម្ពូទ្វីប ក៏បានឃើញព្រះបាទអង្គតិ ។ លំដាប់នោះ នារទព្រហ្ម ឋិតនៅឰដ៏អាកាសក្នុងប្រាសាទ ខាងមុខនៃព្រះបាទវិទេហៈ នាងរុចាបានឃើញនារទព្រហ្មនោះ ដែលមកដល់ហើយ ក៏ថ្វាយបង្គំនារទព្រហ្មដែលកំណើតខ្លួនជាឥសី ។

(៣៤) គ្រានោះ ព្រះរាជា មានព្រះហឫទ័យតក់ស្លុត ក៏ចុះអំពីអាសនៈ ហើយសាកសួរនារទព្រហ្ម ទើបត្រាស់ព្រះតម្រាស់ដូច្នេះថា

កុតោ នុ អាគច្ឆសិ ទេវវណ្ណិ
ឱភាសយំ សព្វទិសា[១] ចន្ទិមាវ
អក្ខាហិ មេ បុច្ឆិតោ នាមគោត្តំ
កថំ តំ ជានន្តិ មនុស្សលោកេ ។

(៣៥) អហញ្ហិ ទេវតោ ឥធាគតោ ម្ហិ
ឱភាសយំ សព្វទិសា ចន្ទិមាវ
អក្ខាមិ តេ បុច្ឆិតោ នាមគោត្តំ
ជានន្តិ មំ នារទោ កស្សបោ ចាតិ ។

(៣៦) អច្ឆរិយរូបំ តវ យាទិសញ្ច
វេហាយសំ គច្ឆសិ តិដ្ឋសិ ច
បុច្ឆាមិ តំ នារទ ឯតមត្ថំ
អថ កេន វណ្ណេន តវាយមិទ្ធិ ។

(៣៧) សច្ចញ្ច ធម្មោ ច ទមោ ច ចាគោ
គុណា មមេតេ បកតា បុរាណា
តេហេវ ធម្មេហិ សុសេវិតេហិ
មនោជវោ យេន កាមំ គតោស្មិ ។

---
១ ម. ស៊ី ។



លោកមានវណ្ណៈដូចទេវតា ញុំាងទិសទាំងអស់ ឲ្យភ្លឺដូចព្រះចន្ទ្រ តើ ទើបនឹងមកអំពីណា យើងសួរហើយ លោកចូរប្រាប់នាមនិងគោត្រ មនុស្សទាំងឡាយក្នុងមនុស្សលោក គេស្គាល់ដូចម្ដេចបាន ។

(៣៥) (នារទព្រហ្ម...) អាត្មាភាពទើបនឹងមកអំពីទេវលោក ក្នុងកាលឥឡូវនេះ ញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ អាត្មាភាពដែលព្រះអង្គសួរហើយ នឹងទូលនាមនិងគោត្រថា មនុស្សទាំងឡាយស្គាល់អាត្មាភាពថា ឈ្មោះនារទៈ ជាកស្សបគោត្រ ។

(៣៦) (ព្រះរាជា...) សណ្ឋានរបស់លោកប្លែកយ៉ាងណាស់ លោកក៏ចូលដើរក្ដី ក៏ចូលឈរក្ដី ក្នុងអាកាសវេហ៍ (នេះ) បាន សភាពជាអស្ចារ្យ បពិត្រនារទៈ ខ្ញុំសួរសេចក្ដីនេះនឹងលោក ឫទ្ធិរបស់លោកនេះ បានដោយហេតុអ្វី ។

(៣៧) (នារទព្រហ្ម...) សច្ចៈ ១ ធម៌ ១ ទមៈ ១ ចាគៈ ១ គុណធម៌នេះ អាត្មាភាព បានសាងមកហើយ អំពីជាតិមុន អាត្មាភាពបានសន្សំចិត្តទៅតាមប្រាថ្នាបាន ព្រោះធម៌ ដែលអាត្មាភាពសេពល្អហើយទាំងនោះឯង ។

(៣៨) អច្ឆរិយមាចិក្ខសិ បុញ្ញស្សម្ពិ
សចេ ហិ ឯវំ យថា ត្វំ វទេសិ[១]
បុច្ឆាមិ តំ នារទ ឯតមត្ថំ
បុដ្ឋោ ច មេ សាធុ វិយាករោហិ ។

(៣៩) បុច្ឆស្សុ មំ រាជ តវេស អត្ថោ
យំ សំសយំ កុរុតេ ភូមិបាល
អហញ្ហិ និស្សំសយតំ តមេមិ
នយេហិ ញាយេហិ ច ហេតុភិ ច ។

(៤០) បុច្ឆាមិ តំ នារទ ឯតមត្ថំ
បុដ្ឋោ ច មេ នារទ មា មុសា ភណិ
អត្ថិ នុ ទេវា បិតរោ នុ អត្ថិ
លោកោ បរោ អត្ថិ ជនោ យមាហ[២] ។

(៤១) អត្ថេវ ទេវា បិតរោ ច អត្ថិ
លោកោ បរោ អត្ថិ ជនោ យមាហ
កាមេសុ គិទ្ធា ច នរា បមូឡ្ហា
លោកំ បរំ ន វិទូ មោហយុត្តា ។

---

១ ម. សចេ ហិ ឯតេ ត្វំ យថា វទេសិ ។ ឱ. សចេហិ ឯតេហិ យថា វទេហិ ។ ២ ម. ឱ. យមាហុ ។



(៣៨) (ព្រះរាជា...) ឥឡូវនេះ លោកប្រាប់ការសម្រេចនៃបុណ្យជា របស់អស្ចារ្យហើយ បពិត្រនារទៈ ប្រសិនបើដូចជាលោក ពោលយ៉ាងនេះមែន ខ្ញុំសូមសួរសេចក្តីនេះនឹងលោកទៀត បើ ខ្ញុំសួរហើយ សូមលោកឆ្លើយឲ្យប្រពៃផង ។

(៣៩) (នារទព្រហ្ម...) បពិត្រព្រះរាជាជាភូមិបាល ព្រះអង្គមានសេចក្តី សង្ស័យណា សូមទ្រង់សួរអាត្មាភាពចុះ អាត្មាភាពជា ប្រយោជន៍របស់ព្រះអង្គហើយ អាត្មាភាពនឹងញ៉ាំងព្រះអង្គឲ្យ ដល់នូវភាពជាអ្នកមិនមានសេចក្តីសង្ស័យ ដោយន័យ ដោយ ញាណ និងដោយហេតុទាំងឡាយ ។

(៤០) (ព្រះរាជា...) បពិត្រនារទៈ ខ្ញុំសូមសួរសេចក្តីនេះនឹងលោក បពិត្រនារទៈ ខ្ញុំសួរហើយ លោកកុំពោលមុសាវាទឡើយ ន:
ជនបានស្តាប់ ទេវតាមានឬ មាតាបិតាមានឬ បរលោកមានឬ ។

(៤១) (នារទព្រហ្ម...) នរជនបានពោលថា ទេវតាមាន មាតាបិតា មាន បរលោកមាន ពួកជនជាអ្នកជាប់ក្នុងកាម ជាអ្នកវង្វេង ប្រកបដោយមោហៈ រមែងមិនបានដឹងនូវបរលោកឡើយ ។

(៦២) អត្ថីតិ ចេ នារទ សទ្ទហាសិ
និវេសនំ បរលោកេ មតានំ
ឥធេវ មេ បញ្ចសតានិ ទេហិ
ទស្សាមិ តេ បរលោកេ សហស្សំ ។

(៦៣) ទជ្ជេមុ ខោ បញ្ចសតានិ ភោតោ
ជញ្ញាមុ ចេ សីលវន្តំ វទញ្ញុំ
លុទ្ទន្តំ ភោន្តំ និរយេ វសន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។

ឥធេវ យោ ហោតិ អធម្មសីលោ
បាបាចារោ អលសោ លុទ្ទកម្មោ
ន បណ្ឌិតា តស្មឹ ឥណំ ទទន្តិ
ន ហិ អាគមោ ហោតិ តថាវិធម្ហា ។

ទក្ខញ្ច បោសំ មនុជា វិទិត្វា
ឧដ្ឋានកំ សីលវន្តំ វទញ្ញុំ
សយមេវ ភោគេហិ និមន្តយន្តិ
កម្មំ ករិត្វា បុនមាហរេសិ ។





(៦២) (ព្រះរាជា...) បពិត្រនារទៈ ប្រសិនបើលោកជឿថា លំនៅនៃជនទាំងឡាយ ដែលស្លាប់ទៅហើយ មាននៅក្នុងបរលោកមែន លោកចូរឲ្យកហាបណៈ ៥០០ ដល់ខ្ញុំ ក្នុងលោកនេះចុះ ខ្ញុំនឹងសងកហាបណៈជា ១ ពាន់ ដល់លោក ក្នុងបរលោកវិញ ។

(៦៣) (នារទព្រហ្ម...) ប្រសិនបើយើងដឹង (នូវអ្នកដ៏ចំរើន) ជាមានសីល ជាអ្នកដឹងនូវពាក្យស្មូម យើងនឹងឲ្យកហាបណៈ ៥០០ ដល់អ្នកដ៏ចំរើន ប៉ុន្តែបើអ្នកដ៏ចំរើននោះ ជាមនុស្សអាក្រក់ទៅក្នុងនរក តើបុគ្គលណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។ សូម្បីក្នុងលោកនេះ បុគ្គលណាមិនមានធម៌ជាប្រក្រតី មានមារយាទបាបលាមក ជាអ្នកខ្ជិលច្រអូស មានការងារអាក្រក់ ពួកបណ្ឌិត ក៏មិនឲ្យបុគ្គលនោះខ្ចីទ្រព្យទេ ព្រោះថា ការបាន(ទ្រព្យ)អំពីបុគ្គលមានប្រការដូច្នោះមិនមានឡើយ ។ ពួកមនុស្សដឹងនូវបុរសថា ជាអ្នកប៉ិនប្រសប់ មានព្យាយាម មានសីល ជាអ្នកដឹងនូវពាក្យស្មូម រមែងអញ្ជើញនូវបុរសនោះដោយភោគៈទាំងឡាយថា អ្នកធ្វើការងារហើយ នាំមកសងយើងវិញ ។

(៦៦) ឥតោ ចុតោ ទក្ខសិ តត្ថ រាជ
កាកោលសង្ឃេហិ វិកស្សមានំ
តំ ខជ្ជមានំ និរយេ វសន្តំ
កាកេហិ គិជ្ឈេហិ ច សេនកេហិ
សញ្ឆិន្នគត្តំ រុហិរំ សវន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។

(៦៧) អន្ធតមំ តត្ថ ន ចន្ទសុរិយា
និរយោ សទា តុមុលោ ឃោររូបោ
សា នេវ រត្តិ ន ទិវា បញ្ញាយតិ
តថាវិធេ កោ វិចរេ ធនត្ថិកោ ។

(៦៨) សពលោ ច សាមោ ច ទុវេ សុវាណា
បវទ្ធកាយា ពលិនោ មហន្តា
ខាទន្តិ ទន្តេហិ អយោមយេហិ
ឥតោ បណុន្នំ បរលោកេ បត្តំ ។
តំ ខជ្ជមានំ និរយេ វសន្តំ
លុទ្ទេហិ វាឡេហិ អឃម្មិគេហិ
សញ្ឆិន្នគត្តំ រុហិរំ សវន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។



(៦៦) បពិត្រព្រះរាជា បើព្រះអង្គច្យុតចាកអត្តភាពនេះទៅ ទ្រង់ទត ឃើញនូវព្រះអង្គ ដែលហ្វូងក្អែកកំពុងចឹកជញ្ជក់ក្នុងនរក នោះ ព្រះអង្គគង់ក្នុងនរក ដែលហ្វូងក្អែកត្មាតនឹងខ្លែងកំពុង ចំពាស៊ី មានខ្លួនខ្ទុះខ្ចាយ កំពុងហូរឈាម តើបុគ្គលណា នឹងទៅទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៦៧) សេចក្តីងងឹតក្រាស់ រមែងមានក្នុងនរកនោះ ព្រះចន្ទនឹងព្រះអាទិត្យក៏មិនមាន នរកនោះមានសូរអឺកងក្រោលសព្វកាល មានសភាពគួរខ្លាច យប់ក៏មិនប្រាកដ ថ្ងៃក៏មិនប្រាកដ នរណាជាអ្នកត្រូវការដោយទ្រព្យ គប្បីត្រាច់ទៅក្នុងនរកដូច្នោះបាន ។

(៦៨) ឆ្កែពាលទាំងពីរ គឺឆ្កែរលឿងនិងឆ្កែខ្មៅ មានកាយធាត់ធំ មានកំឡាំង តែងខាំស៊ី នូវសត្វដែលច្រានចាកលោកនេះ ធ្លាក់ទៅក្នុងបរលោក ដោយធ្មេញជាវិការៈនៃដែក ។ ព្រះអង្គកាលទៅក្នុងនរក ត្រូវពួកម្រឹគដ៏កាចអាក្រក់ នាំមកខ្ទាស់ឆក់ខ្ទក់ ខាំស៊ី មានខ្លួនខ្ទុះខ្ចាយ កំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៦៧) ទុស្សហិ សត្តីហិ សុនិសិតាហិ
ហនន្តិ វិជ្ឈន្តិ ច បច្ចាមិត្តា
កាឡូបកាឡា និរយម្ហិ ឃោរេ
បុព្វេ នរំ ទុក្កដកម្មការឹ ។
តំ ហញ្ញមានំ និរយេ វជន្តំ
កុច្ឆិស្មឹ បស្សស្មឹ វិប្ផាលិតូទរំ
សញ្ឆិន្នគត្តំ រុហិរំ សវន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។

(៦៨) សត្តី ឧសូ តោមរភិណ្ឌិវាលា
វិវិធាវុធា វស្សន្តិ តត្ថ ទេវា
បតន្តិ អង្គារមិវច្ចិមន្តា
សិលាសនី វស្សតិ លុទ្ទកម្មេ ។
ឧណ្ហោ ច វាតោ និរយម្ហិ ទុស្សហោ
ន តម្ហិ[១] សុខំ លព្ភតិ[២] ឥត្តរំបិ
តន្តំ វិធាវន្តមលេនមាតុរំ
កោ ចោទយេ បរលោកេ សហស្សំ ។

១ ម. ន តហំ ។ ២ ឱ. លេភិ ។



(៦៧) ពួកនាយនិរយបាលឈ្មោះកាឡូបកាលៈក្នុងនរកគួរខ្លាចទាំងពួក ជាបច្ចាមិត្រ តែងសម្លាប់ផង ចាក់នរជន ដែលធ្វើអំពើអាក្រក់ក្នុងកាលមុន ដោយព្រួញនឹងលំពែងដែលសំលៀងមុតហើយ ។ ព្រះអង្គកាលទៅក្នុងនរក ត្រូវនាយនិរយបាល ចាក់ត្រង់ក្លៀក ត្រង់ឆ្អឹងជំនីរ ពោះ មានខ្លួនធ្លុះធ្លាយ មានឈាមហូរចេញ តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៦៨) ក្នុងនរកនោះ មានភ្លៀងបង្អុរជាអាវុធផ្សេងៗ គឺលំពែង ព្រួញ លំពែងស្នែងក្របី និងច្បូក ភ្លៀងគឺអាវុធ មានសណ្ឋានដូចជារងើកភ្លើង រមែងធ្លាក់លើក្បាល រន្ទះថ្ម រមែងបង្អុរលើបុគ្គលអ្នកមានអំពើអាក្រក់ ។ ក្នុងនរកនោះ មានខ្យល់ដ៏ក្ដៅ ដែលអត់ធន់បានដោយក្រ ព្រះអង្គដែលមានកម្មអាក្រក់ រមែងមិនបានសេចក្ដីសុខតិចតួច ក្នុងនរកនោះឡើយ តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកនឹងព្រះអង្គនោះ ដែលក្ដៅក្រហាយជានិច្ច ស្ទុះទៅមក មិនមានទីពួន ។

(៤៩) សត្តាហមាហំចិ រថេសុ យុត្តំ
សញ្ចោទិតព្វំ បហរំ កាមទុត្តំ
បតោទលដ្ឋីហិ សុចោទយន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។

(៥០) គមារុហន្តំ ខុរសញ្ចិតំ គិរឹ
វិភឹសនំ បជ្ជលិតំ ភយានកំ
សញ្ឆិន្នគត្តំ រុហិរំ សវន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។

(៥១) គមារុហន្តំ បព្វតសន្និកាសំ
អង្គាររាសឹ ជលិតំ ភយានកំ
សុទឌ្ឍគត្តំ កបណំ រុទន្តំ
កោ ចោទយេ បរលោកេ សហស្សំ ។

(៥២) អព្ភកូដសមា ឧច្ចា កណ្ដកាហិ [1]ចិតា ទុមា
អយោមយេហិ តិក្ខេហិ នរលោហិតបាយិភិ ។
គមារុហន្តិ នារិយោ នរា ច បរទារគូ
ចោទិតា សត្តិហត្ថេហិ យមនិទ្ទេសការិភិ ។
គមារុហន្តំ និរយេ សិម្ពលឹ រុហិរមក្ខិតំ
វិទឌ្ឍកាយំ វិតចំ អាតុរំ គាឡ្ហវេទនំ ។

[1] ឱ. កណ្ដកាបចិតា ។ ម. កណ្ដកាហិ ចិតា ។



(៤៩) ព្រះអង្គសុះទៅសុះមក ដែលនាយនិរយបាលទឹមក្នុងរថ ព្រះអង្គជាន់ផែនដីមានអណ្ដាតភ្លើងសន្ធោសន្ធៅ ដែលនាយនិរយបាលកំពុងវាយ ដោយជន្លួញ តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៥០) ព្រះអង្គឡើងកាន់ភ្នំ ដែលដាសដោយកាំបិត ជាភ្នំគួរស្ញែង មានអណ្ដាតភ្លើងប្រាលរន្ទាលឆួលឆៅគួរខ្លាច ព្រះអង្គមានខ្លួនដាច់ដាយ កំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៥១) ព្រះអង្គឡើងកាន់គំនរភ្លើង ប្រាកដស្មើដោយភ្នំ ដ៏ប្រាលក្ដៅគួរខ្លាច មានខ្លួនឆេះសព្វ ជាសត្វកំព្រា ទ្រហោយំ តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៥២) ដើមឈើដ៏ខ្ពស់ស្មើនឹងពពក រុំព័ទ្ធដោយបន្លាដ៏មុត ជាវិការៈនៃដែក ជាបន្លាផឹកឈាមរបស់នរជន ។ ពួកស្ត្រីនឹងបុរស ដែលគប់ប្រកបនឹងប្រពន្ធដទៃ ត្រូវពួកនាយនិរយបាលកាន់លំពែង ជាអ្នកធ្វើតាមពាក្យរបស់យមរាជដាក់ហើយ រមែងឡើងដើមឈើនោះ ។ ព្រះអង្គនឹងឡើងដើមរកាក្នុងនរក មានកាយរលាយប្រឡាក់ដោយឈាម មានស្បែករបក ក្ដៅក្រហាយជាខ្លាំង មានវេទនាដ៏ខ្លាំង ។

បស្សន្តិ ឧហ៊ាំ ទុណ្ហំ  បុព្វកាម្មាចកជំកាំ
ធុមវត្តេ វិតនំ កត្តំ  កោ តំ យាចេយ្យ តំ ធនំ។

(៨៣) អគ្គិក្ខន្ធសមា ទុក្ខា  អសិបត្តចិតា ទុមា
អយោមយេហិ តិក្ខេហិ  នរលោហិតបាយិភិ ។
តមារុហន្តិ អសិបត្តបាទបំ
អសីហិ តិក្ខេហិ ច ឆិន្នមានា
សញ្ឆិន្នគត្តំ រុហិរំ សវន្តិ
កោ ចោទយេ បរលោកេ សហស្សំ ។

(៨៤) តតោ និក្ខន្តមត្តំ  អសិបត្តនិរយា ទុខា
សម្បតិតំ វេត្តរណឹ  កោ តំ យាចេយ្យ តំ ធនំ។

(៨៥) ខរា ខារោទកា តត្តា  ទុគ្គា វេត្តរណី នទី
អយោបោក្ខរសញ្ឆន្នា  តិក្ខបត្តេហិ សន្ទតិ ។
តត្ថ សញ្ឆិន្នគត្តា  វុយ្ហន្តិ រុហិរមក្ខិតា
វេត្តរញ្ញេ អនាលម្ពេ  កោ តំ យាចេយ្យ តំ ធនំ។



ដែលដុតដើមដាំក្តៅរឿយៗ តាមកំហុសព្រោះបុព្វកម្ម មានខ្ទុះបែកស្បែក
ទៅលើចុងដែក តើនរណានឹងទារទ្រព្យនោះ នឹងព្រះអង្គបាន ។

(៨៣) ដើមឈើខ្ពស់ស្មើនឹងគំនរភ្លើង ថែក្រោដោយស្លឹកជាដាវ ជាវិការៈ
នៃដែកដ៏មុត ផឹកឈាមនៃមនុស្ស ។
ព្រះអង្គនឹងឡើងដើមឈើ មានស្លឹកជាដាវ ត្រូវនាយនិរយ-
បាល កាប់ដោយដាវដ៏មុត មានខ្លួនខ្ទេចខ្ទាយ កំពុងហូរឈាម
តើនរណានឹងទារកហាបណៈ ១ ពាន់ ក្នុងបរលោកបាន ។

(៨៤) ព្រះអង្គនឹងដើរចេញ អំពីនរកមានដើមឈើ មានស្លឹកជាដាវនោះ
ហើយ ក៏ធ្លាក់ទៅក្នុងស្ទឹងឈ្មោះវេត្តរណី តើនរណានឹងទារ
ទ្រព្យនោះ នឹងព្រះអង្គបាន ។

(៨៥) ស្ទឹងឈ្មោះវេត្តរណីដ៏កាច មានទឹកផ្សាក្តៅ ឆ្លងបានដោយក្រ
ដ៏ដេរដាសដោយស្លឹកឈូកជាវិការៈនៃដែក ហើយនឹងហូរទៅតាមស្លឹក
ដ៏មុត ។ ព្រះអង្គមានខ្លួនខ្ទេចខ្ទាយ ប្រឡាក់ដោយឈាម ដែល
ទឹកហូរនាំទៅ ក្នុងស្ទឹងឈ្មោះវេត្តរណីនោះ ជាស្ទឹងមិន
មានអ្វីតោងទេ តើនរណានឹងទារទ្រព្យនោះ នឹងព្រះអង្គបាន ។

(៨៦) វេធាមិ រុក្ខោ វិយ ឆិជ្ជមានោ
ទិសំ ន ជានាមិ បមុឡ្ហសញ្ញោ
ភយានុតប្បាមិ មហា ច មេ ភយា
សុត្វាន គាថា តវ ភាសិតា ឥសេ ។
អាទិត្តេ វារិមជ្ឈំ វ ទីបំវោឃេ មហណ្ណវេ
អន្ធការេវ បជ្ជោតោ ត្វំ នោសិ សរណំ ឥសេ ។
អត្ថញ្ច ធម្មញ្ច អនុសាស មំ ឥសេ ។
អតីតមទ្ធា អបរាធិតំ មយា
អាចិក្ខ មេ នារទ សុទ្ធិមគ្គំ
យថា អហំ នោ និរយំ បតេយ្យំ ។

(៨៧) យថា អហុ ធតរដ្ឋោ វេស្សាមិត្តោ ច អដ្ឋកោ
យមទគ្គិ ឧសិន្នរោ(សិវិរាជា)[១]បរិចារកា សមណព្រាហ្មណានំ
ឯតេ ចញ្ញេ ច រាជានោ យេ សគ្គវិសយំ គតា ។
អធម្មំ បរិវជ្ជេត្វា ធម្មំ ចរ មហីបតិ
អន្នហត្ថា ច តេ ព្យម្ហេ ឃោសយន្តុ បុរេ តវ ។

១ ម. យាមទគ្គិ ឧសិន្នរោ ចាបិ សិវិ ច រាជា ។ ឧ. យមទគ្គិ ឧសិន្នរោ សិវិរាជា ។



(៨៦) (ព្រះរាជា...) ខ្ញុំញាប់ញ័រ ដូចជាដើមឈើប្រុងនឹងដាច់ ខ្ញុំវង្វេងស្មារតី មិនដឹងទិស ក្តៅក្រហាយរឿយ ៗ ព្រោះភ័យ (នឹងបាបដែលខ្ញុំធ្វើហើយ) បពិត្រឥសី ភ័យដ៏ធំកើតឡើងដល់ខ្ញុំ ព្រោះបានស្តាប់គាថាដែលលោកសំដែងហើយ ។ បពិត្រឥសី សូមលោកជាទីពឹងរបស់ខ្ញុំ ដូចជាបុគ្គលកាលចុះទៅកាន់ទីពាក់កណ្តាលទឹក ព្រោះកាយក្តៅភ្លើងកំពុងឆេះ ឬដូចជាកោះរបស់ពួកជន ដែលធ្លាយសំពៅក្នុងអន្លង់ធំ ក្នុងមហាសមុទ្រ ឬក៏ ដូចជាប្រទីបរបស់ពួកជនអ្នកទៅក្នុងទីងងឹត ។ បពិត្រឥសី សូមលោកប្រៀនប្រដៅនូវអត្ថនិងធម៌ដល់ខ្ញុំផង កំហុសខ្ញុំបានប្រព្រឹត្តកន្លងហើយអស់កាលយូរ បពិត្រនារទៈ សូមលោកប្រាប់ផ្លូវសេចក្តីបរិសុទ្ធិដល់ខ្ញុំ កុំឲ្យខ្ញុំធ្លាក់ទៅនរកឡើយ ។

(៨៧) (នារទព្រហ្ម...) ព្រះបាទធតរដ្ឋ ១ វេស្សាមិត្ត ១ អដ្ឋកៈ ១ យមទគ្គិ ១ ឧសិន្នរៈ ១ (សិវិ ១) ព្រះរាជាទាំង ៦ អង្គនេះ និងពួកព្រះរាជាដទៃ ជាអ្នកបំរើសមណព្រាហ្មណ៍ ទៅកាន់វិស័យឋានសួគ៌ យ៉ាងណា ។ បពិត្រព្រះអង្គជាធំលើផែនដី ព្រះអង្គចូរវៀរអធម៌ ហើយប្រព្រឹត្តធម៌ យ៉ាងនោះចុះ មួយទៀត ពួករាជបុរសអ្នកកាន់យកបាយ ក្នុងប្រាសាទរបស់ព្រះអង្គក្តី ក្នុងបុរីរបស់ព្រះអង្គក្តី ចូរឃោសនាថា

កោ ឆាតោ កោ ច តសិតោ កោ មាលំ កោ វិលេបនំ

នានារត្តានិ វត្ថានិ    កោ នគ្គោ បរិទហិស្សតិ ។

កោ បន្ថេ ឆត្តមានេតិ    បាទុកា ច មុទូ សុភា

ឥតិ សាយញ្ច បាតោ ច    ឃោសយន្តុ បុរេ តវ ។

ជិណ្ណំ បោសំ គវស្សញ្ច    មាស្សុ យុញ្ជ យថា បុរេ

បរិហារញ្ច ទជ្ជាសិ    អធិការកតោ ពលី ។

(៤៨) កាយោ តេ រថសញ្ញាតោ    មនោ សារថិកោ លហុ

អវិហឹសា សារិតក្ខោ    សំវិភាគបដិច្ឆទោ ។

បាទសញ្ញមនេមិយោ    ហត្ថសញ្ញមបក្ខរោ

កុច្ឆិសញ្ញមនព្ភន្តោ    វាចាសញ្ញមកូជនោ ។

សច្ចវាក្យសមត្តង្គោ    អបេសុញ្ញសុសញ្ញតោ

គិរាសខិលនេលង្គោ    មិតភាណិសិលេសិតោ ។

សទ្ធាលោភសុសង្ខារោ    និវាតញ្ជលិកុព្ពរោ

អថទ្ធតានតិសាកោ    សីលសំវរនន្ធនោ ។



នរណាឃ្លាន នរណាស្រេក នរណាចង់បានកម្រងផ្កា នរណាចង់បានគ្រឿងលាប នរណាអាក្រាត ចង់ស្លៀកដណ្តប់សំពត់ជ្រលក់ពណ៌ផ្សេងៗ ។ នរណាចង់បាំងឆត្រដើរតាមផ្លូវ នរណាចង់បានស្បែកជើងដ៏ទន់ល្អ ពួកជនបុរស ចូរឃោសនាក្នុងបុរីរបស់ព្រះអង្គ រាល់ព្រឹករាល់ល្ងាចដូច្នេះឯង ។ សូមព្រះអង្គកុំទឹមគោនិងសេះជាសត្វចិញ្ចឹមចាស់ៗ ដូចក្នុងកាលមុនឡើយ (សត្វណា) មានកម្លាំងធ្វើឧបការៈច្រើនដល់ព្រះអង្គ ចូរប្រទានការរក្សា (ដល់សត្វនោះ)ផង ។

(៤៨) កាយរបស់ព្រះអង្គ ចូរសំគាល់ថាដូចរថ មានចិត្តជាឆាយសារថី ជាកាយហើសរហួន មានការមិនបៀតបៀនជាក្ប៉ៅ ដែលគេសម្រួលល្អហើយ មានការចែករំលែកទានជាផ្ទះ មានការសង្រួមជើងជាខ្នងកង់ មានការសង្រួមដៃជាក្រពង់ មានការសង្រួមពោះជាប្រេងលាប មានការសង្រួមវាចាជាសូរមិនលាន់ឮ ។ មានពាក្យពិត ជាអង្គនៃរថដ៏បរិបូណ៌ មានការមិនញុះញង់ ជាក្រណាប់ដ៏ល្អ មានវាចាពីរោះ ជាអង្គនៃរថមិនមានទោស គឺជាលើង មានការពោលល្មមប្រមាណ ជាគ្រឿងចង ។ មានសទ្ធានិងអលោភៈ ជាគ្រឿងប្រដាប់រថ មានការបន្ទន់ខ្លួនទាំងអញ្ជលីកម្ម ជាទូក មានការមិនរឹងត្អឹង ជាចង្កូវរថ មានការសង្រួមសីល ជាព្រ័ត្រប្រោម ។

អក្កោធនមនុគ្ឃាតី    ធម្មបណ្ឌរកម្ពលោ
ពាហុសច្ចមុបាលម្ភោ    ធិតិចិត្តមុបាធិយោ ។
កាលញ្ញុតាចិត្តសារោ    វេសារជ្ជតិទណ្ឌកោ
និវាតវុត្តិយោត្តង្គោ    អនតិមានយុគោ លហុ ។
អលីនចិត្តសន្ថារោ    វុទ្ធិសេវីរជោហតោ
សតិ បតោទោ ធីរស្ស    ធិតិ យោគោ ច រស្មិយោ ។
មនោ ទន្តំ បថំ នេតិ    សមទន្តេហិ វាហិភិ[១]
ឥច្ឆា លោភោ ច កុម្មគ្គោ    ឧជុមគ្គោ ច សញ្ញមោ ។
រូបេ សទ្ទេ រសេ គន្ធេ    វាហនស្ស បធាវតោ
បញ្ញា អាកោដនី រាជ    តត្ថ អត្តាវ សារថិ ។
សចេ ឯតេន យានេន    សមចរិយា ទឡ្ហា ធិតិ
សព្វកាមទុហោ រាជ    ន ជាតុ និរយំ វជេ ។

---
១ ម. វាហិហិ ។ ឱ. វាហិតិ ។



មានការមិនក្រោធ ជាការមិនសណ្តោក មានសុចរិតធម៌ ជាសំពត់ស មានពាហុសច្ចៈ ជាខ្សែរនោល(?) មានចិត្តតាំងនៅនឹង ជាកាសនៈ មានការដឹងកាល ជាឈើទ្រមវិចិត្រ មានសេចក្តីក្លៀវក្លា ជាផ្ទួល មានការប្រព្រឹត្តបន្ទន់ខ្លួនជាខ្សែ មានការមិនមើលងាយជាទឹមដ៏ស្រាល ។ មានចិត្តមិនរួញរា ជាកម្រាល មានការសេពសេចក្តីចំរើន(ដោយបញ្ញា) ជាគំរាស់ សតិរបស់ព្រះអង្គជាអ្នកប្រាជ្ញ ទុកជាជន្លួញមានព្យាយាមដ៏មាំនឹងការប្រកប ជាខ្សែរ ។ ចិត្តដែលទូន្មានល្អហើយរមែងនាំទៅកាន់ផ្លូវ (ផ្លូវដែលទៅកាន់ផ្លូវត្រង់) ដោយសារសេះទាំងឡាយដែលនាយសារថីហ្វឹកហ្វឺនល្អហើយ ព្រោះសេចក្តីប្រាថ្នានឹងសេចក្តីលោភជាផ្លូវខុស ការសង្រួមជាផ្លូវត្រង់ ។ បពិត្រព្រះរាជា កាលបើរថ គឺកាយ (របស់ព្រះអង្គ) ស្ទុះទៅក្នុងរូប សម្លេង រស ក្លិន ប្រាជ្ញាជាជន្លួញសម្រាប់គោះ ខ្លួនព្រះអង្គជានាយសារថីក្នុងរថនោះ ។ បពិត្រព្រះរាជា ប្រសិនបើការប្រព្រឹត្តស្មើនឹងសេចក្តីព្យាយាមដ៏មាំ ដោយយានគឺកាយនោះ ការបន្ធូរសេចក្តីប្រាថ្នាគ្រប់យ៉ាងក៏កើតមាន សត្វមិនទៅកាន់នរកដោយពិតប្រាកដ ។

(៥៩) អលាតោ ទេវទត្តោសិ សុនាមោ អាសិ ភទ្ទជិ
វិជយោ សារិបុត្តោសិ មោគ្គល្លានោសិ វីជកោ ។
សុនក្ខត្តោ លិច្ឆវិបុត្តោ គុណោ អាសិ អចេលកោ
អានន្ទោ សា រុចា អាសិ យា រាជានំ បសាទយិ ។
ឩរុវេលកស្សបោ រាជា បាបទិដ្ឋិ តទា អហុ
មហាព្រហ្មា ពោធិសត្តោ ឯវំ ធារេថ ជាតកន្តិ ។

មហានារទកស្សបជាតកំ អដ្ឋមំ ។

# វិធុរជាតកំ

(៦០) បណ្ឌុ កិសិយាសិ ទុព្ពលា
វណ្ណរូបំ ន តវេទិសំ បុរេ
វិមលេ អក្ខាហិ បុច្ឆិតា
កីទិសី តុយ្ហំ សរីរវេទនា ។

(៦១) ធម្មោ មនុជេសុ មាតីនំ
ទោហឡោ នាម ជនិន្ទ វុច្ចតិ
ធម្មាហតំ នាគកុញ្ជរ
វិធុរស្ស ហទយាភិបត្ថយេ ។



(៥៩) អលាតសេនាបតី គឺទេវទត្ត សុនាមអាមាត្យ គឺភទ្ទជិ វិជយអាមាត្យ គឺសារីបុត្ត វីជកទាសៈ គឺមោគ្គល្លាន ។ អចេលកៈឈ្មោះគុណៈ គឺសុនក្ខត្តលិច្ឆវីបុត្ត នាងរុចាណា បាននាំព្រះរាជា ឲ្យជ្រះថ្លា នាងរុចានោះ គឺអានន្ទ ។ ព្រះរាជា (អង្គតិ) ដែលមានទិដ្ឋិអាក្រក់ក្នុងកាលនោះ គឺឧរុវេលកស្សប មហាព្រហ្ម គឺពោធិសត្វ អ្នកទាំងឡាយ ចូរចាំទុកនូវជាតក ដូចសំដែងមកនេះ ។

ចប់ មហានារទកស្សបជាតក ទី ៨ ។

# វិធុរជាតក

(៦០) (វរុណនាគរាជសួរថា) នាងមានសម្បុរស្លេក ស្គាំងស្គម មានកំឡាំងតិច ពីដើមរូបសម្បុររបស់នាង មិនមែនបែបនេះទេ ម្នាលនាងវិមលា ខ្ញុំសួរហើយ នាងចូរប្រាប់ តើវេទនាក្នុងសរីរៈរបស់នាង ដូចម្តេច ។

(៦១) (នាងវិមលាទូលថា) បពិត្រព្រះអង្គជាធំជាងនាគផង ទំនៀមរបស់ស្ត្រីទាំងឡាយ ក្នុងពួកមនុស្ស (ដែលមានគភ៌) គេហៅថា ចំណង់ផ្ទៃគភ៌ បពិត្រព្រះអង្គជាកុញ្ជររបស់នាគ ខ្ញុំប្រាថ្នាបានដួងហឫទ័យរបស់វិធុរបណ្ឌិត ដែលត្រូវនាំយកមកដោយធម៌ ។

(២២) ចន្ទំ ខោ ត្វំ ទោហឡាយសិ
សុរិយំ វ អថវាបិ មាលុតំ
ទុល្លភំ ហិ វិធុរស្ស ទស្សនំ
កោ វិធុរំ ឥធមានយិស្សតិ ។

(២៣) កិន្នុ តាត តុវំ បជ្ឈាយសិ
បទុមំ ហត្ថគតំវ តេ មុខំ
កិន្នុ ទុម្មនរូបោសិ ឥស្សរ
មា ត្វំ សោចិ អមិត្តតាបន ។

(២៤) មាតា ហិ តវ ឥរន្ធតិ
វិធុរស្ស ហទយំ ធនិយតិ
ទុល្លភំ ហិ វិធុរស្ស ទស្សនំ
កោ វិធុរំ ឥធមានយិស្សតិ ។

(២៥) តំ ភត្តារំ បរិយេសនំ ចរ
យោ វិធុរំ ឥធមានយិស្សតិ ។
បិតុនោ ច សា សុត្វាន វាក្យំ
រត្តឹ និក្ខម្ម អវស្សុតឹ ចរិ ។



(២២) (វរុណនាគរាជ...) ម្នាលនាងវិមលា នាងចង់បាន (ដួងហឫទ័យរបស់វិធុរបណ្ឌិតនោះ ដូចបុគ្គលប្រាថ្នា) ព្រះចន្ទ ព្រះអាទិត្យឬព្រះពាយ ព្រោះថា ការជួបប្រទះនឹងវិធុរបណ្ឌិត គេធ្វើបានដោយក្រ នរណានឹងនាំព្រះវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន ។

(២៣) (នាងឥរន្ទតី...) បពិត្របិតា ហេតុអ្វីហ្ន៎ ព្រះអង្គសញ្ជប់សញ្ជឹងព្រះភ័ក្ត្ររបស់ព្រះអង្គ ដូចជាផ្កាឈូក ដែលគេញីដោយដៃ បពិត្រព្រះអង្គជាឥស្សរៈ ព្រះអង្គខូចព្រះហឫទ័យដូចម្តេច បពិត្រព្រះអង្គអ្នកញ៉ាំងសត្រូវឲ្យក្តៅ សូមព្រះអង្គកុំទ្រង់សោយសោកឡើយ ។

(២៤) (វរុណនាគរាជ...) ម្នាលនាងឥរន្ទតី មាតារបស់នាង ចង់បានហឫទ័យរបស់វិធុរបណ្ឌិត តែការជួបប្រទះនឹងវិធុរបណ្ឌិត គេធ្វើបានដោយក្រ នរណានឹងនាំវិធុរបណ្ឌិត មកក្នុងពិភពនាគនេះបាន ។

(២៥) ភស្តាណានាំវិធុរបណ្ឌិតមកក្នុងទីនេះបាន នាងចូរត្រាច់ទៅស្វែងរកភស្តានោះចុះ ។ នាងឥរន្ទតីនោះ លុះបានស្តាប់បន្ទូលព្រះបិតាហើយ ក៏ចេញទៅក្នុងវេលារាត្រី ជាស្រីជោកជាំ (ដោយកាមៈ) បានត្រាច់ទៅ (ស្វែងរកព្រះភស្តា) ។

(៦៦) កេ គន្ធព្វេ រក្ខសេ ច នាគេ
កេ កិម្បុរិសេ ចាបិ មានុសេ
កេ បណ្ឌិតេ សព្វកាមទទេ
ទីឃរត្តំ ភត្តា មេ ភវិស្សតិ ។

(៦៧) អសុរាស ហោស្សាមិ តេ បតិ
កត្តា តេ ហោស្សាមិ អនិន្ទលោចនេ
បញ្ញាហិ មម តជាវិតាហិ
អសុរាស ហោស្សសិ ភរិយា មម ។

(៦៨) អវោចសិ បុណ្ណកំ ឥរន្ធតី
បុព្វបថានុគតេន[១] ចេតសា
ឯហិ គច្ឆាម បិតុ មមន្តិកេ
ឯសោ តេ ឯតមត្ថំ បវក្ខតិ ។

(៦៩) អលង្កតា សុវសនា មាលិនី ចន្ទនុស្សទា
យក្ខំ ហត្ថេ គហេត្វាន បិតុ សន្តិកុបាគមិ ។

(៧០) នាគវរ វចោ សុណោហិ មេ
បតិរូបំ បដិបជ្ជ សុង្កិយំ

---

១ ម. បុព្វបទានុគតេន ។



(៦៦) (នាងឥរន្ធតី...) នរណាទោះជាគន្ធព្វក្តី នរណាទោះជារាក្ស ទឹកឬជានាគក្តី នរណាទោះជាកិន្នរ ឬជាមនុស្សក្តី នរណាទោះជាបណ្ឌិត ដែលឲ្យសេចក្តីប្រាថ្នាទាំងពួងក្តី អ្នកនោះនឹងជាភស្តារបស់ខ្ញុំ អស់កាលមានរាត្រីដ៏វែង ។

(៦៧) (បុណ្ណកយក្ស...) ម្នាលនាង នាងកុំគិតតិះដៀលម៉េចបាន នាងចូរដកដង្ហើមស្រួល (ក្រែកអា)ចុះ ខ្ញុំនឹងជាប្តីរបស់នាង នឹងជាភស្តារបស់នាង ដោយហេតុថាបញ្ញារបស់ខ្ញុំមានសភាពដូច្នោះ នាងចូរដកដង្ហើមស្រួលចុះ នាងនឹងជាភរិយារបស់ខ្ញុំ ។

(៦៨) នាងឥរន្ធតី ក៏មានចិត្តជាប់តាមគន្លងដែលធ្លាប់ជាប់ក្នុងជាតិមុន បាននិយាយនឹងបុណ្ណកយក្សថា អ្នកចូរមក យើងនឹងនាំគ្នាទៅឯសំណាក់បិតាខ្ញុំ បិតានោះនឹងប្រាប់សេចក្តីនុះដល់អ្នក ។

(៦៩) (អភិសម្ពុទ្ធគាថា) នាងឥរន្ធតី តាក់តែងខ្លួន ស្លៀកពាក់ល្អ ប្រដាប់កម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ ចាប់ដៃបុណ្ណកយក្ស នាំចូលទៅកាន់សំណាក់បិតា ។

(៧០) (បុណ្ណកយក្ស...) បពិត្រព្រះអង្គប្រសើរជាងនាគ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់ទទួលស្លួយដ៏សមគួរ (ដល់ត្រកូលនឹងប្រទេសរបស់ព្រះអង្គ)

យាចាមិ អហំ ឥរន្ធតិំ

តាយ សមង្គឹ ការេហិ មំ តុវំ ។

សតំ ហត្ថី សតំ អស្សា សតំ អស្សតរី រថា

សតំ វឡភិយោ បុណ្ណា នានារត្នស្ស កេវលា

តេ នាគ បដិបជ្ជស្សុ ធីតរំ ទេហិរន្ធតិំ ។

(៧៥) យាវ អាមន្តយេ ញាតី មិត្តេ ច សុហទជ្ជនេ

អនាមន្តកតំ កម្មំ តំ បច្ឆា អនុតប្បតិ ។

(៧៦) តតោ សោ វរុណោ នាគោ បវិសិត្វា និវេសនំ

ភរិយំ អាមន្តយិត្វាន ឥទំ វចនមព្រវិ ។

អយំ សោ បុណ្ណកោ យក្ខោ យាចតិ មំ ឥរន្ធតិំ

ពហុនា វិត្តលាភេន តស្ស ទេម បិយំ មមំ ។

(៧៧) ន ធនេន ន វិត្តេន លព្ភា អម្ហំ ឥរន្ធតី

សចេ ច ខោ ហទយំ បណ្ឌិតស្ស

ធម្មេន លទ្ធា ឥធ មាហរេយ្យ

ឯតេន វិត្តេន កុមារិ លព្ភា

នាញ្ញំ ធនំ ឧត្តរិ បត្ថយាម ។



ខ្ញុំព្រះអង្គចង់បាននាងឥរន្ធតី សូមព្រះអង្គធ្វើខ្ញុំព្រះអង្គឲ្យរួមមិត្តជាមួយនឹងនាងឥរន្ធតីនោះ ។

បពិត្រព្រះអង្គដ៏ប្រសើរ សូមព្រះអង្គទ្រង់ទទួលនូវសួយការនេះ គឺ ដំរី ១០០ សេះ ១០០ រទេះទឹមដោយសេះអស្សតរ ១០០ និងរទេះដែលផ្ទុកពេញ ដោយរតនៈផ្សេងៗ ចំនួន ១០០ សូមព្រះអង្គទ្រង់ព្រះរាជទានធីតា ឈ្មោះនាងឥរន្ធតី ឲ្យខ្ញុំ ។

(៧៥) (ព្រះបាទវរុណ...) អ្នកចូររង់ចាំ យើងប្រឹក្សានឹងពួកញាតិមិត្រ ឬ សំឡាញ់ដ៏ស្និទ្ធស្នាលសិន អំពើដែលយើងធ្វើដោយមិនបានប្រឹក្សាណា អំពើនោះរមែងក្ដៅក្រហាយ ក្នុងកាលខាងក្រោយ ។

(៧៦) លំដាប់នោះ វរុណនាគនោះ ចូលទៅកាន់លំនៅហើយប្រឹក្សានឹងភរិយា ហើយពោលពាក្យនេះថា បុណ្ណកយក្សនេះ សូមនាងឥរន្ធតីពីយើង យើងនឹងឲ្យនាងឥរន្ធតី ជាទីស្រឡាញ់របស់យើងដល់បុណ្ណកយក្សនោះ ដោយការបានវត្ថុជាទីត្រេកអរច្រើនជាថ្នូរ ។

(៧៧) (នាគីវិមលា...) បុណ្ណកយក្សមិនត្រូវបាននាងឥរន្ធតី ជាធីតារបស់យើងដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរទេ តែបើបុណ្ណកយក្ស បាននូវហឫទ័យរបស់បណ្ឌិតដោយធម៌ ហើយនាំមកក្នុងពិភពនាគនេះ ទើបត្រូវបាននាងកុមារីដោយសារវត្ថុជាទីត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ ។

(៤៤) តតោ សោ វិធុរោ ឆាតោ និក្ខមិត្វា និវេសនា

បុណ្ណកាមន្តយិត្វាន ឥទំ វចនមព្រវិ ។

ន ធនេន ន វិត្តេន លព្ភា អម្ហំ ឥវន្តី

សាធុ ត្វំ ហនយំ បណ្ឌិតស្ស

ធម្មេន លទ្ធា ឥធមាហរេសិ

និគេន វិត្តេន កុមារិ លព្ភា

ញាត្វា ធនំ ឧត្តរិ បត្ថយាម ។

(៤៥) យំ បណ្ឌិតោ កោតុកោ វត្តិ លោកោ

តមេវ ភាសេតិ បុនាបរំ អញ្ញំ

អត្ថាហិ មេ វិធុរវត្តិ និត្ថុ

តំ បណ្ឌិតំ នាគ ត្វំ វទេសិ ។

(៤៦) កោរព្យរាជស្ស ធនញ្ជយស្ស

យទិ តេ សុតោ វិធុរោ នាម កត្តា

អានេហិ តំ បណ្ឌិតំ ធម្មលទ្ធា

ឥវន្តី បជ្ជចរី តេ ហោតុ ។



(៤៤) លំដាប់នោះ វិធុរនាគនោះចេញអំពីលំនៅ ហៅបុណ្ណកយក្ស

មកនិយាយពាក្យនេះថា អ្នកមិនត្រូវបាននាងឥវន្តី ជាធីតារបស់

យើងដោយទ្រព្យ មិនត្រូវបាន ដោយវត្ថុជាទីត្រេកអរ ជាថ្នូរ

បើអ្នកបានហ្ឫទ័យរបស់បណ្ឌិត ដោយធម៌ ហើយនាំមកក្នុង

ពិភពនាគនេះ ទើបអ្នកត្រូវបាននាងកុមារី ដោយសារវត្ថុជាទី

ត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃអំពីនេះទៀតទេ ។

(៤៥) (បុណ្ណកយក្ស...) ពលីត្រូវព្រះអង្គដ៏ប្រសើរ បុគ្គលក្នុងលោក

លោកនេះ ហៅមនុស្សណា ជាជាបណ្ឌិត បុគ្គលឯទៀត

វែរជាហៅបុគ្គលនោះថា ជាពាលវិញ អ្នកដទៃកង់ផែក

ក្នុងរឿងនេះ សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គឲ្យបាន

ពលីក្រនាគ ព្រះអង្គត្រាស់ហៅអ្នកណា ថាជាបណ្ឌិត ។

(៤៦) (ព្រះបាទវរុណ...) អាមាត្យឈ្មោះវិធុរៈរបស់ធនញ្ជយកោរព្យរាជ

អ្នកធ្លាប់បានឮហើយ បើអ្នកបានបណ្ឌិតនោះ ដោយធម៌

ហើយនាំមក នាងឥវន្តីគួរបានជាអ្នកបំរើជើង របស់អ្នកចុះ ។

(៨៨) ឥច្ចេវ សុត្វា វិធុរស្ស វាក្យំ
ឧដ្ឋាយ យក្ខោ បរមប្បតីតោ
តត្ថេវ សន្តោ បុរិសំ អសំសិ
អានេហិ អាជញ្ញមិតោវ យុត្តំ ។
ជាតរូបមយា កណ្ណា កាចម្ហិចមយា ខុរា
ជម្ពោនទស្ស បាកស្ស សុវណ្ណស្ស ឧរច្ឆទោ ។

(៨៩) ទេវវាហវហំ យានំ អស្សមារុយ្ហ បុណ្ណកោ
អលង្កតោ កប្បិតកេសមស្សុ
បក្កាមិ វេហាយសមន្តលិក្ខេ ។
សោ បុណ្ណកោ កាមរាគេន គិទ្ធោ
ឥរន្ធតឹ នាគកញ្ញំ ជិគីសំ
គន្ត្វាន តំ ភូតបតឹ យសស្សឹ
ឥច្ចព្រវី វេស្សវណំ កុវេរំ ។
ភោគវតី នាម មន្ទិរេ
វាសា ហិរញ្ញវតីតិ វុច្ចតិ
នគរេ និម្មិតេ កញ្ចនមយេ
មណ្ឌលស្ស ឧរគស្ស និដ្ឋិតំ ។



(៨៨) ចំណែកបុណ្ណកយក្ស លុះបានស្ដាប់ព្រះបន្ទូលរបស់វិធុរបណ្ឌិតនេះហើយ ក៏ក្រោកឡើង ត្រេកអរក្រៃលែង ហើយសំដៅក្នុងទីនោះ បង្គាប់បុរស (អ្នកបំរើរបស់ខ្លួន) ថា អ្នកចូរនាំសេះអាជានេយ្យ ដែលបានសំរិតសំរាំង យកមកក្នុងទីនេះ ។ ត្រចៀក (របស់សេះនោះ) ប្រដាប់ដោយមាស ក្រចកប្រដាប់ដោយកែវណិលមានពណ៌ក្រហម គ្រឿងបិទបាំងទ្រូងដ៏ប្រសើរ ប្រដាប់ដោយមាសសុទ្ធ ឈ្មោះជម្ពូនទ ។

(៨៩) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្សតាក់តែងខ្លួន កាត់កោរសក់ពុកមាត់ស្រេចហើយ ក៏ឡើងជិះសេះដែលជាយាន ដូចជាពាហនៈនៃទេវតា ហោះទៅក្នុងអាកាសវេហា ។

បុណ្ណកយក្សនោះ ជាប់ចំពាក់ដោយកាមរាគ ប្រាថ្នានាងឥរន្ធតី ជាកញ្ញានៃនាគ បានទៅក្រាបទូលព្រះបាទវេស្សវណកុវេរៈ ដ៏ប្រសើរយស ជាម្ចាស់ពួកយក្សនោះ ដូច្នេះថា មន្ទីរឈ្មោះភោគវតី គេហៅថា វាសៈ (ព្រោះជាលំនៅនៃស្ដេចនាគ) គេហៅថា ហិរញ្ញវតី (ព្រោះជាទីដែលបិទបាំងដោយកែវប្រាក់) ជានគរសម្រេច អំពីមាស ដែលសាងសម្រេច ដល់នាគ មានមណ្ឌលនៃខ្លួន ។

អដ្ដាលកា ទិដ្ឋកិរិយោ
លោហិតង្គស្ស មសារគល្លិយោ
បាសាណេត្ថ សិលាមយា
សោវណ្ណរតនេន ឆាទិតា ។
អម្ពា តិលកា ច ជម្ពុយោ
សត្តបណ្ណា មុចលិន្ទកេតកា
បិយង្គុកា ឧទ្ទាលកា សហា
ឧបរិភទ្ទកា សិន្ទុភរិកា
ចម្ពេយ្យកា នាគមល្លិកា
ភគិនីមាលា អថេត្ថ កោលិយា
ឯតេ ទុមា បរិណាមិតា
សោភយន្តិ ឧរគស្ស មន្ទិរំ ។
ខជ្ជុរេត្ថ សិលាមយា សោវណ្ណធុវបុប្ផិតា (ពហូ)
យត្ថ វសតោបបាតិកោ
នាគរាជា វរុណោ មហិទ្ធិកោ ។
តស្ស កោមារិកា ភរិយា
វិមលា កាញ្ចនវេល្លិវិគ្គហា





ប៉មមានសណ្ឋានដូចកន្ទុំ ធ្វើអំពីកែវមណីក្រហម និងកែវមរកត ប្រាសាទក្នុងពិភពនាគធ្វើអំពីកែវមណី ប្រក់ដោយរតនៈគឺមាស ។ ដើមឈើទាំងឡាយ គឺដើមស្វាយ ដើមក្រម្លូង ដើមព្រីង ដើមសត្តបណ្ណ (ឈើមានស្លឹក ៧) ដើមរាំងទន្លក់ ដើមកេតកី ដើមបិយង្គុ ដើមរាជព្រឹក្ស ព្រមទាំងដើមបារិច្ឆត្ត-ព្រឹក្ស ដើមឈើតាលទ្រុប (មានក្នុងពិភពនាគនោះ) ។ ដើមចម្បា ដើមខ្ទឹង ម្ទេះ ដួងស្រី និងដើមក្រញូង មានក្នុងក្រុងពិភពនាគនោះ ដើមឈើទាំងនោះ ទន់ទាបល្អស្រស់ក្នុងមន្ទីរនាគ ។ ព្រះបាទវរុណៈ ជាឧបបាតិកៈកំណើតមានឫទ្ធិច្រើន នៅក្នុងពិភពនាគណា ក្នុងដើមត្នោតជាច្រើន ដ៏ហើយដោយកែវថ្មសិលា មានផ្កាជានិច្ច ជាភោគៈនៃមាស ក្នុងពិភពនាគនោះ ។ នាងវិមលាជាភរិយារបស់ព្រះបាទវរុណ-នាគនោះ ជាស្រីនៅក្មេង មានកាយភ្លឺផុតដូចមាស

កាញ្ចា កេយុរានិ ឧក្កោតា
បុដិមន្តក្ខិ ហារុធស្សរា ។
លោហិតាសរត្តសុច្ឆវី
កណិការោវ និភកប្បិតា
តិទិវេក្កធរា អច្ឆរា
វិជ្ជុវព្ភឃនា និស្សដា ។
សា ទោហឡិនី សុវិម្ហិតា
វិធុរស្ស ហទយំ ធនិយតិ
តំ តេសំ ទេមិ ឥស្សរ
តេន តេ ទេតិ ធីតរំ មមំ ។

[៣៨] សោ បុណ្ណកោ ភូតបតី យសស្សី
អាមន្តយ វេស្សវណំ កុវេរំ
តត្ថេវ សន្តោ បុរិសំ អសំសិ
អាជានិយំ ឥធ មានេហិ យុត្តំ ។
ជាតរូបមយា កណ្ណា កាចម្ហិចមយា ខុរា
ជម្ពោនទស្ស បាកស្ស សុវណ្ណស្ស ឧរច្ឆទោ ។
ទេវវាហវហំ យានំ អស្សមារុយ្ហ បុណ្ណកោ



មានព្រះថនាដូចផ្កាស្ពៅ គួរជាទីរមិលមើលដោយសេចក្តីពេញចិត្ត ឬដូចក្រួយល្វែងប្រវិទ្ធ ។ នាងវិមលាមានសម្បុរដូចក្រហមដូចពណ៌លោ ដូចផ្កាកណ្ណិការរីកក្នុងទីមិនមានខ្យល់ ឬដូចស្រីអប្សរ នៅក្នុងឋានត្រៃត្រិង្ស ឬដូចផ្លេកបន្ទោរដែលចេញចាក់ចេញអំពីស្រទាប់ពពក ។ នាងវិមលានោះ ជាស្រីមានចំណង់ចង់បានស្ងោរព្រៃក្រៃលែង បង់បានហ្ឫទ័យនៃវិធុរបណ្ឌិត ចាំព្រះនាង ជាឥស្សរៈ ។ នាងនិយាយហ្ឫទ័យវិធុរបណ្ឌិតនោះដល់នាគជាស្វាមីនោះ នាគជាប្តីនោះ គឺនិយាយនាងអ៊ីរន្ទតីដល់ទ្រង់ ដោយហេតុនោះ ។

[៣៨] បុណ្ណកយក្សនោះទូលលា ព្រះបាទវេស្សវណកុវេរៈ ជាម្ចាស់នៃខ្លួន ជាព្រះរាជាមានយស ហើយស្ទុះទៅក្នុងទីនោះ បង្គាប់បុរស (អ្នកបំរើខ្លួន) ថា អ្នកចូរនាំសេះអាជានេយ្យដែលបានស្អិតស្អាង យកមកក្នុងទីនេះ ។

គ្រឿង (របស់សេះនោះ) ប្រដាប់ដោយមាស ក្រចកសេះប្រដាប់ដោយកែវមណី មានពណ៌ក្រហម គ្រឿងបិទបាំងទ្រូងប្រដាប់ដោយមាសសុទ្ធ ឈ្មោះជាវត្ថុមាស បុណ្ណកយក្ស

អលង្កតោ កប្បិតកេសមស្សុ
បក្កាមិ វេហាយសមន្តលិក្ខេ ។

[៨០] សោ អគ្គមា រាជគហំ សុរម្មំ
អង្គស្ស រញ្ញោ នគរំ ទុរាយុតំ(១)
បហូតភក្ខំ ពហុអន្នបានំ
មសក្កសារំ វិយ វាសវស្ស ។
មយូរកោញ្ចាគណសម្បឃុដ្ឋំ
ទិជាភិឃុដ្ឋំ ទិជសង្ឃសេវិតំ
នានាសកុន្តាភិរុទំ សុវង្គណំ
បុប្ផាភិកិណ្ណំ ហិមវំវ បព្វតំ ។
សោ បុណ្ណកោ វេបុលមាភិរូហិ
សិលុច្ចយំ(២) កិម្បុរិសានុចិណ្ណំ
អន្វេសមានោ មណិរតនំ ឧឡារំ
តមទ្ទសា បព្វតកូដមជ្ឈេ ។

[៨១] ទិស្វា មណឹ បភស្សរំ ជាតិមន្តំ
មនោហរំ(១) មណិរតនំ ឧឡារំ
ទទ្ទល្លមានំ យសសា យសស្សិំ

១ ឱ. ម. ទុរាយុត្តំ ។ ២ ម. សិលុព្វយំ ។





តាក់តែងខ្លួន កាត់កោរសក់និងពុកចង្ការស្រេចហើយ ក៏ឡើង ដើរលើផ្លូវជាយាន ដូចជាការយានៈនៃមេឃ ហោះទៅ ក្នុងអាកាសវេហា ។

(៨០) បុណ្ណកយក្សនោះបានទៅកាន់នគររាជគ្រឹះ ជាទីរីករាយដ៏ក្រៃលែង ជាក្រុងរបស់ព្រះបាទអង្គរាជ ដែលសត្រូវចូលមកបានដោយក្រ ជាក្រុងមានភក្សាហារច្រើន មានបាយនិងទឹកច្រើន ដូចជាពួកឈ្មោះមសក្កសារៈរបស់វាសវៈ ។ នគរនោះ គឹកកង ដោយហ្វូងនៃសត្វក្ងោកនិងក្រៀល គឹកកងដោយសត្វស្លាប ដែលពួកសត្វស្លាបអាស្រ័យនៅ មានសូរសំឡេងនៃពួកបក្សីផ្សេងៗ មានព្រះលានដ៏ល្អ ដេរដាសដោយផ្កា ដូចជាភ្នំហិមវន្ត ។ បុណ្ណកយក្សនោះឡើងទៅកាន់ភ្នំឈ្មោះវេបុលៈ ជាទីអាស្រ័យនៅនៃពួកកិន្នរ ហើយស្វែងរកកែវមណីដ៏ប្រសើរ បានឃើញកែវមណីនោះ ត្រង់កណ្តាលកំពូលភ្នំ ។

(៨១) បុណ្ណកយក្សឃើញកែវមណី មានជាតិ (ផ្សេងៗ) ជាទីផ្លូយចេញនៃរស្មីរុងរឿង ជាកែវមណីដ៏ប្រសើរ គាប់ចិត្ត មកឱ្យព្រេញ ជាកែវរុងរឿង ជាកែវមានយសជាទីយស

ទិត្តា សតេរី វិជ្ជុរិវន្តលិក្ខេ ។
គបក្កហី វេឡុរិយំ មហគ្ឃំ
មនោហរំ នាម មហានុភាវំ
អាជញ្ញមារុយ្ហ អនោមវណ្ណោ
បក្កាមិ វេហាយសមន្តលិក្ខេ ។

(៨៦) សោ អគ្គមា នគរំ ឥន្ទបត្តំ
ឱរុយ្ហុបាគញ្ឆិ សភំ កុរូនំ
សមាគតេ ឯកសតំ សមគ្គេ
អវ្ហេត្ថ យក្ខោ អវិកម្បមានោ ។
កោ នីធ រញ្ញំ វរមាភិជេតិ
កមាភិជេយ្យាម វរទ្ធនេន
កមនុត្តរំ រតនវរំ ជិនាម
កោ វាបិ នោ ជេតិ វរទ្ធនេន ។

(៨៧) កុហឹ នុ រដ្ឋេ តវ ជាតិភូមិ
ន កោរព្យស្សេវ វចោ តវេទំ
អភីតោសិ នោ វណ្ណនិភាយ សព្វេ
អក្ខាហិ មេ នាមញ្ច ពន្ធុវេ ច[១] ។

---
១ ម. ពន្ធវេ ។



ក៏ផ្ទឹងឡើងដូចផ្លេកបន្ទោរក្នុងអាកាស ក៏បានកាន់យកកែវមណី ឈ្មោះមនោហរៈនោះ ជាកែវពៃទូរ្យ មានដំឡៃច្រើន មានអានុភាពច្រើន ជាអ្នកមានភេទមិនថោកទាប ឡើងជិះសេះអាជានេយ្យ ហោះទៅក្នុងអាកាសវេហា ។

(៨៦) បុណ្ណកយក្សនោះ បានទៅកាន់ក្រុងឥន្ទបត្ត ចុះ(អំពីសេះ) ហើយចូលទៅកាន់ទីប្រជុំនៃអ្នកដែនកុរុ មិនកោតញាញើតព្រះរាជា ១០១ អង្គ ដែលព្រមព្រៀងគ្នាមកប្រជុំ (នៅទីនោះ) បបួលថា បណ្ដាក្សត្រព្រះរាជាក្នុងក្សត្រសមាគមនេះ ព្រះរាជាអង្គណាឈ្នះយើង(ក្នុងភ្នាល់) នឹងនាំកែវដ៏ប្រសើរ (របស់យើង)ទៅ យើងឈ្នះព្រះរាជាអង្គណាវិញ (ក្នុងភ្នាល់) ទ្រព្យដ៏ប្រសើរ ឬយើងឈ្នះព្រះរាជាអង្គណា (នឹងយក) នូវកែវដ៏ប្រសើរថ្លៃថ្លា ក៏បាន ចំណែកព្រះរាជាអង្គណាឈ្នះយើងវិញ (នឹងយក) ទ្រព្យដ៏ប្រសើរ ក៏បាន ។

(៨៧) (ព្រះបាទកោរព្យៈ...) ជាតិភូមិរបស់អ្នក នៅក្នុងដែនណា ពាក្យរបស់អ្នកនេះ មិនមែនជាពាក្យ របស់អ្នកដែនកុរុទេ អ្នកមានពណ៌និងរស្មី មិនកោតខ្លាចយើង ទាំងអស់គ្នា អ្នកចូរប្រាប់ឈ្មោះនិងផៅពង្សដល់យើង ។

(៤៤) កច្ចាយនោ មាណវកោស្មិ រាជ
អនូននាមោ ឥតិ មវ្ហយន្តិ
អង្គេសុ មេ ញាតយោ ពន្ធវា ច
អក្ខេន ទេវស្មិ ឥធានុបត្តោ ។

(៤៥) កឹ មាណវស្ស រតនានិ អត្ថិ
យេ តំ ជិនន្តោ ហរេ អក្ខធុត្តោ
ពហូនិ រញ្ញោ រតនានិ អត្ថិ
តេ ត្វំ ទលិទ្ទោ កថមវ្ហយសិ ។

(៤៦) មនោហរោ នាម មណិ មមាយំ
មនោហរំ មណិរតនំ ឧឡារំ
ឥមញ្ច អាជញ្ញំ អមិត្តតាបនំ
ឯតំ មេ ជិនិត្វា ហរេ អក្ខធុត្តោ ។

(៤៧) ឯកោ មណិ មាណវ កឹ ករិស្សតិ
អាជានិយេកោ បន កឹ ករិស្សតិ
ពហូនិ រញ្ញោ រតនានិ អត្ថិ
អាជានិយា វាតជវា អនប្បកា ។

ទោហឡកណ្ឌំ ចប់ ។



(៤៤) (បុណ្ណកយក្ស...) បពិត្រព្រះរាជា ខ្ញុំជាមាណពកច្ចាយនគោត្រ ពួកញាតិនិងផៅពង្សរបស់ខ្ញុំព្រះអង្គ(កាលចម្លងគនត) ដែនអង្គៈ តែងហៅខ្ញុំថា មាណព មានឈ្មោះមិនថោកទាប បពិត្រព្រះសម្មតិទេព ខ្ញុំមកក្នុងទីនេះ ដើម្បីលេងល្បែងភ្នាល់ ។

(៤៥) (ព្រះបាទកោរព្យៈ...) អ្នកលេងល្បែងភ្នាល់ កាលបើឈ្នះអ្នក គប្បីយកកែវទាំងឡាយណា តែកែវទាំងនោះ របស់មាណពឯង មានដែរឬ តែកែវរបស់ព្រះរាជា មានចំនួនច្រើន អ្នកជាមនុស្សទាល់ក្រ នឹងបបួលព្រះរាជាតាំងនោះ ដូចម្ដេចបាន ។

(៤៦) (បុណ្ណយក្ស...) កែវមណីរបស់ខ្ញុំនេះ អាចនាំមកនូវទ្រព្យបាន អ្នកលេងល្បែងភ្នាល់ បើលេងឈ្នះខ្ញុំហើយ គប្បីយកកែវមណីដ៏ប្រសើរ ជាកែវអាចនាំមកនូវទ្រព្យនេះ ១ នឹងសេះអាជានេយ្យ អាចបង្ក្រាបសត្រូវនេះ ១ របស់ខ្ញុំចុះ ។

(៤៧) (ព្រះបាទកោរព្យៈ...) ម្នាលមាណព កែវមណីមួយ នឹងធ្វើអ្វីបាន ទាំងសេះអាជានេយ្យមួយ នឹងធ្វើអ្វីបាន (ព្រោះ) កែវទាំងឡាយរបស់ព្រះរាជា មានចំនួនច្រើន សេះអាជានេយ្យរបស់ព្រះរាជា មានសន្ទុះដូចខ្យល់ ក៏មានចំនួនមិនតិចទេ ។

ចប់ ទោហឡកណ្ឌ ។

(៨៨) ឥទញ្ច មេ មណីរតនំ បស្ស ត្វំ ទ្វិបទុត្តម
ឥត្ថីនំ វិគ្គហា ចេត្ថ បុរិសានញ្ច វិគ្គហា ។
មិគានំ វិគ្គហា ចេត្ថ សកុណានញ្ច វិគ្គហា
នាគរាជេ សុបណ្ណេ ច មណិម្ហិ បស្ស និម្មិតំ ។

(៨៩) ហត្ថានីកំ រថានីកំ អស្សេ បត្តី ច វម្មិនេ
ចតុរង្គិនិំ សេនំ មណិម្ហិ បស្ស និម្មិតំ ។
ហត្ថារោហេ អនីកដ្ឋេ រថិកេ បត្តិការកេ
ពលគ្គានិ វិយូហានិ មណិម្ហិ បស្ស និម្មិតំ ។

(៩០) បុរំ អដ្ដាលសម្បន្នំ(១) ពហុបាការតោរណំ
សិង្ឃាដកេ សុភូមិយោ មណិម្ហិ បស្ស និម្មិតំ ។
ឯសិកា បរិក្ខាយោ ច បលិឃំ អគ្គឡានិ ច
អដ្ដាលកេ ច ទ្វារេ ច មណិម្ហិ បស្ស និម្មិតំ ។

(៩១) បស្ស តោរណមគ្គេសុ នានាទិជគណា ពហូ
ហំសា កោញ្ចា មយូរា ច ចក្កវាកា ច កុក្កុហា
កុណាលកា ពហូ ចិត្រា សិខណ្ឌី ជីវជីវកា
នានាទិជគណាកិណ្ណំ មណិម្ហិ បស្ស និម្មិតំ ។

---

១ ម. ឧទ្ទាបសម្បន្នំ ។



(៨៨) (បុណ្ណកយក្ស...) បពិត្រព្រះអង្គប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទតកែវមណីរបស់ខ្ញុំនេះចុះ ក្នុងកែវមណីនេះ មានរូបកាយរបស់ស្ត្រី មានរូបកាយរបស់បុរស ៗ មានរូបកាយរបស់ម្រឹគ មានរូបកាយរបស់បក្សី ប្រាកដក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់ទត នាគរាជនិងគ្រុឌ ជារូបនិម្មិត ក្នុងកែវមណី ។

(៨៩) សូមព្រះអង្គទ្រង់ទត សេនាមានអង្គ ៤ គឺពលដំរី ពលរថ ពលសេះ ពលថ្មើរជើងមានគ្រឿងក្រោះ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពលដំរីនិងពួកសេនា ពលរថនិងពលថ្មើរជើង និងពួកពលដែលរៀបជាក្បួន ជារូបនិម្មិត ក្នុងកែវមណី ។

(៩០) សូមព្រះអង្គទ្រង់ទត នគរដែលបរិបូណ៌ដោយប៉ម មានកំផែងនិងក្លោងទ្វារដ៏ច្រើនជាន់ មានផ្លូវបែកជា ៤ និងផែនដីដ៏ល្អ ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត សសរខឿន គូ រនុកទ្វារ គន្លឹះទ្វារ ប៉ម និងទ្វារប៉ម ជារូបនិម្មិត ក្នុងកែវមណី ។

(៩១) សូមព្រះអង្គទ្រង់ទត ពួកបក្សីផ្សេងៗជាច្រើន ទៀបក្លោងទ្វារនឹង ផង គឺ ហង្ស ក្រៀល ក្ងោក ចាក្រពាក កក សូមព្រះអង្គទ្រង់ទតទីក្រុង ដ៏ដេរដាសដោយបក្សីផ្សេងៗ គឺតាវៅ កាវៅក្រស ក្ងោក និងចាបព្រៃជាច្រើន ជារូបនិម្មិត ក្នុងកែវមណី ។

(៤៦) បស្ស នគរំ សុបាការំ អព្ភុតំ លោមហំសនំ

សមុស្សិតទ្ធជំ រម្មំ សុវណ្ណវាលុកសន្ថតំ។

បស្សេត្ថ បណ្ណសាលាយោ វិភត្តា ភាគសោ មិតា

និវេសនេ និវេសេ ច សន្ធិព្យូហេ[1] បថទ្ធិយោ។

(៤៧) បានាគារេ ច សោណ្ឌេ ច សូនា ឱទនិយា ឃរា

វេសី ច គណិកាយោ ច មណិម្ហិ បស្ស និម្មិតំ។

មាលាការេ ច រជកេ គន្ធិកេ អថ ទុស្សិកេ

សុវណ្ណការេ មណិការេ មណិម្ហិ បស្ស និម្មិតំ។

អាឡារិកេ ច សូទេ ច នដនដ្ដកគាយិនេ[2]

បាណិស្សរេ កុម្ភថូណិកេ មណិម្ហិ បស្ស និម្មិតំ។

(៤៨) បស្ស ភេរី មុទិង្គា ច សង្ខា បណវទេណ្ឌិមា

សព្វញ្ច តាលាវចរំ មណិម្ហិ បស្ស និម្មិតំ។

សម្មតាលញ្ច វីណញ្ច នច្ចគីតំ សុវាទិតំ

តុរិយតាឡិតសង្ឃុដ្ឋំ មណិម្ហិ បស្ស និម្មិតំ។

---

១ ម. សន្ធិព្ហូហេ ។ ២ ម. នដនាដកគាយិនោ ។



(៤៦) សូមព្រះអង្គទ្រង់ទត ទីក្រុងមានកំផែងល្អ គួរឲ្យចង្អែកស្លុតព្រឺរោម មានទង់ជ័យលើកឡើង ក្រាលដោយដីខ្សាច់ដែលមានសម្បុរដូចមាស គួរជាទីរីករាយ ។ សូមព្រះអង្គទ្រង់ទត ពួកផ្ទះស្លឹកដែលបែងចែក ដោយចំណិត ដែលគេចែកជាផ្លូវជាសង្កាត់តាមចំណែក មានផ្ទះធំ ទីផ្ទះ កំណាត់ផ្ទះ ច្រកតាល់ និងផ្លូវទាំងឡាយ ។

(៤៧) សូមព្រះអង្គទ្រង់ទត រោងស្រា អ្នកលក់ស្រា អ្នកគ្រួ ផ្ទះបាយ ពួកឈ្មួញ និងពួកស្រីពេស្យា ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកជនអ្នកធ្វើផ្កាកម្រង ជាងជ្រលក់ អ្នកធ្វើគ្រឿងក្រអូប អ្នកលក់សំពត់ ជាងមាសនិងជាងកែវមណី ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកជនអ្នកធ្វើសម្ល ជនធ្វើបាយ អ្នករាំ នាយរាំ អ្នកច្រៀង អ្នកច្រៀងទះដៃជង អ្នកវាយស្គរ ជារូបនិម្មិត ក្នុងកែវមណី ។

(៤៨) សូមព្រះអង្គទ្រង់ទត ស្គរ សំភោរ សង្ខ ខ្លុយ ស្គរដៃ និងគ្រឿងភ្លេងទាំងអស់ ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ក្រាប់ ឈឹង ពិណ រាំ ចម្រៀង ប្រគំ ដែលគឹកកង សូរសព្ទតន្ត្រី ពីរោះ ជារូបនិម្មិត ក្នុងកែវមណី ។

លម្ពិកា មុដ្ឋិកា ចេត្ថ   មាលោការា ច សោភិយា
វេតាលិកោ ច ជល្លោ ច   ឧណ្ណត្តិ បស្ស ធម្មិកំ ។

(៩៥) សមជ្ជា ចេត្ថ វត្តន្តិ   អាកិណ្ណា នរនារិភិ
មញ្ចាតិមញ្ចេ ភូមិយោ   ឧណ្ណត្តិ បស្ស ធម្មិកំ ។
បស្ស មល្លេ សមជ្ជស្មឹ   ផោដេន្តេ ទិគុណំ ភុជំ
និហតេ និហតមានេ ច   ឧណ្ណត្តិ បស្ស ធម្មិកំ ។

(៩៦) បស្ស បព្វតបាទេសុ   នានាមិគគណា ពហូ
សីហា ព្យគ្ឃា វរាហា ច   អច្ឆកោកតរច្ឆយោ ។
បលាសាទា គវជា ច   មហឹសា រោហិតា រុរូ
ឯណេយ្យា សរភា ចេវ   គណិនោ និង្កសូករា[១] ។
កទលិមិគា ពហូ ចេត្ថ   ពិឡារា សសកណ្ណកា
នានាមិគគណាកិណ្ណំ   ឧណ្ណត្តិ បស្ស ធម្មិកំ ។

(៩៧) នជ្ជាយោ សុបតិត្ថាយោ   សោវណ្ណវាលុកសន្ថតា
អច្ឆា សវន្តិ អម្ពូនិ   មច្ឆគុម្ពនិសេវិតា[២] ។
កុម្ភិលា មករា ចេត្ថ   សុសុមារា ច កច្ឆបា
បាឋីនា បាវុសា[៣] មច្ឆា   ពលជា[៤] មុញ្ជរោហិតា ។

---

១ ម. និង្គសូករា ។ ឱ. នង្កសូករា ។ ២ ម. ឱ. មច្ឆគុម្ពនិសេវិតា ។ ៣ ម. បាឋីន ពាវុសា ។ ឱ. បាទីន ពាវុសា ។ ៤ ម. ភលជា ។ ឱ. ពលជា ។



សូមព្រះអង្គទ្រង់ទត ពួកជនអ្នកលោត អ្នកប្រដាល់ អ្នកចំ អ្នកលេងមាយា នឹងស្រីប្រុសដ៏ល្អ ក្នុងកែវមណីនេះ តាំងពួកអ្នកជាសំណៀនគេ នឹងអ្នកកាត់កោរសក់ ជារូបនិម្មិត ក្នុងកែវមណី ។

(៩៥) មហោស្រពទាំងឡាយ ដ៏មីរដេរដាស ដោយបុរសនឹងស្ត្រី ក៏មាន ក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់ទត គ្រែត្រួតនឹងគ្រែ ខ្ពង់ទី (នៃមហោស្រព) ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកអ្នកចំបាប់ ដែលប្រទាញគ្នាដោយដៃទាំងពីរ ក្នុងទីមហោស្រព សូមព្រះអង្គទ្រង់ទត ពួកអ្នកឈ្នះនឹងអ្នកចាញ់ ជារូបនិម្មិត ក្នុងកែវមណី ។

(៩៦) សូមព្រះអង្គទ្រង់ទត ពួកម្រឹគផ្សេង ៗ ជាច្រើនទៀបជើងភ្នំ គឺ រាជសីហ៍ ខ្លាធំ ជ្រូកព្រៃ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន ។ សត្វទោស គោ ក្របី រមាំង ប្រើស ទ្រាយ សរកម្រឹគ ក្ដាន់ ជ្រូកស្រុក ។ ឈ្លូស ពួកម្រឹគជាច្រើន ខ្លាត្រី ទន្សាយ នឹងកន្ធ្លង សូមព្រះអង្គទ្រង់ទត ដើមភ្នំដែលដាសដោយពួកម្រឹគផ្សេង ៗ ជារូបនិម្មិត ក្នុងកែវមណី ។

(៩៧) ស្ទឹងទាំងឡាយ មានកំពង់ចុះបានល្អ ដែលក្រាលដោយខ្សាច់មាស មានទឹកថ្លា មានពួកត្រីអាស្រ័យតែងអាស្រ័យនៅ ។ ពួកក្ដាម មករ ក្រពើ អណ្តើក ត្រីស្លាត ត្រីបណ្តោយ ត្រីឆ្តោ ត្រីក្តុក មានក្នុងកែវមណីនេះ ។

នានាទិជគណាកិណ្ណា  នានាទុមគណាយុតា
វេឡុរិយកលាកោកធាយោ(១) មណិស្មិំ បស្ស និម្មិតំ ។
(៤៨) បស្សន្តុ ពោក្ខរណិយោ សុវិភត្តា ចតុទ្ទិសា
នានាទិជគណាកិណ្ណា បុថុលោមនិសេវិតា(២)
សមន្តោទកសម្បុណ្ណំ មហី សាគរកុណ្ឌលំ
ឧបេតំ វនរាជីហិ មណិស្មិំ បស្ស និម្មិតំ ។
(៤៩) បុរតោ វិទេហេ បស្ស គោយានិយេ ច បច្ឆតោ
កុរុយោ ជម្ពុទីបញ្ច មណិស្មិំ បស្ស និម្មិតំ ។
បស្ស ចន្ទំ សុរិយញ្ច ឱភាសន្តេ ចតុទ្ទិសា
សិនេរុំ អនុបរិយាយន្តេ មណិស្មិំ បស្ស និម្មិតំ ។
សិនេរុំ ហិមវន្តញ្ច សាគរញ្ច មហិទ្ធិយំ(៣)
ចត្តារោ ច មហារាជេ មណិស្មិំ បស្ស និម្មិតំ ។
អារាមេ វនគុម្ពេ ច បាដិយេ ច សិលុច្ចយេ
រម្មេ កិម្បុរិសាកិណ្ណេ មណិស្មិំ បស្ស និម្មិតំ ។

១. ឱ. វេឡុរិយផលកាយោ ។ ២ ឱ. បុថុលោមនិសេវិតា ។ ៣ ឱ. មហិទ្ធិកំ ។ ឱ. មហណ្ណវំ ។



សូមព្រះអង្គទ្រង់ទត ស្រះបោក្ខរណីដែលធ្វើដោយផែនថ្ម ជាវិការៈនៃកែវពិទូរ្យ ដ៏ដេរដាសដោយពពួកសត្វស្លាបផ្សេងៗ មានពួកឈើផ្សេងៗ ដាដុះ ជារូបនិម្មិត ក្នុងកែវមណី ។

(៤៨) សូមព្រះអង្គទ្រង់ទត ស្រះបោក្ខរណីក្នុងកែវមណីនេះ ដែលបានចែកដោយល្អទាំង ៤ ទិស ដ៏ដេរដាសដោយពពួកសត្វស្លាបផ្សេងៗ ដែលត្រីធំៗ អាស្រ័យនៅ សូមព្រះអង្គទត ផែនដីដ៏បរិបូណ៌ដោយទឹកជុំវិញ ជាកុណ្ឌលនៃសាគរ ប្រកបដោយជួរព្រៃព្រឹក្សាទាំងឡាយ ជារូបនិម្មិត ក្នុងកែវមណី ។

(៤៩) សូមព្រះអង្គទ្រង់ទតមើលទ្វីបទាំង ៤ គឺបុព្វវិទេហទ្វីប ខាងកើត អបរគោយានទ្វីប ខាងលិច ឧត្តរកុរុទ្វីប និងជម្ពូទ្វីប ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ព្រះចន្ទនិងព្រះអាទិត្យ កំពុងបំភ្លឺទិសទាំង៤ សូមព្រះអង្គទ្រង់ទត (ព្រះចន្ទនិងព្រះអាទិត្យនោះ) កំពុងដើរប្រទក្សិណភ្នំសិនេរុ ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ភ្នំសិនេរុ ភ្នំហិមពាន្ត សមុទ្រសាគរ ដែលមានឫទ្ធិច្រើន និងមហារាជទាំង ៤ អង្គ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតសួនច្បារ ព្រៃ គុម្ពឈើ ខ្នងថ្ម ហាក់ដូចជាគេក្រាលដំកល់ទុក ដ៏ដេរដាសដោយពួកកិន្នរ គួរជាទីរីករាយ ជារូបនិម្មិតក្នុងកែវមណី ។

ផារុសកំ(១) ចិត្តលតំ មិស្សកំ នន្ទនំ វនំ
វេជយន្តញ្ច បាសាទំ មណិម្ហិ បស្ស និម្មិតំ ។
សុធម្មំ តាវតឹសញ្ច បារិច្ឆត្តញ្ច បុប្ផិតំ
ឯរាវណំ នាគរាជំ មណិម្ហិ បស្ស និម្មិតំ ។
បស្សេត្ថ ទេវកញ្ញាយោ នភា វិជ្ជុរិវុគ្គតា
នន្ទនេ វិចរន្តិយោ មណិម្ហិ បស្ស និម្មិតំ ។
បស្សេត្ថ ទេវកញ្ញាយោ ទេវបុត្តបលោភិនី
ទេវបុត្តេ រមមានេ(២) មណិម្ហិ បស្ស និម្មិតំ ។
(១០០) បរោសហស្សំ បាសាទេ វេឡុរិយផលកសន្ថតេ
បជ្ជលន្តេ វណ្ណេន មណិម្ហិ បស្ស និម្មិតំ ។
តាវតឹសេ ច យាមេ ច តុសិតេ ចាបិ និម្មិតេ
បរនិម្មិតវសវត្តិនោ មណិម្ហិ បស្ស និម្មិតំ ។
បស្សេត្ថ បោក្ខរណិយោ វិប្បសន្នោទកា សុចី
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
(១០១) ទសេត្ថ រាជិយោ សេតា ទស្សនីយា មនោរមា
ឆ បិង្គលា បណ្ណរសា ហលិទ្ទា ច ចតុទ្ទស ។
វីសតិ តត្ថ(៣) សោវណ្ណា វីសតិ រជតាមយា
ឥន្ទគោបកវណ្ណាភា តាវ ទិស្សន្តិ តឹសតិ ។

១ ម. ម. ផារុសកំ ។ ២ ម. បមោទេ ។ ៣ និក្ខាទិ យុត្តាកំ ។



សូមព្រះអង្គទ្រង់ទត ផារុសកវ័ន ចិត្តលតាវ័ន មិស្សកវ័ន នន្ទនវ័ន នឹងវេជយន្តប្រាសាទ ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត សុធម្មសភា ឋានតាវត្តិង្ស ដើមបារិច្ឆត្តព្រឹក្សមានផ្ការីក ស្ដេចដំរីឈ្មោះឯរាវ័ណ ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកស្រីទេពកញ្ញា ដែលភ្លឺផ្លេក ដូចជាផ្លេកបន្ទោរចេញចាកពពក កំពុងត្រាច់ទៅក្នុងនន្ទនវ័ន ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកទេពកញ្ញាប្រលោមទេវបុត្រ នឹងពួកទេវបុត្រកំពុងរីករាយក្នុងនន្ទនវ័ន ជារូបនិម្មិត ក្នុងកែវមណី ។

[១០០] សូមព្រះអង្គទ្រង់ទត ប្រាសាទច្រើនជាងពាន់ ដែលក្រាលដោយផែនក្ដារកែវពិទូរ្យ មានសម្បុររុងរឿង ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ឋានតាវត្តិង្ស យាមា តុសិត និម្មានរតី បរនិម្មិត-វសវត្តី ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ស្រះបោក្ខរណី ក្នុងជាន់នោះៗ មានទឹកថ្លាស្អាត ដែលដាសដោយផ្កាមន្ទាលណី ផ្កាឈូកនឹងផ្កាឧប្បល ក្នុងឋានសួគ៌នុ៎ះ ។

(១០១) ក្នុងកែវមណីនេះ មានជួរស១០ ជួរក្រហម៦ នឹង១៥ (ជា៣១) ជួរលឿង ១៤ គួរជាទីរមិលរមើល ជាទីរីករាយនៃចិត្ត ។ ជួរមាស ២០ ជួរប្រាក់ ២០ ជួរមានពន្លឺ ដូចជាពណ៌នៃមេអណ្ដើកមាស ៣០ ប្រាកដនៅ ក្នុងកែវមណីនេះ ។

ឆសេតា កាឡិយោ ឆ ច   មញ្ជដ្ឋា បញ្ចវីសតិ

មិស្សា លោហិតបុប្ផេហិ   នីលុប្បលវិចិត្តកា ។

សតំ សព្ពង្គសម្បន្នំ   អដ្ឋិមត្តំ (១) ហយស្សរំ

ឥទំ សុត្តំ មហារាជ   បស្ស តំ អស្សមុត្តមំ ។

មណិកណ្ឌំ ចប ។

(១០២) ឧត្តាតកំ រាជ ឧបេហិ លទ្ធំ

ធេនាធិសំ មណិរតនំ តវេទំ

ជយេន ជិយ្យាម អសាហសេន

ជិតោ ច នោ ខិប្បមវាករោហិ ។

(១០៣) បញ្ចាល បច្ចុគ្គតសូរសេន

មច្ឆា ច មទ្ទា សហ កេកកេភិ

បស្សន្តុ នោ តេ អសឋេន យុទ្ធំ

ន នោ សភាយំ ន ករោន្តិ កិញ្ចិ ។

(១០៤) តេ បាវិសុំ អក្ខមទេន មត្តា

រាជា កុរូនំ បុណ្ណកោ ចាបិ យក្ខោ

១ ម. អដ្ឋិមន្តំ ។



ឆ្កែខ្មៅ ១៦ ឆ្កែហង្សពាទ ២៥ ឆ្កែលាយដោយផ្កាល្បា វិចិត្រដោយផ្កាឧប្បលខៀវ មានកន្ទៃកែវមណីនេះ ។ បពិត្រមហារាជប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទត (កែវមណី) មានរស្មីជាទីផ្ចុយ ចេញនៃពន្លឺ ដ៏ប្រកបដោយអង្គជាងតួន យ៉ាងនេះ (អ្នកណាលេងឈ្នះខ្ញុំ) បានណែកនៃសួយ (ឬខ្ញុំចាញ់ទៅអ្នកនោះចុះ) ។

ចប់ មណិកណ្ឌ ។

(១០២) (បុណ្ណកយក្ស...) បពិត្រព្រះរាជា (ការរៀបចំលេងល្បែង) សម្រេចហើយ សូមព្រះអង្គស្តេចចូលមកកាន់ទីជាទីក្រសាលល្បែង កែវមណីគ្រាកដូច្នេះ របស់ព្រះអង្គ មិនមានទេ យើងតបស្មើឈ្នះគ្នាដោយធម៌ មិនបាច់កំហែងទេ មួយទៀត ព្រះអង្គ បើខ្ញុំឈ្នះហើយ សូមសងឲ្យឆាប់ ។

(១០៣) បពិត្រព្រះបាទបញ្ចាលដ៏ល្បីល្បាញ សូមព្រះបាទសូរសេន ព្រះបាទមច្ឆៈ ព្រះបាទមទ្ទៈ ព្រមទាំងព្រះបាទកេកកៈទាំងនោះ ទ្រង់ទតបញ្ចុំល្បែង ដោយការមិនឆ្អោកនៃរបស់យើងចុះ ក្សត្រទាំងឡាយសូម្បីនៅក្នុង (ជាសាក្សី) របស់យើងក្តីកេង ។

(១០៤) (អភិសម្ពុទ្ធគាថា) ព្រះរាជារបស់អ្នកដែនកុរុនិងបុណ្ណកយក្សនោះ ជាអ្នកស្រវឹងស្រាលបង់ក្នុងល្បែងភ្លាត់ចូលមក (កាន់កន្លែងល្បែង)

រាជា កលឹ វិចិនមគ្គហេសិ
កដមគ្គហី បុណ្ណកោ នាម យក្ខោ
តេ តត្ថ ជូតេ ឧភយេ សមាគតេ
រញ្ញោ សកាសេ សខិនញ្ច មជ្ឈេ
អជេសិ យក្ខោ នរវីរសេដ្ឋំ
តត្ថប្បនាទោ តុមុលោ អភូ ។

(១០៥) ជយោ មហារាជ បរាជយោ ច
អាយូហតំ អញ្ញតរស្ស ហោតិ
ជនិន្ទ ជិន្នោសិ[១] វរទ្ធនេន
ជិតោ ច មេ ខិប្បមវាករោហិ ។

(១០៦) ហត្ថី គវស្សា មណិកុណ្ឌលា ច
យញ្ចាបិ មយ្ហំ រតនំ បថព្យា
គណ្ហាហិ កច្ចាន វរំ ធនានំ
អាទាយ យេនិច្ឆសិ តេន គច្ឆ ។

(១០៧) ហត្ថី[២] គវស្សា មណិកុណ្ឌលា ច
យញ្ចាបិ តុយ្ហំ រតនំ បថព្យា
តេសំ វរោ វិធុរោ នាម កត្តា
សោ មេ ជិតោ តំ មេ អវាករោហិ ។

---
១ ម. ជិតោសិ ។ ២ ម. អត្ថិ ។



ព្រះរាជា ជ្រើសយកកូនបាសកា ជាទោស (ខាងចាញ់) បុណ្ណកយក្ស ចាប់យកកូនបាសកាខាងឈ្នះ ជនទាំងពីរនោះ បានលេងបាសកា ជួបគ្នា ក្នុងកន្លែងបាសកានោះហើយ បុណ្ណកយក្ស ឈ្នះព្រះរាជា មានព្យាយាមប្រសើរជាងនោះ ក្នុងសំណាក់នៃពួកព្រះរាជា ក្នុងកណ្ដាលនៃពួកសំឡាញ់ សំឡេងគឹកកង សំឡេងហោកញ្ជ្រៀវ ក៏កើតមានក្នុងទីនោះ ។

(១០៥)(បុណ្ណកយក្ស...) បពិត្រមហារាជ បណ្ដាពួកជនដែលធ្វើព្យាយាម ការឈ្នះនឹងការចាញ់នឹងមានដល់អ្នកណាមួយ បពិត្រព្រះអង្គជាធំជាងជន ឥឡូវនេះខ្ញុំព្រះអង្គឈ្នះហើយ(ត្រូវយក)ទ្រព្យដ៏ប្រសើរ ព្រះអង្គដែលខ្ញុំឈ្នះហើយ សូមសងឲ្យឆាប់ ។

(១០៦) (ព្រះបាទកោរព្យ...) ម្នាលកច្ចាយនគោត្រ ដំរី គោ សេះ កែវមណី និងកុណ្ឌល ឬកែវណាមួយរបស់ខ្ញុំលើផែនដី បណ្ដាទ្រព្យទាំង(នោះ) អ្នកចូរយកទ្រព្យណាដែលប្រសើរនោះចុះ អ្នកចូរកាន់យក ទៅតាមសេចក្ដីពេញចិត្តចុះ ។

(១០៧) (បុណ្ណកយក្ស...) ដំរី គោ សេះ កែវមណី និងកុណ្ឌល ឬកែវណាមួយ របស់ព្រះអង្គលើផែនដី វិធុរបណ្ឌិតអាមាត្យ ទុកជាទ្រព្យប្រសើរជាងទ្រព្យទាំងនោះ ព្រះអង្គដែលខ្ញុំឈ្នះហើយ សូមព្រះអង្គប្រទានវិធុរបណ្ឌិតនោះ មកខ្ញុំ ។

(១០៨) អត្តា ច មេ សោ សរណំ គតី ច
ទីបោ ច លេណោ ច បរាយណោ ច
អសន្តុលេយ្យោ មម សោ ធនេន
បាណេន មេ សទិសោ ឯស កត្តា ។

(១០៩) ចិរំ វិវាទោ មម តុយ្ហញ្ចស្ស
កាមញ្ច បុច្ឆាម តមេវ គន្ត្វា
ឯសេវ នោ វិវរតុ ឯតមត្ថំ
យំ វក្ខតិ ហោតុ កថា ឧភិន្នំ ។

(១១០) អទ្ធា ហិ សច្ចំ ភណសិ ន ច មាណវ សាហសំ
តមេវ គន្ត្វា បុច្ឆាម តេន តុស្សាមុភោ ជនា ។

(១១១) សច្ចំ (១) នុ ទេវា វិទហូ កុរូនំ
ធម្មេ ឋិតំ វិធុរំ នាមមច្ចំ
ទាសោសិ រញ្ញោ ឧទ ហោសិ ញាតិ
វិធុរោតិ សង្ខា កតមាសិ លោកេ ។

(១១២) អាមាយទាសាបិ ភវន្តិ ហេកេ
ធនេន កីតាបិ ភវន្តិ ទាសា
សយំបិ ទាសា ឧបយន្តិ ហេកេ
ភយា បណុន្នាបិ ភវន្តិ ទាសា

១ ឱ. សច្ចន្នុ ។



(១០៨) (ព្រះបាទកោរព្យៈ...) វិធុរបណ្ឌិតនោះ ទុកដូចជាខ្លួនខ្ញុំ ជាទីពឹង ជាគតិ ជាប្រទីប ជាទីពំនាក់ ជាទីបវិដ្ឋករបស់ខ្ញុំ វិធុរបណ្ឌិតនោះ គេមិនគប្បីប្រៀបផ្ទឹមដោយទ្រព្យរបស់ខ្ញុំបានទេ វិធុរបណ្ឌិតនុ៎ះ ជាអាមាត្យ ប្រាកដស្មើដោយជីវិតរបស់ខ្ញុំ ។

(១០៩) (បុណ្ណកយក្ស...) ការវិវាទរបស់ខ្ញុំនឹងព្រះអង្គ តាំងយូរហើយ យើងត្រូវទៅសួរសេចក្ដីកិច្ចនឹងវិធុរបណ្ឌិតនោះវិញ សូមឲ្យវិធុរបណ្ឌិតនុ៎ះ ញែកសេចក្ដីនុ៎ះដល់យើង បើវិធុរបណ្ឌិតពោលពាក្យណា ពាក្យ(នោះ)ជួរសម្រេចដល់យើងទាំងពីរនាក់ចុះ ។

(១១០) (ព្រះបាទកោរព្យៈ...) ម្នាលមាណព អ្នកនិយាយនេះ ទៀងទាត់ពិតហើយ មិនមែននិយាយទាំងឥតប្រមាទេ យើងនឹងទៅសួរវិធុរបណ្ឌិតនោះចុះ យើងទាំង ២ នាក់ នឹងត្រេកអរព្រោះវិធុរបណ្ឌិតនោះ ។

(១១១) (បុណ្ណកយក្ស...) ពួកទេវតាសរសើរអ្នកឈ្មោះវិធុរៈ ជាអាមាត្យឋិតនៅក្នុងធម៌របស់អ្នកដែនកុរុ ពិតមែនឬ អ្នកជាទាសៈ ឬជាញាតិរបស់ព្រះរាជា ការរាប់ (អ្នក) ថាវិធុរៈ តើអ្នកជាអ្វី ក្នុងលោក ។

(១១២) (វិធុរបណ្ឌិត...) បុគ្គលពួកខ្លះជាទាសៈកើតក្នុងផ្ទៃខ្ញុំស្រី ពួកខ្លះជាទាសៈគេលោះដោយទ្រព្យ ពួកខ្លះជាទាសៈចូលទៅនៅខ្លួនឯង ពួកខ្លះបោះបង់(ទីលំនៅ)ព្រោះភ័យ ទៅនៅជាទាសៈគេ

ឯតេ នរានំ ចតុរោវ ទាសា ។

អទ្ធា ហិ យោនិតោ អហម្បិ ជាតោ

ភវោ ច រញ្ញោ អភវោ ច រញ្ញោ

ទាសាហំ ទេវស្ស បរម្បិ គន្ត្វា

ធម្មេន មំ មាណវ តុយ្ហ ទជ្ជា ។

(១១៣) អយម្បិ ទុតិយោ វិជយោ មមជ្ជ

បុដ្ឋោ ហិ កត្តា វិវរិត្ថ បញ្ហំ

អធម្មរូបោ វត រាជសេដ្ឋោ

សុភាសិតំ នានុជានាសិ មយ្ហំ ។

(១១៤) ឯវញ្ចេ នោ សោ វិវដ្ដ បញ្ហោ

ទាសោហមស្មិ ន ច ខោស្មិ ញាតិ

គណ្ហាហិ កច្ចាន វរំ ធនានំ

អាទាយ យេនិច្ឆសិ តេន គច្ឆ ។

អក្ខកណ្ឌំ នាម ។

(១១៥) វិធុរ ឃរមាវសស្ស គហដ្ឋស្ស សកំ ឃរំ

ខេមា វុត្តិ កថំ អស្ស កថន្នុ អស្ស សង្គហោ ។



ទាសៈរបស់ជនទាំងឡាយមាន ៤ពួកនេះឯង ។ ឯយើង ពិតជាទាសៈកើតអំពីកំណើត ព្រោះជាមានសេចក្តីចំរើនក្តី ព្រោះជាមានសេចក្តីមិនចំរើនក្តី (យើងមិនអាចនឹងពោលកុហកបានទេ) យើងបើទុកជាទៅកាន់ទីដទៃ ក៏គង់នៅជាទាសៈរបស់ព្រះសម្មតិទេព ម្នាលមាណព ព្រះរាជាគួរប្រទានយើងដល់អ្នក ដោយធម៌ ។

(១១៣) (បុណ្ណកយក្ស...) នេះឯងជាជ័យជំនះទី ២ របស់ខ្ញុំ ក្នុងថ្ងៃនេះ ព្រោះថា (វិធុរៈ)អាមាត្យ ដែលខ្ញុំសួរហើយ ក៏ញែកប្រស្នាហើយ [illegible] ព្រះរាជាដ៏ប្រសើរមិនតាំងនៅក្នុងធម៌ ទ្រង់មិនអនុញ្ញាតឲ្យនូវវិធុរបណ្ឌិត ជាអ្នកពោលពាក្យពីរោះ ដល់ខ្ញុំ ។

(១១៤) (ព្រះបាទកោរព្យ...) បើវិធុរបណ្ឌិតនោះ ញែកប្រស្នាដល់យើងយ៉ាងនេះថា ខ្ញុំជាទាសៈ មិនមែនជាញាតិទេ ម្នាលកច្ចានៈ អ្នកចូរយកវិធុរបណ្ឌិត ជាទ្រព្យដ៏ប្រសើរជាងទ្រព្យទាំងឡាយចុះ អ្នកចូរយក ទៅតាមពេញចិត្តចុះ ។

ចប់ អក្ខកណ្ឌ ។

១១៥) (ព្រះបាទកោរព្យ...) ម្នាលវិធុរៈ កាលបុគ្គលជាគ្រហស្ថ នៅគ្រប់គ្រងផ្ទះរបស់ខ្លួន តើគួរមានការប្រព្រឹត្តដ៏ក្សេមក្សាន្ត ដោយប្រការដូចម្តេច គួរមានការសង្គ្រោះ ដោយប្រការដូចម្តេចហ្ន៎ ។

អព្យាបជ្ជំ ការំ អស្ស    សព្វភូតេ ច មាណវេ
អស្មា លោកា បរំ លោកំ    ការំ បេច្ច ន សោចតិ ។

(១១៦) កំ ឥត្ថ ការំ ជិគិមា    មតិមា អត្ថទស្សិតា
សង្គាហ សព្វធម្មានំ    វិទ្ធុរោ ឯតទព្រវិ ។
ន សាធារណទារស្ស    ន ភុញ្ជេ សាទុមេកកោ
ន សេវេ លោកាយតិកំ    នេតំ បញ្ញាយ វឌ្ឍនំ ។
សីលវា វត្តសម្បន្នោ    អប្បមត្តោ វិចក្ខណោ
និវាតវុត្តិ អត្ថទ្ធោ    សុរតោ សខិលោ មុទុ ។
សង្គហេតា ច មិត្តានំ    សំវិភាគី វិធានវា
តប្បេយ្យ អន្នបានេន សទា    សមណព្រាហ្មណេ ។
ធម្មកាមោ សុតាធារោ    ការេយ្យ បរិបុច្ឆកោ
សក្កច្ចំ បយិរុបាសេយ្យ    សីលវន្តេ ពហុស្សុតេ ។



ក្រោយឥតមិនមានទុក្ខ ដោយប្រការដូចម្តេច មាណព ឈ្មោះជា ពោលពាក្យពិត តើដោយប្រការដូចម្តេច បុគ្គលជាគ្រហស្ថចេញអំពីលោកនេះ ទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយ រមែងមិនសោកស្តាយ តើដោយប្រការដូចម្តេច ។

(១១៦)(អភិសម្ពុទ្ធគាថា) វិធុរបណ្ឌិតអ្នកមានញាណគតិ មានព្យាយាមមាំ ប្រាជ្ញ យល់អត្ថ យល់ធម៌ទាំងពួង បានឆ្លើយប្រស្នាទុំ នឹងព្រះរាជានោះ គឺកើតឡើងសេចក្តីនោះថា គ្រហស្ថមិនគប្បីជាអ្នកមានប្រពន្ធសាធារណៈ មិនគួរបរិភោគភោជនមានរសឆ្ងាញ់តែម្នាក់ឯង មិនគួរគប់គេរៀនវេទសាស្ត្រ ដែលនាំទៅនឹងអំពើគ (ព្រោះ) ទៀនបែបនុ៎ះ មិនមែនជាគ្រឿងចំរើនប្រាជ្ញាទេ ។ គ្រហស្ថ គួរជាអ្នកមានសីល បរិបូណ៌ដោយវត្ត មិនប្រមាទ មានប្រាជ្ញាក្រៃលែង ជាអ្នកប្រព្រឹត្តទន់ទាប មិនរឹងរូស ជាអ្នកស្លូតបូត មានពាក្យផ្អែមល្ហែម មានការទន់ភ្លន់ ។ ជាអ្នកសង្គ្រោះមិត្តទាំងឡាយ ជាអ្នកចែករំលែកទាន មានការចាត់ចែងដ៏ល្អ ញុំាងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក គ្រប់កាលទាំងពួង ។ ជាអ្នកប្រាថ្នាសុចរិតធម៌ ទ្រទ្រង់ការរៀនដឹង ជាអ្នកសាកសួរ ឲ្យស្កប់ចូលទៅរកអ្នកមានសីល ជាពហុស្សូត ដោយគោរព ។

ឃរមាវសមានស្ស គហដ្ឋស្ស សកំ ឃរំ

ខេមា វុត្តិ សិយា ឯវំ ឯវំ នុ អស្ស សង្គហោ ។

អព្យាបជ្ឈោ សិយា ឯវំ សច្ចវាទី ច មាណវោ

អស្មា លោកា បរំ លោកំ ឯវំ បេច្ច ន សោចតិ ។

ឃរាវាសបញ្ហា ចប់ ។

(១១៧) ឯហិ ទានិ គមិស្សាម ទិន្នោ នោ ឥស្សរេន មេ

មមេវត្ថំ បដិបជ្ជ ឯស ធម្មោ សនន្តនោ ។

(១១៨) ជានាមិ មាណវ តយាហមស្មិ

ទិន្នោហមស្មិ តវ ឥស្សរេន

តីហញ្ច តំ វាសយេមុ អគារេ

យេនទ្ធុនា អនុសាសេមុ បុត្តេ ។

(១១៩) តថេវ មេ ហោតុ វសេមុ តីហំ

កុរុតំ ភវំ អជ្ជ ឃរេសុ កិច្ចំ



កាលបុគ្គលជាគ្រហស្ថនៅគ្រប់គ្រងផ្ទះរបស់ខ្លួន គួរមានការប្រព្រឹត្តិដ៏ក្សេមក្សាន្តយ៉ាងនេះ គួរមានការសង្គ្រោះយ៉ាងនេះ ។ គ្រហស្ថគួរជាអ្នកមិនមានទុក្ខយ៉ាងនេះ មាណពណោះជា ពោលពាក្យពិតយ៉ាងនេះ គ្រហស្ថចេញចាកលោកនេះ ទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយ រមែងមិនសោកស្តាយយ៉ាងនេះ ។

ចប់ ឃរាវាសបញ្ហា ។

(១១៧) (បុណ្ណកយក្ស...) លោកចូរមក យើងនឹងទៅឥឡូវនេះ លោក (ដែលព្រះរាជាធនញ្ជ័យ) ជាឥស្សរៈ បានព្រះរាជទាន ដល់ខ្ញុំហើយ ចូរប្រតិបត្តិឲ្យជាប្រយោជន៍ដល់ខ្ញុំ នេះជាទំនៀម របស់អ្នកប្រាជ្ញ ក្នុងកាលមុន ។

(១១៨) (វិធុរបណ្ឌិត...) ម្នាលមាណព ខ្ញុំដឹងថា ខ្លួនខ្ញុំនៅក្នុងកណ្តាប់ដៃអ្នកហើយ (ព្រោះ) ខ្ញុំត្រូវព្រះរាជាធនញ្ជ័យ ជាឥស្សរៈ ព្រះរាជទានដល់អ្នកហើយ តែយើងសូមឲ្យអ្នកនៅ ក្នុងផ្ទះ យើងអស់បីថ្ងៃ ទំរាំយើងប្រៀនប្រដៅកូននឹងប្រពន្ធសិន ។

(១១៩) (បុណ្ណកយក្ស...) លោកពោលពាក្យណា ពាក្យនោះចូរមានដល់ខ្ញុំ ដោយប្រការដូច្នោះ យើងគប្បីនៅអស់ ៣ ថ្ងៃ លោកដ៏ចំរើន ចូរធ្វើកិច្ចក្នុងផ្ទះ (របស់លោក) ក្នុងថ្ងៃនេះចុះ

អនុសាសតំ បុត្តទារេ កវដ្ឋ
យថា តយិ ចេន្ទ សុទី កវេយ្យ ។

(១២០) សាធូនិ រម្មាណ បហុតការាមា
បត្តោមិ យក្ខោ វិធុរេន សទ្ធិំ
តិ កុញ្ជរផញ្ញាហយានុចិណ្ណំ
ទាវេត្តិ អន្តេបុរមរិយសេដ្ឋោ ។

(១២១) កោញ្ចោ មយូរញ្ច ចិយញ្ច កោកំ
ឧទាកមិ គគ្គ សុវម្ពរំ
បហុតកញ្ចំ គហុអន្តធានំ
ខសញ្ញសារំ វិយ កុសរស្ស ។

(១២២) គគ្គ ចទ្ទន្តិ ការយន្តិ អវ្ហយន្តិ វភាំ
អន្ធក វិយ ខេមេសុ ទាវិយោ សខលព្ភតា ។
សមន្តិកាផា បមុតាហិ យត្តំ
អទ្ធុក តាខេន ច ឧម្មតាលោ
អត្ថកម្មេកក្ខុវិចិត្តយន្តោ
ហារេត្តិ ការយាយ គតោ សកាសេ ។



លោកដំដេវ ចូរប្រៀនប្រដៅបុត្រនឹងភរិយា ក្នុងថ្ងៃនេះ
កាលបើលោកចេញទៅ (បុត្រនឹងភរិយារបស់លោក) បាន
សេចក្ដីសុខយ៉ាងណា (សូមប្រៀនប្រដៅយ៉ាងនោះ) ។

(១២០) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្ស មានភោគៈជាគ្រឿងប្រាថ្នា
ច្រើន បានពោលថា លោកខ្លួន ក៏ចៀសចេញទៅជាមួយនឹង
វិធុរបណ្ឌិត មិត្តបណ្ឌិតជាបុគ្គលប្រសើរថ្លៃថ្លា ចូលទៅកាន់
នគរតូចនោះ ដែលបរិបូណ៌ដោយដំរីនឹងសេះជាគ្រឿងវេយ្យៈ

(១២១) បណ្ដាប្រាសាទទាំងនោះ គឺកញ្ចប្រាសាទ មយូរប្រាសាទ
បិយកេតប្រាសាទ ព្រះមហាសត្វ(នាំបុណ្ណកយក្ស)ចូលទៅកាន់
ប្រាសាទជាទីគាប់ក្រៃលែង ជាប្រាសាទមានកញ្ចាំងហារច្រើន
មានបាយនឹងទឹកច្រើន ដូចជា(ភព)មសក្កសារៈនៃព្រះអិសរៈ ។

(១២២) នាងនារីទាំងឡាយ នាំនៃនគ្នបនឹងសមាមញ្ញ ក៏ ច្រៀង រៀក
ដ៏ប្រសើរក្រៃលែង ក្នុងប្រាសាទនោះ ដូចស្រីអប្សរក្នុងទេវលោក ។
ព្រះមហាសត្វអាគ្រទាយ ធ្វើបុណ្ណកយក្សឲ្យបរិបូណ៌ដោយភ្លេងនារី
ជាទីគាប់យ៉ាងនោះ ដោយបាយនឹងទឹកផង ហើយព្រឹសរិះរកសេចក្ដី
យ៉ាងសំខាន់ ទើបចូលទៅក្នុងសំណាក់ភរិយា ក្នុងកាលនោះ ។

តំ ចន្ទនគន្ធរសានុលិត្តំ
សុវណ្ណជាលុត្តមគណ្ឋិតាសិសិ
ភរិយំ អវច ឯហិ សុណោហិ ភោតិ
បុត្តានិ អាមន្តយ តម្ពនេត្តេ ។
សុត្វាន វាក្យំ បតិនោ អនោជា
សុណិសំ អវច តម្ពនខី សុនេត្តិ
អាមន្តយ ចម្ពកធិ ចេតេ
បុត្តានិ វម្មធរុប្បសាទេ ។

(១៤៣) តេ អាគតេ មុទ្ធនិ ធម្មរាជា
ឃាយិត្វា បុត្តេ អវិកម្បមានោ
អាមន្តយិត្វាន អវោច-វាក្យំ
ធិន្នោហំ វញ្ញ ឥទ មាណវស្ស ។
តស្សជ្ជហំ អត្តសុខី វិនេយ្យា
អាហាយ យេធិច្ចតិ ខេធ កច្ចតិ
អហាញ្ញ កំ អនុសាសិតុំ អាគតាស្មិ
កាដំ អហំ អបវិត្តាយ កស្ស ។



មហាសត្វនិយាយនឹងភរិយា ដែលមានខ្លួនប្រោះព្រំដោយទឹកក្រអូបនៃខ្លឹមចន្ទន៍ មានសម្បុរប្រាកដស្មើដោយភួងនៃមាសដូច្នេះថា ម្នាលនាងដ៏ចំរើនមានភ្នែកក្រហម នាងចូរមក ចូរស្តាប់នូវ ចូរហៅបុត្រនឹងធីតាមក ៗ នាងអនោជា បានស្តាប់ពាក្យរបស់ប្តីហើយ ក៏និយាយនឹងកូនប្រសាស្រី មានក្រចកក្រហម មានភ្នែកល្អថា ម្នាលនាងមានសម្បុរដូចផ្កាកព្រឹក្ស នាងចូរហៅបុត្រនឹងធីតា ដែលទ្រទ្រង់ប្រដាប់ចំពាក់នោះមក ៗ

(១៤៣) ព្រះមហាសត្វជាអ្នកកាន់ធម៌ កាលមានញាតិញោមនឹងកូនចៅទាំងឡាយ ថើបក្បាលកូនចៅទាំងឡាយនោះ ដែលមកដល់ហើយ ហៅមកនិយាយពាក្យថា អញត្រូវព្រះរាជា ក្នុងក្រុងឥន្ទបត្តនេះប្រទានដល់មាណពហើយ ៗ ថ្ងៃនេះអញមានសេចក្តីសុខក្នុងខ្លួនទេ (តអំពី ៣ ថ្ងៃទៅ) អញនឹងជាអ្នកបំរើមាណពនោះ មាណពនោះ ចាំអញទៅកាមសេចក្តីត្រេកអរ បំណែកខាងអញដែលមកនេះដើម្បីប្រៀនប្រដៅអ្នកទាំងឡាយ(ព្រោះថា) អញនឹងទៅ ដោយមិនបានការពារ(មុន) ដូចម្តេចបាន ៗ

សចេ វោ រាជា កុរុរដ្ឋវាសី
ជនសន្ធោ បុច្ឆេយ្យ បហូតកាមោ
កិមាភិជានាថ បុរេ បុរាណំ
កឹ វោ បិតា អនុសាសេ បុរត្ថា ។
សមាសមា ហោថ មយា ច សព្វេ
កោ នីធ រញ្ញោ អព្ភធិកោ មនុស្សោ
តមញ្ជលឹ ករិយ វទេថ ឯវំ
មា ហេវ ទេវ ន ហិ ឯស[១] ធម្មោ
វិយគ្ឃរាជស្ស និហីនជាតោ
សមាសមោ ហេវ កថំ ករេយ្យ ។

លក្ខណកណ្ឌំ[២] ។

(១២៤) សោ ច បុត្តេ អមច្ចេ ច ញាតយោ សុហទជ្ជនេ
អលីនមនសង្កប្បោ វិធុរោ ឯតទព្រវិ ។
ឯថយ្យា រាជវសតឹ និសីទិត្វា សុណាថ មេ
យថា រាជកុលំ បត្តោ យសំ បោសោ និគច្ឆតិ ។

---

[១] ម. ឯស ។ [២] ម. បញ្ញាណកណ្ឌំ នាម ។



បើព្រះរាជាទ្រង់គ្រងនៅក្នុងដែនកុរុ ជាអ្នកភ្ជាប់ចិត្តជន មានកាមៈជាច្រើន ត្រាស់សួរកូនឯងទាំងឡាយថា អ្នកទាំងឡាយ ដឹងច្បាស់នូវដំណើរបូរាណក្នុងកាលមុនដែរឬ បិតារបស់អ្នកទាំងឡាយបានប្រៀនប្រដៅក្នុងកាលមុនដូចម្តេចខ្លះ មួយទៀត កូនអ្នកទាំងអស់គ្នា ចូរមានឋានៈស្មើនឹងយើងចុះ (ព្រោះ) ក្នុងរាជត្រកូលនេះ តើមនុស្សណារបស់ព្រះរាជា ជាអ្នកខ្ពង់ខ្ពស់ (ស្មើនឹងអ្នក) មិនមានទេ កូនកូនឯងគប្បីធ្វើអញ្ជលីទូលព្រះរាជាយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំត្រាស់យ៉ាងនេះ ព្រោះថា នេះមិនមែនជាបវេណីធម៌ទេ បពិត្រព្រះសម្មតិទេព សត្វចចកមានជាតិថោកទាប គប្បីមានឋានៈ ស្មើនឹងរាជសីហៈ ដូចម្តេចបាន ។

ចប់ លក្ខណកណ្ឌ ។

(១២៤) (អភិសម្ពុទ្ធគាថា) វិធុរបណ្ឌិតនោះមានសេចក្តីត្រិះរិះ ដោយចិត្តមិនរួញរា ចុះកាលពាក្យនេះនឹងបុត្រ អាមាត្យ ញាតិ សំឡាញ់ថា ម្នាលកូនសំឡាញ់ទាំងឡាយ ចូរអ្នកទាំងឡាយមកអង្គុយស្តាប់រាជវសតិធម៌ (ច្បាប់សម្រាប់នៅក្នុងរាជត្រកូល) របស់អញដែលជាច្បាប់សម្រាប់បុរសចូលទៅកាន់រាជត្រកូល រមែងបានយស ។

[១៦៤] ន ហិ រាជកុលំ បត្តោ អញ្ញាតោ លភតេ យសំ
នាសូរោ នាបិ ទុម្មេធោ នប្បមត្តោ កុទាចនំ ។
យទាស្ស សីលំ បញ្ញញ្ច សោចេយ្យញ្ចាធិគច្ឆតិ
អថ វិស្សសតេ ត្យម្ហិ គុយ្ហញ្ចស្ស ន រក្ខតិ ។
[១៦៥] តុលា យថា បគ្គហិតា សមទណ្ឌា សុធារិតា
អជ្ឈិដ្ឋោ ន វិកម្បេយ្យ ស រាជវសតី វសេ ។
តុលា យថា បគ្គហិតា សមទណ្ឌា សុធារិតា
សព្ពានិ អភិសម្ភោន្តោ ស រាជវសតី វសេ ។
[១៦៦] ទិវា វា យទិ វា រត្តឹ រាជកិច្ចេសុ បណ្ឌិតោ
អជ្ឈិដ្ឋោ ន វិកម្បេយ្យ ស រាជវសតី វសេ ។
ទិវា វា យទិ វា រត្តឹ រាជកិច្ចេសុ បណ្ឌិតោ
សព្ពានិ អភិសម្ភោន្តោ ស រាជវសតី វសេ ។



(១៦៤) រាជសេវកៈ ដែលចូលទៅកាន់រាជត្រកូល (មានគុណសម្បត្តិ) មិនប្រាកដ រមែងមិនបានយសទេ រាជសេវកៈមិនត្រូវជាអ្នកកៀកកេក មិនត្រូវជាអ្នកខ្ចាចខេក មិនត្រូវធ្វេសប្រហែស ក្នុងកាលណាឡើយ ។ ព្រោះរាជាជ្រាបច្បាស់ នូវសីលសម្បត្តិ និងសេចក្តីចេះដឹង ព្រមទាំងសេចក្តីស្អាត របស់រាជសេវកៈនោះ ក្នុងកាលណា ព្រះរាជាក៏រមែងស្និទ្ធស្នាលចំពោះរាជសេវកៈនោះ ក្នុងកាលនោះ ទាំងមិនលាក់នូវការចិត្តកំបាំង (របស់ព្រះអង្គ) នឹងរាជសេវកៈនោះទេ ។

(១៦៥) រាជសេវកៈ ដែលព្រះរាជាត្រាស់ប្រើ (ក្នុងរាជកិច្ចណាមួយ) មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក (ល្អៀង) ទេ ត្រូវធ្វើឲ្យដូចជាជញ្ជីង ដែលគេលើកឡើងហើយ មានដងស្មើ ទៀងល្អ ។ រាជសេវកៈ ធ្វើរាជកិច្ចទាំងពួង ដូចជញ្ជីងដែលគេលើកឡើងហើយ មានដងស្មើ ទៀងល្អ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

(១៦៦) រាជសេវកៈ ជាអ្នកឈ្លាសវៃ ក្នុងរាជកិច្ចទាំងឡាយ ដែលព្រះរាជាត្រាស់ប្រើ ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ ជាអ្នកឈ្លាសវៃ ក្នុងរាជកិច្ចទាំងឡាយ ធ្វើរាជកិច្ចគ្រប់យ៉ាង ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ (ឲ្យសម្រេចដោយរៀបរយ) រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

យោ ចស្ស សុកតោ មគ្គោ រញ្ញោ សុប្បដិយាទិតោ
ន តេន វុត្តោ គច្ឆេយ្យ ស រាជវសតឹ វសេ ។

(១៦៨) ន រញ្ញោ សទិសំ ភុញ្ជេ កាមភោគេ កុទាចនំ
សព្វត្ថ បច្ឆតោ គច្ឆេ ស រាជវសតឹ វសេ ។
ន រញ្ញោ សទិសំ វត្ថំ ន មាលំ ន វិលេបនំ
អាកប្បំ សរកុត្តឹ វា ន រញ្ញោ សទិសមាចរេ
អញ្ញំ ករេយ្យ អាកប្បំ ស រាជវសតឹ វសេ ។

(១៦៩) កីឡេ រាជា អមច្ចេហិ ភរិយាហិ បរិវារិតោ
នាមច្ចោ រាជភរិយាសុ ភាវំ កុព្វេថ បណ្ឌិតោ ។
អនុទ្ធតោ អចបលោ និបកោ សំវុតិន្ទ្រិយោ
មនោបណិធិសម្បន្នោ ស រាជវសតឹ វសេ ។

(១៧០) នាស្ស ភរិយាហិ កីឡេយ្យ ន មន្តេយ្យ រហោគតោ
នាស្ស កោសា ធនំ គណ្ហេ ស រាជវសតឹ វសេ ។



ផ្លូវណាដែលគេធ្វើល្អ តាក់តែងល្អសម្រាប់ព្រះរាជា រាជសេវកៈ ដែលព្រះរាជាត្រាស់ហើយ មិនត្រូវដើរទៅតាមផ្លូវនោះ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

(១៦៨) រាជសេវកៈ មិនគួរប្រើប្រាស់កាមភោគៈស្មើនឹងព្រះរាជាក្នុងកាលណាឡើយ ត្រូវដើរខាងក្រោយក្នុងកាមគុណគ្រប់យ៉ាង រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈមិនត្រូវប្រើប្រាស់សំពត់ មិនត្រូវប្រើប្រាស់ផ្កាកម្រង មិនត្រូវប្រើប្រាស់គ្រឿងលាប ឲ្យដូចរបស់ព្រះរាជា មិនត្រូវប្រព្រឹត្តកិរិយា ឬការនិយាយស្តី ឲ្យដូចព្រះរាជា ត្រូវធ្វើតាមកិរិយាដទៃវិញ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

(១៦៩) ព្រះរាជា ទ្រង់ក្រសាលនឹងរាជសេវកៈ មានស្រីស្នំគាល់ចោមរោម អាមាត្យជាបណ្ឌិត មិនត្រូវធ្វើសេចក្តីស្និទ្ធស្នាលចំពោះពួកស្រីស្នំរបស់ព្រះរាជាទេ ។ រាជសេវកៈ ជាអ្នកមិនឆ្មើងឆ្មៃ មិនឃ្លើសឃ្លើង ជាអ្នកមានប្រាជ្ញាប្រកបខ្លួន សង្រួមឥន្ទ្រិយល្អ បរិបូណ៌ដោយការតាំងចិត្ត រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

(១៧០) រាជសេវកៈ មិនត្រូវលេងសើច មិនត្រូវនៅក្នុងទីស្ងាត់ ប្រឹក្សាជាមួយនឹងពួកស្រីស្នំរបស់ព្រះរាជា មិនត្រូវលួចយកព្រះរាជទ្រព្យអំពីឃ្លាំងរបស់ព្រះរាជាទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

ន និទ្ទំ ពហុ មញ្ញេយ្យ ន មទាយ សុរំ បិវេ

នាស្ស ទាយេ មិគេ ហញ្ញេ ស រាជវសតឹ វសេ ។

នាស្ស បីឋំ ន បល្លង្កំ ន កោច្ឆំ ន នាវំ រថំ

សម្មតោម្ហីតិ អារុហេ ស រាជវសតឹ វសេ ។

នាតិទូរេ ភជេ រញ្ញោ នាច្ចាសន្នេ វិចក្ខណោ

សមេក្ខញ្ចស្ស (១) តិដ្ឋេយ្យ សន្ទិស្សន្តោ សភត្តុនោ ។

ន វេ រាជា សខា ហោតិ ន រាជា ហោតិ មេថុនោ

ខិប្បំ កុជ្ឈន្តិ រាជានោ សូកេនក្ខីវ ឃដ្ដិតំ ។

ន បូជិតោ មញ្ញមានោ មេធាវី បណ្ឌិតោ នរោ

ផរុសំ បតិមន្តេយ្យ រាជានំ បរិសំ គតំ ។

(១៣១) លទ្ធទ្វារោ លភេ ទ្វារំ នេវ រាជូសុ វិស្សសេ

អគ្គីវ សំយតោ តិដ្ឋេ ស រាជវសតឹ វសេ ។

១ ម. សម្មុខញ្ចស្ស ។



រាជសេវកៈ មិនគប្បីសំគាល់ការដេកច្រើន មិនត្រូវផឹកសុរាឲ្យស្រវឹង មិនត្រូវបៀតបៀនពួកម្រឹគដែលទ្រង់ឲ្យអភ័យ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ មិនត្រូវឡើងកាន់តាំង មិនត្រូវឡើងកាន់បល្ល័ង្ក មិនត្រូវឡើងកាន់កោអី មិនត្រូវឡើងកាន់នាវា ឬរាជរថរបស់ព្រះរាជា ដោយគិតថា ខ្លួនអញព្រះរាជាប្រោសប្រាណហើយដូច្នេះ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកវាងវៃ ត្រូវគាល់ព្រះរាជា ក្នុងទីមិនឆ្ងាយពេក មិនជិតពេក គប្បីឋិតនៅល្មមតែព្រះរាជាទតឃើញ ទាំងខ្លួនឯងក៏មើលឃើញព្រះរាជាជាម្ចាស់ ។ រាជសេវកៈ(គួរគិតថា) ព្រះរាជាមិនមែនជាសំឡាញ់របស់អញទេ ព្រះរាជា មិនមែនជាគូគន(របស់អញទេ) ពួកព្រះរាជាទាំងឡាយ រមែងក្រោធឆាប់ ដូចភ្នែកដែលត្រូវវត្ថុមានកន្ទុយស្រូវ (ជាដើម) ចំពាល់ ។ ជនជាបណ្ឌិត អ្នកមានប្រាជ្ញា មិនត្រូវសំគាល់ថា ព្រះរាជាបូជាអញហើយ ក៏ពោលទូលពាក្យគ្រក់ ចំពោះព្រះរាជា ដែលយាងមកកាន់បរិស័ទ ។

(១៣១) រាជសេវកៈ ទុកជាបានអនុញ្ញាតទ្វារហើយ ត្រូវបានអនុញ្ញាតទ្វារ (ទៀតសឹមចូល) មិនត្រូវទុកចិត្តចំពោះព្រះរាជាទាំងឡាយ គប្បីប្រយ័ត្នដូចភ្លើង រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

បុត្តំ វា ភាតរំ សំ វា  សមុក្កំសេតិ ខត្តិយោ
គាមេហិ និគមេហិ វា  រដ្ឋេហិ ជនបទេហិ វា
តុណ្ហីភូតោ ឧបេក្ខេយ្យ(១)  ន ភណេ ឆេកបាបកំ ។
(១៣២) ហត្ថារោហា អនីកដ្ឋា  រថិកា បត្តិការកា
តេសំ កម្មាវទានេន  រាជា វឌ្ឍេតិ វេតនំ
ន តេសំ អន្តរា គច្ឆេ  ស រាជវសតឹ វសេ ។
ចាបោវូនុទរោ ធីរោ  វំសោវាបិ បកម្បយេ
បដិលោមំ ន វត្តេយ្យ  ស រាជវសតឹ វសេ ។
ចាបោវូនុទរោ អស្ស  មច្ឆោវស្ស អជិវ្ហវា
អប្បាសី និបកោ សូរោ  ស រាជវសតឹ វសេ ។
(១៣៣) ន ពាឡ្ហំ ឥត្ថឹ គច្ឆេយ្យ  សម្បស្សំ តេជសង្ខយំ
កាសំ សាសំ ទរំ ពាល្យំ  ខីណមេធោ និគច្ឆតិ ។
នាតិវេលំ បភាសេយ្យ  ន តុណ្ហី សព្វទា សិយា
អវិកិណ្ណំ មិតំ វាចំ  បត្តេ កាលេ ឧទីរយេ ។
អក្កោធនោ អសង្ឃដ្ដោ សច្ចោ  សណ្ហោ អបេសុណោ
សម្ផំ គិរំ ន ភាសេយ្យ  ស រាជវសតឹ វសេ ។

---
១ ម. ឧបេក្ខេយ្យ ។



ព្រះរាជាជាក្សត្រិយ៍ទ្រង់លើកតំកើងព្រះរាជបុត្រ ឬក្សត្រិយ៍ជាបងប្អូនរបស់ព្រះអង្គ ដោយស្រុកឬនិគម ដោយដែនឬជនបទ រាជសេវកៈត្រូវនៅស្ងៀម កំពុងមើល មិនត្រូវនិយាយពីគុណឬទោសឡើយ ។
(១៣២) ព្រះរាជាទ្រង់បន្ថែមបៀវត្សរ៍ដល់ពលដំរី ពលសេះ ពលរថ ពលថ្មើរជើងទាំងនោះ ដោយការប្រគល់ឲ្យចំពោះការងារ រាជសេវកៈមិនត្រូវធ្វើឲ្យអន្តរាយ (លាភ) របស់ពលទាំងនោះ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកប្រាជ្ញ ត្រូវមានពោះដូចជាធ្នូ ត្រូវញាប់ញ័រដូចជាឫស្សី មិនត្រូវប្រព្រឹត្តទទឹងទាស់ទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈត្រូវមានពោះដូចធ្នូ ដូចមច្ឆា មិនត្រូវមានអណ្ដាតដូចត្រី ត្រូវស៊ីតិច មានប្រាជ្ញា ក្លៀវក្លា រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។
(១៣៣) រាជសេវកៈមិនត្រូវចំពោះលត់ស្រី ជាហេតុឲ្យអស់តេជៈទាំងពេកទេ សេវកៈដែលអស់ប្រាជ្ញា រមែងដល់នូវរោគក្អក ហឺត ទុរន់ទុក មានកំឡាំងថយ ។ រាជសេវកៈមិនត្រូវនិយាយហួសព្រំដែន មិនត្រូវស្ងៀមគ្រប់កាលទាំងពួងទេ ត្រូវពោលពាក្យមិនរាយមាយ ល្មមប្រមាណក្នុងកាលដែលត្រូវការ ។ រាជសេវកៈគប្បីជាអ្នកមិនក្រោធ មិនបៀតបៀនគេ មានពាក្យសច្ចៈ ផ្អែមល្ហែម មិនញុះញង់ មិននិយាយពាក្យឥតប្រយោជន៍ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។

[១៣៤] មាតាបេត្តិភរោ ជន្តុ កុលេ ជេដ្ឋាបចាយិកោ

សណ្ហោ សខិលសម្ភាសោ ស គេហវាសី ទិវំ វជេ ។

វិធីតោ សំវិភាគី ច   កតញ្ញូ ធិយតោ មុទុ

អប្បមត្តោ សុចិនច្ឆោ   ស គេហវាសី ទិវំ វជេ ។

ធិកត្តិ វុស្សិស្ស   សម្បត្តិស្សេ សតាវេ

សុរតោ សុខសំភាសោ   ស គេហវាសី ទិវំ វជេ ។

អាគោ យវីជ្ជេយ្យ   សង្គាកុំ ឧបាតិ ជនំ

ភត្តារំ ញ្ញាតិភេច្ចយ្យ   ឥ ធ អញ្ញស្ស ភជិតោ ។

[១៣៥] សមណេ ព្រាហ្មណេ ចាបិ សីលវន្តេ ពហុស្សុតេ

សក្កច្ចំ បយិរុបាសេយ្យ   ស គេហវាសី ទិវំ វជេ ។

សមណេ ព្រាហ្មណេ ចាបិ   សីលវន្តេ ពហុស្សុតេ

សក្កច្ចំ អនុភាសេយ្យ   ស គេហវាសី ទិវំ វជេ ។



[១៣៤] គហវាសិកៈ ត្រូវចិញ្ចឹមមាតាបិតា ត្រូវមានសេចក្តីគោរព ចំពោះបុគ្គលជាចាស់ក្នុងត្រកូល មានពាក្យផ្អែមល្ហែម ពោលពាក្យម៉ត់ចត់ គហវាសិកៈនោះ ទើបគួរទៅកាន់ឋានសួគ៌ ។ គហវាសិកៈត្រូវមានសណ្តាប់ធ្នាប់មានសំលេងស្រទន់ មានកតញ្ញូដឹងគុណហើយ មានខុនចិត្តហើយ (ចេះស្តាប់) ជាអ្នកទីពឹង មានអធ្យាស្រ័យទន់ភ្លន់ មិនរឹងប្រឹងហស ជាអ្នកស្អាត តាំងផ្ចាសរិ គហវាសិកៈនោះទើបគួរទៅកាន់ឋានសួគ៌ ។ គហវាសិកៈត្រូវមានសេចក្តីប្រព្រឹត្តិទៅតាម ពាក្យគ្រូ គោរព ចំពោះបុគ្គលចំរើន (ដោយវ័យជាដើម) ជាអ្នកស្មូតត្រង់ នៅរួមជាសុខ គហវាសិកៈនោះទើបគួរទៅកាន់ឋានសួគ៌ ។ គហវាសិកៈគប្បីវៀរឲ្យឆ្ងាយចេញ គួរជួនដល់ព្រះរាជាជាវិចបក្ខ មកដើម្បីការសុខក៏តុង គប្បីរកមើលចំពោះព្រះរាជាជាម្ចាស់ (របស់ខ្លួន) មិនត្រូវនិយាយចំពោះព្រះរាជាដទៃទេ ។

[១៣៥] គហវាសិកៈ គប្បីគប់រក ចំពោះសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូត ដោយគោរព គហវាសិកៈនោះ ទើបគួរទៅកាន់ឋានសួគ៌ ។ គហវាសិកៈ គួរប្រព្រឹត្ត តាមអ្នក សមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូត ដោយគោរព គហវាសិកៈនោះ ទើបគួរទៅ កាន់ឋានសួគ៌ ។

សមណោ ព្រាហ្មណោ វាបិ សីលវន្តេ ពហុស្សុតេ

តប្បេយ្យ អន្នបានេន ស ឃរាវាសតី ឃរេ ។

សមណោ ព្រាហ្មណោ វាបិ សីលវន្តេ ពហុស្សុតេ

អាសជ្ជ បញ្ញោ សេវេថ អាគន្ត្វា វេទិតព្ពកោ ។

(១៣៦) ទិន្នបុព្វំ ន ហាបេយ្យ ទានំ សមណព្រាហ្មណេ

ន ច កិញ្ចិ និវារេយ្យ ទានកាលេ វណិព្វកេ ។

បញ្ញាយ គុត្តិសម្បន្នោ វិធានវិធិកោវិទោ

កាលញ្ញូ សមយញ្ញូ ច ស ឃរាវាសតី ឃរេ ។

ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិចក្ខណោ

សុសំវិហិតកម្មន្តោ ស ឃរាវាសតី ឃរេ ។

(១៣៧) ខលំ សាលំ បសុំ ខេត្តំ គន្តា ចស្ស អភិក្ខណំ

មិតំ ធញ្ញំ និធាបេយ្យ មិតំ ច បាចយេ ឃរេ ។





ឃរាវាសកៈ គួរញ៉ាំងសមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ឃរាវាសកៈនោះ ទើបគួរនៅក្នុងគេហត្រកូល ។ ឃរាវាសកៈ កាលបើប្រាថ្នាសេចក្ដីចំរើនដល់ខ្លួន គប្បីចូលទៅរកសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូត ជាបណ្ឌិត ។

(១៣៦) ឃរាវាសកៈ មិនគួរញ៉ាំងទានដែលព្រះរាជា ធ្លាប់ព្រះរាជទានដល់សមណៈនិងព្រាហ្មណ៍ ឲ្យសាបសូន្យ ហើយមិនគួរឃាត់អ្នកណាមួយ ចំពោះពួកស្មូម ក្នុងកាលជាទីព្រះរាជទាន ។ ឃរាវាសកៈជាអ្នកមានប្រាជ្ញា ចាំបូណ៌ដោយឧបាយ ជាអ្នកឈ្លៀវឈ្លាសក្នុងវិធីចាត់ចែង ជាអ្នកដឹងកាល (ជាទីធ្វើបុណ្យ) ដឹងសម័យ (ប្រកបការងារ) ឃរាវាសកៈនោះ ទើបគួរនៅក្នុងគេហត្រកូល ។ ឃរាវាសកៈជាអ្នកខ្នះខ្នែង មិនប្រមាទ ឈ្លាសវៃ ចាត់ចែងការងារល្អ ក្នុងគ្រឿងការងារទាំងឡាយ ត្រូវមានសេចក្ដីព្យាយាម ចាត់ចែងកិច្ចឲ្យប្រព្រឹត្តទៅដោយស្រួល ឃរាវាសកៈនោះ ទើបគួរនៅក្នុងគេហត្រកូល ។

(១៣៧) ឃរាវាសកៈគួរទៅ (ត្រួតត្រាមើល) លានស្រូវ គោក្របីសត្វ និងស្រែចំការ (របស់ព្រះរាជា) ឲ្យរឿយៗ គប្បីទុកដាក់ស្រូវដែលល្មមហើយផង ឲ្យគេចំអិនអង្ករ ដែលល្មមហើយក្នុងផ្ទះផង ។

បុត្តំ វ ភាតរំ សំ វ　　សីលេសុ អសមាហិតំ

អនត្ថំ ហិ តេ កាលា　　យថា បេតា តថេវ តេ ។

ពោឡ្ញា ឯសំ បិណ្ឌាតុ　　អាសីនានំ បជាបយេ

ទាសេ កម្មករេ ពោសេ　　សីលេសុ សុសមាហិតេ

ទក្ខេ ឧដ្ឋានសម្បន្នេ　　អាធិបច្ចស្មឹ ឋបយេ ។

(១៣៨) សីលវា ច អលោលោ ច　　អនុវត្តោ ច ភជិនោ

អាវិរោហា ហិតោ តស្ស　　ស ភជសេតំ វិសេ ។

ឧទ្ធញ្ញ ភជិតោ ចស្ស　　ចិត្តញ្ញោ ចស្ស ភជិតោ

អសន្តិសការីត្តិស្ស　　ស ភជសេតំ វិសេ ។

អញ្ញាណេន ច ចហោបាន　　ពោរេ ទានេ អពោសិនំ

អាហោតោបិ ន កុប្បេយ្យ　　ស ភជសេតំ វិសេ ។



មិនត្រូវលើកតំកើងកូន ឬបងប្អូនរបស់ខ្លួន ដែលមិនតាំងនៅក្នុង សីលាចារវត្ត ព្រោះថា ជនទាំងនោះជាមនុស្សពាល មិនឈ្មោះថា ជាអវយវៈ (របស់ខ្លួន) ជនទាំងនោះ ទុកដូចជាមនុស្សស្លាប់ហើយ តែជាត្រូវឲ្យសំពត់និងដុំបាយ ដល់ជនទាំងនោះ ដែលមកអង្គុយ ជិតហើយ តបើតែកល់ក្នុងបុរសជាទាសកម្មករ ដែលជាអ្នកខ្ជាប់ ខ្លួនល្អ ក្នុងសីលាចារវត្ត ជាអ្នកឈ្លាសវៃ ប្រឹប្រណិដោយសេចក្តី ព្យាយាម ក្នុងទីជាអធិបតី (ក្នុងការងារ) ។

(១៣៨) ឧបាសកៈ ត្រូវមានសីល មិនលោភ ជាអ្នកប្រព្រឹត្តតាមព្រះពុទ្ធ ជាគុណដល់ព្រះពុទ្ធ តាំងក្នុងទីចំពោះព្រះភ័ក្ត្រនិងទីកំបាំងព្រះភ័ក្ត្រ ឧបាសកៈនោះ ទើបគួរនៅក្នុងឧត្តមត្រកូល ។ ឧបាសកៈជាអ្នក ស្គាល់បំណងរបស់ព្រះពុទ្ធនោះផង តាំងនៅដូចព្រះហឫទ័យរបស់ ព្រះពុទ្ធនោះផង ជាអ្នកមិនប្រព្រឹត្តទទឹងទាស់នឹងព្រះពុទ្ធនោះផង ឧបាសកៈនោះ ទើបគួរនៅក្នុងឧត្តមត្រកូល ។ ឧបាសកៈតបើខ្លួន ក្បាលលាងព្រះបាទ (របស់ព្រះពុទ្ធ) ក្នុងកាលជាទីទ្រង់ព្រះកេស្រ្ត ឬក្នុងកាលជាទីស្រង់ព្រះពន្លា ស្ងួមព្រះពុទ្ធទ្រង់ច្រាល់ ក៏មិនតបើ ទឹងតបវិញទេ ឧបាសកៈនោះ ទើបគួរនៅក្នុងឧត្តមត្រកូល ។

(១៥៩) ការុញ្ញក្តិ បញ្ជលី កាយិក ទាតំ ទេបំ បទក្ខិណំ

គាយេថ សព្វកាមានំ ទាតារំ ជីវមុត្តមំ ។
យោ ទេតិ សយនំ វត្ថំ យានំ អាវសថំ ឃរំ
បជ្ជុន្នោរិវ ភូតានិ ភោគេហិ អភិវស្សតិ ។
ឯសេយ្យោ រាជវសតី វត្តមានោ យថា នរោ
អារាធយតិ រាជានំ បូជំ លភតិ ភត្តុសុ ។

រាជវសតី តាទុ ។

(១៦០) ឯវំ សមនុសាសិត្វា ញាតិសង្ឃំ វិចក្ខណោ
បរិកិណ្ណោ សុហជ្ជេហិ រាជានមុបសង្កមិ
វន្ទិត្វា សិរសា បាទេ កត្វា ច នំ បទក្ខិណំ
វិធុរោ អវច រាជានំ បគ្គហេត្វាន អញ្ជលឹ ។
អយំ មំ មាណវោ នេតិ កត្តុកាមោ យថាមតិ
ញាតីនត្ថំ បវក្ខាមិ តំ សុណោហិ អរិន្ទម ។



(១៥៩) ពុំនគប្បីលបុរសប្រាជ្ញជាសេចក្តីពិតនេះ គប្បីធ្វើអញ្ជលីចំពោះក្នុងទិស ប្តូរធ្វើបទក្សិណចំពោះបក្សីក្តែក បុគ្គលមិនគប្បីសម្រាកចំពោះព្រះរាជា ជាបណ្ឌិតខ្ពង់ខ្ពស់ ព្រះអង្គប្រទានសេចក្តីប្រាថ្នាគ្រប់យ៉ាង ដូចមេឃបាន ព្រោះព្រះអង្គប្រទានទីដេក សំពត់ យាន ទីនៅ សម្រាប់សំណាក់អាស្រ័យ ប្រទានផ្ទះកោតសម្បូ ដូចមេឃបង្អុរភ្លៀងដល់ពួកសត្វ ។ ម្នាលកូនសំឡាញ់ទាំងឡាយ នេះជារាជវសតិធម៌ ដែលនរជនប្រព្រឹត្តតាម រមែងញ៉ាំងព្រះរាជាឱ្យត្រេកអរប្រាណ រមែងបានការបូជាអំពីពួកនាយទាំងឡាយ ។

ចប់ រាជវសតិកណ្ឌ ។

(១៦០) (អភិសម្ពុទ្ធគាថា) វិធុរបណ្ឌិតមានប្រាជ្ញាពេញ ប្រៀនប្រដៅពួកញាតិយ៉ាងនេះហើយ ក៏ចូលទៅគាល់ព្រះរាជា ដោយមានពួកញាតិចោមរោម វិធុរបណ្ឌិតថ្វាយបង្គំព្រះបាទាដោយត្បូង ធ្វើប្រទក្សិណព្រះអង្គ ផ្គងអញ្ជលីក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះអង្គជាអ្នកបង្ក្រាបសត្រូវ មាណពនេះ មានប្រាថ្នានឹងធ្វើតាមអធ្យាស្រ័យ នឹងនាំខ្ញុំព្រះអង្គទៅ ខ្ញុំព្រះអង្គ នឹងនិយាយពាក្យ ជាប្រយោជន៍ដល់ពួកញាតិ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ នូវពាក្យនោះ ។

បុត្តេ ច មេ ឧទិក្ខាសិ យញ្ចញ្ញំ ឃរេ ធនំ
យថា បេច្ច ន ហាយេថ ញាតិសង្ឃោ មយី គតេ
យថេវ ខលតី ភូម្យំ ភូម្យាយេវ បតិដ្ឋតិ
ឯវេតំ ខលិតំ មយ្ហំ ឯតំ បស្សាមិ អច្ចយំ ។

(១៤១) សក្កា ន គន្តុំ ឥតោ[១] មយ្ហំ ហោតិ
ឆេត្វា វធិត្វា ឥធ កាតិយានំ
ឥធេវ ហោហី ឥតិ មយ្ហំ រុច្ចតិ
មា ត្វំ អគា[២] ឧត្តមភូរិបញ្ញ ។

(១៤២) មា ហេវធម្មេសុ មនំ បណីធហិ
អត្ថេ ច ធម្មេ ច យុត្តោ ភវស្សុ
ធិរត្ថុ កម្មំ អកុសលំ អនរិយំ
យំ កត្វា បច្ឆា និរយំ វជេយ្យ ។
នេវេស ធម្មោ ន បុនេតំ កិច្ចំ
អយិរោ[៣] ហិ ទាសស្ស ជនិន្ទ ឥស្សរោ
ឃាតេតុំ ឈាបេតុំ អថោបិ ហន្តុំ
ន ច មយ្ហំ កោធត្ថិ វជាមិ ចាហំ ។

១ ឱ. សក្កា គន្តុំ ឥតិ ។ ២ ឱ. អគមា ។ ៣ ឱ. អយ្យោ ។



សូមព្រះអង្គទ្រង់ទតមើលកូនចៅទាំងឡាយរបស់ខ្ញុំព្រះអង្គផង ទាំងទ្រព្យដទៃក្នុងផ្ទះរបស់ខ្ញុំព្រះអង្គផង កាលបើខ្ញុំព្រះអង្គទៅហើយ សូមកុំឲ្យពួកញាតិសាសន៍ក្នុងកាលខាងក្រោយឡើយ ប្រសិនបើទូលព្រះបង្គំមានសេចក្ដីភ្លាំងភ្លាត់ ទូលព្រះបង្គំនឹងយកញាតិទាំងនោះវិញ ដូចជាបុរសភ្លាត់ដួលលើផែនដី ហើយឈរលើផែនដីវិញ ។

(១៤១) (ព្រះរាជា...) សេចក្ដីគាប់ចិត្តខ្ញុំថា អ្នកមិនគួរទៅទេ ខ្ញុំគាប់ចិត្តថា ឲ្យអ្នកកាប់សំឡាប់មាណពក្លាយខៈ ក្នុងទីនេះហើយនៅក្នុងទីនេះចុះ ម្នាលបណ្ឌិតមានប្រាជ្ញាធ្ងន់ដូចផែនដី អ្នកកុំទៅ ។

(១៤២) (មហោសថ...) សូមព្រះអង្គកុំតាំងព្រះហឫទ័យ ក្នុងការមិនមែនជាធម៌ សូមប្រកបក្នុងប្រយោជន៍និងក្នុងធម៌ផង ថ្វីយបុគ្គលធ្វើកម្មណា ហើយទៅកាន់នរក ក្នុងកាលខាងក្រោយ កម្មនោះជាអំពើអកុសល មិនប្រសើរ ។ បពិត្រព្រះអង្គជាធំជាងជន ព្រោះថា ធម្មតាម្ចាស់ជាធំរបស់ទាសៈ ចង់សំឡាប់ ចង់ដុតក្រោលបៀតបៀនក៏បាន តែនេះមិនមែនជាធម៌ (របស់បុគ្គលបណ្ឌិតទេ) ទាំងមិនមែនជាកិច្ចរបស់ព្រឹត្តឡើយ សេចក្ដីក្រោធនៃខ្ញុំព្រះអង្គ មិនមានទេ ខ្ញុំព្រះអង្គសូមលាទៅ ។

(១៤៣) ជេដ្ឋបុត្តំ ឧបគុយ្ហ    វិនេយ្យ ហទយេ ទរំ
អស្សុបុណ្ណេហិ នេត្តេហិ បាវិសី សោ មហាឃរំ ។

(១៤៤) សាលាវ សម្បមទ្ទិតា    មាលុតេន បមទ្ទិតា
សេន្តិ បុត្តា ច ទារា ច    វិធុរស្ស និវេសនេ ។
ឥត្ថិសហស្សំ ភរិយានំ    ទាសីសត្តសតានិ ច
ពាហា បគ្គយ្ហ បក្កន្ទុំ    វិធុរស្ស និវេសនេ ។
ឱរោធា ច កុមារា ច    វេសិយានា ច ព្រាហ្មណា
ពាហា បគ្គយ្ហ បក្កន្ទុំ    វិធុរស្ស និវេសនេ ។
ហត្ថារោហា អនីកដ្ឋា    រថិកា បត្តិការកា
ពាហា បគ្គយ្ហ បក្កន្ទុំ    វិធុរស្ស និវេសនេ ។
សមាគតា ជានបទា    នេគមា ច សមាគតា
ពាហា បគ្គយ្ហ បក្កន្ទុំ    វិធុរស្ស និវេសនេ ។
ឥត្ថិសហស្សំ ភរិយានំ    ទាសីសត្តសតានិ ច
ពាហា បគ្គយ្ហ បក្កន្ទុំ    កស្មា នោ វិជហិស្សសិ ។
ឱរោធា ច កុមារា ច    វេសិយានា ច ព្រាហ្មណា
ពាហា បគ្គយ្ហ បក្កន្ទុំ    កស្មា នោ វិជហិស្សសិ ។
ហត្ថារោហា អនីកដ្ឋា    រថិកា បត្តិការកា
ពាហា បគ្គយ្ហ បក្កន្ទុំ    កស្មា នោ វិជហិស្សសិ ។





(១៤៣) (អភិសម្ពុទ្ធគាថា) ព្រះមហាសត្វនោះ មានព្រះនេត្រពេញដោយទឹកភ្នែក ឱបនូវបុត្រ(ធម្មបាលកុមារ)ជាបុត្រច្បង លុះបន្ទោបង់សេចក្ដីក្រវល់ក្រវាយក្នុងហឫទ័យហើយ ក៏ចូលទៅកាន់ផ្ទះធំ ។

(១៤៤) ពួកបុត្រនិងភរិយារបស់វិធុរបណ្ឌិត ដេក (បក្រោស់ខ្ទៀល) ក្នុងលំនៅ ដូចជាដើមរាំងដែលត្រូវខ្យល់បក់បោកញាំញី ។ ស្ត្រីជាប្រពន្ធ ១ ពាន់នាក់ និងទាសី ៧ រយនាក់ ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញ ក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញ និងពួកព្រាហ្មណ៍ ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញ ក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញ ក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកអ្នកជនបទ មកជួបជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួបជុំគ្នា ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញ ក្នុងលំនៅនៃវិធុរបណ្ឌិត ។ ស្ត្រីជាប្រពន្ធ ១ ពាន់នាក់ និងទាសី ៧ រយនាក់ ផ្គងដៃ ឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញ និងពួកព្រាហ្មណ៍ ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វី ទើបលោកលះចោល ពួកយើង ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វី ទើបលោកលះចោល ពួកយើង ។

សមាគតា ជានបទា  នេគមា ច សមាគតា

ពាហា បគ្គយ្ហ បក្កន្ទុំ  កស្មា នោ វិជហិស្សសិ ។

(១៦៥) កត្វា យានេសុ កិច្ចានិ  អនុសាសិត្វា សព្ពំ ជនំ

មិត្តាមច្ចេ ច ភច្ចេ ច  បុត្តទារេ ច ពន្ធវេ ។

កាមន្តំ សំវិធេត្វាន  អាចិក្ខិត្វា ឃរេ ធនំ

និធិញ្ច ឥណទានញ្ច  បុណ្ណកំ ឯតទព្រវិ ។

អវសី តុវំ មយ្ហ តីហំ អគារេ

កតានិ កិច្ចានិ ឃរេសុ មយ្ហំ

អនុសាសិតា បុត្តទារា មយា ច

ករោមិ កិច្ចានិ យថាមតិន្តេ ។

(១៦៦) សចេ ហិ កត្តា អនុសាសិតា តេ

បុត្តា ច ទារា អនុជីវិនោ ច

ហន្ទេហិ ទានិ តរមានរូបោ

ទីឃោ ហិ អទ្ធាបិ អយំ បុរត្ថា ។

អសម្ភិតោវ[១] គណ្ហាហិ  អាជានេយ្យស្ស វាលធិំ

ឥទំ បច្ឆិមកំ តុយ្ហំ  ជីវលោកស្ស ទស្សនំ ។

(១៦៧) សោហំ កិស្សានុ ភាយិស្សំ  យស្ស មេ នត្ថិ ទុក្កដំ

កាយេន វាចា មនសា  យេន គច្ឆេយ្យ ទុគ្គតិំ ។

១ ម. អឆម្ភិតោ ។



ពួកអ្នកជនបទ មកជួបជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួបជុំគ្នា ខ្ញុំនឹង លើកដៃប្រណម្យកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។

(១៦៥) ព្រះមហាសត្វបានធ្វើកិច្ចទាំងឡាយក្នុងផ្ទះ ប្រៀនប្រដៅជនរបស់ខ្លួន គឺពួកមិត្រ អាមាត្យ ជនអ្នកនៅអាស្រ័យ បុត្រ ភរិយា និងផៅពង្ស ។ ព្រះមហាសត្វចាត់ចែងការងារ ប្រាប់ទ្រព្យក្នុងផ្ទះ ទីកំណប់ និងការឱ្យខ្ចី ហើយពោលពាក្យនេះ នឹងបុណ្ណកយក្សថា

អ្នកបាននៅក្នុងផ្ទះរបស់ខ្ញុំអស់បីថ្ងៃហើយ កិច្ចក្នុងផ្ទះខ្ញុំ

ធ្វើហើយ ទាំងបុត្រនិងភរិយា ខ្ញុំក៏បានប្រៀនប្រដៅហើយ

អ្នកចូរធ្វើកិច្ចទាំងឡាយ តាមអធ្យាស្រ័យរបស់អ្នកចុះ ។

(១៦៦) (បុណ្ណកយក្ស...) បពិត្រអ្នកជាអាមាត្យ បើអ្នកបានប្រៀន

ប្រដៅបុត្រ ភរិយា នឹងពួកជនអ្នកចិញ្ចឹមជីវិតដោយសារ

ហើយ អើអ្នកចូរប្រញាប់ប្រញាល់ មកក្នុងកាលឥឡូវនេះចុះ

ព្រោះថាផ្លូវខាងមុខនេះ ជាផ្លូវដាច់ស្រយាលវែងឆ្ងាយ ។

អ្នកកុំភ័យ ចូរចាប់កន្ទុយសេះអាជានេយ្យចុះ នេះជាការ

ឃើញជីវលោក ជាទីបំផុត របស់អ្នក ។

(១៦៧) (ព្រះមហាសត្វ...) បុគ្គលទៅកាន់ទុគ្គតិ ដោយអំពើណា

ដែលកើតអំពីកាយវាចាចិត្ត អំពើអាក្រក់ (នោះ) របស់ខ្ញុំមិនមានទេ

ខ្ញុំនឹងខ្លាចចំពោះអំពើអ្វី ។

(១៦៨) សោ អស្សរាជា វិធុរំ វហន្តោ
បក្កាមិ វេហាយសមន្តលិក្ខេ
សាខាសុ សេលេសុ អសជ្ជមានោ
កាឡាគិរិ ខិប្បមុបាគមាសិ ។

(១៦៩) ឥត្ថីសហស្សំ ភរិយានំ ទាសីសតានិ ច
ពាហា បគ្គយ្ហ បក្កន្ទុំ
យក្ខោ ព្រាហ្មណវណ្ណេន វិធុរំ អាទាយ គច្ឆតិ ។
ឱរោធា ច កុមារា ច វេសិយានា ច ព្រាហ្មណា
ពាហា បគ្គយ្ហ បក្កន្ទុំ
យក្ខោ ព្រាហ្មណវណ្ណេន វិធុរំ អាទាយ គច្ឆតិ ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
ពាហា បគ្គយ្ហ បក្កន្ទុំ
យក្ខោ ព្រាហ្មណវណ្ណេន វិធុរំ អាទាយ គច្ឆតិ ។
សមាគតា ជានបទា នេគមា ច សមាគតា
ពាហា បគ្គយ្ហ បក្កន្ទុំ
យក្ខោ ព្រាហ្មណវណ្ណេន វិធុរំ អាទាយ គច្ឆតិ ។
ឥត្ថីសហស្សំ ភរិយានំ ទាសីសតានិ ច
ពាហា បគ្គយ្ហ បក្កន្ទុំ បណ្ឌិតោ សោ កុហឹ គតោ ។





(១៦៨) (អភិសម្ពុទ្ធគាថា) ស្ដេចសេះនោះនាំវិធុរបណ្ឌិតហោះទៅ ក្នុងអាកាសវេហាស៍ ឥតប៉ះទង្គិចនឹងមែកឈើភ្នំ ក៏ចូលទៅកាន់កាឡាគិរីបព៌ត ដោយឆាប់រហ័ស ។

(១៦៩) ស្ត្រីជាប្រពន្ធមួយពាន់នាក់ នឹងទាសីរយនាក់ ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍ នាំវិធុរបណ្ឌិតទៅ ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញ និងពួកព្រាហ្មណ៍ ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍ នាំវិធុរបណ្ឌិតទៅ ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ផ្គងដៃឡើងខ្សឹកខ្សួល កន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍ នាំវិធុរបណ្ឌិតទៅ ។ ពួកអ្នកជនបទ មកជួបជុំគ្នា ពួកអ្នកនិគម ក៏មកជួបជុំគ្នា ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍ នាំវិធុរបណ្ឌិតទៅ ។ ស្ត្រីជាប្រពន្ធមួយពាន់នាក់ នឹងទាសីរយនាក់ ផ្គងដៃឡើងខ្សឹកខ្សួលកន្ទក់កន្ទេញថា វិធុរបណ្ឌិតទៅឯណាហ្ន៎ ។

ឥត្ថិយោ ច កុមារា ច វេសិយានា ច ព្រាហ្មណា

ពាហា បគ្គយ្ហ បក្កន្ទុំ បណ្ឌិតោ សោ កុហិំ គតោ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា

ពាហា បគ្គយ្ហ បក្កន្ទុំ បណ្ឌិតោ សោ កុហិំ គតោ ។

សមាគតា ជានបទា នេគមា ច សមាគតា

ពាហា បគ្គយ្ហ បក្កន្ទុំ បណ្ឌិតោ សោ កុហិំ គតោ ។

(២៨០) សចេ សោ សត្តរត្តេន បណ្ឌិតោ នាគមិស្សតិ

សព្វេ អគ្គិំ បវិស្សាម នត្ថត្ថោ ជីវិតេន នោ ។

(១៨១) បណ្ឌិតោ ច វិយត្តោ ច វិភាវី ច វិចក្ខណោ

ខិប្បំ មោចេសិ អត្តានំ មា ភាយិត្ថាគមិស្សតិ ។

អន្តរាបេយ្យាលំ ឥម ។

(១៨២) សោ តត្ថ គន្ត្វាន វិចិន្តយន្តោ

ទុក្ខាវហា គេហនកា ករន្តិ



ពួកស្រ្តី ពួកកុមារ ពួកអ្នកដំណើរនិងពួកព្រាហ្មណ៍ ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា តើបណ្ឌិតទៅកាន់ទីណាហ្ន៎ ។ ពួកពលដំរី (ពលសេះ) ពលរថ ពលថ្មើរជើង ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា តើបណ្ឌិតនោះទៅកាន់ទីណាហ្ន៎ ។ ពួកអ្នកជនបទ មកជួបជុំគ្នា ព្រមទាំងពួកអ្នកនិគមក៏មកជួបជុំគ្នា ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា តើបណ្ឌិតនោះទៅកាន់ទីណាហ្ន៎ ។

(១៨០) (មហាជន...) បើបណ្ឌិតនោះ នឹងមិនត្រឡប់មក ក្នុងរវាង ៧ រាត្រីទេ ពួកខ្ញុំព្រះបង្គំទាំងអស់គ្នា នឹងចូលភ្លើង ពួកខ្ញុំព្រះបង្គំ មិនបានសេចក្តីត្រូវការដោយជីវិតឡើយ ។

(១៨១) (ព្រះរាជា...) បណ្ឌិតជាបុគ្គលឈ្លាសវៃ អាចសំរេច(ប្រយោជន៍) នឹងមិនមែនប្រយោជន៍ មានប្រាជ្ញាឈ្វេងយល់ រមែងដោះខ្លួនបានដោយឆាប់ អ្នកទាំងឡាយកុំខ្លាចឡើយ បណ្ឌិតនោះគង់តែនឹងត្រឡប់មកវិញ ។

ចប់ អន្តរាបេយ្យាលៈ ។

(១៨២) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្សនោះកាលទៅលើកំពូលភ្នំកាឡាគិរីនោះគិតថា គំនិតទាំងឡាយរមែងជាធម្មជាតិខ្ពស់នឹងទាប

នយិមស្ស ជីវេន មមត្ថិ កិញ្ចិ
ហន្ត្វានិមំ ហទយំ អានយិស្សំ ។

(១៨៣) សោ តត្ថ គន្ត្វា បព្វតមន្តរស្មឹ
អន្តោ បវិសិត្វាន បទុដ្ឋចិត្តោ
អសំវុតស្មឹ ជគតិប្បទេសេ
អធោសិរំ ធារយិ កាតិយានោ ។

(១៨៤) សោ លម្ពមានោ នរកេ បបាតេ
មហព្ភយេ លោមហំសេ វិធុរោ
អសន្តសន្តោ កុរូនំ កត្តុសេដ្ឋោ
ឥច្ចព្រវិ បុណ្ណកំ នាម យក្ខំ ។
អរិយាវកាសោសិ អនរិយរូបោ
អសញ្ញតោ សញ្ញតសន្និកាសោ
អច្ចាហិតំ កម្មំ ករោសិ លុទ្ទំ
ភាវេ ច តេ កុសលំ នត្ថិ កិញ្ចិ ។
យំ មំ បបាតស្មឹ បបាតុមិច្ឆសិ
កោ នុ តវត្ថោ មរណេន មយ្ហំ
អមានុសស្សេវ តវជ្ជ វណ្ណោ
អាចិក្ខ មេ ត្វំ កតមាសិ ទេវតា ។



អញមិនមែនមានកិច្ចកិច្ចណា ដោយជីវិតរបស់វិធុរបណ្ឌិតនេះ (ក្នុងកាលមាននៅរស់ទេ) អញនឹងសំឡាប់វិធុរបណ្ឌិតនេះ ហើយនាំយកតែបេះដូងទៅ ។

(១៨៣) មាណពកច្ចាយនគោត្រនោះ មានចិត្តប្រទូស្ត បានទៅក្នុងចន្លោះភ្នំនោះ ហើយចូលទៅខាងក្នុង ចាប់ព្រះមហាសត្វយកក្បាលចុះក្រោម (ត្រឹងទៅ) ក្នុងប្រទេសនៃផែនដីដែលមិនមានអ្វីប៉ះពាល់ឡើយ ។

(១៨៤) វិធុរបណ្ឌិតនោះ ជាអាចារ្យដ៏ប្រសើររបស់អ្នកដែនកុរុ កាលសំយុងចុះទៅក្នុងរណ្ដៅជ្រោះ ជាទីមានភ័យដ៏ធំ គួរព្រឺព្រោម ដែលរលំចុះក្នុងនរកទៅក្រលែង តែមិនតក់ស្លុត ហើយពោលនឹងបុណ្ណកយក្សយ៉ាងនេះថា អ្នកជាមនុស្សមិនប្រសើរ តែធ្វើដូចជាប្រសើរ ជាអ្នកមិនសង្រួម តែមានអាការហាក់ដូចជាអ្នកសង្រួម អ្នកធ្វើអំពើអាក្រក់ឥតប្រយោជន៍ ចំណែកកុសលតិចតួចឥតមានក្នុងចិត្តនៃអ្នកទេ ។ អ្នកចង់ទំលាក់ខ្ញុំទៅក្នុងរណ្ដៅជ្រោះ ដោយហេតុណា ប្រយោជន៍ដូចម្ដេចដោយការសំឡាប់ខ្ញុំ នឹងមានដល់អ្នក ដោយហេតុនោះ ក្នុងថ្ងៃនេះ អ្នកមានភេទដូចជាមិនមែនភេទនៃមនុស្សទេ ចូរអ្នកប្រាប់ខ្ញុំ អ្នកជាទេវតា ឬជាអ្វី ។

(១៨៥) យទិ តេ សុតោ បុណ្ណកោ នាម យក្ខោ
វេស្សវណស្ស ហិ សោ សជិព្វោ
ភុម្មិន្ធរោ វរុណោ នាម នាគោ
ព្រហា សុចី វណ្ណពលូបបន្នោ(១) ។
តស្សានុជំ ធីតរំ កាមយាមិ
ឥរន្ធតី នាម សា នាគកញ្ញា
តស្សា សុមជ្ឈាយ បិយាយ ហេតុ
បតារយឹ តុយ្ហំ វធាយ ធីរ ។

(១៨៦) មា ហេវ តេ យក្ខ អហោសិ មោហោ
នដ្ឋា ពហូ ទុគ្គហិតេន លោកា
កិំ តេ សុមជ្ឈាយ បិយាយ កិច្ចំ
មរណេន មេ ឥង្ឃ សុណោម សព្វំ ។

(១៨៧) មហានុភាវស្ស មហោរគស្ស
ធីតុកាមោ ញាតិភតោហមស្មិ
តំ យាចមានំ សសុរោ អវោច
យថា មមញ្ញឹសុ សុកាមនីតំ ។
ទជ្ជេមុ ខោ តេ សុតនុំ សុនេត្តំ
សុចិម្ហិតំ ចន្ទនលិត្តគត្តំ

---

១ ម. សុចិវណ្ណពលូបបន្នោ ។



(១៨៥) (បុណ្ណកយក្ស...) ខ្ញុំបាទឈ្មោះបុណ្ណកយក្ស ជាអាមាត្យព្រះបាទកុវេរៈ ដែលអ្នកធ្លាប់បានឮហើយ នាគឈ្មោះវរុណៈ ជាអ្នកទ្រទ្រង់ផែនដី មានទំហំនឹងកំពស់ មានទ្រង់ទ្រាយដ៏ស្អាត ប្រកបដោយពណ៌នឹងកំឡាំង ។ ម្នាលអ្នកប្រាជ្ញ ខ្ញុំចង់បានធីតា ជាអនុជាត នៃព្រះបាទវរុណនាគនោះ នាគកញ្ញានោះឈ្មោះឥរន្ធតី ខ្ញុំក្លាយមកសំឡាប់អ្នក ព្រោះហេតុនាងឥរន្ធតី មានចង្កេះល្អ ជាទីស្រឡាញ់នោះ ។

(១៨៦) (ព្រះមហាសត្វ...) ម្នាលយក្ស សេចក្តីវង្វេង កុំមានដល់អ្នកឡើយ ពួកសត្វលោកជាច្រើន វិនាសហើយ ព្រោះតែសេចក្តីដែលខ្លួនប្រកាន់ខុស ចុះអ្នកមានកិច្ចអ្វី ដោយការសម្លាប់ខ្ញុំ (ព្រោះនាគកញ្ញា) មានចង្កេះល្អ ជាទីស្រឡាញ់ សូមអញ្ជើញប្រាប់ ខ្ញុំនឹងស្តាប់ការទាំងអស់មើល ។

(១៨៧) (បុណ្ណកយក្ស...) ខ្ញុំចង់បានធីតារបស់ព្រះបាទវរុណនាគជាធំ មានអានុភាពច្រើន ខ្ញុំជាអ្នកស៊ីឈ្នួលរបស់ពួកញាតិ ព្រោះហេតុ ពួកញាតិនឹងឲ្យខ្ញុំ ជាអ្នកត្រូវការចង់បានដោយពិត (បានជា) ឪពុកក្មេកខ្ញុំ ពោលនឹងខ្ញុំដែលសូមនាងឥរន្ធតីនោះថា យើងនឹងឲ្យកូនស្រី មានកាយល្អ មានភ្នែកល្អ មានទ្រង់ទ្រាយរីករាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ ដល់អ្នក

សចេ តុវំ ហទយំ បណ្ឌិតស្ស
ធម្មេន លទ្ធា ឥធមាហរេសិ ។
ឯតេន វិត្តេន កុមារី លទ្ធា
ចាញ្ញំ ធនំ ឧត្តរិ បត្ថយាម
ឯវំ ន មុញ្ចេស្សំ សុវណ្ណាហិ កាមេ ។
ន ចាបិ មេ ទុព្ភិតមត្ថិ កិញ្ចិ
ហទយេន តេ ធម្មលទ្ធេន នាគា
ឥរន្ធតី នាគកញ្ញា ទទន្តិ
តស្មា អហំ តុយ្ហំ វធាយ យុត្តោ
ឯវំ មមត្ថោ មរណេន តុយ្ហំ
ឥធេវ តំ នរកេ ឃាតយិត្វា
ហន្ត្វាន តំ ហទយំ អានយិស្សំ ។

(១៨៨) ខិប្បំ មមំ ឧទ្ធរ កាតិយាន
ហទយេន មេ យទិ តេ អត្ថិ កិច្ចំ
យេ កេចិ មេ សាធុនរស្ស ធម្មា
សព្វេវ តេ បាតុករោមិ អជ្ជ ។

(១៨៩) សោ បុណ្ណកោ កុរូនំ កត្តុសេដ្ឋំ
នគមុទ្ធនិ ខិប្បំ បតិដ្ឋបេត្វា



បើអ្នកបាននូវហឫទ័យរបស់វិធុរបណ្ឌិត មកដោយធម៌ ហើយនាំមកក្នុងទីក្រុងនាគនេះ ។ អ្នកត្រូវបាននាងកុមារី ដោយទ្រព្យជាទីត្រេកអរនុ៎ះ យើងមិនប្រាថ្នាទ្រព្យដទៃក្រៅពីនេះទេ ព្រោះបណ្ឌិតជាអាមាត្យ ខ្ញុំមិនលែងនូវអ្នកទេ អ្នកចូរស្ដាប់ចុះ ។ មួយទៀត សេចក្ដីទុច្ចរិតដែលខ្ញុំប្រព្រឹត្តខុសមិនមានទេ កាលខ្ញុំបានហឫទ័យរបស់អ្នកដោយធម៌ ពួកនាគនឹងឲ្យនាងកញ្ញាឈ្មោះឥរន្ធតី ។ ព្រោះហេតុនោះ ទើបខ្ញុំលលកសំឡាប់អ្នក ខ្ញុំមានសេចក្ដីត្រូវការដោយការសំឡាប់អ្នកយ៉ាងនេះឯង ខ្ញុំនឹងទំលាក់អ្នកក្នុងទីរណ្ដៅនេះ សម្លាប់អ្នកហើយ នឹងនាំយកនូវហឫទ័យទៅ ។

(១៨៨) (មហាសត្វ...) ម្នាលកច្ចាយនៈ បើអ្នកមានកិច្ចត្រូវការដោយហឫទ័យរបស់ខ្ញុំ ចូរអ្នកលើកខ្ញុំដោយឆាប់រហ័ស ឯកសាធុនរធម៌ (ធម៌ល្អរបស់នរៈ) របស់ខ្ញុំណាមួយ ខ្ញុំនឹងសំដែងសាធុនរធម៌ទាំងអស់នោះ ដល់អ្នក ក្នុងថ្ងៃនេះ ។

(១៨៩) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្សនោះ ដាក់វិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ លើកំពូលភ្នំ ឆាប់រហ័ស

អស្សត្ថមាសីនំ សមេក្ខិយាន
បរិបុច្ឆិ កត្តារមនោមបញ្ញំ ។
សមុទ្ធរោ មេសិ តុវំ បបាតា
ហទយេន តេ អជ្ជ មមត្ថិ កិច្ចំ
យេកេចិ តេ សាធុ នរស្ស ធម្មា
សព្វេ មេ បាតុករោហិ អជ្ជ ។
(១៦០) សមុទ្ធរោ ត្យស្មិ អហំ បបាតា
ហទយេន មេ យទិ តេ អត្ថិ កិច្ចំ
យេកេចិ តេ សាធុ នរស្ស ធម្មា
សព្វេ តេ បាតុករោមិ អជ្ជ ។
(១៦១) យាតានុយាយី ច ភវាហិ មាណវ
អល្លញ្ច បាណឹ បរិវជ្ជយស្សុ
មា ចស្សុ មិត្តេសុ កទាចិ ទុព្ភី
មា ច វសំ អសតីនំ និគច្ឆេ ។
(១៦២) កថំ នុ យាតំ អនុយាយី ហោតិ
អល្លញ្ច[1] បាណឹ ទហតេ កថំ សោ
អសតី ច កា កោ បន មិត្តទុព្ភោ
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ ។

[1] ម. អលំ ។



ឃើញវិធុរបណ្ឌិតជាលោកាចារ្យមានប្រាជ្ញាមិនជាប់កតាប អង្គុយ ដែលផ្ដើមស្រួលហើយ ក៏សាកសួរថា អ្នកនឹងខ្ញុំលើកឡើងពីតាករណ្ដៅហើយ ក្នុងថ្ងៃនេះ ខ្ញុំត្រូវការដោយហឫទ័យរបស់អ្នក អ្នកចូរសំដែងសាធុធម៌ទាំងអស់នោះ ដល់ខ្ញុំ ក្នុងថ្ងៃនេះ ។

(១៦០) (មហាសត្វ...) ខ្ញុំនឹងអ្នកលើកឡើងពីតាករណ្ដៅហើយ បើអ្នកត្រូវការដោយហឫទ័យរបស់ខ្ញុំ ខ្ញុំនឹងសំដែងសាធុធម៌ទាំងអស់នោះ ដល់អ្នក ក្នុងថ្ងៃនេះ ។

(១៦១) ម្នាលមាណព អ្នកចូរដើរតាមផ្លូវដែលគេដើរហើយ អ្នកចូរវៀរ គឺកុំដុតបាតដៃដែលទទឹក អ្នកកុំប្រទូស្តមិត្រ ក្នុងកាលណាមួយ អ្នកកុំលុះអំណាច នៃស្ត្រីដែលប្រកបដោយអសទ្ធម្ម ។

(១៦២) (បុណ្ណកយក្ស...) បុគ្គលដែលឈ្មោះថាដើរទៅកាន់ផ្លូវ ដែលគេដើរហើយ តើដូចម្ដេច គេដុតបាតដៃដែលទទឹក តើដូចម្ដេច ស្ត្រីដូចម្ដេច ឈ្មោះថាស្ត្រីប្រកបដោយអសទ្ធម្ម នរណាឈ្មោះថាជាអ្នកប្រទូស្តមិត្រ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនុ៎ះ ។

(១៦៣) អស្សន្ថុតំ(១) នោបិច ទិដ្ឋបុព្វំ

យោ អាសនេនាបិ និមន្តយេយ្យ

តស្សេវ អត្ថំ បុរិសោ ករេយ្យ

យាតានុយាយីតិ តមាហុ បណ្ឌិតា ។

យស្សេករត្តិម្បិ ឃរេ វសេយ្យ

យត្ថន្នបានំ បុរិសោ លភេថ

ន តស្ស បាបំ មនសាបិ ចិន្តយេ(២)

អទុព្ភ បាណី(៣) ទហតេ មិត្តទុព្ភិំ ។

យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា

ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ ។

បុណ្ណម្បិ ចេមំ បឋវឹ ធនេន

ទជ្ជិត្ថិយា បុរិសោ សម្មតាយ

លទ្ធា ខណំ អតិមញ្ញេយ្យ តម្បិ

តាសំ វសំ អសតីនំ ន គច្ឆេ

ឯវំ ខោ យាតំ អនុយាយី ហោតិ

អទុព្ភ បាណី ទហតេ បុនេវំ

---

១ ម. អសន្ថុតំ ។ ឱ. អសន្ថវំ ។ ២ ម. មនសាភិចេតយេ ។
៣ ម. អទុព្ភបាណី ។ ឱ អទុព្ភិបាណំ ។



(១៦៣) (វិធុរបណ្ឌិត...) បុគ្គលណាអញ្ជើញមនុស្ស ដែលមិនធ្លាប់នៅជាមួយគ្នា ឬមិនធ្លាប់ឃើញគ្នា សូម្បីដោយអាសនៈ បុរសត្រូវធ្វើប្រយោជន៍តបស្នង ដល់បុគ្គលនោះឯង បណ្ឌិតទាំងឡាយពោលថា អ្នកនោះឯងជាអ្នកដើរតាមផ្លូវ ដែលគេដើរហើយ ។ បុរសស្នាក់នៅក្នុងផ្ទះ របស់បុគ្គលណា សូម្បីមួយយប់ បានបាយនិងទឹក ក្នុងសំណាក់បុគ្គលណា មិនត្រូវគិតគំនិតអាក្រក់ ដល់បុគ្គលនោះ សូម្បីដោយចិត្ត បុគ្គលអ្នកប្រទូស្តមិត្រ ឈ្មោះថាដុតបាតដៃទាំងទទេ ។ បុគ្គលគង្គុយឬដេក ក្នុងម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះ ព្រោះថា បុគ្គលប្រទូស្តមិត្រ ជាបុគ្គលអាក្រក់ ។

បុរសណា ឲ្យផែនដីនេះដែលពេញដោយទ្រព្យដល់ស្រីដែលខ្លួនសន្មតថា(ល្អ) ស្រីនោះបានឱកាស (ក្បត់ចិត្ត) គប្បីមើលងាយបុរសនោះវិញ បុគ្គលមិនត្រូវលុះអំណាចស្រីដែលប្រកបដោយអសទ្ធម្មនោះទេ ។ បុគ្គលឈ្មោះថាដើរតាមផ្លូវដែលគេដើរហើយយ៉ាងនេះ ឈ្មោះថាដុតបាតដៃទាំងទទេយ៉ាងនេះ

អសតី ច សា សោ បន មិត្តទុព្ភោ

សោ ចេតិតោ ហោហិ ជហស្សុ អខេមំ ។

សាធុសីលវគ្គោ តតិយោ ។

(១៦៤) អវសឹ អហំ តុយ្ហំ តីហំ អគារេ

អន្នេន បានេន ឧបដ្ឋិតោស្មិ

មិត្តោ មមាសិ វិសជ្ជាមហំ តំ

កាមំ ឃរំ ឧត្តមបញ្ញ គច្ឆ ។

អបិ ហាយតុ វាតកុលស្ស អន្តោ

អលម្បិ មេ វាតកញ្ញាយ ហេតុ

សោ ត្វំ សកេនេវ សុភាសិតេន

មុត្តោសិ មេ អជ្ជ វធាយ បញ្ញ ។

(១៦៥) មាទុ តុវំ យក្ខ មមម្បិ ទេហិ

សស្សុរំ នុ តេ អត្ថំ មយី ចរស្សុ

អហម្បិ តាតាធិបតីវិមានំ

ឧក្កោមិ តាតស្ស អធិដ្ឋតុំ ។

(១៦៦) យំ វេ នរស្ស អហិតាយ អស្ស

ន តំ បញ្ញោ អរហតិ ជស្សតាយ



ស្រីនោះឈ្មោះថាប្រកបដោយអសទ្ធម្ម បុរសនោះឈ្មោះថា ជាអ្នកប្រទូស្តមិត្រ អ្នកចូរជាអ្នកប្រកបដោយធម៌ ចូរលះ បង់អំពើមិនមែនធម៌ចេញ ។

ចប់ សាធុសីលវគ្គ ។

(១៦៤) (បុណ្ណកយក្ស...) ខ្ញុំបាននៅក្នុងផ្ទះរបស់អ្នក អស់ ៣ ថ្ងៃ ដែលអ្នកបានចំណុះបម្រើខ្ញុំដោយបាយនិងទឹក អ្នក សម្មាជាមិត្ររបស់ខ្ញុំ ចាំនឹងខ្ញុំនឹងលែងអ្នកដែរ ម្នាលបណ្ឌិតមាន ប្រាជ្ញាខ្ពង់ខ្ពស់ ចូរអ្នកអញ្ជើញទៅកាន់ផ្ទះរបស់អ្នក តាម ប្រាថ្នាចុះ ។ ចាំនឹងសេចក្ដីត្រូវការរបស់ត្រកូលនាគ ក៏សាប សូន្យទៅចុះ អំពើព្រោះហេតុនៃនាគកញ្ញាក៏ល្មមដល់ខ្ញុំ ហើយ ម្នាលអ្នកមានប្រាជ្ញា អ្នកបានរួចចាកការសម្លាប់របស់ ខ្ញុំ ក្នុងថ្ងៃនេះ ព្រោះសុភាសិតរបស់ខ្លួន ។

(១៦៥) (ព្រះមហាសត្វ...) ម្នាលយក្ស ណ្ហើយ អ្នកចូរនាំខ្ញុំទៅ កាន់សំណាក់ឪពុកក្មេក របស់អ្នកចុះ អ្នកចូរប្រព្រឹត្តឲ្យជា ប្រយោជន៍ចំពោះខ្ញុំ ដ្បិតខ្ញុំនឹងឃើញនាគជាធិបតី និង វិមានរបស់នាគនោះ ដែលខ្ញុំមិនធ្លាប់ឃើញ ។

(១៦៦) (បុណ្ណកយក្ស...) របស់ណាដែលប្រព្រឹត្តទៅ មិនជាប្រយោ- ជន៍ដល់ជន ជនមានប្រាជ្ញា មិនគួរឃើញ របស់នោះទេ

អថ កេន វណ្ណេន អមិត្តគាមំ
តុវំមិច្ឆសិ ឧត្តមបញ្ញ គន្តុំ ។

(១៦៧) អទ្ធា បជានាមិ អហម្បិ ឯតំ
ន តំ បញ្ញោ អរហតិ ទស្សនាយ
បាបញ្ច មេ នត្ថិ កតំ កុហិញ្ចិ
តស្មា ន សង្កេ មរណាគមាយ ។

(១៦៨) ហន្ទ ច ឋានំ អតុលានុភាវំ
មយា សហ ទក្ខសិ ឯហិ កត្តេ
យត្ថច្ឆតិ នច្ចគីតេហិ នាគោ
រាជា យថា វេស្សវណោ នឡិញ្ញំ ។

តំ នាគកញ្ញា ចរិតំ គណេន
និកីឡិតំ និច្ចមហោ ច រត្តិំ
បហូតមាល្យំ ពហុបុប្ផឆន្នំ
ឱភាសតិ វិជ្ជុរិវន្តលិក្ខេ ។

អន្នេន បានេន ឧបេតរូបំ
នច្ចេហិ គីតេហិ ច វាទិតេហិ
បរិបូរំ កញ្ញាហិ អលង្កតាហិ
ឧបសោភតិ វត្ថបិលន្ធនេន ។



ម្នាលបណ្ឌិតមានប្រាជ្ញខ្ពង់ខ្ពស់ កាលបើដូច្នេះ អ្នកប្រាជ្ញ ទៅកាន់ស្រុករបស់សត្រូវ ដោយហេតុដូចម្តេច ។

(១៦៧) (ព្រះមហាសត្វ...) ខ្ញុំច្បាស់ជាដឹងហេតុនុ៎ះ ជនមានប្រាជ្ញ មិនគួរឃើញសត្រូវនោះទេ តែកំពើអាក្រក់ ខ្ញុំមិនបានធ្វើទុក ក្នុងទីណាមួយ ព្រោះហេតុនោះ ខ្ញុំមិនរង្កៀសចំពោះសេចក្តី ស្លាប់ដែលនឹងមកដល់ឡើយ ។

(១៦៨) (បុណ្ណកយក្ស...) ម្នាលអ្នកជាកត្តា បើដូច្នោះ អ្នកនឹង ឃើញឋាន ដែលមានអានុភាពប្រៀបមិនបាន ជាមួយនឹងខ្ញុំ អ្នកចូរមកចុះ នាគរាជនៅដោយការរាំនិងច្រៀងក្នុងទីណា ដូចជាព្រះបាទវេស្សវ័ណ នៅក្នុងឧទ្យានឈ្មោះនឡិញ្ញៈ ។

ទីនោះមានពួកនៃនាគកញ្ញាត្រាច់ទៅដោយពួកៗ លេង រាល់ថ្ងៃនិងយប់ជានិច្ច ជាទីមានផ្កាកម្រងច្រើន ដេរដាស ដោយផ្កាឈើច្រើនបែប ភ្លឺផ្លេកដូចផ្លេកបន្ទោរក្នុងអាកាស ។

ឋានៃនាគនោះ មានភាពសម្បូណ៌ដោយបាយនិងទឹក និង ការរាំច្រៀងប្រគំ បរិបូណ៌ដោយពួកនាគកញ្ញា ដែល តាក់តែងខ្លួន ដោយសំពត់ និងគ្រឿងប្រដាប់លម្អរាងកាយ ។

(១៦៩) សោ បុណ្ណកោ កុរូនំ កត្តុសេដ្ឋំ
និសីទយំ បច្ឆតោ អាសនស្មឹ
អាទាយ កត្តារមនោមបញ្ញំ
ឧទានយិ ភវនំ[1] នាគរញ្ញោ ។
បត្វាន ឋានំ អតុលានុភាវំ
អដ្ឋាសិ កត្តា បច្ឆតោ បុណ្ណកស្ស
សាមគ្គិបេក្ខី បន នាគរាជា
បុព្វេវ ជាមាតរមជ្ឈភាសថ ។

(១៧០) យំ នុ ត្វំ អគមា មនុស្សលោកំ
អន្វេសមានោ ហទយំ បណ្ឌិតស្ស
កច្ចិ សមិទ្ធេន ឥធានុបត្តោ
អាទាយ កត្តារមនោមបញ្ញំ ។

(១៧១) អយំ ហិ សោ អាគតោ យំ ត្វមិច្ឆសិ
ធម្មេន លទ្ធោ មម ធម្មបាលោ
តំ បស្សថ សម្មុខា ភាសមានំ
សុខោ ហវេ សប្បុរិសេហិ សង្គមោ ។

កាលាគិរិកណ្ឌំ [illegible] ។

---

[1] ម. សេនំ ។





(១៦៩) (អភិសម្ពុទ្ធគាថា) ពុណ្ណកយក្សនោះ បានលើកវិធុរបណ្ឌិតជាអាចារ្យដ៏ប្រសើររបស់អ្នកដែនកុរុឲ្យអង្គុយលើអាសនៈអំពីខាងក្រោយ នាំវិធុរបណ្ឌិតជាអាចារ្យមានប្រាជ្ញាមិនថោកទាប ចូលទៅកាន់ភពនៃនាគរាជ ។ វិធុរបណ្ឌិតជាអាចារ្យល្អ ដល់ទីដែលមានអានុភាពប្រៀបមិនបាន ក៏ឈរខាងក្រោយពុណ្ណកយក្ស ចំណែកនាគរាជ ក្រឡេកមើលឃើញពុណ្ណកយក្សមានសេចក្តីស្មោះសរ បានក្រោកទៅក្នុងប្រសាទមុនជា

(១៧០) (នាគរាជ...) អ្នកកាលស្វែងរកហឫទ័យរបស់បណ្ឌិត បានទៅកាន់មនុស្សលោក ហើយនាំអាចារ្យមានប្រាជ្ញាមិនថោកទាបមកដល់ក្នុងទីនេះ ដោយសួស្តីហើយឬ ។

(១៧១) (ពុណ្ណកយក្ស...) ព្រះអង្គប្រាថ្នាបណ្ឌិតណា បណ្ឌិតនោះមកដល់ហើយ បណ្ឌិតអ្នករក្សាធម៌ គឺខ្ញុំព្រះអង្គបានមកដោយធម៌ហើយ សូមព្រះអង្គទ្រង់ទតបណ្ឌិតនោះ ដែលកំពុងនិយាយក្នុងទីចំពោះព្រះភក្ត្រនៃព្រះអង្គ ការជួបជុំដោយសប្បុរសទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខ ដោយពិត ។

ចប់ កាលាគិរិកណ្ឌ ។

(១៧៦) អនិដ្ឋមុត្តិ ចស្សាច មច្ចោ មច្ចុភយដ្ដិតោ
ព្យម្ហិតោ នាភិវាទេសិ ន ឥទំ បញ្ញវតាមិវ ។
(១៧៧) ន ចម្ហិ ព្យម្ហិតោ នាគ ន ច មច្ចុភយដ្ដិតោ
ន វជ្ឈោ អភិវាទេយ្យ វជ្ឈំ វា នាភិវាទយេ ។
កថំ នុ អភិវាទេយ្យ អភិវាទាបយេថ វេ
យំ នរោ ហន្តុមិច្ឆេយ្យ តំ កម្មំ នុបបជ្ជតិ ។
(១៧៨) ឯវមេតំ យថា ព្រូសិ សច្ចំ ភាសសិ បណ្ឌិត
ន វជ្ឈោ អភិវាទេយ្យ វជ្ឈំ វា នាភិវាទយេ ។
កថំ នុ អភិវាទេយ្យ អភិវាទាបយេថ វេ ។
យំ នរោ ហន្តុមិច្ឆេយ្យ តំ កម្មំ នុបបជ្ជតិ ។
(១៧៩) អសស្សតំ សស្សតំ នុ តវយិទំ វិមានំ
ឥទ្ធី ជុតី ពលវីរិយូបបត្តិ



(១៧៦) (នាគរាជ...) អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុត ព្រោះឃើញភុជនាគ ដែលខ្លួនមិនធ្លាប់ឃើញ ទើបមិនថ្វាយបង្គំ (ខ្ញុំ) ដំណើរនេះ មិនមែនជាបុគ្គលមានប្រាជ្ញាទេ ។

(១៧៧) (មហាសត្វ...) បពិត្រនាគ ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យគ្របសង្កត់ទេ ព្រោះអ្នកទោសដែលគួរគេសម្លាប់ មិនគប្បីថ្វាយបង្គំ (ខ្លួនគេវជ្ឈឃាត) ឬគេវជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំ អ្នកទោសដែលគួរគេសម្លាប់ដែរ ។ ជនប្រាជ្ញាសម្លាប់អ្នកណា គប្បីថ្វាយបង្គំ (អ្នកនោះ) ឬឲ្យ (អ្នកនោះ) ថ្វាយបង្គំ (ខ្លួន) ដូចម្ដេចកើត កម្មនោះ មិនសម្រេចទៅជាក្ដីទេ ។

(១៧៨) (នាគរាជ...) ម្នាលបណ្ឌិត ដំណើរនុ៎ះ ដូចអ្នកពោលមែន អ្នកពោលពាក្យពិត អ្នកទោសដែលគួរគេសម្លាប់ មិនគប្បីថ្វាយបង្គំគេវជ្ឈឃាត ឬគេវជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោស ដែលគួរគេសម្លាប់ដែរ ។ នរជនប្រាជ្ញាសម្លាប់អ្នកណា គប្បីថ្វាយបង្គំ (អ្នកនោះ) ឬឲ្យ(អ្នកនោះ) ថ្វាយបង្គំ(ខ្លួន)ដូចម្ដេចកើត កម្មនោះ មិនកើតទៅជាក្ដីទេ ។

(១៧៩) (មហាសត្វ...) វិមាននេះ ទាំងឫទ្ធិ សេចក្ដីរុងរឿង កំឡាំងកាយ សេចក្ដីព្យាយាម និងការកើត (ក្នុងភពនាគ) របស់ព្រះអង្គ មិនទៀង តែដូចជារបស់ទៀង

បុច្ឆាមិ តំ នាគរាជេតមត្ថំ
កថំ នុ តេ លទ្ធមិទំ វិមានំ ។
អធិច្ច លទ្ធំ បរិណាមជន្តេ
សយំ កតំ ឧទាហុ ទេវេហិ ទិន្នំ
អក្ខា មេ នាគរាជេតមត្ថំ
យថេវ តេ លទ្ធមិទំ វិមានំ ។
(១៧៦) នាធិច្ច លទ្ធំ ន បរិណាមជម្មេ
ន សយំ កតំ នាបិ ទេវេហិ ទិន្នំ
សកេហិ កម្មេហិ អបាបកេហិ
បុញ្ញេហិ មេ លទ្ធមិទំ វិមានំ ។
(១៧៧) កិំ តេ វតំ កិំ បន ព្រហ្មចរិយំ
កិស្ស សុចិណ្ណស្ស អយំ វិបាកោ
ឥទ្ធី ជុតី ពលវីរិយូបបត្តិ
ឥទញ្ច តេ នាគ មហាវិមានំ ។
(១៧៨) អហញ្ច ភរិយា ច មនុស្សលោកេ
សទ្ធា ឧភោ ទានបតី អហុម្ហា
ឱបានភូតំ មេ ឃរំ តទាសិ
សន្តប្បិតា សមណព្រាហ្មណា ច ។



បពិត្រនាគរាជ ខ្ញុំព្រះអង្គសូមសួរសេចក្តីនុះ នឹងព្រះអង្គថា វិមាននេះព្រះអង្គបានហើយដោយប្រការដូចម្តេច ? វិមាននេះ ព្រះអង្គបានព្រោះអាស្រ័យ (កកតាន) ឬកើតអំពីផ្លូវប្រែប្រួល ឬព្រះអង្គកសាងដោយព្រះអង្គឯង ឬមួយទេវតាឲ្យ បពិត្រនាគរាជ វិមាននេះព្រះអង្គបានហើយដោយប្រការណា សូមព្រះអង្គប្រាប់សេចក្តីនុះដល់ខ្ញុំព្រះអង្គ ដោយប្រការដូច្នោះ ។
(១៧៦) (នាគរាជ...) វិមាន (នេះ) មិនមែនខ្ញុំបាន ព្រោះអាស្រ័យ (កកតាន) មិនមែនកើតអំពីផ្លូវប្រែប្រួល មិនមែនខ្ញុំធ្វើខ្លួនឯង ទាំងមិនមែនទេវតាឲ្យទេ វិមាននេះខ្ញុំបាន ដោយបុញ្ញកម្ម មិនអាក្រក់របស់ខ្លួន ។
(១៧៧) (មហាសត្វ...) អ្វីជាវត្តរបស់ព្រះអង្គ អ្វីជាព្រហ្មចរិយៈរបស់ព្រះអង្គ បពិត្រនាគ ឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាមនឹងការកើត (ក្នុងភពនាគ) ទាំងវិមានធំរបស់ព្រះអង្គនេះ នេះជាផលនៃកម្មដែលព្រះអង្គសន្សំល្អហើយ ដូចម្តេច ?
(១៧៨) (នាគរាជ...) ខ្ញុំនឹងភរិយា ទាំងពីរនាក់ (កាលនៅ)ក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំ ដូចជាអណ្តូង (នៃមហាជន) ទាំងពួកសមណៈ នឹងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់

មាលញ្ច គន្ធញ្ច វិលេបនញ្ច
បទីបិយំ សេយ្យមុបស្សយញ្ច
អច្ឆាទនំ សាយនមន្នបានំ
សក្កច្ច ទានានិ អទម្ហ តត្ថ ។
តំ មេ វតំ តម្បន ព្រហ្មចរិយំ
តស្ស សុចិណ្ណស្ស អយំ វិបាកោ
ឥទ្ធី ជុតី ពលវីរិយូបបត្តិ
ឥទញ្ច មេ ធីរ មហាវិមានំ ។
(១៧៩) ឯវញ្ចេ លទ្ធមិទំ វិមានំ
ជានាសិ បុញ្ញានំ ផលូបបត្តិំ
តស្មា ហិ ធម្មំ ចរ អប្បមត្តោ
យថា វិមានំ បុន មាវសេសិ ។
(១៨០) នយិធ សន្តិ សមណព្រាហ្មណា ច
យេសន្នបានានិ ទទេមុ កត្តេ
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ
យថា វិមានំ បុន មាវសេម ។
(១៨១) ភោគី ហិ តេ សន្តិ ឥធូបបន្នា
បុត្តា ច ទារា អនុជីវិនោ ច





ខ្ញុំ(កាលនៅ) ក្នុងកាលមនុស្សជាតិនោះ បានឲ្យទានដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក ។ នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ នែអ្នកប្រាជ្ញ ឫទ្ធិ សេចក្តីរុងរឿង កំឡាំងកាយ សេចក្តីព្យាយាម និងការកើត (ក្នុងឋាន) ទាំងវិមានក៏របស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ ។

(១៧៩) (មហាសត្វ...) បើវិមាននេះ ព្រះអង្គបានហើយយ៉ាងនេះ ឈ្មោះថា ព្រះអង្គជ្រាបកំណើត នៃផលរបស់បុណ្យ ព្រោះហេតុនោះ ព្រះអង្គកុំប្រមាទ សូមប្រព្រឹត្តធម៌ ជាហេតុឲ្យបានត្រឡប់ត្រងវិមាននេះ តទៅទៀត ។

(១៨០) (នាគរាជ...) នែបណ្ឌិតជាអាមាត្យ ខ្ញុំគប្បីឲ្យបាយនិងទឹកដល់ពួកសមណៈនិងព្រាហ្មណ៍ណា ពួកសមណៈនិងព្រាហ្មណ៍នោះ មិនមានក្នុងនាគភពនេះទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុះ ដែលជាហេតុឲ្យខ្ញុំទៅត្រឡប់ត្រងវិមានតទៅ ។

(១៨១) (មហាសត្វ...) ពួកនាគ គឺបុត្រ ភរិយា និងអ្នកអាស្រ័យនៅ ដោយសារ ដែលចូលមកកើត ក្នុងនាគភពនេះ

តេសុ ត្វំ វចសា កម្មុនា ច
អសម្បទុដ្ឋោ ច ភវាហិ និច្ចំ ។
ឯវំ ត្វំ នាគ អសម្បទោសំ
អនុបាលយ វចសា កម្មុនា ច
ឋត្វា ឥធ យាវតាយុកំ វិមានេ
ឧទ្ធំ ឥតោ គច្ឆសិ ទេវលោកំ ។

(១៨៦) អទ្ធា ហិ សោ សោចតិ រាជសេដ្ឋោ
តយា វិនា យស្ស តុវំ សជិច្ចោ
ទុក្ខូបនីតោបិ តយា សមេច្ច
វិន្ទេយ្យ បោសោ សុខមាតុរោបិ ។

(១៨៧) អទ្ធា សតំ ភាសសិ នាគ ធម្មំ
អនុត្តរំ អត្ថបទំ សុចិណ្ណំ
ឯតាទិសិយាសុ ហិ អាបទាសុ
បញ្ញាយតេ មាទិសានំ វិសេសោ ។

(១៨៨) អក្ខាហិ នោ តាយំ មុធា នុ លទ្ធោ
អក្ខេហិ នោ តាយំ អជេសិ ជូតេ
ធម្មេន លទ្ធោ ឥតិ តាយមាហ
កថំ នុ ត្វំ ហត្ថមិមស្ស មាគតោ ។





សូមព្រះអង្គជាអ្នកមិនប្រទូស្ត កុំប្រទូស្តនាគនោះ ដោយពាក្យ ឬដោយកាយវិការ អស់កាលជានិច្ច ។ បពិត្រនាគ សូមព្រះអង្គ ក្រោយសេចក្ដីមិនប្រទូស្តដោយពាក្យឬដោយកាយវិការហើយនេះចុះ ព្រះអង្គនឹងឋិតនៅក្នុងវិមាននេះ រហូតអស់ព្រះជន្មាយុ ហើយ នឹងបានទៅកាន់ទេវលោក ជាន់ខាងលើ អំពីភពនាគនេះ ។

(១៨៦) (នាគរាជ...) អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជានឹង ប្រសើរនោះ បើរៀរចាកអ្នកហើយ រមែងសោកស្ដាយ ដោយពិត បុរសលុះត្រាសេចក្ដីទុក្ខគ្របសង្កត់ ឬឈឺ មានជម្ងឺធ្ងន់ បើបានជួបនឹងអ្នកហើយ ក៏នឹងបានសុខវិញ ។

(១៨៧) (មហាសត្វ...) បពិត្រនាគ ព្រះអង្គពោលធម៌របស់សប្បុរសជាធម៌ប្រសើរ ជាចំណែកនៃប្រយោជន៍ដែលសមគួរ ដោយពិត ជាសេចក្ដីវិសេសរបស់បណ្ឌិតទាំងឡាយ បែបខ្ញុំ ព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ ។

(១៨៨) (នាគរាជ...) អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ បាននូវអ្នកមកដោយទទេ អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ ឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្សនេះ បាននិយាយថា បណ្ឌិតនេះបាននាំមកដោយធម៌ តើអ្នកមកនៅក្នុងកណ្ដាប់ដៃនៃបុណ្ណកយក្សនេះ ដោយប្រការដូចម្ដេច ។

(១៨៥) យោ មិស្សរោ តត្ថ អហោសិ រាជា

តមាយមក្ខេហិ អជេសិ ជូតេ

សោ មំ ជិតោ រាជា ឥមស្សទាសិ

ធម្មេន លទ្ធោស្មិ អសាហសេន ។

(១៨៦) មហោរគោ អត្តមនោ ឧទគ្គោ

សុត្វាន ធីរស្ស សុភាសិតានិ

ហត្ថេ គហេត្វាន អនោមបញ្ញំ

បាវេក្ខិ ភរិយាយ តទា សកាសេ ។

យេន ត្វំ វិមលេ បណ្ឌុ យេន ភត្តំ ន រុច្ចតិ

ន ច មេ តាទិសោ វណ្ណោ អយមេសោ តមោនុទោ ។

យស្ស តេ ហទយេនត្ថោ អាគតាយំ បភង្ករោ

តស្ស វាក្យំ និសាមេហិ ទុល្លភំ ទស្សនំ បុន ។



(១៨៥)(មហាសត្វ...) ព្រះរាជារបស់ខ្ញុំព្រះអង្គណា ជាធំក្នុងក្រុងឥន្ទបត្ត ដែលក្រុងនោះ បុណ្ណកយក្សនេះ បានឈ្នះល្បែងភ្នាល់នឹងព្រះរាជា នោះដោយការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះ បានប្រទានខ្ញុំព្រះអង្គ ដល់បុណ្ណកយក្សនេះ បុណ្ណកយក្សឈ្មោះ ថាបានខ្ញុំព្រះអង្គមកដោយធម៌ មិនមែនដោយការកំហែងទេ ។

(១៨៦) (អភិសម្ពុទ្ធគាថា) នាគដ៏ប្រសើរ មានចិត្តត្រេកអរពេកក្រៃ ហើយ ព្រោះបានស្ដាប់សុភាសិតនៃវិធុរបណ្ឌិត ជាអ្នកប្រាជ្ញ ក៏ចាប់ដៃវិធុរបណ្ឌិតមានប្រាជ្ញាមិនថោកទាប នាំចូលទៅក្នុង សំណាក់នៃនាងវិមលាជាភរិយា ក្នុងកាលនោះ (ក្រាបទូលថា) ម្នាលនាងវិមលា នាងមានសម្បុរស្លៀង ដោយហេតុណា ម្ហូបមិន ឆ្ងាញ់ពិសា ដោយហេតុណា ពណ៌ (នៃវិធុរបណ្ឌិត) បែបនេះ មិន មាន(ដល់នាង) ដោយហេតុនោះទេ វិធុរបណ្ឌិតនេះឯង ជាអ្នក បន្ទោបង់នូវងងឹត ។ នាងមានសេចក្តីត្រេកអរដោយហឫទ័យរបស់ វិធុរបណ្ឌិតណា វិធុរបណ្ឌិតនេះ ជាអ្នកធ្វើពន្លឺ មកដល់ហើយ នាង ចូរស្ដាប់ ពាក្យរបស់វិធុរបណ្ឌិតនោះចុះ (ព្រោះ) ការ ជួបប្រទះ (នូវវិធុរបណ្ឌិត) ទៀត ជាកិច្ចបានដោយកម្រ ។

(១៨៧) ទិស្វាន តំ វិមលា ភូរិបញ្ញំ
ទសង្គុលី អញ្ជលឹ បគ្គហេត្វា
ហដ្ឋេន ភាវេន បតីតរូបា
ឥច្ចព្រវិ កុរូនំ កត្តុសេដ្ឋំ ។
អទិដ្ឋបុព្វំ ទិស្វាន មច្ចោ មច្ចុភយដ្ដិតោ
ព្យម្ហិតោ នាភិវាទេសិ ន ឥទំ បញ្ញវតាមិវ ។

(១៨៨) ន ចម្ហិ ព្យម្ហិតោ នាគិ ន ច មច្ចុភយដ្ដិតោ
ន វជ្ឈោ អភិវាទេយ្យ វជ្ឈំ វា នាភិវាទយេ ។
កថំ នុ អភិវាទេយ្យ អភិវាទាបយេថ វេ
យំ នរោ ហន្តុមិច្ឆេយ្យ តំ កម្មំ នុបបជ្ជតិ ។

(១៨៩) ឯវមេតំ យថា ព្រូសិ សច្ចំ ភាសសិ បណ្ឌិត
ន វជ្ឈោ អភិវាទេយ្យ វជ្ឈំ វា នាភិវាទយេ ។
កថំ នុ អភិវាទេយ្យ អភិវាទាបយេថ វេ
យំ នរោ ហន្តុមិច្ឆេយ្យ តំ កម្មំ នុបបជ្ជតិ ។



(១៨៧) ព្រះនាងវិមលាទ្រង់ទតឃើញវិធុរបណ្ឌិត ដែលជាអ្នកមានប្រាជ្ញាក្រាស់ដូចផែនដីនោះ ក៏មានព្រះទ័យត្រេកអរសោមនស្ស ទ្រង់លើកប្រាមដៃទាំង ១០ ផ្គងអញ្ជលី ហើយក្រាស់ចំពោះវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ យ៉ាងនេះថា អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុត ព្រោះឃើញភពនៃនាគ ដែលខ្លួនមិនធ្លាប់ឃើញ ទើបមិនថ្វាយបង្គំ(ខ្ញុំ) ដំណើរនេះ ដូចមិនមែនជាការរបស់បុគ្គលមានប្រាជ្ញាទេ ។

(១៨៨) (មហាសត្វ...) បពិត្រព្រះនាងនាគី ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យគ្របសង្កត់ទេ អ្នកទោសដែលត្រូវគេសំឡាប់ មិនគប្បីថ្វាយបង្គំ (គេផ្សេងទៀត) ម្នាក់ផ្សេងទៀតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសំឡាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណា គប្បីថ្វាយបង្គំ (អ្នកនោះ) ឬឲ្យ (អ្នកនោះ) ថ្វាយបង្គំ (ខ្លួន) ដូចម្ដេចកើត កម្មនោះមិនកើតជាទេ ។

(១៨៩) (ព្រះនាងវិមលា...) ម្នាលបណ្ឌិត ដំណើរនុ៎ះ ដូចអ្នកពោលមែន អ្នកពោលពាក្យពិត អ្នកទោសដែលត្រូវគេសំឡាប់ មិនគប្បីថ្វាយបង្គំគេផ្សេងទៀត ឬគេផ្សេងទៀតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសំឡាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ(អ្នកនោះ) ឬឲ្យ (អ្នកនោះ) ថ្វាយបង្គំ(ខ្លួន) ដូចម្ដេចកើត កម្មនោះមិនកើតទេ ។

(១៤០) អសស្សតំ សស្សតំ នុ តវយិទំ វិមានំ
ឥទ្ធី ជុតី ពលវីរិយូបបត្តិ
បុច្ឆាមិ តំ នាគកញ្ញេតមត្ថំ
កថំ នុ តេ លទ្ធមិទំ វិមានំ ។
អធិច្ច លទ្ធំ បរិណាមជន្តេ
សយំ កតំ ឧទាហុ ទេវេហិ ទិន្នំ
អក្ខាហិ មេ នាគកញ្ញេតមត្ថំ
យថេវ តេ លទ្ធមិទំ វិមានំ ។

(១៤១) នាធិច្ច លទ្ធំ ន បរិណាមជម្មេ
ន សយំ កតំ នាបិ ទេវេហិ ទិន្នំ
សកេហិ កម្មេហិ អបាបកេហិ
បុញ្ញេហិ មេ លទ្ធមិទំ វិមានំ ។

(១៤២) កិន្តេ វតំ កិំ បន ព្រហ្មចរិយំ
កិស្ស សុចិណ្ណស្ស អយំ វិបាកោ
ឥទ្ធី ជុតី ពលវីរិយូបបត្តិ
ឥទញ្ច តេ នាគិ មហាវិមានំ ។





(១៤០) (មហាសត្វ...) វិមាននេះ ទាំងឫទ្ធិ សេចក្តីរុងរឿង សេចក្តីព្យាយាម និងការកើតក្នុងភពនាគរបស់ព្រះនាង មិនទៀង តែដូចជារបស់ទៀង បពិត្រនាគកញ្ញា ខ្ញុំព្រះអង្គសួរសេចក្តីនុះ នឹងព្រះនាងថា វិមាននេះ ព្រះនាងបានហើយដោយប្រការដូចម្តេច វិមានដែលព្រះនាងបាន ព្រោះអាស្រ័យ (ភពនាគ) ឬកើតអំពីផ្លាស់ប្រែប្រួល ឬព្រះនាងធ្វើខ្លួនឯង ឬមួយទេវតាឲ្យ បពិត្រនាគកញ្ញា វិមាននេះ ព្រះនាងបានហើយដោយប្រការណា សូមព្រះនាងប្រាប់សេចក្តីនុះដល់ខ្ញុំ ដោយប្រការនោះ ។

(១៤១) (ព្រះនាងវិមលា...) វិមាននេះមិនមែនខ្ញុំបាន ព្រោះអាស្រ័យភពនាគ មិនមែនកើតអំពីផ្លាស់ប្រែប្រួល មិនមែនធ្វើខ្លួនឯង តាំងមិនមែនទេវតាឲ្យទេ វិមាននេះ ខ្ញុំបានដោយបុញ្ញកម្ម មិនអាក្រក់ ជារបស់ខ្លួន ។

(១៤២) មហាសត្វ...) អ្វីជាវត្ត អ្វីជាព្រហ្មចរិយៈរបស់ព្រះនាង បពិត្រព្រះនាងនាគី ឫទ្ធិ អំណាច សេចក្តីរុងរឿងកំឡាំងកាយ សេចក្តីព្យាយាម និងការកើត(ក្នុងភពនាគ) ទាំងវិមានធំរបស់ព្រះនាងនេះ នេះជាផលនៃកម្ម ដែលព្រះនាងសន្សំល្អហើយដូចម្តេច ។

(១៨៣) អហញ្ច ខោ សាមិកោ ចាបិ មយ្ហំ
សទ្ធា ឧភោ ទានបតី អហុម្ហា
ឱបានភូតំ មេ ឃរំ តទាសិ
សន្តប្បិតា សមណព្រាហ្មណា ច ។
មាលញ្ច គន្ធញ្ច វិលេបនញ្ច
បទីបិយំ សេយ្យមុបស្សយញ្ច
អច្ឆាទនំ សាយនមន្នបានំ
សក្កច្ច ទានានិ អទម្ហ តត្ថ ។
តំ មេ វតំ តម្បនព្រហ្មចរិយំ
តស្ស សុចិណ្ណស្ស អយំ វិបាកោ
ឥទ្ធី ជុតី ពលវីរិយូបបត្តិ
ឥទញ្ច មេ ធីរ មហាវិមានំ ។
(១៨៤) បីតញ្ច តេ លទ្ធមិទំ វិមានំ
ជានាសិ បុញ្ញានំ ផលូបបត្តិំ
តស្មាហិ ធម្មញ្ចរ អប្បមត្តា
យថា វិមានំ បុន មាវសេសិ
(១៨៥) នយិធ សន្តិ សមណព្រាហ្មណា ច
យេសន្នបានានិ អទេមុ បុព្វេ



(១៨៣) (ព្រះនាងវិមលា...) ខ្ញុំនឹងស្វាមីទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាម្ចាស់ទាន ផ្ទះរបស់ខ្ញុំដូចអណ្តូងទឹកជាទីចុះផឹកនៃ (មហាជន) ទាំងសមណព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ៗ ខ្ញុំ (កាលនៅ) ក្នុងកាលចម្បានគរនោះ បានឲ្យទានដោយគោរព គឺផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយនឹងទឹក ៗ នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ នៃអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្តីរុងរឿង កំឡាំងកាយ សេចក្តីព្យាយាម នឹងការកើត (ក្នុងឋាននេះ) ទាំងវិមានធំរបស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ ៗ

(១៨៤) (មហាសត្វ...) វិមាននេះ គឺព្រះនាងបានហើយយ៉ាងនេះ ឈ្មោះថា ព្រះនាងប្រាប់ចកំណើត នៃផលរបស់បុណ្យទាំងឡាយ ព្រោះហេតុនោះ ព្រះនាងកុំប្រហែស សូមប្រព្រឹត្តធម៌ ជាហេតុឲ្យបានគ្រប់គ្រងវិមាននេះតទៅ ៗ

(១៨៥) (ព្រះនាងវិមលា...) នែបណ្ឌិត ជាអាមាត្យ ខ្ញុំនឹងឲ្យបាយនឹងទឹក ដល់ពួកសមណៈនឹងព្រាហ្មណ៍ណា ពួកសមណៈនឹងព្រាហ្មណ៍ (ទាំងនោះ) មិនមានក្នុងកាលនេះទេ

អក្ខាហិ មេ បុដ្ឋោ ឯតមត្ថំ
យថា វិមានំ បុន មាវសេម ។

(១៨៦) ញាតី ហិ តេ សន្តិ ឥធប្បភូតា
បុត្តា ច សាមី អនុជីវិនោ ច
តេសុ តុវំ វចសា កម្មុនា ច
អសម្បទុដ្ឋា ច ភវាហិ និច្ចំ ។
ឯវំ តុវំ នាគិ អសម្បទោសំ
អនុបាលយ វចសា កម្មុនា ច
ឋត្វា ឥធ យាវតាយុកំ វិមានេ
ឧទ្ធំ ឥតោ គច្ឆសិ ទេវលោកំ ។

(១៨៧) អទ្ធា ហិ សោ សោចតិ រាជសេដ្ឋោ
តយា វិនា យស្ស តុវំ សជិព្វោ
ទុក្ខូបនីតោបិ តយា សមេច្ច
វិន្ទេយ្យ បោសោ សុខមាតុរោបិ ។

(១៨៨) អទ្ធា សតំ ភាសសិ នាគិ ធម្មំ
អនុត្តរំ អត្ថបទំ សុចិណ្ណំ
ឯតាទិសិយាសុ ហិ អាបទាសុ
បញ្ញាយតេ មាទិសានំ វិសេសោ ។



ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ ដែលជាហេតុឲ្យខ្ញុំ នៅគ្រប់គ្រងវិមានតទៅ ។

(១៨៦) (មហាសត្វ...) ពួកញាតិក្តី បុត្រ ស្វាមី និងអ្នករស់នៅដោយសារ ដែលកើតមានក្នុងភពនាគនេះ សូមព្រះនាងជាអ្នកមិនប្រទូស្តក្នុងពួកញាតិនោះ ដោយពាក្យ ឬដោយការគិត អស់កាលជានិច្ច ។ បពិត្រព្រះនាងនាគី សូមព្រះនាងរក្សាសេចក្តីមិនប្រទូស្ត ដោយពាក្យ ឬដោយការគិតយ៉ាងនេះចុះ ព្រះនាងនឹងឋិតនៅក្នុងវិមាននេះ រហូតអស់ជន្មាយុ ហើយនឹងបានទៅកាន់ទេវលោក ជាន់ខាងលើ អំពីភពនាគនេះ ។

(១៨៧) (ព្រះនាងវិមលា...) អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើវៀរចាកអ្នកហើយ រមែងសោកស្តាយដោយពិត បុរសសូម្បីត្រូវសេចក្តីទុក្ខគ្របសង្កត់ ឬសូម្បីមានជម្ងឺធ្ងន់ បើបានជួបនឹងអ្នកហើយ ក៏នឹងបានសុខវិញ ។

(១៨៨) (មហាសត្វ...) បពិត្រព្រះនាងនាគី ព្រះនាងពោលធម៌របស់សប្បុរស ជាធម៌ប្រសើរ ជាបទដែលនាំប្រយោជន៍ ដែលសន្សំល្អដោយពិត ឯសេចក្តីវិសេសរបស់បណ្ឌិតទាំងឡាយ បែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ ។

(៥៩៩) អក្ខាហិ នោ តាយំ មុទ្ធាធុលទ្ធោ
អក្ខាហិ នោ តាយំ អជេសិ ជូតេ
ធម្មេន លទ្ធោ ឥតិតាយមាហ
កថំ ត្វំ ហត្ថមិមស្សមាគតោ ។

(៦០០) យោ មិស្សកេ តត្ថ អហោសិ រាជា
តមាយមក្ខេហិ អជេសិ ជូតេ
សោ មំ ជិតោ រាជា ឥមស្សទាសិ
ធម្មេន លទ្ធោស្មិ អសាហសេន ។

(៦០១) យថេវ វរុណោ នាគោ បញ្ហំ បុច្ឆតិ បណ្ឌិតំ
តថេវ នាគកញ្ញាបិ បញ្ហំ បុច្ឆតិ បណ្ឌិតំ ។
យថេវ វរុណំ នាគំ ធីរោ តោសេសិ បុច្ឆិតោ
តថេវ នាគកញ្ញម្បិ ធីរោ តោសេសិ បុច្ឆិតោ ។



(៥៩៩) (ព្រះនាងវិមលា...) អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្ស នេះបានអ្នកមក ដោយទ្រព្យ អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ ឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្ស នេះបាននិយាយថា បណ្ឌិតខ្ញុំបានមកដោយធម៌ តើអ្នកមក នៅក្នុងកណ្ដាប់ដៃបុណ្ណកយក្សនេះ ដោយប្រការដូចម្ដេច ។

(៦០០) (មហាសត្វ...) ព្រះរាជាដែលខ្ញុំព្រះអង្គណា ជាធំក្នុងក្រុងឥន្ទ-បត្ត ដែលក្រុងនោះ បុណ្ណកយក្សនេះ បានឈ្នះល្បែងភ្នាល់នឹង ព្រះរាជានោះ ដោយការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្ស ឈ្នះហើយនោះ បានប្រគល់ខ្ញុំព្រះអង្គដល់បុណ្ណកយក្សនេះ ឯបុណ្ណកយក្ស ឈ្មោះថាបានខ្ញុំព្រះអង្គដោយធម៌ មិនមែន ដោយកំហែងទេ ។

(៦០១) (អភិសម្ពុទ្ធគាថា) វរុណនាគបានសួរប្រស្នានឹងវិធុរបណ្ឌិត យ៉ាងណា ព្រះនាងនាគកញ្ញា ក៏បានសួរប្រស្នានឹងវិធុរបណ្ឌិត យ៉ាងនោះដែរ ។ វិធុរបណ្ឌិត ជាអ្នកប្រាជ្ញ ដែលវរុណនាគ ត្រាស់សួរហើយ ក៏បានញុំាងវរុណនាគឲ្យត្រេកអរ យ៉ាងណា វិធុរបណ្ឌិត ជាអ្នកប្រាជ្ញ ដែលព្រះនាងនាគកញ្ញាសួរហើយ ក៏បានញុំាងព្រះនាងនាគកញ្ញា ឲ្យត្រេកអរ យ៉ាងនោះដែរ ។

ឧបោចិ តេ អត្ថបទេ វិចិត្តា
មហោរគំ នាគកញ្ញា ជិនេ
អច្ឆម្ភី អភីតោ អលោមហដ្ឋោ
ឥច្ចព្រវិ វណ្ណំ នាគរាជំ ។
មា ពេធយិ[1] នាគ អយោមហស្ស
យេន ករេ អត្ថា ឥតិ សរី
ហទយេន មំសេន ករោហិ កិច្ចំ
សយំ ករិស្សាមិ យថាមតិន្តេ ។

(២០២) បញ្ញា ហវេ[2] ហទយំ បណ្ឌិតានំ
តេ ត្យស្សុ បញ្ញាយ មយំ សុតុដ្ឋា
អនូននាមោ លភតជ្ជ ទារំ
អជ្ជេវ តំ កុរុយោ បាបយាតុ ។

(២០៣) ស បុណ្ណកោ អត្តមនោ ឧទគ្គោ
ឥរន្ធតឹ នាគកញ្ញំ លភិត្វា
ហដ្ឋេន ភាវេន បតីតរូបោ
ឥច្ចព្រវិ កុរូនំ កត្តុសេដ្ឋំ ។

---

១ ម. មា ហេឋយិ ។ អដ្ឋកថាយំ មា ហេឋយិ ។ ២ ម. បញ្ញា ភវេ ។



វិធុរបណ្ឌិត ជាអ្នកប្រាជ្ញ លុះដឹងច្បាស់ថានាគរាជពីប្រសើរ នឹងនាងនាគកញ្ញា តាំងពីព្រះអង្គនោះ នាងត្រូវចិត្តរើសយកហើយ ក៏មិនតក់ស្លុត មិនខ្លាច មិនព្រឺរោម បានទូលវរុណនាគរាជនូវថា បពិត្រនាគ ព្រះអង្គកុំខ្វល់ឡើយ ខ្ញុំនេះហើយជាសេចក្ដីត្រូវការរបស់ព្រះអង្គ នេះសីរៈ សូមព្រះអង្គធ្វើកិច្ចដោយសាច់ហ្ឫទ័យចុះ ខ្ញុំនឹងធ្វើតាមអធ្យាស្រ័យរបស់ព្រះអង្គដោយខ្លួនឯង ។

(២០២) (នាគរាជ...) បញ្ញាហ្នឹងឯង ជាដួងហ្ឫទ័យរបស់បណ្ឌិតទាំងឡាយ យើងទាំងនោះត្រេកអរក្រៃលែង ដោយប្រាជ្ញារបស់អ្នក យក្សមានឈ្មោះមិនថោកទាប គឺបុណ្ណកៈ ចូរបានភរិយាក្នុងថ្ងៃនេះចុះ ចូរញុំាងអ្នកឲ្យទៅដល់ដែនកុរុ ក្នុងថ្ងៃនេះចុះ ។

(២០៣) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្សនោះ មានចិត្តត្រេកអររីករាយ ព្រោះបាននាងនាគកញ្ញា ឈ្មោះឥរន្ធតី មានចិត្តត្រេកអរសប្បាយហើយ បាននិយាយនឹងវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើរ របស់អ្នកដែនកុរុ ដូច្នេះថា

ភរិយាយ មំ ត្វំ អករិ សមង្គិំ
អហញ្ច តេ វិធុរ ករោមិ កិច្ចំ
ឥទញ្ច តេ មណិរតនំ ទទាមិ
អជ្ជេវ តំ កុរុយោ បាបយាមិ ។

[២០៦] អវេយ្យមេសា តវ ហោតុ មិត្តិ
ភរិយាយ កច្ចាន បិយាយ សទ្ធឹ
អានន្ទចិត្តា សុមនា បតីតា
ទត្វា មណឹ មញ្ច នយិន្ទបត្តំ ។

[២០៧] ស បុណ្ណកោ កុរូនំ កត្តុសេដ្ឋំ
និសីទយិ បុរតោ អាសនស្មឹ
អាជញ្ញមារុយ្ហ មនោមវណ្ណំ
បក្កាមិ វេហាយសមន្តលិក្ខេ ។
មនោ មនុស្សស្ស យថាបិ គច្ឆេ
តតោបិស្ស ខិប្បតរំ អហោសិ
ស បុណ្ណកោ កុរូនំ កត្តុសេដ្ឋំ
ឧបានយិ នគរំ ឥន្ទបត្តំ[១] ។

---

១ ម. អានយិ កត្តារមនោមបញ្ញំ ឧបានយិ នគរំ ឥន្ទបត្តំ ។



អ្នកធ្វើខ្ញុំឲ្យបានព្រមព្រៀងដោយភរិយា បពិត្រវិធុរបណ្ឌិត ខ្ញុំសូមធ្វើកិច្ច (តបគុណ) ដល់អ្នក ខ្ញុំនឹងឲ្យកែវមណីនេះដល់អ្នក ចាំនឹងនាំអ្នកឲ្យដល់ដែនកុរុ ក្នុងថ្ងៃនេះឯង ។

(២០៦) (មហាសត្វ...) ម្នាលកច្ចានៈ មេត្រីជាគុណជាតិ គឺបុគ្គលផ្ចាញ់មិនបាននេះ ចូរមានដល់អ្នក ព្រមទាំងភរិយាជាទីស្រឡាញ់ អ្នកមានចិត្តត្រេកអរចុះទៅ មានចិត្តល្អ មានចិត្តរីករាយឡើង ឲ្យមណីដល់ខ្ញុំហើយ ចូរនាំខ្ញុំទៅកាន់ឥន្ទបត្តនគរចុះ ។

(២០៧) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្សនោះ ឡើងនឹងសេះអាជានេយ្យមានវណ្ណៈមិនថោកទាប ហើយអញ្ជើញវិធុរបណ្ឌិតជាអាចារ្យដ៏ប្រសើររបស់ពួកអ្នកដែនកុរុ ឲ្យអង្គុយលើអាសនៈអំពីខាងមុខ ហោះទៅឰដ៏អាកាសវេហា ។ ចិត្តរបស់មនុស្សរមែងស្ទុះទៅ (កាន់អារម្មណ៍ក្នុងទីឆ្ងាយ) យ៉ាងណា ដំណើរសេះរបស់សេះអាជានេយ្យនោះ ក៏ឆាប់រហ័សក្រៃលែងជាងចិត្តនោះ ក៏យ៉ាងនោះដែរ បុណ្ណកយក្សនោះ នាំវិធុរបណ្ឌិតជាអាចារ្យដ៏ប្រសើររបស់អ្នកដែនកុរុ ទៅកាន់ឥន្ទបត្តនគរ ។

(៦០៦) បវិទ្ធបត្តំ[១] ឧគ្គំ បធិស្សុតំ

វេឡានិ ច អមត្តកានិ ការកោសោ

អហញ្ញ កាយាយ សមន្តកូតោ

តុរញ្ញ បក្កាសិ សកំ និកេតំ ។

(៦០៧) ស បុណ្ណកោ កុរូនំ កត្តុសេដ្ឋំ

ឱរោបយិត្វា ធម្មសភាយ មជ្ឈេ

អាជញ្ញមារុយ្ហ អនោមវណ្ណោ

បក្កាមិ វេហាយសមន្តលិក្ខេ ។

តំ ទិស្វា រាជា បរមប្បតីតោ

ឧដ្ឋាយ ពាហាហិ បលិស្សជិត្វា

អវិកម្បយំ ធម្មសភាយ មជ្ឈេ

និសីទយិ បមុខេ អាសនស្មិំ ។

(៦០៨) ត្វំ នោ វិនេតាសិ រថំវ នទ្ធំ

នន្ទន្តិ តំ កុរុយោ ទស្សនេន

អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ

កថំ បមោក្ខោ អហុ មាណវស្ស ។

---

១ ឱ. វិហិទ្ធបត្តំ ។



(៦០៦) (បុណ្ណកយក្ស...) ទ្រង់គ្រឿងឥន្ទបត្ត ដែលឃើញច្បាស់ ទ្រង់វៃព្រហ្វាយ គួរជាទីគាប់យកជាយចំណែក ខ្ញុំក៏បានព្រមព្រៀង ដោយកាយា ចាំងអ្នកក៏បានមកដល់ទីលំនៅរបស់ខ្លួន ។

(៦០៧) (អភិសម្ពុទ្ធគាថា) បុណ្ណកយក្សនោះ ញុំាងវិធុរបណ្ឌិតជា អាមាត្យដ៏ប្រសើររបស់ពួកអ្នកដែនកុរុ ឲ្យចុះក្នុងកណ្តាលធម្មសភា ហើយឡើងជិះសេះអាជានេយ្យ ជាអ្នកមានវណ្ណៈមិនថោកថយ ហោះទៅក្នុងអាកាសវេហា ។ ព្រះរាជាទត ឃើញមហាសត្វនោះហើយ ព្រះអង្គមានព្រះហឫទ័យសោមនស្សរីក្រៃលែង ទ្រង់ក្រោកឡើងយកព្រះពាហុស្រវាឱប ទ្រង់មិនបានឲ្យកំរើក ហើយអញ្ជើញព្រះមហាសត្វឲ្យគង់លើអាសនៈក្នុងកណ្តាលធម្មសភា ចំពោះព្រះភក្ត្រ ។

(៦០៨) (ព្រះរាជា...) អ្នកជាអ្នកណែនាំយើង ដូចនាយសារថី នាំយករថដែលបាក់ទៅ (មកវិញ) អ្នកដែនកុរុទាំងឡាយ ត្រេកអរ ព្រោះបានឃើញអ្នក ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ អ្នករួចផុតពីមាណព ដោយប្រការដូចម្តេច ។

(៦០៩) យំ មាណវោ ត្យាភិវទិ ជនិន្ទ
ន សោ មនុស្សោ នរិន្ទសេដ្ឋ
យទិ តេ សុតោ បុណ្ណកោ នាម យក្ខោ
រញ្ញោ កុវេរស្ស ហិ សោ សជិព្វោ ។
ភូមិន្ធរោ វរុណោ នាម នាគោ
ព្រហា សុចី វណ្ណពលូបបន្នោ
តស្សានុជំ ធីតរំ កាមយានោ
ឥរន្ទតី នាម សា នាគកញ្ញា ។
តស្សា សុមជ្ឈាយ បិយាយ ហេតុ
បតារយិត្ថ មរណាយ មយ្ហំ
សោ ចេវ ភរិយាយ សមង្គិភូតោ
អហញ្ចានុញ្ញាតោ មណិ ច លទ្ធោ ។
(៦១០) ទុមោ ហិ មយ្ហំ ឃរទ្វារេ ជាតោ
បញ្ញាក្ខន្ធោ សីលមយស្ស សាខា
អត្ថេ ច ធម្មេ ច ឋិតោ និបាកោ
គវប្ផលោ ហត្ថិគវស្សុបន្នោ ។



(៦០៩) (មាណវោ...) បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រ-សើរជាងជន ព្រះអង្គត្រាស់ហៅបុរសណាថាមាណព បុរសនោះមិនមែនជាមនុស្សទេ គឺជាយក្ស ឈ្មោះបុណ្ណកៈ ព្រះអង្គក៏ធ្លាប់បានឮមកហើយ បុណ្ណកយក្សនោះជាក្មួយនៃព្រះបាទកុវេរៈ មានស្តេចនាគមួយឈ្មោះវរុណៈ ទ្រង់ទ្រទ្រង់ផែនដី មានទំហំនឹងកំពស់ស្អាត បរិបូណ៌ដោយពណ៌សម្បុរនឹងកំឡាំង បុណ្ណកយក្សនោះ ចង់បាននាងជាប្អូនជាកូននៃវរុណនាគនោះ (ធ្វើជាប្រពន្ធ) នាងនាគកញ្ញានោះឈ្មោះឥរន្ទតី ។ បុណ្ណកយក្ស ព្យាយាមដើម្បីសំឡាប់ខ្ញុំព្រះអង្គ ព្រោះហេតុនៃនាងឥរន្ទតីនោះ មានចង្កេះល្អជាទីស្រឡាញ់ផងវរុណៈ បុណ្ណកយក្សនោះ បានព្រមព្រៀងដោយភរិយា ចំណែកខ្ញុំព្រះអង្គ ក៏បុណ្ណកយក្សអនុញ្ញាតហើយ ទាំងកែវមណី ខ្ញុំព្រះអង្គក៏បានហើយ ។

(៦១០) (ព្រះករុណា...) ដើមឈើដុះទៀបទ្វារដំណាក់របស់ខ្ញុំមានដើមសម្រេចដោយប្រាជ្ញា មែករបស់ឈើនោះសម្រេចដោយសីល ដើមឈើ(នោះ) សម្រេចដោយប្រាជ្ញាខ្ជាប់ខ្ជួន តាំងនៅក្នុងអត្ថនិងធម៌ មានផ្លែជាបញ្ចគោរស ដេរដាសដោយដំរីគោនិងសេះ

ឆេត្វាគត្រិយាកិតាជាតេ
ឧទ្ធិជ្ជ សេតិ បុរិសោ អហោសិ
សោ ទោ អយំ អាគតោ សន្តិកេតំ
រុក្ខស្សិមស្សាបចិតិំ ករោថ ។
យេ កេចិ វិត្តា មម បច្ចយេន
សព្វេ តេ បាតុករោន្តុ អជ្ជ
តិព្វានិ កត្វាន ឧបាយនានិ
រុក្ខស្សិមស្សាបចិតិំ ករោថ ។
យេ កេចិ ពន្ធា មម អត្ថិ រដ្ឋេ
សព្វេ តេ ពន្ធា មោចយន្តុ
យថេវយំ ពន្ធនស្មា បមុត្តោ
ឯវមេតេ មុញ្ចរេ ពន្ធនស្មា ។
ឧណ្ណង្គលា មាសមិមំ ករោន្តុ
មំសោទនំ ព្រាហ្មណា ភក្ខយន្តុ
អមជ្ជបា មជ្ជរហា បិវន្តុ
បុណ្ណាហិ ថាលាហិ បលិស្សុតាហិ ។





កាលដើមឈើនោះ ត្រូវគេដោយការកាប់ ការស្រៀង និងកន្ត្រៃ បុរស (ម្នាក់) កាត់ដើមឈើនោះ ហើយញ៉ាំងសេនា(ឲ្យទៅទៅ) បណ្ឌិតនេះទុកដូចជាដើមឈើរបស់យើងនោះ មកកាន់លំនៅរបស់ខ្លួនវិញហើយ អ្នកទាំងឡាយ ចូរធ្វើសេចក្ដីគោរពក្រែងដើមឈើនេះ ។ ជនទាំងឡាយណានីមួយ មានចិត្តត្រេកអរ (ដោយយស) ព្រោះបច្ច័យនៃយើង ពួកជនទាំងអស់នោះ ចូរធ្វើ (ចិត្តរបស់ខ្លួន) ឲ្យប្រាកដក្នុងថ្ងៃនេះចុះ អ្នកទាំងឡាយធ្វើបណ្ណាការឲ្យច្រើន ចូរធ្វើសេចក្ដីគោរពក្រែងដល់ដើមឈើនេះចុះ ។ ពួកសត្វណានីមួយ ដែលគេចងទុកក្នុងដែនរបស់យើង ពួកសត្វទាំងអស់នោះចូរឲ្យរួចចាកចំណង វិធុរបណ្ឌិតនេះរួចចាកចំណងយ៉ាងណា ពួកសត្វទាំងនុ៎ះ គប្បីរួចចាកចំណងយ៉ាងនោះ ។ ចូរពួកប្រជាជនទុកដាក់នង្គ័ល ធ្វើ(មហាស្រព)អស់មួយខែនេះចុះ ពួកព្រាហ្មណ៍ចូរបរិភោគបាយលាយដោយសាច់ ពួកអ្នកមិនផឹកទឹកស្រវឹងគួរផឹកទឹកស្រវឹង ចូរផឹកដោយភាជនៈដ៏ពេញហូរហៀរ ។

មហាបថំ និច្ច សមវ្ហយន្តុ
ភិក្ខញ្ច ទេន្តុ វិទហន្តុ រដ្ឋេ
យថាញ្ញមញ្ញំ ន វិហេឋយេយ្យុំ
វុត្តាសមស្សា បជតិ តាភេជ ។

(២១១) ឥត្ថិយោ ច កុមារា ច វេសិយានា ច ព្រាហ្មណា
ពហុំ អន្នញ្ច បានញ្ច បណ្ឌិតស្សាភិហារយុំ ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
ពហុំ អន្នញ្ច បានញ្ច បណ្ឌិតស្សាភិហារយុំ ។
សមាគតា ជានបទា នេគមា ច សមាគតា
ពហុំ អន្នញ្ច បានញ្ច បណ្ឌិតស្សាភិហារយុំ ។
ពហុជ្ជនោ បសន្នោសិ ទិស្វា បណ្ឌិតមាគតំ
បណ្ឌិតម្ហិ អនុប្បត្តេ ចេលុក្ខេបោ បវត្តថាតិ ។

វិធុរជាតកំ នវមំ ។

---

## វេស្សន្តរជាតកំ

(២១២) ផុស្សតី វរវណ្ណាភេ វរស្សុ ទសធា វរេ
បថព្យា ចារុបុព្វង្គី យំ តុយ្ហំ មនសោ បិយំ ។



ស្រីរាល់សព្វកាលទាំងឡាយ (គាស្រ័យ) ផ្លូវធំ ចូរហៅគេចុះសម្អក ក្រៅការអស់កាលជានិច្ចចុះ មួយទៀត ពួកចុះសព្វទាំងឡាយ ចូរបាត់បែនការក្បា ឱ្យនាំមួនក្នុងដែន កុំឲ្យពួកមនុស្សបៀតបៀនគ្នានឹងគ្នា អ្នកទាំងឡាយចូរធ្វើសេចក្តីគោរពក្រែងចំពោះជើងឈើនេះ ។

(២១១) ពួកស្ត្រី ពួកកុមារ ពួកអ្នកជំនួញនឹងពួកព្រាហ្មណ៍ នាំយកបាយនឹងទឹកជាច្រើន មកជូនចំពោះបណ្ឌិត ។ ពលដំរី (ពលសេះ) ពលរថ ពលថ្មើរជើង នាំយកបាយនឹងទឹកជាច្រើន មកជូនចំពោះបណ្ឌិត ។ ពួកអ្នកជនបទមកជួបជុំគ្នា ពួកអ្នកនិគមមកជួបជុំគ្នា នាំយកបាយនឹងទឹកជាច្រើន មកជូនចំពោះបណ្ឌិត ។ ប្រជាជនជាច្រើន ជាអ្នកមានចិត្តជ្រះថ្លា ព្រោះឃើញបណ្ឌិត មកដល់ហើយ កាលបណ្ឌិតមកដល់ ការលើកទង់ក៏ប្រព្រឹត្តទៅ ។

ចប់ វិធុរជាតក ទី ៩ ។

---

## វេស្សន្តរជាតក

(២១២) (ព្រះឥន្ទ្រទ្រង់ត្រាស់ថា) ម្នាលនាងផុស្សតី ដ៏មានពន្លឺនៃសម្បុរដ៏ប្រសើរ មានអវយវៈខាងដើមដ៏ល្អ នាងចូរទទួលពរ ១០ ប្រការ លើផែនដី ដែលជាទីគាប់ចិត្តរបស់នាង ។

(២១៣) ទេវរាជ នមោ ត្យត្ថុ  កឹ បាបំ បកតំ មយា
រម្មា ចាវេសិ មំ ឋានា  វាតោវ ធរណីរុហំ ។

(២១៦) ន ចេវ តេ កតំ បាបំ  ន ច មេ ត្វមសិ អប្បិយា
បុញ្ញញ្ច តេ បរិក្ខីណំ  យេន តេវំ វទាមហំ ។
សន្តិកេ មរណំ តុយ្ហំ  វិនាភាវោ ភវិស្សតិ
បដិគ្គណ្ហាហិ មេ ផុស្សេ  វរេ ទស បវេច្ឆតោ ។

(២១៨) វរញ្ចេ មេ អទោ សក្ក  សព្វភូតានមិស្សរ
សិវិរាជស្ស ភទ្ទន្តេ  តត្ថ អស្សំ និវេសនេ ។
នីលនេត្តា នីលភមូ  នីលក្ខី យថា មិគី
ផុស្សតី នាម នាមេន  តត្ថ អស្សំ បុរិន្ទទ ។
បុត្តំ លភេថ វរទំ  យាចយោគំ អមច្ឆរិំ
បូជិតំ បដិរាជូហិ  កិត្តិមន្តំ យសស្សិនំ ។





(៦១៣) (នាងផុស្សតីទេវធីតាក្រាបបង្គំទូលថា) បពិត្រទេវរាជ ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះអង្គ ចុះខ្ញុំម្ចាស់បានធ្វើអំពើអាក្រក់ដូចម្ដេច បានជាព្រះអង្គមកញ៉ាំងខ្ញុំម្ចាស់ឲ្យឃ្លាតចាករមណីយដ្ឋាន ដូចជាខ្យល់ដែលបក់រំលើងដើមឈើដូច្នោះ ។

(៦១៦) (ព្រះឥន្ទ្រ...) នាងឯងបានធ្វើអំពើអាក្រក់ទេ មួយទៀត នាងមិនមែនជាទីស្អប់នៃខ្ញុំទេ តែថានាងអស់បុណ្យហើយ បានជាខ្ញុំនិយាយនឹងនាងយ៉ាងនេះ ។ នាងមានសេចក្ដីស្លាប់កៀកជិតណាស់ហើយ មុខជានឹងមានសេចក្ដីព្រាត់ប្រាស កាលបើខ្ញុំឲ្យពរ ១០ ប្រការនេះ នាងចូរទទួលយកចុះ ។

(៦១៨) (នាងផុស្សតី...) បពិត្រសក្កទេវរាជដ៏ចំរើន ជាឥស្សរៈលើពួកទេវតាទាំងអស់ បើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមឲ្យបាននៅ ក្នុងព្រះរាជនិវេសន៍ នៃព្រះបាទសិវិរាជនោះ ១ សូមឲ្យមាននេត្រាខៀវ ដូចជាកូនម្រឹគញីមានភ្នែកខៀវ ១ សូមឲ្យមានចិញ្ចើមខៀវ ១ បពិត្រព្រះអង្គទ្រង់បានបំពេញទានក្នុងកាលមុន ខ្ញុំម្ចាស់ទៅកើត ក្នុងព្រះរាជនិវេសន៍នោះ សូមឲ្យមានឈ្មោះថាផុស្សតី (ដូចដើម) សូមឲ្យបានបុត្រដ៏ប្រសើរ ដែលចូលចិត្តឲ្យទាន ជាអ្នកគួរដល់ស្មូម មិនមានសេចក្ដីកំណាញ់ ជាបុគ្គលដែលព្រះរាជាប្រទេសដទៃបូជា ជាអ្នកមានកេរ្តិ៍ឈ្មោះ មានយស ១ ។

គព្ភំ មេ ធារយន្តិយា / មជ្ឈិមង្គំ អនុណ្ណតំ
កុច្ឆិ អនុណ្ណតោ អស្ស / ចាបំវ លិខិតំ សមំ ។
ថនា មេ នប្បតេយ្យុំ / បលិតា ន សន្តុ វាសវ
កាយេ រជោ ន លិម្បេថ / វជ្ឈញ្ចាបិ បមោចយេ ។
មយូរកោញ្ចាភិរុទេ / នារីវរគណាយុតេ
ខុជ្ជចេលាបកាកិណ្ណេ / សូតមាគធវណ្ណិតេ[១]
ចិត្រគ្គឡេរុឃុសិតេ / សុរាមំសបពោធនេ
សិវិរាជស្ស ភវនេ / មហេសី បិយា ។
[៦១៦] យេ តេ ទស វរា ទិន្នា / មយា សព្វង្គសោភនេ
សិវិរាជស្ស វិជិតេ / សព្វេ តេ លច្ឆសី វរេ ។
[៦១៧] ឥទំ វត្វាន មឃវា / ទេវរាជា សុជម្បតិ
ផុស្សតិយា វរំ ទត្វា / អនុមោទិត្ថ វាសវោ ។

ទសវរកថា ឋនា ។

---

១ ម. សូទមាគធវណ្ណិតេ ។



កាលខ្ញុំម្ចាស់ទ្រទ្រង់គភ៌ សូមកុំឲ្យមានពោះប៉ោងឡើង ដូចជាធ្នូ ដែលគេសិតស្មើល្អហើយ ១ ។ បពិត្រព្រះវាសវៈ ខ្ញុំម្ចាស់សូមកុំឲ្យមានដោះយារធ្លាក់ ១ សក់ខ្ញុំម្ចាស់សូមកុំឲ្យមានស្កូវ ១ ខ្ញុំម្ចាស់សូមកុំឲ្យធូលីជាប់លើកាយ ១ ខ្ញុំម្ចាស់សូមដោះលែងទោសដែលមានកំហុសគួរគេសម្លាប់ ១ ។ បពិត្រទេវរាជដ៏ចំរើន ខ្ញុំម្ចាស់សូមឲ្យបានជាអគ្គមហេសីជាទីស្រឡាញ់ នៃព្រះបាទសិវិក្នុងព្រះរាជនិវេសន៍នោះ ដែលជាទីកងរំពង ដោយសំឡេងក្ងោកនិងក្រៀល ប្រកបដោយពួកនាងនារីដ៏ប្រសើរ ដេរដាសដោយមនុស្សគមនិងមនុស្សតឿ ជាព្រះរាជនិវេសន៍ដែលពួកអ្នកសូត្រៈ និងពួកអ្នកមាគធៈ សរសើរហើយ ដ៏កងរំពងដោយសំឡេងនៃសន្ទះទ្វារបន្ទះដ៏វិចិត្រ ដែលជាទីមានពួកជនដាស់គ្នាឲ្យផឹកសុរានិងឲ្យបរិភោគសាច់ ។

(៦១៦) (ព្រះឥន្ទ្រ...) ម្នាលនាងមានអវយវៈទាំងអស់ដ៏ល្អ ពរ ១០ ប្រការណា ដែលខ្ញុំឲ្យដល់នាងហើយ នាងនឹងបានពរទាំងអស់នោះក្នុងដែននៃព្រះបាទសិវិ ។

(៦១៧) (អភិសម្ពុទ្ធគាថា) ព្រះមឃវាៈទេវរាជ សុជម្បតិ ពោលៈ លុះទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ ក៏ប្រទានពរ ដល់ព្រះនាងផុស្សតី ហើយក៏មានព្រះហឫទ័យរីករាយ ។

ចប់ គាថាទសពរ ។

[៦០៨] តតោ ចុតា សា ផុស្សតី ខត្តិយេ ឧបបជ្ជថ

ជេតុត្តរម្ហិ នគរេ សញ្ជយេន សមាគមី ។

ទស មាសេ ធារយិត្វា ករោន្តី បុរំ បទក្ខិណំ

វេស្សានំ វីថិយា មជ្ឈេ ជនេសិ ផុស្សតី មមំ ។

ន មយ្ហំ មត្តិកំ នាមំ នបិ បេត្តិកសម្ភវំ

ជាតេត្ថ វេស្សវីថិយា តស្មា វេស្សន្តរោ អហុំ ។

យទាហំ ទារកោ ហោមិ ជាតិយា អដ្ឋវស្សិកោ

តទា និសជ្ជ បាសាទេ ទានំ ទាតុំ វិចិន្តយឹ

ហទយំ ទទេយ្យំ ចក្ខុំ មំសម្បិ រុធិរម្បិ ច

ទទេយ្យំ កាយំ សាវេត្វា យទិ កោចិ យាចយេ មមំ ។

សភាវំ ចិន្តយន្តស្ស អកម្បិតមសណ្ឋិតំ

អកម្បិ តត្ថ បថវី សិនេរុវនវដំសកា ។

[៦០៩] បរូឡ្ហកច្ឆនខលោមា បង្កទន្តា រជស្សិរា

បគ្គយ្ហ ទក្ខិណំ ពាហុំ កឹ មំ យាចន្តិ ព្រាហ្មណា ។





[៦០៨] (អភិសម្ពុទ្ធគាថា) ទាំងផុស្សតីទេវីការនោះ ច្យុតចាកទេវលោក នោះមកហើយ ក៏ទៅកើតក្នុងខត្តិយត្រកូល បានទៅរួមនឹងព្រះបាទសញ្ជ័យក្នុងនគរជេតុត្តរ ។ ព្រះនាងទេវីទ្រង់ព្រះនាមផុស្សតី ទ្រង់គភ៌អស់ ១០ ខែ ក៏ធ្វើប្រទក្សិណព្រះនគរបុរី រួចប្រសូតអាត្មាអញ ក្នុងកណ្ដាលផ្លូវនៃពួកឈ្មួញ ។ នាមអាត្មាអញមិនមែនជារបស់មាតា ទាំងមិនមែនកើតមកពីបិតាទេ អាត្មាអញកើតក្នុង (កណ្ដាល) ផ្លូវនៃពួកឈ្មួញ ព្រោះហេតុនោះ បានជាអាត្មាអញឈ្មោះវេស្សន្តរ ។ កាលដែលអាត្មាអញនៅក្មេងតូច ទើបនឹងមានអាយុ ៨ ឆ្នាំអំពីកំណើត អាត្មាអញបានអង្គុយលើប្រាសាទ រំពឹងគិតនឹងឲ្យទានថា បើមានស្មូមណាមួយ មកបន្ទាល់សុំអាត្មាអញ ។ គួរឲ្យបេះដូង គួរឲ្យភ្នែក គួរឲ្យសាច់ គួរឲ្យឈាម គួរឲ្យកាយ (ដល់ស្មូមនោះឯង) ។ កាលអាត្មាអញនោះ កំពុងគិតសភាវធម៌ដែលមិនកម្រើក មិនតាំងនៅក្នុងកាលនោះ ប្រថពីមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ក៏ កក្រើកញាប់ញ័រ ។

[៦០៩] (ព្រះបាទវេស្សន្តរ...) ពួកព្រាហ្មណ៍មានរោមភ្នែកនិងក្រចក ដុះវែង មានធ្មេញប្រឡាក់ដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលី ផ្គងដើមដៃខាងស្ដាំ តើសុំអ្វីនឹងអញ ។

(៦៦០) តវំ ចេវ យាចាម សិវីនំ រដ្ឋវឌ្ឍន

ទទាហិ បវរំ នាគំ ឦសាទន្តំ ឧរូឡ្ហវំ ។

(៦៦១) ទទាមិ ន វិកម្បាមិ យំ មំ យាចន្តិ ព្រាហ្មណា

បភិន្នំ កុញ្ជរំ ទន្តិំ ឱបវុយ្ហំ(១) គជុត្តមំ ។

(៦៦២) ហត្ថិក្ខន្ធតោ ឱរុយ្ហ រាជា ចាគាធិមានសោ

ព្រាហ្មណានំ អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោ ។

(៦៦៣) តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ

ហត្ថិនាគេ បទិន្នម្ហិ មេទនី សម្បកម្បថ ។

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ

ហត្ថិនាគេ បទិន្នម្ហិ ខុភិត្ថ នគរំ តទា ។

សមាកុលំ បុរំ អាសិ ឃោសោ ច វិបុលោ មហា

ហត្ថិនាគេ បទិន្នម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។

(៦៦៤) អថេត្ថ វត្តតិ សទ្ទោ តុមុលោ ភេរវោ មហា

ហត្ថិនាគេ បទិន្នម្ហិ ខុភិត្ថ នគរំ តទា ។

---

១ ម. ឧបវយ្ហំ ។



(៦៦០) (ពួកព្រាហ្មណ៍...) បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះបង្គំសូមហត្ថិ-រតន៍ ដែលញុំាងដែនដីនៃពួកអ្នកសិវិរដ្ឋឲ្យចំរើន សូមព្រះអង្គ ទ្រង់ប្រទានដំរីដ៏ប្រសើរ ដែលមានភ្លុកដ៏វែង គង់ញាំញីសត្រូវបាន ។

(៦៦១) (ព្រះបាទវេស្សន្តរ...) ព្រាហ្មណ៍ទាំងឡាយ សុំដំរីណានឹងអញ ដំរីចុះប្រេង ជាកុញ្ជរជាតិ មានភ្លុកដ៏ល្អ ជាដំរីប្រសើរ គួរជាពាហនៈ អញនឹងឲ្យ (ដំរីនោះ) អញមិនញាប់ញ័រទេ ។

(៦៦២) (អភិសម្ពុទ្ធគាថា) ព្រះរាជាដែលជាអ្នកញុំាងពួកអ្នកសិវិរដ្ឋឲ្យចំរើន ទ្រង់មានព្រះហឫទ័យប្រាថ្នាយ៉ាងលើសលុបក្នុងការបរិច្ចាគ ទ្រង់ចុះចាកកនៃដំរី រួចទ្រង់ប្រទាន(ដំរី)ជាទានដល់ពួកព្រាហ្មណ៍ ។

(៦៦៣) កាលដែលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ផែនដីក៏កក្រើកញាប់ញ័រ ការកើតហេតុគួរខ្លាច គួរព្រឺរោម ក៏មានក្នុងកាលនោះ ។ កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ការកើតហេតុគួរខ្លាច គួរព្រឺរោម ក៏មានក្នុងកាលនោះ នគរក៏ជ្រួលជ្រើមក្នុងកាលនោះ ។ កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ដែលជាអ្នកញុំាងពួកអ្នកសិវិរដ្ឋឲ្យចំរើន នគរក៏ជ្រួលច្របល់ ទាំងសំឡេងក៏គឹកកងរំពងខ្លាំង ។

(៦៦៤) កាលព្រះរាជា ទ្រង់ប្រទាន នូវដំរីដ៏ប្រសើរ គ្រានោះ សំឡេង យ៉ាងខ្លាំងគឹកកង ជាសំឡេងគួរខ្លាច ក៏ប្រព្រឹត្តទៅក្នុងនគរនោះ ក្នុងកាលនោះ នគរក៏ជ្រួលជ្រើម ។

អថេត្ថ វត្តតិ សទ្ទោ តុមុលោ ភេរវោ មហា
ហត្ថិនាគេ បទិន្នម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។

(៦៦៨) ខត្តិយា ច រាជបុត្តា ច វេស្សាយនា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
កេវលោ ចាបិ និគមោ សិវយោ ចាបិ សមាគតា
ទិស្វា នាគំ និយ្យមានំ តេ រញ្ញោ បដិវេទយុំ ។
វិធមំ ទេវ តេ រដ្ឋំ បុត្តោ វេស្សន្តរោ តវ
កថំ នោ ហត្ថិនំ ទជ្ជា នាគំ រដ្ឋស្ស បូជិតំ ។
កថំ នោ កុញ្ជរំ ទជ្ជា ឦសាទន្តំ ឧរូឡ្ហវំ
ខេត្តញ្ញុំ សព្វយុទ្ធានំ សព្វសេតំ គជុត្តមំ ។
បណ្ឌុកម្ពលសញ្ឆន្នំ បភិន្នំ សត្តុមទ្ទនំ
ទន្តិំ សវាលវីជនិំ សេតំ កេលាសសាទិសំ ។
សសេតច្ឆត្តំ សឧបាធេយ្យំ សាថព្វនំ សហត្ថិបំ
អគ្គយានំ រាជវាហិំ ព្រាហ្មណានំ អទា ធនំ[១] ។

១ ម. គជំ ។



កាលព្រះរាជាទ្រង់ប្រទានដំរីប្រសើរ ជាដំរីញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យចំរើន គ្រានោះ សម្លេងយ៉ាងខ្លាំងក្តងក្តឹក គួរខ្លាច ព្រឺក្បាល កក្រើកនគរនោះ ។

(៦៦៨). ពួកជនអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ ពួកព្រាហ្មណ៍ ពួកពលហាត់ដំរី ពលហាត់ (សេះ) ពលហាត់រថ និងពលថ្មើរជើង អ្នកនិគមទាំងអស់ និងពួកអ្នកសិវិរដ្ឋ ក៏មកប្រជុំគ្នា ពួកជនទាំងនោះបានឃើញដំរី ដែលពួកព្រាហ្មណ៍កំពុងនាំទៅ ក៏ក្រាបទូលចំពោះព្រះរាជា (ទ្រង់ព្រះនាមសញ្ជ័យ) ថា បពិត្រព្រះសម្មតិទេព ដែនរបស់ព្រះអង្គសាបសូន្យហើយ ព្រះវេស្សន្តរជាព្រះរាជបុត្តរបស់ព្រះអង្គ ម្តេចក៏ប្រទានដំរីប្រសើររបស់យើង ជាដំរីដែលអ្នកដែនបូជាហើយ ម្តេចក៏ប្រទានដំរីកុញ្ជររបស់យើង ដែលជាដំរីមានភ្លុក-ដ៏ខ្លាំ ដាបញ៉ាំញីសត្រូវបាន ជាសត្វស្គាល់ទ្រង់ចម្បាំងទាំងអស់ ជាដំរីដ៏ឧត្តម សសុទ្ធ ។ ដំរីនោះមានខ្នងពាសដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេង ញ៉ាំញីសត្រូវបាន មានភ្លុកដ៏ល្អ ប្រកបដោយផ្លិត ជាដំរី-ស ប្រៀបដូចនឹងភ្នំកៃលាស ។ ព្រះរាជបុត្តរបស់ព្រះអង្គ បានប្រទានដំរី រាជវាហនៈ ជាយានដ៏ប្រសើរ ព្រមទាំងស្វេតច្ឆត្រ ព្រមទាំងគ្រឿងលម្អសម្រាប់ក្រោយខ្នង ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សាដំរី ទៅជាទានដល់ពួកព្រាហ្មណ៍ ។

[៦៦៦] អដ្ឋិ តាបញ្ញសោ ឧដ្ឋា វត្តសេតាសតាតិ ច

បតិតោ ដាឋបដិរូបំ បតិតោ ព្រាហ្មណាហិ។

អយំ តេ វិសកជាតោ សិវីនំ រដ្ឋវឌ្ឍនោ

កថំ វេស្សន្តរោ បុត្តោ គជំ ភាជេតិ សញ្ជយ។

សចេ[១] តុំ ន ករិស្សសិ សិវីនំ វចនំ ឥទំ

មញ្ញេ តំ សហ បុត្តេន សិវីហត្ថេ ករិស្សរេ ។

[៦៦៧] កាមំ ជនបទោ មាសិ រដ្ឋញ្ចាបិ វិនស្សតុ

នាហំ សិវីនំ វចនា រាជបុត្តំ អទូសកំ

បព្វាជេយ្យំ សកា រដ្ឋា បុត្តោ ហិ មម ឱរសោ។

កាមំ ជនបទោ មាសិ រដ្ឋញ្ចាបិ វិនស្សតុ

នាហំ សិវីនំ វចនា រាជបុត្តំ អទូសកំ

បព្វាជេយ្យំ សកា រដ្ឋា បុត្តោ ហិ មម អត្រជោ។

ន ចាហំ តស្មិំ ទុព្ភេយ្យំ អរិយសីលវតោ ហិ សោ

---

១ ឧ. សចេ ។



[៦៦៦] ព្រះរាជបុត្ររបស់ព្រះអង្គនោះ គួរតែឲ្យញាយចំណែកចាក់ចិនសេតា-
សន: (ព្រោះថា) តែឆ្នូនឯងជារបស់ពួកជល់ពាន តែឆ្នូនឯងជា
របស់ពួកផល់ព្រាហ្មណ៍ ។ បពិត្រព្រះបាទសញ្ជ័យ ព្រះវេស្សន្តរ
ជាបុត្ររបស់ព្រះអង្គនេះ ជាព្រះអង្គកើតក្នុងវង្សរបស់ព្រះអង្គ ជា
អ្នកញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យចំរើន ម្ដេចក៏ចែកដំរីទៅឲ្យព្រាហ្មណ៍ ។
ជាបើព្រះអង្គ មិនធ្វើតាមសំដីរបស់ពួកអ្នកដែនសិវិនេះទេ ខ្ញុំ
ជាពួកអ្នកសិវិរដ្ឋ ធ្វើព្រះអង្គព្រមទាំងព្រះរាជបុត្រ ឲ្យឋិតនៅក្នុង
កណ្ដាប់ដៃមិនខាន ។

[៦៦៧] (ព្រះរាជា...) ជនបទសាបសូន្យទៅចុះ ទាំងដែនទៀតក៏វិនាស
ទៅចុះ យើងនឹងមិនបណ្ដេញរាជបុត្រ ដែលជាអ្នកមិនប្រទូស្ត
ឲ្យចេញចាកដែនរបស់ខ្លួន តាមសំដីពួកអ្នកសិវិរដ្ឋទេ ព្រោះកូន
ប្រុសនេះ គឺកជាកើតអំពីទ្រូង របស់យើង ។ ជនបទសាបសូន្យ
ទៅចុះ ទាំងដែនទៀតក៏វិនាសទៅចុះ យើងនឹងមិនបណ្ដេញ
រាជបុត្រ ដែលជាអ្នកមិនប្រទូស្ត ឲ្យចេញចាកដែនរបស់ខ្លួនតាម
សំដីពួកអ្នកសិវិរដ្ឋទេ ព្រោះកូនប្រុសនេះ គឺកជាកើតអំពីខ្លួន
របស់យើង ។ មួយទៀត យើងមិនគួរប្រទូស្តចំពោះកូនយើង
នោះទេ ព្រោះថា កូនយើងនោះជាអ្នកមានសីលនឹងវត្តដ៏ប្រសើរ

អេសោ ចេ ភោគោ ច មេ អស្ស   អបុញ្ញំ បសវេ ពហុំ
កាមំ វេស្សន្តរំ បុត្តំ   សត្ថេន ឃាតយាមសេ ។
(៦៦៨) មា នំ ទណ្ឌេន សត្ថេន   ន ហិ សោ វជ្ឈតារហោ
បព្វាជេថ ច នំ រដ្ឋា   វង្កេ វសតុ បព្វតេ ។
(៦៦៩) យិ សោ ចេ សិវីនំ ឆន្ទោ   ឆន្ទំ ន បនុទាមសេ
ឥមំ សោ វសតុ រត្តឹ   កាមេ ច បរិភុញ្ជតុ ។
តតោ រត្យា វិវសានេ   សុរិយស្សុគ្គមនំ បតិ(១)
សមគ្គា សិវយោ ហុត្វា   រដ្ឋា បព្វាជយន្តុ នំ ។
(៦៧០) ឧដ្ឋេហិ កត្តេ តរមានោ   គន្ត្វា វេស្សន្តរំ វទ
សិវយោ ទេវ តេ កុទ្ធា   នេគមា ច សមាគតា
ឧគ្គា ច រាជបុត្តា ច   វេសិយានា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា   រថិកា បត្តិការកា
កេវលោ ចាបិ និគមោ   សិវយោ ចាបិ សមាគតា
អស្មា រត្យា វិវសានេ   សុរិយស្សុគ្គមនំ បតិ

១ ម. សុរិយុគ្គមនំ បតិ ។



ដំណោះដំឡៀលនឹងមានដល់យើងផង យើងត្រូវសាយបាបច្រើនផង យើងនឹងសម្លាប់វេស្សន្តរជាកូនដោយគ្រឿងសស្ត្រាវុធឲ្យម្តងបាន ។

(៦៦៨) (ពួកអ្នកដែន...) សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រនោះដោយដំបង ឬគ្រឿងសស្ត្រាឡើយ ព្រោះព្រះរាជបុត្រនោះមិនគួរដល់ចំណាត់ទេ ព្រះអង្គគ្រាន់តែបណ្តេញព្រះរាជបុត្រនោះ ចេញអំពីដែនទៅចុះ សូមឲ្យព្រះរាជបុត្រនោះទៅគង់នៅឯវង្កបព៌តចុះ ។

(៦៦៩) (ព្រះរាជា...) ជាបើពួកអ្នកដែនសិវី មានចំណង់បែបនេះហើយ យើងក៏មិនកាចបន្ទោបង់ចំណង់នេះបានទេ តែសូមឲ្យកូនយើងនោះនៅបរិភោគកាមបានមួយរាត្រីនេះសិនចុះ ។ លុះកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យរះឡើង ទើបសូមឲ្យពួកអ្នកសិវិរដ្ឋ ព្រមព្រៀងគ្នាបណ្តេញកូនរបស់យើងនោះ ចេញអំពីដែនចុះ ។

(៦៧០) នែកាមាត្យ អ្នកចូរក្រោកឡើង អ្នកចូរប្រញាប់ទៅប្រាប់វេស្សន្តរ ថា បពិត្រព្រះទេវៈ ពួកអ្នកសិវិរដ្ឋ ពួកអ្នកនិគម ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្រ ពួកអ្នកជំនួញនឹងពួកព្រាហ្មណ៍ មកប្រជុំគ្នា ទឹងនឹងព្រះអង្គហើយ ។ ពួកពលហាត់ដំរី ពលហាត់ (សេះ) ពលហាត់រថ នឹងពលថ្មើរជើង ពួកអ្នកនិគមទាំងអស់ នឹងពួកអ្នកសិវិរដ្ឋ ក៏មកប្រជុំគ្នាដែរ លុះរាត្រីនេះអស់ហើយ ព្រះអាទិត្យរះឡើង

សមគ្គា សិវិយោ ហុត្វា    រដ្ឋា បព្វាជយន្តិ តំ ។

[៦៣១] ស កត្តា តរមានោវ    សិវិរាជេន បេសិតោ
អាមុត្តហត្ថាភរណោ    សុវត្ថោ ចន្ទនភូសិតោ
សីសំ ន្ហាតោ ឧទកេ សោ    អាមុត្តមណិកុណ្ឌលោ
ឧបាគមិ បុរំ រម្មំ    វេស្សន្តរនិវេសនំ ។
តត្ថទ្ទស កុមារំ សោ    រមមានំ សកេ បុរេ
បរិកិណ្ណំ អមច្ចេហិ    តិទសានំវ វាសវំ ។

[៦៣២] សោ តត្ថ គន្ត្វា តរមានោ    កត្តា វេស្សន្តរំ ព្រវិ
ទុក្ខន្តេ វេទយិស្សាមិ    មា មេ កុជ្ឈ រថេសភ ។
វន្ទិត្វា រោទមានោ សោ    កត្តា រាជានមព្រវិ
ភត្តា មេសិ មហារាជ    សព្វកាមរសាហរោ
ទុក្ខន្តេ វេទយិស្សាមិ    តត្ថ អស្សាសយន្តុ មំ ។
សិវិយោ ទេវ តេ កុទ្ធា    នេគមា ច សមាគតា
ឧគ្គា ច រាជបុត្តា ច    វេសិយានា ច ព្រាហ្មណា ។



ពួកអ្នកដែនសិវិព្រមព្រៀងគ្នា នឹងបណ្ដេញព្រះអង្គចាកដែន ។

[៦៣១] នាមាត្យនោះលុះព្រះបាទសិវិប្រើបញ្ជូនទៅ ក៏ប្រញាប់ប្រញាល់ងូតទឹកកក់ក្បាល ពាក់គ្រឿងប្រដាប់ដៃ ស្លៀកសំពត់ល្អ ប្រោសព្រំដោយខ្លឹមចន្ទន៍ ពាក់កុណ្ឌលកែវមណី ចូលទៅកាន់ព្រះរាជនិវេសន៍នៃព្រះបាទវេស្សន្តរដែលជាបុរីរម្យ ។ នាមាត្យនោះបានឃើញព្រះរាជកុមារ (វេស្សន្តរ) កំពុងរីករាយក្នុងបុរីរបស់ព្រះអង្គនោះ ដ៏កុះករដោយពួកអាមាត្យ ដូចព្រះឥសូរៈរបស់ទេវតាជាន់ត្រៃត្រិង្ស ។

[៦៣២] នាមាត្យនោះប្រញាប់ប្រញាល់ទៅក្នុងរាជបុរីនោះហើយ ក្រាបទូលព្រះបាទវេស្សន្តរថា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលសេចក្ដីទុក្ខរបស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងទូលព្រះបង្គំជាខ្ញុំឡើយ ។ នាមាត្យនោះលុះថ្វាយបង្គំហើយក៏យំទួញក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ ព្រះអង្គតែងនាំនូវរសជាទីប្រាថ្នាគ្រប់យ៉ាងមកចិញ្ចឹមទូលព្រះបង្គំ ។ នឹងក្រាបទូលសេចក្ដីទុក្ខរបស់ព្រះអង្គ សូមឲ្យអ្នកទូលព្រះបាទ ឲ្យទូលព្រះបង្គំដកដង្ហើមស្រួលក្នុងទីដំណើរក្រោយទូលនោះ ។ បពិត្រព្រះទេវៈ ពួកអ្នកសិវិរដ្ឋ ពួកអ្នកនិគម ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្រ ពួកអ្នកជំនួញ នឹងពួកព្រាហ្មណ៍ ប្រជុំគ្នា ទាំងខឹងព្រះអង្គហើយ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា

កោរលោ ជាតំ និគមោ សិវិយោ ចាបិ សមាគតា ។

អស្សា រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ

សមគ្គា សិវិយោ ហុត្វា រដ្ឋា បព្វាជយន្តិ តំ ។

(២៣៣) កិស្មឹ មេ សិវិយោ កុទ្ធា នាហំ បស្សាមិ ទុក្កដំ

តំ មេ កត្តេ វិយាចិក្ខ កស្មា បព្វាជយន្តិ មំ ។

(២៣៤) ឧគ្គា ច រាជបុត្តា ច វេសិយានា ច ព្រាហ្មណា

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា

នាគទានេន ខីយន្តិ តស្មា បព្វាជយន្តិ តំ ។

(២៣៥) ហទយំ ចក្ខុម្បាហំ ទជ្ជំ កឹ មេ ពាហិរកំ ធនំ

ហិរញ្ញំ វា សុវណ្ណំ វា មុត្តា វេឡុរិយា មណិ

ទក្ខិណំ វាបហំ(១) ពាហុំ ទិស្វា យាចកមាគតេ

ទទេយ្យំ ន វិកម្បេយ្យំ ទានេ មេ រមតី មនោ ។

កាមំ មំ សិវិយោ សព្វេ បព្វាជេន្តុ ហនន្តុ វា

នេវ ទានា វិរមិស្សំ កាមំ ឆិន្ទន្តុ សត្តធា ។

---

១ ម. អទក្ខិណំ វាមហំ ។



ពួកពលហាត់ដំរី ពលហាត់(សេះ) ពលរថនឹងពលថ្មើរជើង ព្រមទាំង អ្នកនិគមទាំងអស់ នឹងពួកអ្នកសិវិរដ្ឋ ក៏មកប្រជុំគ្នាដែរ ។ លុះ កន្លងរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង ពួកអ្នកសិវិរដ្ឋ ព្រម ព្រៀងគ្នានឹងបណ្តេញព្រះអង្គចាកដែន ។

(២៣៣) (ព្រះវេស្សន្តរ...) ព្រោះអំពើដូចម្តេច បានជាពួកអ្នកសិវិរដ្ឋ ទាស់នឹងយើង ដ្បិតយើងកមិនឃើញអំពើអាក្រក់ទេ ម្នាលអាមាត្យ អ្នកចូរប្រាប់អំពើនោះដល់យើង ព្រោះហេតុអ្វីបានជាគេបណ្តេញយើង

(២៣៤) (អាមាត្យ..) ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្រ ពួកអ្នក ជំនួញ ពួកព្រាហ្មណ៍ ពួកពលហាត់ដំរី ពលហាត់(សេះ) ពលរថ នឹងពលថ្មើរជើង ទាស់នឹងព្រះអង្គ ព្រោះតែការប្រទានដំរី ហេតុនោះ បានជាគេបណ្តេញព្រះអង្គ ។

(២៣៥) (ព្រះវេស្សន្តរ..) យើងគប្បីឲ្យបេះដូង ឬភ្នែកក៏បាន ទ្រព្យខាង ក្រៅរបស់យើង គឺប្រាក់ មាស កែវមុក្តា កែវពិទូរ្យ នឹងកែវ មណី ជាប្រយោជន៍អ្វី បើយើងបានឃើញស្មូម មកសុំដៃស្តាំឬដៃ ឆ្វេង គួរតែឲ្យ មិនគប្បីរំកើបទេ (ព្រោះថា) ចិត្តរបស់យើងត្រេកអរ ក្នុងការឲ្យ(ទាន) ។ ពួកអ្នកសិវិរដ្ឋទាំងអស់នោះ ចង់បណ្តេញ ឬចង់សម្លាប់យើងក៏ដោយចុះ យើងនឹងមិនវៀរចាកការឲ្យ(ទាន)ទេ អ្នកផងទាំងអស់ចង់កាត់យើងជាប្រាំពីរកំណាត់ក៏ដោយចុះ ។

(២៣៦) ឯវន្តិ សិវិយោ អាហុ   នេគមា ច សមាគតា
កោន្តិមារាយ តីរេន   គិរិមារញ្ជរំ បតិ
យេន បព្វជិតា យន្តិ   តេន គច្ឆតុ សុព្វតោ ។

(២៣៧) សោហំ តេន គមិស្សាមិ   យេន គច្ឆន្តិ ទូសកា
រត្តិន្ទិវំ មេ ខមថ   យាវ ទានំ ទទាមហំ ។

(២៣៨) អាមន្តយិត្ថ រាជានំ   មទ្ទី សព្វង្គសោភនំ
យំ តេ កិញ្ចិ មយា ទិន្នំ   ធនំ ធញ្ញញ្ច វិជ្ជតិ
ហិរញ្ញំ វា សុវណ្ណំ វា   មុត្តា វេឡុរិយា ពហូ
សព្វន្តំ និទហេយ្យាសិ   យញ្ច តេ បេត្តិកំ ធនំ ។

(២៣៩) តមព្រវិ រាជបុត្តី   មទ្ទី សព្វង្គសោភនា
កុហឹ ទេវ និទហាមិ   តំ មេ អក្ខាហិ បុច្ឆិតោ ។

(២៤០) សីលវន្តេសុ ទជ្ជាសិ   ទានំ មទ្ទិ យថារហំ
ន ហិ ទានា បរំ អត្ថិ   បតិដ្ឋា សព្វបាណិនំ ។



(២៣៦) (អាមាត្យ...) ពួកអ្នកសិវិរដ្ឋ និងពួកអ្នកនិគម ប្រជុំគ្នា និយាយអំពីព្រះអង្គយ៉ាងនេះថា ពួកអ្នកតាបសក្រៅនិងរមេស តែងទៅ តាមច្រាំងទន្លេកោន្តិមារាណា ព្រះបាទវេស្សន្តរដែលមានវត្តល្អ ចូរ យាងសំដៅទៅកាន់ភ្នំគារញ្ជរ តាមច្រាំងទន្លេកោន្តិមារាណានោះចុះ ។

(២៣៧) (ព្រះវេស្សន្តរ...) ពួកជនអ្នកប្រទុស្ត តែងទៅតាមផ្លូវណា យើងនឹងទៅតាមផ្លូវនោះឯង តែសូមឲ្យអ្នកទាំងឡាយអត់ទោសឲ្យ យើងបានមួយយប់មួយថ្ងៃ ទាំងយើងឲ្យទានសិន ។

(២៣៨) ព្រះរាជាទ្រង់ត្រាស់ហៅព្រះនាងមទ្រីទេវី ដែលមានអវយវៈល្អ ទាំងអស់នោះមកប្រាប់ថា ទ្រព្យស្រូវណាមួយដែលយើងឲ្យដល់នាង នៅមានក្ដី ប្រាក់មាសកែវមុក្ដាកែវពិទូរ្យណាដ៏ច្រើនក្ដី ទ្រព្យណា ជារបស់ព្រះបិតានាងក្ដី នាងចូរតំកល់ទ្រព្យទាំងអស់នោះទុកចុះ ។

(២៣៩) ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈល្អទាំងអស់បាន ក្រាបបង្គំទូលសួរព្រះរាជានោះថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់នឹងតំកល់ទុក ទីណា ខ្ញុំម្ចាស់ក្រាបទូលសួរហើយ សូមព្រះអង្គប្រាប់ដំណើរនោះ ។

(២៤០) (ព្រះវេស្សន្តរ...) ម្នាលនាងមទ្រី នាងគួរឲ្យទានដល់ពួកអ្នកមាន សីលទាំងឡាយ តាមសមគួរ ព្រោះថាទីពឹងរបស់សព្វសត្វ ដទៃ ក្រៅអំពីទានមិនមានទេ ។

[៦៦១] បុត្តេសុ មទ្ទិ ទយេសិ សស្សុយា សសុរម្ហិ ច
យោ ច តំ ភត្តា មញ្ញេយ្យ សក្កច្ចំ ឧបដ្ឋហេ ។
នោ ចេ តំ ភត្តា មញ្ញេយ្យ មយា វិប្បវសេន តេ
អញ្ញំ ភត្តារំ បរិយេស មា កិលិត្ថ មយា វិនា ។
[៦៦២] អហំ ហិ វនំ គច្ឆាមិ ឃោរំ វាឡមិគាយុតំ
សំសយោ ជីវិតំ មយ្ហំ ឯកកស្ស ព្រហាវនេ ។
[៦៦៣] តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភនា
អភុម្មេ កថំ នុ ភណសិ បាបកំ វត ភាសសិ ។
នេស ធម្មោ មហារាជ យំ ត្វំ គច្ឆេយ្យ ឯកកោ
អហំបិ តេន គច្ឆាមិ យេន គច្ឆសិ ខត្តិយ ។
មរណំ វា តយា សទ្ធិំ ជីវិតំ វា តយា វិនា
តទេវ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។
អគ្គិំ ឧជ្ជាលយិត្វាន[1] ឯកជាលសមាហិតំ
តត្ថ មេ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។

១ ម. ឧជ្ជាលយិត្វាន ។ ឱ. ឧជ្ជ្វាលយិត្វាន ។



(៦៦១) ម្នាលនាងមទ្រី នាងត្រូវមេត្តាបុត្ត ព្រមទាំងគោរពនឹងព្រះបិតាក្មេក មួយទៀត បើអ្នកណាសំគាល់នាងថាជាប្តីនាង នាងត្រូវបំរើអ្នកនោះ ដោយគោរពចុះ ។ បើគ្មានគេសំគាល់នាងថាជាប្តីនាងទេ កាលនាងព្រាត់ប្រាសអំពីយើងទៅហើយ នាងត្រូវស្វែងរកប្តីដទៃទៀតចុះ កុំឲ្យនាងលំបាក ព្រោះព្រាត់ប្រាសអំពីយើងឡើយ ។
(៦៦២) ព្រោះយើងនឹងទៅកាន់ព្រៃប្រកបដោយម្រឹគសាហាវគួរខ្លាច សេចក្តីសង្ស័យនៃជីវិត រមែងមានដល់យើងដែលនៅម្នាក់ឯងក្នុងព្រៃធំ ។
(៦៦៣) ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី មានអវយវៈល្អគ្រប់អង្គ នាងក្រាបទូលព្រះបាទវេស្សន្តរថា បពិត្រព្រះអង្គមានព្រះបន្ទូលនូវព្រះវាចាដែលមិនធ្លាប់មាន ព្រះអង្គមានព្រះបន្ទូលនូវព្រះវាចាដ៏អាក្រក់ពេកម្ល៉េះ ។ បពិត្រមហារាជ ដំណើរនោះមិនត្រូវតាមធម៌ទេ ដើម្បីព្រះអង្គទ្រង់ស្តេចយាងទៅតែម្នាក់ឯង បពិត្រក្សត្រិយ៍ ព្រះអង្គស្តេចយាងទៅតាមផ្លូវណា ខ្ញុំម្ចាស់នឹងទៅតាមផ្លូវនោះដែរ ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី សេចក្តីរស់នៅតែព្រាត់ប្រាសចាកព្រះអង្គក្តី សេចក្តីស្លាប់នោះឯងប្រសើរជាង ខ្ញុំម្ចាស់រស់នៅតែព្រាត់ប្រាសចាកព្រះអង្គ មិនប្រសើរទេ ។ ខ្ញុំម្ចាស់នឹងដុតភ្លើងឲ្យមានអណ្តាតឆេះរមូលត្រែលោម សេចក្តីស្លាប់នៅក្នុងភ្លើងនោះឯងប្រសើរជាង ខ្ញុំម្ចាស់រស់នៅតែព្រាត់ប្រាសចាកព្រះអង្គ មិនប្រសើរទេ ។

យថា អារញ្ញកំ នាគំ ទន្តិំ អន្វេតិ ហត្ថិនី
ជេស្សន្តំ គិរិទុគ្គេសុ សមេសុ វិសមេសុ ច ។
ឯវំ តំ អនុគច្ឆាមិ បុត្តេ អាទាយ បច្ឆតោ
សុភរា តេ ភវិស្សាមិ ន តេ ហេស្សាមិ ទុព្ភរា ។

(៦៦៦) ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
អាសីនេ វនគុម្ពស្មិំ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
កីឡន្តេ វនគុម្ពស្មិំ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
អស្សមេ រមណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
កីឡន្តេ អស្សមេ រម្មេ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មាលធារី អលង្កតេ
អស្សមេ រមណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មាលធារី អលង្កតេ
កីឡន្តេ អស្សមេ រម្មេ ន រជ្ជស្ស សរិស្សសិ ។



មេដំរី តែងដើរតាមដំរីឈ្មោល ដែលមានភ្លុកល្អ ដែលនៅក្នុងព្រៃ កាលត្រាច់ទៅក្នុងទីជ្រោះ ជ្រលង ភ្នំស្មើរ មិនស្មើរ យ៉ាងណាមិញ ។ ខ្ញុំម្ចាស់នឹងនាំកូនទាំងពីរ ដើរតាមក្រោយព្រះអង្គ យ៉ាងនោះដែរ ខ្ញុំម្ចាស់ជាស្រី ដែលព្រះអង្គចិញ្ចឹមបានដោយងាយ មិនមែនជាស្រី ដែលព្រះអង្គចិញ្ចឹមបានដោយក្រទេ ។

(៦៦៦) ព្រះអង្គកាលទតឃើញកុមារទាំងនេះ ដែលមានសម្តីពីរោះ និយាយសំដីជាទីស្រឡាញ់ អង្គុយក្បែរគុម្ពឈើ នឹងមិនរលឹករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះ មានសម្តីពីរោះ និយាយសំដីជាទីស្រឡាញ់ កំពុងលេងក្បែរគុម្ពឈើ នឹងមិនរលឹករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះ មានសម្តីពីរោះ និយាយពាក្យជាទីស្រឡាញ់ ក្នុងអាស្រម ជាទីរមណីយដ្ឋាន នឹងមិនរលឹករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញរាជកុមារទាំងនេះ មានសម្តីពីរោះ និយាយពាក្យជាទីស្រឡាញ់ កំពុងលេងក្បែរអាស្រមជាទីត្រេកអរ នឹងមិនរលឹករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះ ពាក់កម្រងផ្កា មានខ្លួនប្រដាប់ហើយ ក្នុងអាស្រមជាទីរមណីយដ្ឋាន នឹងមិនរលឹករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះ ពាក់កម្រងផ្កា មានខ្លួនប្រដាប់ហើយ កំពុងលេងក្បែរអាស្រម ដែលជាទីត្រេកអរ នឹងមិនរលឹករាជសម្បត្តិ ។

យទា ទក្ខសិ នច្ចន្តេ កុមារេ មាលធារិនេ
អស្សមេ រមណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ នច្ចន្តេ កុមារេ មាលធារិនេ
កីឡន្តេ អស្សមេ រម្មេ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ មាតង្គំ កុញ្ជរំ សដ្ឋិហាយនំ
ឯកំ អរញ្ញេ វិចរន្តំ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ មាតង្គំ កុញ្ជរំ សដ្ឋិហាយនំ
សាយំ បាតោ វិចរន្តំ ន រជ្ជស្ស សរិស្សសិ ។
យទា ករេណុសង្ឃស្ស យូថស្ស បុរតោ វជំ
កោញ្ចំ កាហតិ មាតង្គោ កុញ្ជរោ សដ្ឋិហាយនោ
តស្ស តំ នទតោ សុត្វា ន រជ្ជស្ស សរិស្សសិ ។
ឧភតោ វនវិកាសេ យទា ទក្ខសិ កាមទំ
វនេ វាឡមិគាកិណ្ណេ ន រជ្ជស្ស សរិស្សសិ ។
មិគំ ទិស្វាន សាយណ្ហំ បញ្ចមាលិនមាគតំ
កិម្បុរិសេ ច នច្ចន្តេ ន រជ្ជស្ស សរិស្សសិ ។
យទា សោស្សសិ និគ្ឃោសំ សន្ទមានាយ សិន្ធុយា
គីតំ កិម្បុរិសានញ្ច ន រជ្ជស្ស សរិស្សសិ ។



កាលណាព្រះអង្គទតឃើញកុមារពាក់កម្រងផ្កា កំពុងរាំក្នុងអាស្រម ជារមណីយដ្ឋាន នឹងមិនរលឹកដល់រាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញកុមារពាក់កម្រងផ្កា កំពុងលេងក្នុងអាស្រមជាទីត្រេកអរ នឹងមិនរលឹកដល់រាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដំរីធំ ជាកុញ្ជរ-ជាតិ មានអាយុ ៦០ ឆ្នាំ ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង នឹងមិនរលឹកដល់រាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ ត្រាច់ទៅមកពេលល្ងាច ពេលព្រឹក នឹងមិនរលឹកដល់រាជសម្បត្តិ ។ កាលណាដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ កាលដើរទៅខាងមុខនៃហ្វូងដំរីញីនឹងហ្វូងដំរីឈ្មោល ហើយបន្លឺកោញ្ចនាទ ព្រះអង្គបានទ្រង់ព្រះសណ្ដាប់ដំរី បន្លឺកោញ្ចនាទនោះហើយ នឹងមិនរលឹកដល់រាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញវនព្រៃសងខាងផ្លូវ ជាទីឲ្យសេចក្ដីត្រេកអរក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ នឹងមិនរលឹកដល់រាជសម្បត្តិ ។ ព្រះអង្គទតឃើញម្រឹគជាបញ្ច-មាលិន៍ដើរមក នឹងឃើញពួកកិន្នរ ដែលកំពុងរាំក្នុងវេលាល្ងាច នឹងមិនរលឹកដល់រាជសម្បត្តិ ។ កាលណាព្រះអង្គស្ដាប់សូរសំឡេងទឹកកងនៃទន្លេ កំពុងហូរទៅផង ឮចម្រៀងនៃពួកកិន្នរផង នឹងមិនរលឹកដល់រាជសម្បត្តិ ។

យទា សុស្សុសិ និគ្ឃោសំ គិរិគព្ភរចារិនោ

ឥស្សមានស្សសុកាស្ស ន រជ្ជស្ស សរិស្សសិ ។

យទា សីហស្ស ព្យគ្ឃស្ស ខគ្គស្ស គវយស្ស ច

វនេ សុស្សសិ វាឡានំ ន រជ្ជស្ស សរិស្សសិ ។

យទា មោរីហិ បរិកិណ្ណំ ពរិហិនំ មត្ថកាសិនំ

មោរំ ទក្ខសិ នច្ចន្តំ ន រជ្ជស្ស សរិស្សសិ ។

យទា មោរីហិ បរិកិណ្ណំ អណ្ឌជំ ចិត្របេក្ខុណំ[១]

មោរំ ទក្ខសិ នច្ចន្តំ ន រជ្ជស្ស សរិស្សសិ ។

យទា មោរីហិ បរិកិណ្ណំ នីលគីវំ សិខណ្ឌិនំ

មោរំ ទក្ខសិ នច្ចន្តំ ន រជ្ជស្ស សរិស្សសិ ។

យទា ទក្ខសិ ហេមន្តេ បុប្ផិតេ ធរណីរុហេ

សុរភិសម្បវាយន្តេ ន រជ្ជស្ស សរិស្សសិ ។

យទា ហេមន្តិកេ មាសេ ហរិតំ ទក្ខសិ មេទនិំ

ឥន្ទគោបកសញ្ឆន្នំ ន រជ្ជស្ស សរិស្សសិ ។

---

១ ម. ចិត្របក្ខុណំ ។



កាលណាព្រះអង្គទ្រង់ស្ដាប់សម្លេងគឹកកងនៃសត្វរមៀម ដែលត្រាច់ក្នុងញកនៃភ្នំ នឹងមិនរលឹកដល់សម្បត្តិ ។ កាលណាព្រះអង្គទ្រង់ស្ដាប់សម្លេងគឹកកងនៃព្រែនសាហាវក្នុងព្រៃ គឺពួកសីហ៍ ខ្លា រមាស គោព្រៃ នឹងមិនរលឹកដល់សម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោល ដែលមានពួកក្ងោកញីចោមរោម ជាសត្វដែលដាស ដោយសំណុំកន្ទុយ ទំលើកំពូលភ្នំ កំពុងរេខគង់ នឹងមិនរលឹកដល់សម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោល ដែលមានក្ងោកញីចោមរោម ជាអណ្ឌជាតិ មានស្លាបដ៏វិចិត្រ កំពុងរេខគង់ នឹងមិនរលឹកដល់សម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោល ដែលមានក្ងោកញីចោមរោម ជាសត្វមានស្លឹកខៀវ មានកំពូយ កំពុងរេខគង់ នឹងមិនរលឹកដល់សម្បត្តិ ។ កាលណាព្រះអង្គទតឃើញដើមឈើទាំងឡាយ មានផ្កាកែ ក្នុងហេមន្តរដូវ ផ្សព្វផ្សាយដោយក្លិនក្រអូប នឹងមិនរលឹកដល់សម្បត្តិ ។ កាលណាព្រះអង្គទតឃើញផែនដី មានស្មៅខៀវខ្ចី ក្នុងខែទាំងឡាយក្នុងហេមន្តរដូវ ដ៏ដេរដាសដោយមមាចក្មៀង នឹងមិនរលឹកដល់សម្បត្តិ ។

យទា ទក្ខិសិ ហេមន្តេ  បុប្ផិតេ ធរណីរុហេ
កុដជំ ពិម្ពជាលញ្ច  បុប្ផិតំ លោទ្ទបទ្មកំ[១]
សុរភិសម្បភិយន្តេ  ន រជ្ជស្ស សរិស្សសិ ។
យទា ហេមន្តិកេ មាសេ  វនំ ទក្ខសិ បុប្ផិតំ
ឱបុប្ផានិ ច បទ្មានិ[២]  ន រជ្ជស្ស សរិស្សសិ ។

ហិមវន្តំ និដ្ឋិតំ ។

(៦៦៩) តេសំ លាលប្បិតំ សុត្វា  បុត្តស្ស សុណិសាយ ច
កលុនំ បរិទេវេសិ  រាជបុត្តី យសស្សិនី ។
សេយ្យោ វិសំ មេ ខាយិតំ  បបាតា បបតេយ្យហំ
រជ្ជុយា ពជ្ឈមិយាហំ
កស្មា វេស្សន្តរំ បុត្តំ  បព្វាជេន្តិ អទូសកំ ។
អជ្ឈាយកំ ទានបតិំ  យាចយោគំ អមច្ឆរឹ
កស្មា វេស្សន្តរំ បុត្តំ  បព្វាជេន្តិ អទូសកំ ។
បូជិតំ បដិរាជូហិ  កិត្តិមន្តំ យសស្សិនំ
កស្មា វេស្សន្តរំ បុត្តំ  បព្វាជេន្តិ អទូសកំ ។

---

១ ម. លោទបទ្មកំ ។ ឧ. លោទ្ទបទ្មកំ ២ ម. គគ្គានិ ។



កាលណា ព្រះអង្គទតឃើញដើមឈើចំពីឡាយ ដែលមានផ្ការីកស្គុះស្គាយក្នុងហេមន្តរដូវផង ដើមរំដួលផង ដើមឈើដែលមានគ្រឿង មានស្លឹកក្រហមផង ដើមលោទ្ធដើមឈើមួយមានផ្ការីក ផ្សព្វផ្សាយក្លិនក្រអូបផង នឹងមិនរលឹកកាន់រាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញព្រៃ មានផ្ការីកក្នុងខែមាឃក្នុងហេមន្តរដូវផង ឈូកចំពីឡាយមានផ្កាផ្ទុះហើយផង នឹងមិនរលឹកកាន់រាជសម្បត្តិ ។

ចប់ ហិមវន្ត ។

(៦៦៩) (អភិសម្ពុទ្ធគាថា) ព្រះនាងផុស្សតីជារាជបុត្រី មានយស បានទ្រង់ព្រះសណ្ដាប់ការខ្សឹកខ្សួលនៃព្រះរាជបុត្រ នឹងព្រះរាជសុណិសាទាំងពីរនោះហើយ ទ្រង់ព្រះកន្សែង ទួញទូរអាណោចអធ្រាំ ខុសគ្នា អញគួរនឹងបរិភោគថ្នាំពិស ឬគួរតែអញលោតទំលាក់ខ្លួនក្នុងជ្រោះ ....កុំនោះ ចង (ក) នឹងខ្សែ (ឱ្យស្លាប់) ប្រសើរជាង ។ ម្ដេចឡើយ ក៏ពួកអ្នកសិវិរដ្ឋបណ្ដេញបុត្រវេស្សន្តរ ជាកូនអញ ដែលជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយ ក៏ពួកអ្នកសិវិរដ្ឋបណ្ដេញបុត្រវេស្សន្តរជាកូនអញ ដែលជាអ្នករៀនចប់ត្រៃវេទ ជាម្ចាស់មានទាន អ្នកគួរដល់សូម ឥតមានសេចក្ដីកំណាញ់ ជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយ ក៏ពួកអ្នកសិវិរដ្ឋ បណ្ដេញបុត្រវេស្សន្តរជាកូនអញ ដែលពួកព្រះរាជាប្រទេសដទៃបូជា មានកិត្តិយស ជាអ្នកមិនប្រទូស្ត ។

មាតាបេត្តិភរំ ជន្តុំ   កុលេ ជេដ្ឋាបចាយិនំ

កស្មា វេស្សន្តរំ បុត្តំ   បព្វាជេន្តិ អទូសកំ ។

រញ្ញោ ហិតំ ទេវហិតំ   ញាតីនំ សខិនំ ហិតំ

ហិតំ សព្វស្ស រដ្ឋស្ស

កស្មា វេស្សន្តរំ បុត្តំ   បព្វាជេន្តិ អទូសកំ ។

(៦៦៦) មធូនីវ បលាតានិ   អម្ពាវ បតិតា ឆមា

ឯវំ ហេស្សតិ តេ រដ្ឋំ   បព្វាជេន្តិ អទូសកំ ។

ហំសោ និក្ខីណបត្តោវ   បល្លលស្មឹ អនូទកេ

អបវិទ្ធោ អមច្ចេហិ   ឯកោ រាជា វិហិយ្យសិ ។

តំ តំ ព្រូមិ មហារាជ   អត្ថោ តេ មា ឧបច្ចគា

មា នំ សិវីនំ វចនា   បព្វាជេសិ អទូសកំ ។

[៦៦៧] ធម្មស្សាបចិតិំ កុម្មិ   សិវីនំ វិនយំ ធជំ

បព្វាជេមិ សកំ បុត្តំ   បាណា បិយតរោ ហិ មេ ។



ម្ដេចឡើយ ពួកអ្នកសិវិរាស្ត្រ បណ្ដេញព្រះវេស្សន្តរជាកូនអញ ដែលជាបុគ្គលចិញ្ចឹមមាតាបិតា ជាអ្នកគោរពកោតក្រែងបុគ្គលជាធំក្នុងត្រកូល ជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយ ពួកអ្នកសិវិរាស្ត្រ បណ្ដេញព្រះវេស្សន្តរជាកូនអញ ជាប្រយោជន៍ដល់ព្រះរាជា ជាប្រយោជន៍ដល់ទេវតា ជាប្រយោជន៍ដល់ពួកញាតិនិងសំឡាញ់ ជាប្រយោជន៍ដល់អ្នកដែនដីទាំងអស់ ជាអ្នកមិនប្រទូស្ត ។

៦៦៦) ដែនរបស់ព្រះអង្គ មុខជានឹងសាបរលាបដល់ជនទាំងឡាយ ដូចទឹកឃ្មុំ ដែលមេឃ្មុំហើរចោល ពុំនោះដូចផ្លែស្វាយដែលជ្រុះលើផែនដី (ព្រោះ) ពួកអ្នកសិវិរាស្ត្រ បណ្ដេញវេស្សន្តរជាអ្នកមិនប្រទូស្ត ។ ព្រះអង្គដែលពួកអាមាត្យបោះបង់ហើយ ជាព្រះរាជាម្នាក់ឯង រមែងស្រៀមក្រៀមដូចហង្ស ដែលអស់ស្លាបលើភក់ ដែលគ្មានទឹក ។ បពិត្រមហារាជ ព្រោះហេតុនោះបានជាខ្ញុំម្ចាស់ក្រាបទូលព្រះអង្គ កុំឲ្យប្រយោជន៍កន្លងផុតព្រះអង្គឡើយ សូមព្រះអង្គកុំបំបរបង់វេស្សន្តរ ដែលជាអ្នកមិនប្រទូស្តនោះ តាមសំដីពួកអ្នកសិវិរាស្ត្រឡើយ ។

៦៦៧) (ព្រះរាជា...) យើងបណ្ដេញព្រះវេស្សន្តរ ដែលជាទង់ជ័យនៃពួកអ្នកសិវិរាស្ត្រ ឈ្មោះថាធ្វើនូវសេចក្ដីគោរពចំពោះបវេណីធម៌ ទុកជាព្រះវេស្សន្តរ ជាទីស្រឡាញ់ដ៏លើសជាងជីវិតរបស់យើង ក៏យើងនៅតែបណ្ដេញព្រះវេស្សន្តរ ដែលជាកូនរបស់យើងមិនខាន ។

(៦៦៨) យស្ស បុព្វេ ធជគ្គានិ កណិការាវ បុប្ផិតា
យាយន្តមនុយាយន្តិ ស្វាជ្ជេកោវ គច្ឆតិ ។
យស្ស បុព្វេ ធជគ្គានិ កណិការវនានីវ
យាយន្តមនុយាយន្តិ ស្វាជ្ជេកោវ គច្ឆតិ ។
យស្ស បុព្វេ អនីកានិ កណិការាវ បុប្ផិតា
យាយន្តមនុយាយន្តិ ស្វាជ្ជេកោវ គច្ឆតិ ។
យស្ស បុព្វេ អនីកានិ កណិការវនានីវ
យាយន្តមនុយាយន្តិ ស្វាជ្ជេកោវ គច្ឆតិ ។
ឥន្ទគោបកវណ្ណាភា គន្ធារា បណ្ឌុកម្ពលា
យាយន្តមនុយាយន្តិ ស្វាជ្ជេកោវ គច្ឆតិ ។
យោ បុព្វេ ហត្ថិនា យាតិ សិវិកាយ រថេន ច
ស្វជ្ជ វេស្សន្តរោ រាជា កថំ គច្ឆតិ បត្តិកោ ។





(៦៦៨) (ព្រះនាងផុស្សតីថា...) ក្នុងកាលមុន ចុងទង់ជ័យទាំងឡាយ ដូចជាផ្កាកណិការីក រមែងទៅតាមព្រះវេស្សន្តរណា កាលទៅ (កាន់ទុងខ្សែនជាដើម) តែក្នុងថ្ងៃនេះ ព្រះវេស្សន្តរនោះ ទ្រង់ទៅតែម្នាក់ឯង ។ ក្នុងកាលមុន ចុងទង់ជ័យទាំងឡាយ ដូចជាព្រៃផ្កាកណិការ រមែងទៅតាមព្រះវេស្សន្តរណា កាលទៅ (កាន់ទុងខ្សែនជាដើម) តែក្នុងថ្ងៃនេះ ព្រះវេស្សន្តរនោះ ទ្រង់ទៅតែម្នាក់ឯង ។ ក្នុងកាលមុន ពលទាំងឡាយដូចជាដើមកណិការីក រមែងទៅតាមព្រះវេស្សន្តរណា កាលទៅ (កាន់ទុងខ្សែនជាដើម) តែក្នុងថ្ងៃនេះ ព្រះវេស្សន្តរនោះ ទ្រង់ទៅតែម្នាក់ឯង ។ ក្នុងកាលមុន ពលទាំងឡាយ ដូចជាព្រៃផ្កាកណិការ រមែងទៅតាមព្រះវេស្សន្តរណា កាលទៅ (កាន់ទុងខ្សែនជាដើម) តែក្នុងថ្ងៃនេះ ព្រះវេស្សន្តរនោះ ទ្រង់ទៅតែម្នាក់ឯង ។ ពួកសេនាស្លៀកសំពត់កម្ពលមានពណ៌លឿង ដែលកើតក្នុងដែនគន្ធារៈ មានរស្មីដូចជាសម្បុរមេភ្លៀង រមែងទៅតាមព្រះវេស្សន្តរណា កាលទៅ (កាន់ទុងខ្សែនជាដើម) តែក្នុងថ្ងៃនេះ ព្រះវេស្សន្តរនោះ ទ្រង់ទៅតែម្នាក់ឯង ។ ក្នុងកាលមុន ព្រះវេស្សន្តរណា ទៅដោយដំរី ដោយសាសៀង ទ្រង់រថ តែក្នុងថ្ងៃនេះ ព្រះរាជាវេស្សន្តរនោះ ទ្រង់ដើរទៅដូចម្តេចបាន ។

កថំ ចន្ទនលិត្តង្គី   នច្ចគីតប្បពោធនា
ខុរាជិនំ ផរុសញ្ច   ធារិកាជញ្ញ ហារិតិ ។
កស្មា ញាតិហារិយន្តិ   កាសាវ អជិនានិ ច
បវិសន្តំ ព្រហារញ្ញំ   កស្មា ចីរំ ន ពជ្ឈរេ ។
កថំ នុ ចីរំ ធារេន្តិ   រាជបព្វជិតា ជនា
កថំ កុសមយំ ចីរំ   មទ្ទី បរិទហេស្សតិ ។
កាសិយានិ ច ធារេត្វា   ខោមកោទុម្ពរានិ ច
កុសចីរានិ ធារេន្តី   កថំ មទ្ទី ករិស្សតិ ។
វយ្ហាហិ បរិយាយិត្វា   សិវិកាយ រថេន ច
សា កថជ្ជ អនុជ្ជង្គី   បថំ គច្ឆតិ បត្តិកា ។
យស្សា មុទុតលា ហត្ថា   ចលនា[១] ច សុខេធិតា
សា កថជ្ជ អនុជ្ជង្គី   បថំ[២] គច្ឆតិ បត្តិកា ។
យស្សា មុទុតលា បាទា   ចលនា ច សុខេធិតា

---
១ ឧ ម. ចរណា ។ ២ ម. បិ ។



ចុះស្ត្រីដែលមានអវយវៈលាបដោយខ្លឹមចន្ទន៍ ធ្លាប់ត្រាក់លើក ដោយចុងទំនងសម្រៀង (ស្លៀកដណ្ដប់) ស្បែកខ្លាតាំងក្រចកក្រោក ក្រោកផង រែកនាំស្រែកទម្ងន់មួយការផង ដូចម្ដេចកើត ។ ព្រោះហេតុដូចម្ដេច ក៏ជនទាំងឡាយមិននាំសំពត់កាសាវៈផង ស្បែកខ្លាផង ដើម្បីបុរសនោះ កាលចូលទៅក្នុងព្រៃធំ ព្រោះហេតុអ្វីក៏ជនទាំងឡាយ មិនក្រាញសំពត់សម្បកឈើថ្វាយ ។ ពួកជនជាកដបព្វជិត នឹងស្លៀកសំពត់សម្បកឈើ ដូចម្ដេចកើត នាងមទ្រីនឹងស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំង ដូចម្ដេចកើត ។ នាងមទ្រីធ្លាប់តែស្លៀកសំពត់ដែលកើតក្នុងដែនកាសីផង សំពត់ដែលកើតក្នុងដែនខោមៈ នឹងដែនកោទុម្ពរៈផង ឥឡូវនេះ មកស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំង តើនឹងកើតអ្វីកើត ។ នាងមទ្រីនោះមានអវយវៈគួរសរសើរ ធ្លាប់ទៅដោយ គ្រែសាលៀង នឹងរថ ថ្ងៃនេះ នឹងដើរដោយជើងតាមផ្លូវ ដូចម្ដេចបាន ។ នាងមទ្រីណា មានដៃផ្លុំដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់បិតនៅ ក្នុងសេចក្ដីសុខ ថ្ងៃនេះ នាងមទ្រីមានអវយវៈគួរសរសើរនោះ នឹងដើរដោយជើងតាមផ្លូវ ដូចម្ដេចបាន ។ នាងមទ្រីណា មានដៃជើងដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់បិតនៅ ក្នុងសេចក្ដីសុខ

ចាតុក្កាហំ សុវណ្ណាហំ    បីឡ្យមាបាវ គច្ឆតិ
សា ការជ្ជ អនុព្វត្តី    បជំ គច្ឆតិ បត្តិកា ។
យស្ស ឥត្ថីសហស្សស្ស    បុរតោ គច្ឆតិ មាលិនី
សា ការជ្ជ អនុព្វត្តី    វនំ គច្ឆតិ ឯកិកា ។
យា សា សិវិកាយ សុត្វាន    ខុបិំ ទុក្ខសោក បុរេ
សា ការជ្ជ អនុព្វត្តី    វនំ គច្ឆតិ ភីរុកា ។
យា សា ឥន្ទសគោត្តស្ស    ទល្ហកស្ស បរិស្សតោ
សុត្វាន ឆទកោ គីតា    កុរុណីវ បវេធតិ
សា ការជ្ជ អនុព្វត្តី    វនំ គច្ឆតិ ភីរុកា ។
សកុណី ហតបុត្តាវ    សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ    សុញ្ញំ អាគម្មិមំ បុរំ ។
សកុណី ហតបុត្តាវ    សុញ្ញំ ទិស្វា កុលាវកំ
កិសា បណ្ឌុ ភវិស្សាមិ    បិយេ បុត្តេ អបស្សតី ។
សកុណី ហតបុត្តាវ    សុញ្ញំ ទិស្វា កុលាវកំ
តេន តេន បធាវិស្សំ    បិយេ បុត្តេ អបស្សតី ។





នាងមទ្រីមានអវយវៈ ល្អសព្វសព៌ាងនោះ តែងពាក់ស្បែកជើងមាស ហើយដើរទៅ ថ្ងៃនេះ នឹងដើរជាយជើងទៅតាមផ្លូវ ដូចម្ដេចបាន ។ នាងមទ្រីណា តែងកាន់កម្រងផ្កា ដើរទៅខាងមុខនៃស្រីមួយពាន់ ថ្ងៃនេះ នាងមទ្រីមានអវយវៈល្អសព្វសព៌ាងនោះ នឹងដើរទៅព្រៃតែម្នាក់ឯង ដូចម្ដេចបាន ។ នាងមទ្រីណា ដែលនៅក្នុងទីបូរី គ្រាន់តែបានឮសម្លេងចចកលូរឿយៗ រមែងតក់ស្លុត ថ្ងៃនេះ នាងមទ្រីមានអវយវៈល្អសព្វសព៌ាងនោះ ជាស្រីខ្លាច នឹងទៅព្រៃ ដូចម្ដេចបាន ។ នាងមទ្រីណា គ្រាន់តែបានឮសម្លេងមៀម ជាកោសិយគោត្រ កាលស្រែកហៅ ក៏ភ្ញាក់ខ្លាច ដូចមេមាន់ដែលរោយចូល ថ្ងៃនេះ នាងមទ្រីមានអវយវៈល្អសព្វសព៌ាងនោះ ជាស្រីមានសេចក្ដីខ្លាច នឹងដើរទៅព្រៃ ដូចម្ដេចបាន ។ ខ្ញុំម្ចាស់ត្រឡប់មកកាន់ព្រះអាស្រមទទេហើយ មុខជានឹងឆេះដោយសេចក្ដីទុក្ខ អស់កាលយូរ ដូចមេបក្សីដែលបាត់កូន ឃើញតែសំបុកស្ងួតស្ងាត់ទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន (ទាំងពីរ)ហើយ មុខជានឹងស្គមស្លេកស្លាំង ដូចជាមេបក្សីដែលបាត់កូន ឃើញតែសំបុកស្ងួតទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន (ទាំងពីរ)ជាទីស្រឡាញ់ហើយ មុខជានឹងស្ទុះទៅតាមទីនោះ ៗ ដូចជាមេបក្សី ដែលបាត់កូន ឃើញតែសំបុកស្ងួតទទេដូច្នោះ ។

កុររី ហតច្ឆាបាវ    សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ    សុញ្ញំ អាគម្មិមំ បុរំ ។

កុររី ហតច្ឆាបាវ    សុញ្ញំ ទិស្វា កុលាវកំ
កិសា បណ្ឌុ ភវិស្សាមិ    បិយេ បុត្តេ អបស្សតី ។

កុររី ហតច្ឆាបាវ    សុញ្ញំ ទិស្វា កុលាវកំ
តេន តេន បធាវិស្សំ    បិយេ បុត្តេ អបស្សតី ។

សា នូន ចក្កវាកីវ    បល្លលស្មិំ អនុទកេ
ចិរំ ទុក្ខេន ឈាយិស្សំ    សុញ្ញំ អាគម្មិមំ បុរំ ។

សា នូន ចក្កវាកីវ    បល្លលស្មិំ អនុទកេ
កិសា បណ្ឌុ ភវិស្សាមិ    បិយេ បុត្តេ អបស្សតី ។

សា នូន ចក្កវាកីវ    បល្លលស្មិំ អនុទកេ
តេន តេន បធាវិស្សំ    បិយេ បុត្តេ អបស្សតី ។

ឯវំ មេ វិលបន្តិយា    រាជបុត្ត អទូសកំ
បព្វាជេសិ វនំ រដ្ឋា    មញ្ញេ ហេស្សាមិ ជីវិតំ ។



ខ្ញុំម្ចាស់ លុះមកកាន់បុរីនេះសូន្យទទេហើយ នឹងនេះដោយសេចក្តីទុក្ខអស់កាលយូរ ដូចមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន (ទាំងពីរ) ជាទីស្រឡាញ់ហើយ មុខជានឹងស្គមស្លេកស្លាំង ដូចជាមេអក ដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន (ទាំងពីរ) ជាទីស្រឡាញ់ហើយ មុខជានឹងស្ទុះទៅតាមទីនោះៗ ដូចជាមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់នោះ មកកាន់បុរីនេះសូន្យទទេហើយ មុខជានឹងនេះដោយសេចក្តីទុក្ខអស់កាលយូរដោយពិត ដូចជាមេចាក្រពាក ដែល (សំគុក) លើភក់មិនមានទឹក ។ ខ្ញុំម្ចាស់នោះមិនឃើញកូន (ទាំងពីរ) ជាទីស្រឡាញ់ហើយ មុខជានឹងស្គមស្លេកស្លាំងដោយពិត ដូចជាមេចាក្រពាក ដែល (សំគុក) នៅលើភក់មិនមានទឹក ។ ខ្ញុំម្ចាស់កាលមិនឃើញកូន (ទាំងពីរ) ជាទីស្រឡាញ់ហើយ មុខជានឹងស្ទុះទៅតាមទីនោះៗ ដោយពិត ដូចជាមេចាក្រពាក ដែលនៅលើភក់មិនមានទឹក ។ កាលបើខ្ញុំម្ចាស់យំរៀបរាប់យ៉ាងនេះហើយ ព្រះអង្គនៅតែបណ្តេញរាជបុត្តនោះ ដែលជាអ្នកមិនប្រទូស្ត ឲ្យចេញចាកដែន ខ្ញុំម្ចាស់ទំនងជានឹងលះបង់ជីវិតមិនខាន ។

(៦៦៤) តស្ស លាលប្បិតំ សុត្វា តស្សា អន្តេបុរេ អហុ

ពាហា បគ្គយ្ហ បក្កន្ទុំ សិវិកញ្ញា សមាគតា ។

សាលាវ សម្បមទ្ទិតា មាលុតេន បមទ្ទិតា

សេន្តិ បុត្តា ច ទារា ច វេស្សន្តរនិវេសនេ ។

ឱរោធា ច កុមារា ច វេសិយានា ច ព្រាហ្មណា

ពាហា បគ្គយ្ហ បក្កន្ទុំ វេស្សន្តរនិវេសនេ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា

ពាហា បគ្គយ្ហ បក្កន្ទុំ វេស្សន្តរនិវេសនេ ។

តតោ រត្យា វិវសានេ សុរិយស្សុគ្គមនំ បតិ

អថ វេស្សន្តរោ រាជា ទានំ ទាតុំ ឧបាគមិ ។

វត្ថានិ វត្ថកាមានំ សោណ្ឌានំ ទេថ វារុណឹ

ភោជនំ ភោជនត្ថីនំ សម្មទេវ បវេច្ឆថ ។

មា ច កិញ្ចិ វនិព្វកេ ហេដ្ឋយិត្ថ ឥធាគតេ

តប្បេថ អន្នបានេន គច្ឆន្តុ បដិបូជិតា ។

(អថេត្ថ វត្តតិ សទ្ទោ តុមុលោ ភេរវោ មហា

ទានេន តំ នីហរន្តិ បុន ទានំ អទា តុវំ) ។



(៦៦៤) (អភិសម្ពុទ្ធគាថា) ពួកកញ្ញារបស់ព្រះបាទសិវិទាំងអស់ដែលនៅក្នុងបុរី លុះបានឮពាក្យទំនួញរៀបរាប់នៃព្រះនាងផុស្សតីនោះហើយ ក៏មកប្រជុំគ្នា ផ្គងដើមដៃកន្ទក់កន្ទេញ ។ កូននឹងប្រពន្ធទាំងឡាយ ក៏ដួលដេកក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ដូចដើមឈើដែលត្រូវខ្យល់បក់បោកបំបាក់ ។ ពួកស្រីស្នំ ពួករាជកុមារ ពួកអ្នកជំនួញ និងពួកព្រាហ្មណ៍ ផ្គងដើមដៃកន្ទក់កន្ទេញ ក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ។ ពួកពលដំរី ពល (សេះ) ពលរថ ពលថ្មើរជើង ផ្គងដើមដៃកន្ទក់កន្ទេញក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ។ រាត្រីនោះអស់ហើយ ព្រះអាទិត្យរះឡើង គ្រានោះ ព្រះបាទវេស្សន្តរស្តេចចូលទៅ ដើម្បីឲ្យទាន ។ មានព្រះរាជបន្ទូលថា អ្នកទាំងឡាយចូរឲ្យសំពត់ដល់ពួកជនដែលត្រូវការសំពត់ ឲ្យសុរាដល់ពួកអ្នកលេងស្រា ឲ្យភោជនដល់ពួកអ្នកត្រូវការដោយភោជន ចូរឲ្យដោយប្រពៃចុះ ។ អ្នកទាំងឡាយ កុំបៀតបៀនពួកវណិព្វកៈ ដែលមកក្នុងទីនេះគ្រប់គ្នាឡើយ អ្នកទាំងឡាយ ចូរញ៉ាំងពួកវណិព្វកៈឲ្យស្កប់ស្កល់ ដោយបាយនិងទឹក ពួកវណិព្វកៈ ដែលយើងបានបូជាហើយ ចូរទៅចុះ ។ (លំដាប់នោះ ស្រាប់តែសម្លេងគ្រលួចយ៉ាងអឹកធឹក ប្រព្រឹត្តទៅក្នុងព្រះនគរនោះថា ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះអង្គ ព្រោះតែឲ្យទាន ឥឡូវនេះ ព្រះអង្គឲ្យទានទៀតហើយ) ។

[២៨០] តេ សុមត្តា ពលត្តា សម្បតន្តិ វណិព្វកា
និក្ខមន្តេ មហារាជេ សិវីនំ រដ្ឋវឌ្ឍនេ ។
អច្ឆិន្ទិំ វត ភោ រុក្ខំ នានាផលធរំ(១) ទុមំ
យថា វេស្សន្តរំ រដ្ឋា បព្វាជេន្តិ អទូសកំ ។
អច្ឆិន្ទិំ វត ភោ រុក្ខំ នានាផលំ(២) ទុមំ
យថា វេស្សន្តរំ រដ្ឋា បព្វាជេន្តិ អទូសកំ ។
អច្ឆិន្ទិំ វត ភោ រុក្ខំ សព្វកាមទទំ ទុមំ
យថា វេស្សន្តរំ រដ្ឋា បព្វាជេន្តិ អទូសកំ ។
អច្ឆិន្ទិំ វត ភោ រុក្ខំ សព្វកាមរសាហរំ
យថា វេស្សន្តរំ រដ្ឋា បព្វាជេន្តិ អទូសកំ ។
យេ វុឌ្ឍា យេ ច ទហរា យេ ច មជ្ឈិមពោរិសា
ពាហា បគ្គយ្ហ បក្កន្ទុំ
និក្ខមន្តេ មហារាជេ សិវីនំ រដ្ឋវឌ្ឍនេ ។

---

១ ម. នានាផលធរំ ។ ២ ឱ. ម. សព្វកាមទទំ ។



[២៨០] កាលមហារាជព្រះអង្គញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យចំរើន ទ្រង់យាងចេញទៅ វណិព្វកៈទាំងនោះកើតជួលជុះ ដូចជាបុគ្គលស្រវឹង ឬដូចជាបុគ្គលឡើយពាក់ក្នុង (ដោយពាក្យថា) ម្នាលអ្នកដ៏ចំរើន ពួកអ្នកសិវិរដ្ឋ បានបណ្ដេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចគេកាត់ផ្ដាច់ដើមឈើ ជាឈើឲ្យផ្លែផ្សេងៗ ។ ម្នាលអ្នកដ៏ចំរើន ពួកអ្នកសិវិរដ្ឋបានបណ្ដេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់គោល់នូវដើមឈើជាឈើទ្រទ្រង់នូវផ្លែផ្សេងៗ ។ ម្នាលអ្នកដ៏ចំរើន ពួកអ្នកសិវិរដ្ឋ បានបណ្ដេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ដើមឈើ ជាឈើឲ្យសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ ម្នាលអ្នកដ៏ចំរើន ពួកអ្នកសិវិរដ្ឋ បានបណ្ដេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ដើមឈើជាឈើនាំមកនូវរសជាទីប្រាថ្នាគ្រប់យ៉ាង ។ ពួកជនណាដែលចាស់ក្ដី ពួកជនណាដែលនៅក្មេងក្ដី ពួកជនណាដែលមានវ័យកណ្ដាលក្ដី ជនទាំងនោះ កាលដែលមហារាជព្រះអង្គញ៉ាំងដែន របស់ពួកអ្នកសិវិរដ្ឋឲ្យចំរើន ទ្រង់យាងចេញទៅ ក៏ផ្គងដៃកន្ទក់កន្ទេញ ។

អតិយក្ខា វស្សវរា ឥត្ថាគារា ច រាជិនោ
ពាហា បគ្គយ្ហ បក្កន្ទុំ
និក្ខមន្តេ មហារាជេ សិវីនំ រដ្ឋវឌ្ឍនេ ។
ឋិយោបិ តត្ថ បក្កន្ទុំ យា តម្ហិ នគរេ អហុ
និក្ខមន្តេ មហារាជេ សិវីនំ រដ្ឋវឌ្ឍនេ ។
យេ ព្រាហ្មណា យេ ច សមណា អញ្ញេ វាបិ វណិព្វកា
ពាហា បគ្គយ្ហ បក្កន្ទុំ អធម្មោ កិរ ភោ ឥតិ ។
យថា វេស្សន្តរោ រាជា យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត ហត្ថិសតេ ទត្វា សព្វាលង្ការភូសិតេ
សុវណ្ណកច្ឆេ មាតង្គេ ហេមកប្បនវាសសេ
អារូឡ្ហេ គាមណីយេហិ តោមរង្កុសបាណិភិ
ឯស វេស្សន្តរោ រាជា សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត អស្សសតេ ទត្វា សព្វាលង្ការភូសិតេ
អាជានីយេវ ជាតិយា សិន្ធវេ សីឃវាហនេ
អារូឡ្ហេ គាមណីយេហិ ឥន្ទិយាចាបធារិភិ
ឯស វេស្សន្តរោ រាជា សម្ហា រដ្ឋា និរជ្ជតិ ។



កាលមហារាជព្រះអង្គញុំាងដែនអ្នកសិវីឲ្យចំរើន ទ្រង់យាងចេញទៅ ពួកពេទ្យតាមចាំយាម ពួកអ្នកក្រៀវស្រីស្នំ[១] ទាំងពួកស្រីស្នំរបស់ព្រះរាជា ក៏ផ្គងដើមដៃ គន្ទក់គន្ទេញ ។ កាលមហារាជ ព្រះអង្គញុំាងដែនអ្នកសិវីឲ្យចំរើន ទ្រង់យាងចេញទៅ ពួកស្ត្រីដែលនៅក្នុងព្រះនគរនោះ ក៏គន្ទក់គន្ទេញ ។ ពួកព្រាហ្មណ៍ សមណៈ និងវណិព្វកៈដទៃៗ ផ្គងដើមដៃគន្ទក់គន្ទេញថា ម្នាលអ្នកដ៏ចំរើន ឮថា នេះមិនមែនជាធម៌ទេ ។ ដូចយ៉ាងព្រះបាទវេស្សន្តរ កាលបូជាក្នុងបុរីរបស់ព្រះអង្គ ទ្រង់យាងចេញចាកដែនរបស់ព្រះអង្គ ព្រោះហេតុតែសំដីពួកអ្នកសិវីរាស្ត្រ ។ ព្រះបាទវេស្សន្តរនុ៎ះ បានប្រទានដំរីមាតង្គៈប្រាំពីររយ ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង មានខ្សែជង្គង់មាស មានគ្រឿងប្រដាប់ក្បាល ជាវិការៈនៃមាស ដែលពួកហ្មដំរីមានលំពែងនិងកង្វេរក្នុងដៃឡើងជិះហើយ ក៏យាងចេញទៅចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរនុ៎ះ បានប្រទានសេះអាជានេយ្យប្រាំពីររយ ជាសេះសិន្ធពដោយជាតិ ជាពាហនៈមានសន្ទុះលឿន ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកអ្នកជិះសេះកាន់ធ្នូនិងដាវឡើងជិះហើយ ក៏យាងចេញចាកដែនរបស់ព្រះអង្គ ។

១ អ្នកឃាំរាំងស្រីស្នំ [illegible] ។

សត្ត រថសតេ ទត្វា សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ
អារូឡ្ហេ គាមណីយេហិ ចាបហត្ថេហិ វម្មិភិ
ឯស វេស្សន្តរោ រាជា សកា រដ្ឋា និរជ្ជតិ ។
សត្ត ឥត្ថីសតេ ទត្វា ឯកមេកា រថេ ឋិតា
សន្នទ្ធា និក្ខរជ្ជូហិ សុវណ្ណេហិ អលង្កតា
បីតាលង្ការា បីតវសនា បីតាភរណភូសិតា
អាឡារបម្ហា[១] ហសុលា សុសញ្ញា តនុមជ្ឈិមា
ឯស វេស្សន្តរោ រាជា សកា រដ្ឋា និរជ្ជតិ ។
សត្ត ធេនុសតេ ទត្វា សព្វា កំសុបធារណា
ឯស វេស្សន្តរោ រាជា សកា រដ្ឋា និរជ្ជតិ ។
សត្ត ទាសីសតេ ទត្វា សត្ត ទាសសតានិ ច
ឯស វេស្សន្តរោ រាជា សកា រដ្ឋា និរជ្ជតិ ។
ហត្ថី អស្សេ រថេ ទត្វា នារិយោ ច អលង្កតា
ឯស វេស្សន្តរោ រាជា សកា រដ្ឋា និរជ្ជតិ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
មហាទានេ បទិន្នម្ហិ មេទនី សម្បកម្បថ ។

---
១ ម. អឡារបម្ហា ។



ព្រះបាទវេស្សន្តរ បានប្រទានរថប្រាំពីររយ ដែលប្រដាប់ហើយ មានទង់លើកឡើងហើយ ចិទ ហ៊ុំដោយស្បែកខ្លាដំបង និងស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូក្នុងដៃនិងពាក់អាវក្រោះឡើងជិះហើយ ក៏យាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរ បានប្រទានស្ត្រីប្រាំពីររយ ឋិតនៅលើរថមួយនាក់ៗ ដែលស្អិតស្អាងហើយ ប្រដាប់ដោយខ្សែដាំការៈនៃមាសល្អ មានគ្រឿងប្រដាប់លឿង មានសំពត់ពាក់លឿង ស្អិតស្អាងដោយគ្រឿងអាភរណៈលឿង មានត្របកភ្នែកដ៏ល្អ ញញឹមហើយទើបនិយាយ ជាស្ត្រីមានត្រគាកល្អ មានចង្កេះរៀវ ក៏យាងចេញចាកដែន របស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរ បានប្រទានមេគោប្រាំពីររយ ព្រមទាំងភាជន៍មាសសម្រាប់ត្រងទឹកដោះទាំងអស់ ហើយយាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរ បានប្រទានខ្ញុំស្រីប្រាំពីររយ ខ្ញុំប្រុសប្រាំពីររយ ហើយយាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរ បានប្រទានដំរី សេះ រថ និងនាងនារីដែលប្រដាប់ហើយ ក៏យាងចេញចាកដែនរបស់ព្រះអង្គ ។ កាលដែលព្រះបាទវេស្សន្តរ ប្រទានមហាទាន ការស្ញប់ស្ញែង ការព្រឺរោមក៏កើតមាន ក្នុងកាលនោះ ផែនដី ក៏ញាប់ញ័រ ។

តទាសិ យំ ភឹសនកំ  តទាសិ លោមហំសនំ

យំ បញ្ជលីកតោ កជា  សព្វា រដ្ឋា និរជ្ជតិ ។

(៤៩១) អថេត្ថ វត្តតិ សទ្ទោ  តុមុលោ ភេរវោ មហា

ទានេន តំ នីហរន្តិ  បុន ទានំ ទទាតុ សោ ។(១)

(៤៩២) តេ សុ មត្តា កិលន្តាវ  សម្បតន្តិ វណិព្វកា

និក្ខមន្តេ មហារាជេ  សិវីនំ រដ្ឋវឌ្ឍនេ ។

(៤៩៣) អាមន្តយិត្ថ រាជានំ  សញ្ជយំ ធម្មិកំ វរំ

អវរុទ្ធសិ មំ ទេវ  វង្កំ គច្ឆាមិ បព្វតំ ។

យេ ហិ កេចិ មហារាជ  ភូតា យេ ច ភវិស្សរេ

អតិត្តាយេវ កាមេហិ  គច្ឆន្តិ យមសាធនំ ។

សោហំ សកេ អភិស្សសី  យជមានោ សកេ បុរេ

សិវីនំ វចនត្ថេន  សម្ហា រដ្ឋា និរជ្ជហំ(២)

អឃន្តំ បដិសេវិស្សំ

[illegible]



ព្រះរាជាដែលមហាជនកំពុងផ្គងអញ្ជលី ទ្រង់យាងចេញចាកដែន របស់ព្រះអង្គ ដោយហេតុណា ហេតុនោះ ជាការគួរស្ញប់ស្ញែង គួរព្រឺរោម កើតមានក្នុងកាលនោះ ។

(៤៩១) (អភិសម្ពុទ្ធគាថា) គ្រានោះ សំឡេងគ្រលួចយ៉ាងគគ្រឹកប្រព្រឹត្ត ទៅក្នុងព្រះរាជនិវេសន៍នុះថា ពួកអ្នកសិវិរដ្ឋបណ្ដេញព្រះវេស្សន្ដរ នោះ ព្រោះតែឲ្យទាន ព្រះវេស្សន្ដរនោះ នៅតែឲ្យទានទៀត ។

(៤៩២) កាលមហាជន ព្រះអង្គញុំាងពួកអ្នកសិវិរដ្ឋឲ្យចំរើន យាង ចេញទៅ ពួកវណិព្វកៈទាំងនោះ ក៏ដួលចុះ ដូចដំរីស្រវឹង ឬ ដូចដំរីលះឡើយតាត់ទាំង ។

(៤៩៣) ព្រះបាទវេស្សន្ដរ បានក្រាបទូលព្រះរាជាព្រះនាមសញ្ជ័យ ជា ធម្មិកជនីប្រសើរថា បពិត្រព្រះបិតា ព្រះអង្គទ្រង់បណ្ដេញ ទូល ព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងទៅឯវង្កបព៌ត ។ បពិត្រមហារាជ សត្វទាំងឡាយណាមួយកើតហើយក្ដី ទាំងសត្វទាំងឡាយណានឹង កើតក្ដី (ពួកសត្វដែលកំពុងកើតក្ដី) សត្វទាំងនោះសុទ្ធតែមិនឆ្អែត ដោយកាមទាំងអស់ រមែងទៅកាន់ទីរបស់យមៈ ។ ទូលព្រះបង្គំ ជាខ្ញុំនោះ កាលឲ្យទានក្នុងបុរីជារបស់ខ្លួន ឈ្មោះថា បៀតបៀន ពួកអ្នកដែនរបស់ខ្លួន ទូលព្រះបង្គំជាខ្ញុំ កាលចេញចាកដែនរបស់ ខ្លួន ព្រោះហេតុតែសំដីពួកអ្នកសិវិរដ្ឋ ទូលព្រះបង្គំនឹងដល់នូវទុក្ខ

វនេ វាឡមិគាកិណ្ណេ   ខគ្គទីបិនិសេវិតេ
អហំ បុញ្ញានិ ករោមិ   តុម្ហេ បង្កម្ហិ សីទថ ។

(៦៨៤) អនុជានាហិ មំ អម្ម   បព្វជ្ជា មម រុច្ចតិ
សោហំ សកោ អភិសសឹ   យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន   សម្ហា រដ្ឋា និរជ្ជហំ
អយម្ពុំ បជំសោរិស្សំ
វនេ វាឡមិគាកិណ្ណេ   ខគ្គទីបិនិសេវិតេ
អហំ បុញ្ញានិ ករោមិ   វង្កំ គច្ឆាមិ បព្វតំ ។

(៦៨៥) អនុជានាមិ តំ បុត្ត   បព្វជ្ជា តេ សមិជ្ឈតុ
អយញ្ច មទ្ទី កល្យាណី   សុសញ្ញា តនុមជ្ឈិមា
អច្ឆតំ សហ បុត្តេហិ   កឹ អរញ្ញេ ករិស្សតិ ។

(៦៨៦) នាហំ អកាមា ទាសីបិ   អរញ្ញំ នេតុមុស្សហេ
សចេ ឥច្ឆតិ អន្វេតុ   សចេ ឥច្ឆតិ អច្ឆតុ ។



ក្នុងព្រៃ ដែលច្រូកច្រាល់ដោយម្រឹគសាហាវ ដែលមានសត្វខ្លា ដំបងនិងស្រម៉ោះហើយ ខ្ញុំព្រះបង្គំ នឹងធ្វើបុណ្យទាំងឡាយ ឯព្រះអង្គលិចក្នុងភក់គឺកាមចុះ ។

(៦៨៤) (ព្រះវេស្សន្តរ...) បពិត្រព្រះមាតា សូមទ្រង់អនុញ្ញាតខ្ញុំព្រះបង្គំចុះ ខ្ញុំព្រះបង្គំ គាប់ចិត្តនឹងបព្វជ្ជា ខ្ញុំព្រះបង្គំនោះ កាលឲ្យទានក្នុងបុរីជារបស់ខ្លួន ឈ្មោះថា បៀតបៀនពួកអ្នកដែនរបស់ខ្លួន ខ្ញុំព្រះបង្គំ កាលចេញចាកដែន របស់ខ្លួន ព្រោះពាក្យនៃសំដីពួកអ្នកសិវិរដ្ឋ ខ្ញុំព្រះបង្គំ នឹងសោយទុក្ខក្នុងព្រៃ ដែលច្រូកច្រាល់ដោយម្រឹគសាហាវ ដែលមានសត្វខ្លាដំបងនិងស្រម៉ោះហើយ ខ្ញុំព្រះបង្គំ តែងធ្វើបុណ្យទាំងឡាយ នឹងទៅឯគីរីវង្កត ។

(៦៨៥) (ព្រះនាងផុស្សតីទេវី...) ម្នាលកូន យើងអនុញ្ញាតអ្នកហើយ បព្វជ្ជា ចូរសម្រេចដល់អ្នកចុះ តែនាងមទ្រីកល្យាណីនេះ នាងមានត្រគាកតូចល្អ មានចង្កេះរៀវ ចូរនៅជាមួយនឹងកូនទាំងពីរចុះ នាងនឹងធ្វើអ្វីក្នុងព្រៃ ។

(៦៨៦) (ព្រះវេស្សន្តរ...) សូម្បីតែទាសី ដែលប្រាថ្នានឹងទៅ ខ្ញុំព្រះបង្គំ ក៏មិនអាចនាំទៅកាន់ព្រៃទេ ប្រសិនបើនាងមទ្រីចង់ ចូរទៅតាមចុះ បើមិនចង់ ចូរនៅចុះ ។

(៦៨៧) តតោ សុណ្ហំ មហារាជា យាចិតុំ បដិបជ្ជថ
មា ចន្ទនសមាចារេ រជោជល្លំ អធារយិ ។
កាសិយានិ បធារេត្វា(១) កុសចីរំ អធារយិ
ទុក្ខោ កិលេសោ អរញ្ញស្មឹ មា ហិ ត្វំ លក្ខណេ គមិ ។
(៦៨៨) តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភនា
នាហន្តំ សុខមិច្ឆេយ្យំ យំ មេ វេស្សន្តរំ វិនា ។
(៦៨៩) តមព្រវិ មហារាជា សិវីនំ រដ្ឋវឌ្ឍនោ
ឥង្ឃ មទ្ទិ និសាមេហិ វនេ យេ ហោន្តិ ទុស្សហា ។
ពហូ កីដា បដង្គា ច មកសា មធុមក្ខិកា
តេបិ តំ តត្ថ ហឹសេយ្យុំ តន្តេ ទុក្ខតរំ សិយា ។
អបរេ បស្ស សន្តាបេ នទីកូបនិសេវិតេ
សប្បា អជគរា នាម អវិសា តេ មហព្វលា ។
តេ មនុស្សំ មិគំ វាបិ អបិ មាសន្នមាគតំ
បរិក្ខិបិត្វា ភោគេហិ វសមានេន្តិ អត្តនោ ។

---

១ ម. កាសិយានិ ធារេត្វា ។ ឱ. កាសិយានិ ច ធារេត្វា ។



(៦៨៧) លំដាប់នោះ មហារាជទ្រង់យាងទៅអង្វរព្រះសុណ្ហាថា ម្នាលនាងមានរាងកាយប្រោះព្រំ ដោយខ្លឹមចន្ទន៍ នាងកុំស្លៀកដណ្តប់សំពត់ប្រឡាក់ធូលីឡើយ ។ នាងធ្លាប់ស្លៀកដណ្តប់សំពត់អ្នកដែនកាសី ហើយត្រឡប់ជាស្លៀកដណ្តប់សំពត់ ដែលក្រងដោយស្បូវភ្លាំងវិញ ការនៅក្នុងព្រៃ តែងនាំមកនូវសេចក្តីទុក្ខ ម្នាលនាងមានលក្ខណ៍ នាងកុំទៅឡើយ ។

(៦៨៨) ព្រះរាជបុត្រីព្រះនាមមទ្រី នាងមានអវយវៈទាំងអស់ដ៏ល្អ បានក្រាបបង្គំទូលព្រះបិតាក្មេកថា ខ្ញុំម្ចាស់ បើប្រាសចាកព្រះវេស្សន្តរ របស់ខ្ញុំម្ចាស់ហើយ មិនចង់បានសេចក្តីសុខទេ ។

(៦៨៩) មហារាជជាអ្នកញុំាងដែនអ្នកសិវីឲ្យចំរើន មានព្រះបន្ទូលនឹងនាងមទ្រីនោះថា ម្នាលនាងមទ្រី បើដូច្នោះ នាងចូរស្តាប់សេចក្តីអន្តរាយទាំងឡាយ ដែលនាងអត់ទ្រាំបានដោយក្រ ក្នុងព្រៃចុះ ។ កណ្តូប រោមម មូស នឹងឃ្មុំដ៏ច្រើន សត្វទាំងនោះ គប្បីបៀតបៀននាងក្នុងព្រៃនោះ ការបៀតបៀននោះ មុខជានាំមកនូវទុក្ខយ៉ាងខ្លាំងដល់នាង ។ នាងចូរមើលពួកសត្វដទៃ ដែលគួរឲ្យតក់ស្លុត ដែលអាស្រ័យនៅនឹងទន្លេ គឺពស់ថ្លាន់ ពស់ទាំងនោះមិនមានពិសទេ តែមានកំឡាំងច្រើន ។ ពស់ថ្លាន់ទាំងនោះ តែងយកភោគៈរឹតមនុស្សឬម្រឹគ ដែលមកជិតក៏ ហើយនាំមកកាន់អំណាចខ្លួន ។

អញ្ញេបិ កណ្ហា ជដិលា អច្ឆា ណាម អឃម្មិគា
ន តេហិ បុរិសោ ទិដ្ឋោ រុក្ខមារុយ្ហ មុច្ចតិ ។
សង្ឃដ្ដយន្តា សិង្គានិ តិក្ខគ្គានិ បហារិនោ
មហិសា វិចរន្តេត្ថ នទឹ សោតុម្ពរំ បតិ ។
ទិស្វា មិគានំ យូថានំ គវំ សញ្ចរិតំ វនេ
ធេនុំវ វច្ឆគិទ្ធាវ កថំ មទ្ទិ ករិស្សសិ
ទិស្វា សម្បតិតេ ឃោរេ ទុមគ្គេសុ បលវង្គមេ[1]
អខេត្តញ្ញាយ តេ មទ្ទិ ភវិស្សតេ មហព្ភយំ ។
យា ត្វំ សិវាយ សុត្វាន មុហុំ ឧត្តសយេ បុរេ
សា ត្វំ វង្កំ អនុប្បត្តា កថំ មទ្ទិ ករិស្សសិ ។
ឋិតេ មជ្ឈន្ហិកេ កាលេ សន្និសិន្នេសុ បក្ខិសុ
សណតេវ ព្រហារញ្ញំ តត្ថ កឹ គន្តុមិច្ឆសិ ។
(៦៦០) តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភនា
យានិ ឯតានិ អក្ខាសិ វនេ បដិភយានិ មេ
សព្វានិ អភិសម្ភោស្សំ គច្ឆញ្ញេវ រថេសភ ។

១ ម. ប្លវង្គមេ ។ ឱ. ប្លវង្គមេ ។





ខ្លាឃ្មុំដទៃទៀត មានសម្បុរខ្មៅ រោមវែង ជាម្រឹគឲ្យទុក្ខ បុរសដែលខ្លាទាំងនោះឃើញហើយ រត់ឡើងដើមឈើ ក៏មិនរួច ។ ក្របីជាសត្វប្រហារ តែងតែងនឹងស្នែងមានចុងមុត តែងត្រាច់ទៅមកក្នុងព្រៃនោះ ជិតទន្លេឈ្មោះសោតុម្ពរ ។ ម្នាលនាងមទ្រី នាងដូចជាមេគោដែលមានចិត្តជាប់នឹងកូន ឃើញគោឈ្មោលកំពុងទៅតាមហ្វូងម្រឹគក្នុងព្រៃ នឹងធ្វើដូចម្ដេច ។ ម្នាលនាងមទ្រី ក៏យល់ មុខជានឹងមានភ័យធំ ដែលជាស្ត្រីមិនដឹងទីខេត្ត ព្រោះឃើញស្វាទាំងឡាយដ៏កាច ដែលផ្ដុំនៅក្បាលឈើ ដែលទៅមកបានដោយព្រៃ ។ ម្នាលនាងមទ្រី កាលពីមុន នាងត្រាប់តែឮ (សូរសម្លេង) ចចក រមែងតក់ស្លុតរឿយៗ ដល់ទៅភ្នំវង្កត តើនឹងធ្វើដូចម្ដេចទៅ ។ កាលដែលពួកបក្សីប្រជុំគ្នា ក្នុងវេលា ដែលព្រះអាទិត្យឋិតនៅ ត្រង់កណ្ដាល (ថ្ងៃត្រង់) ព្រៃធំក៏លាន់ឮសម្លេងគឹកកង ចុះនាងចង់ទៅក្នុងព្រៃធំនោះធ្វើអ្វី ។

(៦៦០) ព្រះរាជបុត្រីព្រះនាងមទ្រី មានអវយវៈទាំងអស់ល្អ បានក្រាបបង្គំទូលព្រះរាជាក្នុងកាលនោះថា ព្រះអង្គទ្រង់ត្រាស់ប្រាប់ ដល់ខ្ញុំម្ចាស់ នូវភ័យ ដែលមានចំពោះមុខទាំងឡាយណា ក្នុងព្រៃ ៦ ខ្ញុំម្ចាស់អាចទទួលអត់ទ្រាំភ័យ ដែលមានចំពោះមុខទាំងអស់នោះបាន ហេតុនោះព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅក្នុងព្រៃឡើយ ។

កាសំ កុសំ[១] បោដកិលំ ឧសិរំ មុញ្ជបព្វជំ
ឧរសា បនុទហិស្សាមិ នាស្ស ហិស្សាមិ ទុន្នយា ។
ពហូហិ វត្តចរិយាហិ កុមារី វិន្ទតេ បតឹ
ឧទរស្សុបរោធេន គោហនុវេឋនេន ច
អគ្គិស្ស បារិចរិយាយ ឧទកុម្មុជ្ជនេន ច
វេធព្យំ កដុកំ លោកេ គច្ឆញ្ញេវ រថេសភ ។
អបិស្សា ហោតិ អប្បត្តោ ឧច្ឆិដ្ឋំ បរិភុញ្ជតិ
យោ នំ ហត្ថេ គហេត្វាន អកាមំ បរិកឌ្ឍតិ
វេធព្យំ កដុកំ លោកេ គច្ឆញ្ញេវ រថេសភ ។
កេសគ្គហណមុក្ខេបា ភូម្យា ច បរិសុម្ភនា
ទត្វា ច នោ បក្កមតិ ពហុំ ទុក្ខំ អនប្បកំ
វេធព្យំ កដុកំ លោកេ គច្ឆញ្ញេវ រថេសភ ។

១ ម. កុតំ ។





ខ្ញុំម្ចាស់នឹងយកទ្រូងរុញរានរំលើងនូវស្មៅក្រ ស្មៅភ្លាំង ស្មៅសសិត ស្មៅក្ដាស ស្មៅបាបូស នឹងស្មៅដំណេកខ្លាយ (មើលមុខព្រះវេ-ស្សន្តរជាប្ដីខ្ញុំម្ចាស់) ខ្ញុំម្ចាស់នឹងនាំព្រះភស្ដាទៅមិនឲ្យលំបាក ។ កុមារីតែងបានប្ដីដោយការប្រព្រឹត្តនូវវត្តដ៏ច្រើនគឺដោយការចិញ្ចឹមពោះ (បន្ថយអាហារឲ្យពោះតូច) ដោយការដើរអង្គុំ ដោយការបើមានស-ណ្ដាប់ខ្ទួចថ្គាមគោ នឹងការរឹតចង្កេះខ្លួនដោយឈ្នួត (ធ្វើឲ្យចង្កេះរៀវ) ដោយការបំរើភ្លើង (គាំងភ្លើង) នឹងដោយការមុជលាងនិងសំអាតដោយទឹក ភាពជាស្ត្រីមេម៉ាយ រមែងក្ដៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅក្នុងពេលនេះឯង ។ ម្យ៉ាងទៀត បុរសមិនគួរបរិភោគរបស់សំណល់នៃស្ត្រីមេម៉ាយនោះ បុរសណា ស្ទុះ (មានជាតិជាបុរសអាក្រក់) ក៏ចាប់ដៃទាញស្ត្រីមេម៉ាយនោះដែលមិនប្រាថ្នាផង ភាពជាស្ត្រីមេម៉ាយ រមែងក្ដៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅក្នុងពេលនេះឯង ។ បុរសតែងឲ្យសេចក្ដីទុក្ខយ៉ាងច្រើនលើសលុប ដោយការចាប់សក់ទាញលើក ដោយការផ្ដួលលើផែនដី ហើយក៏មិនដើរចេញទៅណា (នៅឈរមើលព្រងើយ) ភាពជាស្ត្រីមេម៉ាយរមែងក្ដៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅមិនខានឡើយ ។

សុក្កច្ឆវី វេធវេរា  ទត្តា សុខសមេធិតា

អកាមំ បរិកឌ្ឍន្តិ  ឧលូកញ្ញេវ វាយសា

វេធព្យំ កដុកំ លោកេ  គច្ឆញ្ញេវ រថេសភ ។

អបិ ញាតិកុលេ ផីតេ  កំសបជ្ជោតនេ វសំ

នេវាភិវាក្យំ ន លភេ  ភាតូហិ សខិនីហិ ច

វេធព្យំ កដុកំ លោកេ  គច្ឆញ្ញេវ រថេសភ ។

នគ្គា នទី អនុទកា  នគ្គំ រដ្ឋំ អរាជកំ

ឥត្ថីបិ វិធវា នគ្គា  យស្សាបិ ទស ភាតរោ

វេធព្យំ កដុកំ លោកេ  គច្ឆញ្ញេវ រថេសភ ។

ធជោ រថស្ស បញ្ញាណំ  ធូមោ បញ្ញាណមគ្គិនោ

រាជា រដ្ឋស្ស បញ្ញាណំ  ភត្តា បញ្ញាណមិត្ថិយា

វេធព្យំ កដុកំ លោកេ  គច្ឆញ្ញេវ រថេសភ ។



កូនប្រុសដែលមានសម្បុរ-ស ជាអ្នកត្រូវការនឹងស្ត្រីមេម៉ាយ ប្រកាន់ខ្ពស់ មានលំអដ៏ប្រសើរ ឬធន្យ (ទ្រព្យបរិបូណ៌) ហើយទទឹងទាញស្ត្រីមេម៉ាយដែលមិនត្រូវការនឹងខ្លួន ដូចក្អែកដែលទាញមៀម ដូច្នោះ ការជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅកុំខានឡើយ ។ មួយវិញទៀត ស្ត្រីមេម៉ាយ កាលនៅក្នុងត្រកូលញាតិដ៏ស្តុកស្តម្ភ រុងរឿងដោយភាជន៍មាស ក៏នៅតែបានពាក្យតិះដៀលអំពីបងប្អូនប្រុស និងពួកស្ត្រីជាសំឡាញ់ពុំខាន ការជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅកុំខានឡើយ ។ ទន្លេដែលគ្មានទឹក ហៅថា ទន្លេស្រាត ដែនដែលគ្មានព្រះរាជា ហៅថា ដែនស្រាត ចំណែកស្ត្រីមេម៉ាយ បើទុកជាមានបងប្អូនប្រុសដល់ ១០ នាក់ ក៏ហៅថា ស្ត្រីស្រាត ការជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅកុំខានឡើយ ។ ទង់ជាគ្រឿងប្រាកដរបស់រថ ផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ព្រះរាជាជាគ្រឿងប្រាកដរបស់ដែន ភស្តាជាគ្រឿងប្រាកដរបស់ស្ត្រី ការជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅកុំខានឡើយ ។

យា ទលិទ្ទី ទលិទ្ទស្ស អឌ្ឍា អឌ្ឍស្ស កិត្តិមា
តំ វេ ទេវា បសំសន្តិ ទុក្ករំ ហិ ករោតិ សា ។
សាមិកំ អនុពន្ធិស្សំ សទា កាសាយវាសិនី
បថព្យាបិ អភិជ្ជន្ត្យា វេធព្យំ កដុកិត្ថិយា ។
អបិ សាគរបរិយន្តំ ពហុវិត្តធរំ មហឹ
នានារតនបរិបូរំ និច្ឆេ វេស្សន្តរំ វិនា ។
កថំ នុ តាសំ ហទយំ សុខរា វត ឥត្ថិយោ
យា សាមិកេ ទុក្ខិតម្ហិ សុខមិច្ឆន្តិ អត្តនោ ។
និក្ខមន្តេ មហារាជេ សិវីនំ រដ្ឋវឌ្ឍនេ
តមហំ អនុពន្ធិស្សំ សព្វកាមទទោ ហិ មេ ។
(៦៦១) តមព្រវិ មហារាជា មទ្ទឹ សព្វង្គសោភនំ
ឥមេ តេ ទហរា បុត្តា ជាលី កណ្ហាជិនា ចុភោ
និក្ខិប្ប លក្ខណេ គច្ឆ មយន្តេ បោសយាមសេ ។



ស្ត្រីណាដែលមានកេរ្តិ៍ឈ្មោះ កាលស្វាមីទាល់ក្រ ក៏ជាស្ត្រីទាល់ក្រ (ជាមួយ) កាលស្វាមីស្តុកស្តម្ភ ក៏ជាស្ត្រីស្តុកស្តម្ភ (ជាមួយ) ពួកទេវតារមែងសរសើរស្ត្រីនោះឯង ព្រោះថា ស្ត្រីនោះធ្វើអំពើដែលគេធ្វើបានដោយក្រ ។ ខ្ញុំម្ចាស់នឹងស្លៀកសំពត់កាសាយៈ ហើយដើរតាមប្តីសព្វៗកាល ការជាស្ត្រីមេម៉ាយ ទោះបីមានផែនដីមិនបែក (បានជាធំលើផែនដីទាំងមូល) ក៏នៅតែក្តៅក្រហាយដែរ ។ មួយវិញទៀត ខ្ញុំម្ចាស់បើប្រាសចាកព្រះវេស្សន្តរជាប្តីហើយ មិនចង់បានផែនដីដែលមានសមុទ្រកៀកព័ទ្ធជុំវិញ ប្រកបដោយទ្រព្យដ៏ច្រើន ជាផែនដីបរិបូណ៌ដោយរតនៈផ្សេងៗ ទេ ។ ចិត្តស្ត្រីណា ជាស្ត្រីដ៏សែនយ៉ាប់ក្រៃលែង កាលដែលស្វាមីដល់នូវសេចក្តីទុក្ខហើយ ប្រាថ្នាសេចក្តីសុខដល់ខ្លួនតែម្នាក់ឯង ហ្ឫទ័យរបស់ស្ត្រីទាំងនោះនឹងទៅជាដូចម្តេចហ្ន៎ ។ កាលបើមហារាជ ដែលញ៉ាំងដែនអ្នកសិវីឲ្យចំរើន ចេញចេញទៅហើយ ខ្ញុំម្ចាស់ នឹងទៅតាមមហារាជនោះ ព្រោះថា ព្រះអង្គជាអ្នកឲ្យនូវវត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ខ្ញុំម្ចាស់ ។

(៦៦១) ព្រះបាទសញ្ជយមហារាជ មានព្រះរាជឱង្ការនឹងព្រះនាងមទ្រី ដែលមានអវយវៈទាំងអស់ដ៏ល្អនោះថា ម្នាលនាងមានលក្ខណ៍ នាងចូរទុកកូនតូចទាំងពីររបស់នាង គឺជាលី និងនាងកណ្ហាជិនានេះ ហើយទៅចុះ យើងនឹងចិញ្ចឹមកូនតូចទាំងនោះ ។

(៦៦៦) តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា

បិយា មេ បុត្តកា ទេវ ជាលី កណ្ហាជិនា ចុភោ

ត្យម្ហិ ឥត្ថ រមិស្សន្តិ អរញ្ញេ ជីវិសោកិនំ ។

(៦៦៧) តមព្រវិ មហារាជា សិវីនំ រដ្ឋវឌ្ឍនោ

សាលីនមោទនំ ភុត្វា សុចិំ មំសូបសេចនំ

រុក្ខផលានិ ភុញ្ជន្តា កថំ កាហន្តិ ទារកា ។

ភុត្វា សតបលេ កំសេ សោវណ្ណេ សតរាជិកេ

រុក្ខបត្តេសុ ភុញ្ជន្តា កថំ កាហន្តិ ទារកា ។

កាសិយានិ ច ធារេត្វា ខោមកោទុម្ពរានិ ច

កុសចីរានិ ធារេន្តា កថំ កាហន្តិ ទារកា ។

វយ្ហាហិ បរិយាយិត្វា សិវិកាយ រថេន ច

បត្តិកា បរិធាវន្តា កថំ កាហន្តិ ទារកា ។

កូដាគារេ សយិត្វាន និវាតេ ផុសិតគ្គឡេ

សយន្តា រុក្ខមូលស្មឹ កថំ កាហន្តិ ទារកា ។



(៦៦៦) ព្រះរាជបុត្រីព្រះនាងមទ្រី ដែលមានអវយវៈទាំងអស់ល្អ បាន ក្រាបទូលព្រះរាជាវិញថា បពិត្រព្រះទេវៈ កូនខ្ញុំទាំងពីរគឺជាលីនឹងនាងកណ្ហាជិនា ជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ កូនខ្ញុំទាំងពីរនោះ នឹង (ញុំាងហឫទ័យ) នៃយើងខ្ញុំ ដែលមិនទាន់ប្រាសចាកសេចក្តីសោក ឲ្យត្រេកអរក្នុងព្រៃនោះបាន ។

(៦៦៧) ព្រះបាទសញ្ជយមហារាជ ទ្រង់ញុំាងដែនអ្នកសិវិរដ្ឋឲ្យចំរើន មានព្រះបន្ទូលនឹងព្រះនាងមទ្រីនោះថា ក្មេងទាំងពីរ ធ្លាប់បរិភោគបាយអង្ករសាលី លាយដោយសាច់ដ៏ស្អាត នឹងបរិភោគផ្លែឈើធ្វើម្តេចកើត ។ ក្មេងទាំងពីរ ធ្លាប់បរិភោគភោជនក្នុងភាជន៍មាស ដែលមានទម្ងន់ ១០០ បល: មានស្នាមចំឡាក់មួយ ១០០ នឹងបរិភោគភោជនដែលដាក់ក្នុងស្លឹកឈើធ្វើម្តេចកើត ។ ក្មេងទាំងពីរ ធ្លាប់ស្លៀកដណ្តប់សំពត់អ្នកដែនកាសីផង សំពត់ខោមៈផង សំពត់កោទុម្ពរៈផង នឹងស្លៀកដណ្តប់សំពត់ ដែលគ្រងដោយស្បូវភ្លាំងធ្វើម្តេចកើត ។ ក្មេងទាំងពីរ ធ្លាប់ទៅដោយដំរី ដោយគ្រែស្នែង ដោយរថ នឹងដើរទៅដោយជើង ធ្វើម្តេចកើត ។ ក្មេងទាំងពីរ ធ្លាប់ដេកក្នុងផ្ទះមានកំពូល មានសន្ទះទ្វារនឹងបង្អួច ដ៏ជិតស្និទ្ធ ខ្យល់ចេញចូលមិនបាន នឹងដេកទៀបគល់ឈើ ធ្វើម្តេចកើត ។

បល្លង្កេសុ សយិត្វាន គោណកេ ចិត្តសន្ថតេ
សយន្តា តិណសន្ថារេ កថំ កាហន្តិ ទារកា ។
កុង្កុមេន វិលិម្បិត្វា អគលុចន្ទនេន ច
រជោជល្លានិ ធារេន្តា កថំ កាហន្តិ ទារកា ។
ចាមរីមោរហត្ថេហិ វីជិតង្គា សុខេ ឋិតា
ផុដ្ឋា(១) ឌំសេហិ មកសេហិ កថំ កាហន្តិ ទារកា ។

(៦៦៦) តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភនា
មា ទេវ បរិទេវេសិ មា ច ត្វំ វិមនោ អហុ
យថា មយំ ការិស្សាម តថា ហេស្សន្តិ ទារកា ។
ឥទំ វត្វាន បក្កាមិ មទ្ទី សព្វង្គសោភនា
សិវិមគ្គេន អន្វេសិ បុត្តេ អាទាយ លក្ខណា ។

(៦៦៧) តតោ វេស្សន្តរោ រាជា ទានំ ទត្វាន ខត្តិយោ
បិតុ មាតុញ្ច វន្ទិត្វា កត្វា ច នំ បទក្ខិណំ ។
ចតុវាហឹ រថំ យុត្តំ សីឃមារុយ្ហ សន្ទនំ
អាទាយ បុត្តទារញ្ច វង្កំ បាយាសិ បព្វតំ ។

---
១ ម. ឌដ្ឋា ។





ក្មេងទាំងពីរ ធ្លាប់ដេកលើបល្ល័ង្ក លើកម្រាលរោមវែង នឹងលើកម្រាលដ៏វិចិត្រ នឹងដេកលើកម្រាលស្មៅ ធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់លាបស្រឡាបដោយគ្រឿងក្រអូប គឺខ្លឹមក្រឹស្នា ខ្លឹមចន្ទន៍ នឹងស្លៀកដណ្ដប់សំពត់ប្រឡាក់ធូលី ធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់ឋិតនៅក្នុងសេចក្ដីសុខ មានអ្នកបក់នៅដោយផ្លិតរោមចាមរី នឹងកន្ទុយក្ងោក ត្រូវរបោមមូសបំពាល់ នឹងធ្វើដូចម្ដេចកើត ។

(៦៦៦) ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈទាំងអស់ដ៏ល្អ ក្រាបទូលព្រះរាជបតីនោះថា បពិត្រព្រះទេវៈ ព្រះអង្គកុំទ្រង់ព្រះកន្សែងឡើយ សូមព្រះអង្គកុំមានព្រះហឫទ័យតក់អន់ឡើយ ខ្ញុំម្ចាស់ទាំងពីរនាក់នឹងរស់នៅយ៉ាងណា ក្មេងទាំងពីរនាក់ ក៏រស់នៅយ៉ាងនោះដែរ ។ ព្រះនាងមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អ ដ៏ទ្រង់លក្ខណ៍ លុះបានពោលពាក្យយ៉ាងនេះហើយ ក៏នាំព្រះរាជបុត្រាបុត្រីទៅតាមផ្លូវដែលព្រះបាទសិវិ (វេស្សន្តរ) ទ្រង់ស្ដេចទៅ ។

(៦៦៧) លំដាប់នោះ ព្រះវេស្សន្តរជាក្សត្រទ្រង់បានឲ្យទាន ហើយក៏ថ្វាយបង្គំព្រះបិតានឹងព្រះមាតា ធ្វើប្រទក្សិណព្រះបិតានឹងព្រះមាតានោះ ។ ព្រះវេស្សន្តរឡើងកាន់រថ ដែលទឹមដោយសេះ ៤ មានសន្ទុះដ៏លឿន នាំបុត្រាបុត្រីនឹងព្រះជាយា ស្ដេចទៅកាន់គិរីវង្កត ។

(៦៦៦) តតោ វេស្សន្តរោ រាជា យេនាសិ ពហុកោ ជនោ
អាមន្ត ខោ តំ គច្ឆាម អរោគា ហោន្តុ ញាតយោ ។

(៦៦៧) និក្ខមិត្វាន នគរា និវត្តិត្វា វិលោកិតេ
តទាបិ បថវី កម្បិ សិនេរុវនវដំសកា ។

(៦៦៨) ឥង្ឃ មទ្ទិ និសាមេហិ រម្មរូបំ(១) ទិស្សតិ
អាវាសោ សិវិសេដ្ឋស្ស បេត្តិកំ ភវនំ មម ។

(៦៦៩) តំ ព្រាហ្មណា អន្វគមុំ តេ នំ អស្សេ អយាចិសុំ
យាចិតោ បដិបាទេសិ ចតុន្នំ ចតុរោ ហយេ ។

(៦៧០) ឥង្ឃ មទ្ទិ និសាមេហិ ចិត្តរូបំ ទិស្សតិ
មិគរោហិច្ចវណ្ណេន ទក្ខិណស្សា វហន្តិ មំ ។

១ ឱ. រម្មរូបំ ។





(៦៦៦) លំដាប់នោះ ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរ ទ្រង់ប្រាប់សំដៅទៅរកទីដែលមានជនច្រើន ហើយត្រាស់ថា យើងសូមលាអ្នកទាំងអស់គ្នាទៅហើយ សូមឱ្យពួកញាតិកុំមានរោគឡើយ ។

(៦៦៧) (អភិសម្ពុទ្ធគាថា) កាលដែលព្រះបាទវេស្សន្តរ ស្តេចចេញអំពីព្រះនគរ ហើយងាកក្រោយក្រឡេកទតព្រះរាជនិវេសន៍ គ្រានោះឯង ផែនដី ដែលមានភ្នំសិនេរុនឹងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។

(៦៦៨) (ព្រះវេស្សន្តរ...) នែនាងមទ្រី នាងចូរគន់មើលចុះ (នុ៎ះ) និវេសន៍ របស់ព្រះបាទសិវីដ៏ប្រសើរ (នុ៎ះ) គឺនិវេសន៍របស់យើងដែលព្រះបិតាប្រទានឱ្យ ប្រាកដជារូបគួរត្រេកអរ ។

(៦៦៩) ពួកព្រាហ្មណ៍បានទៅតាមព្រះបាទវេស្សន្តរនោះ ព្រាហ្មណ៍ទាំងនោះ បានសុំសេះទាំងឡាយអំពីព្រះបាទវេស្សន្តរនោះ ព្រះបាទវេស្សន្តរ លុះពួកព្រាហ្មណ៍សុំហើយ ក៏បានប្រទានសេះទាំង ៤ ដល់ព្រាហ្មណ៍ទាំង ៤ នាក់ ។

(៦៧០) (ព្រះបាទវេស្សន្តរ ..) នែមទ្រី នាងចូរគន់មើលចុះ ម្រឹគទាំងឡាយមានភេទជារមាំង នាំខ្ញុំទៅ ដូចសេះដែលគេទូន្មានល្អហើយ ប្រាកដជាប្រពៃវិចិត្រ ។

(៦៧១)អថេត្ថ បញ្ចមោ អាគា សោ តំ រថមយាចថ

តស្ស តំ យាចមានស្ស ន ចស្សុបហតោ មនោ។

(៦៧២)តតោ វេស្សន្តរោ រាជា ឱរោបេត្វា សកំ ជនំ

អស្សាសយិ អស្សរថំ ព្រាហ្មណស្ស ធនេសិនោ។

(៦៧៣)ត្វំ មទ្ទិ កណ្ហំ គណ្ហាហិ លហុកា ឯសា កនិដ្ឋិកា

អហំ ជាលឹ គហេស្សាមិ គរុកោ ភាតិកោ ហិ សោ។

(៦៧៤)រាជា កុមារមាទាយ រាជបុត្តី ច ទារិកំ

សម្មោទមានា បក្កាមុំ អញ្ញមញ្ញំ បិយំវទា។

ទានកណ្ឌំ នាម ។

(៦៧៥)យទិ កេចិ មនុជា ឯន្តិ អនុមគ្គេ បដិបថេ

មគ្គន្តេ បដិបុច្ឆាម កុហឹ វង្កតបព្វតោ ។

តេ តត្ថ អម្ហេ បស្សិត្វា ករុណំ គិរមុទីរយុំ

ទុក្ខន្តេ បដិវេទេន្តិ ទូរេ វង្កតបព្វតោ ។



(៦៧១) លំដាប់នោះ ព្រាហ្មណ៍ទី៥ ក៏មកក្នុងព្រៃនោះ ព្រាហ្មណ៍នោះបានសុំរថអំពីព្រះបាទវេស្សន្តរនោះ ព្រះបាទវេស្សន្តរក៏ប្រទានរថដល់ព្រាហ្មណ៍នោះ ព្រះហឫទ័យរបស់ព្រះបាទវេស្សន្តរ មិនបានរួញរាឡើយ ។

(៦៧២) ព្រះបាទវេស្សន្តរទ្រង់ឲ្យជន គឺព្រះទេវី បុត្រា បុត្រីរបស់ព្រះអង្គ (ចុះពីរថនោះ) រួចប្រទានរថសេះ ដល់ព្រាហ្មណ៍អ្នកស្វែងទ្រព្យ ។

(៦៧៣)(ព្រះបាទវេស្សន្តរ...)ថាមទ្រី នាងចូរពរកណ្ហាចុះ ព្រោះកណ្ហានុះជាប្អូននៅតូចស្រាល ខ្ញុំនឹងពរជាលី ព្រោះជាលីនោះជាបងធំធ្ងន់ ។

(៦៧៤) ព្រះរាជាទ្រង់ពរជាលីកុមារ ចំណែកព្រះរាជបុត្រី ទ្រង់ពរនាងកណ្ហាជិនា ទ្រង់យាងទៅ មានព្រះបន្ទូលពីរោះជាទីស្រឡាញ់ សំណេះសំណាលទៅវិញទៅមក ។

ចប់ ទានកណ្ឌ ។

(៦៧៥) (អភិសម្ពុទ្ធគាថា) (ក្សត្រទាំងនោះ មានព្រះបន្ទូលសំណេះសំណាលថា) ប្រសិនបើពួកមនុស្សណាមួយ មកតាមផ្លូវជាលំដាប់ យើងនឹងសួរគេនូវផ្លូវនឹងមនុស្សទាំងនោះថា វង្កតបព្វតនៅក្នុងទីណា ។ មនុស្សទាំងនោះ បានឃើញយើងក្នុងទីនោះហើយ សមជាខ្លួនយំ មុខគួរឲ្យអាណោចអាធម្ម មនុស្សទាំងនោះ ក៏ប្រាប់សេចក្តីទុក្ខថា វង្កតបព្វតនៅក្នុងទីឆ្ងាយ ។

(២៧៦) យទិ បស្សន្តិ បវនេ ទារកា ផលិនេ ទុមេ
តេសំ ផលានំ ហេតុម្ហិ ឧបក្កមន្តិ ទារកា ។
រោទន្តេ ទារកេ ទិស្វា ឧព្ពិគ្គា[១] វិបុលា ទុមា
សយមេវោនមិត្វាន ឧបគច្ឆន្តិ ទារកេ ។
ឥទំ អច្ឆេរកំ ទិស្វា អព្ភុតំ លោមហំសនំ
សាធុការំ បវត្តេសិ មទ្ទី សព្វង្គសោភនា ។
អច្ឆេរំ វត លោកស្មឹ អព្ភុតំ លោមហំសនំ
វេស្សន្តរស្ស តេជេន សយមេវោនតា ទុមា ។
(២៧៧) សង្ខិបឹសុ បថំ យក្ខា អនុកម្បាយ ទារកេ
និក្ខន្តទិវសេនេវ ចេតរដ្ឋមុបាគមុំ ។
(២៧៨) តេ គន្ត្វា ទីឃមទ្ធានំ ចេតរដ្ឋមុបាគមុំ
ឥទ្ធំ ផីតំ ជនបទំ ពហុមំសសុរោទនំ ។
(២៧៩) ចេតិយោ បរិកិរឹសុ ទិស្វា លក្ខណមាគតំ
សុខុមាលី វតាយយ្យា[២] បត្តិកា បរិធាវតិ ។
វយ្ហាហិ បរិយាយិត្វា សិវិកាយ រថេន ច
សាជ្ជ អជ្ជ អញ្ញស្មឹ បត្តិកា បរិធាវតិ ។

---

១ ម. ឧព្ពិគ្គា ។ ២ ម. តិណមយ្យា ។



(២៧៦) បើក្មេងទាំងពីរ បានឃើញដើមឈើ ដែលមានផ្លែក្នុងព្រៃ ក្មេងទាំងពីររមែងយំទារ ព្រោះហេតុចង់បានផ្លែឈើទាំងនោះ ។ ដើមឈើទាំងឡាយដ៏ខ្ពស់ ឃើញក្មេងទាំងពីរ កំពុងយំ ក៏ទោរទន់មកជិតក្មេងទាំងពីរ ដោយខ្លួនឯងតែម្តង ។ ព្រះនាងមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អ បានឃើញហេតុនេះ ជាហេតុអស្ចារ្យចំឡែកគួរឲ្យព្រឺរោម ក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ឱហ្ន៎ (នេះ) គួរអស្ចារ្យណាស់ ចំឡែកណាស់ គួរឲ្យព្រឺរោមក្នុងលោក ដើមឈើទាំងឡាយស្រាប់តែទោរទន់មកឯង ដោយតេជះនៃព្រះវេស្សន្តរ ។

(២៧៧) យក្ខទាំងឡាយ បំប្រួញផ្លូវដោយសេចក្តីអនុគ្រោះចំពោះក្មេងទាំងពីរ ក្សត្រទាំងនោះ បានទៅដល់ដែនឈ្មោះចេតៈ តែមួយថ្ងៃ រាប់ពីស្តេចចេញទៅ ។

(២៧៨) ក្សត្រទាំងនោះយាងទៅកាន់ផ្លូវឆ្ងាយ ក៏បានដល់ដែនឈ្មោះចេតៈ ដែលជាជនបទស្តុកស្តម្ភទូលាយ មានសាច់ សុរា និងបាយច្រើន ។

(២៧៩) អ្នកដែនចេតៈទាំងឡាយ បានឃើញព្រះនាងមទ្រីដែលប្រកបដោយលក្ខណៈ ស្តេចមកដល់ហើយ ក៏នាំគ្នាចោមរោមពោលថា ឱហ្ន៎ ព្រះនាងម្ចាស់ជាសុខុមាលជាតិ ស្តេចសព្វាមកដោយព្រះបាទទទេ ។ សម្តេចព្រះមទ្រីនោះ ធ្លាប់ស្តេចទៅដោយវរ គ្រែស្នែង និងរថ តែក្នុងថ្ងៃនេះ ស្តេចទៅក្នុងព្រៃដោយព្រះបាទទទេ ។

(៦៨០) តំ ទិស្វា ចេតបាមោក្ខា រោទមានា ឧបាគមុំ

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ ។

កច្ចិ បិតា អរោគោ តេ សិវីនញ្ច អនាមយំ

កោ តេ ពលំ មហារាជ កោ នុ តេ រថមណ្ឌលំ ។

អនស្សកោ អរថកោ ទីឃមទ្ធានមាគតោ

កច្ចាមិត្តេហិ បកតោ អនុប្បត្តោសិមំ ទិសំ ។

(៦៨១) កុសលញ្ចេវ មេ សម្ម អថោ សម្ម អនាមយំ

អថោ បិតា អរោគោ មេ សិវីនញ្ច អនាមយំ ។

អហំ ហិ កុញ្ជរំ ទជ្ជំ ឦសាទន្តំ ឧរូឡ្ហវំ

ខេត្តញ្ញុំ សព្វយុទ្ធានំ សព្វសេតំ គជុត្តមំ ។

បណ្ឌុកម្ពលសញ្ឆន្នំ បភិន្នំ សត្តុមទ្ទនំ

ទន្តឹ សវាលវីជនឹ សេតំ កេលាសសាទិសំ ។

សសេតច្ឆត្តំ សុបធេយ្យំ សាថព្វនំ សហត្ថិបំ

អគ្គយានំ រាជវាហឹ ព្រាហ្មណានំ អទាសហំ[1] ។

[1] ម. អទាតតំ ។





(៦៨០) ព្រះរាជាចេតៈទាំងឡាយ លុះបានឃើញព្រះបាទវេស្សន្តរនោះ ហើយ ក៏ទ្រង់ព្រះកន្សែងចូលទៅជិតថា បពិត្រព្រះទេវៈ ព្រះអង្គសុខស្រួលទេឬ បពិត្រព្រះទេវៈ ព្រះអង្គមិនមានជម្ងឺដម្កាត់ទេឬ ។ ព្រះបិតារបស់ព្រះអង្គ មិនមានរោគទេឬ ពួកអ្នកសិវិរដ្ឋមិនមានជម្ងឺដម្កាត់ទេឬ បពិត្រមហារាជ ទៅណាទៅពួកពលរបស់ព្រះអង្គ ទៅណាទៅរថមណ្ឌលរបស់ព្រះអង្គ ។ ព្រះអង្គទ្រង់ស្ដេចមកកាន់ផ្លូវឆ្ងាយ មិនមានសេះ មិនមានរថ ពួកបច្ចាមិត្រគ្របសង្កត់ព្រះអង្គឬ ទើបស្ដេចយាងមកកាន់ទិសនេះ ។

(៦៨១) (ព្រះបាទវេស្សន្តរ...) ម្នាលសំឡាញ់ទាំងឡាយ យើងមានសេចក្ដីសុខស្រួលទេ ម្នាលសំឡាញ់ទាំងឡាយ យើងមិនមានជម្ងឺដម្កាត់ទេ ព្រះបិតារបស់យើង ក៏មិនមានរោគទេ ទាំងពួកអ្នកសិវិរដ្ឋ ក៏មិនមានជម្ងឺដម្កាត់ដែរ ។ យើងបានឱ្យដំរី មានភ្លុក-ដ៏វែង អាចពុះពារសត្រូវ ស្គាល់ទីក្រៅចម្បាំងគ្រប់យ៉ាង ជាដំរីដ៏ឧត្ដម-សសុទ្ធ បិទបាំងដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេងអាចញាំញីសត្រូវបាន មានភ្លុក(ល្អ)ប្រកបដោយផ្លិត ជាដំរី-ស ប្រៀបហាក់ដូចភ្នំកៃលាស ។ ខ្ញុំបានឱ្យដំរីនោះព្រមទាំងស្វេ-តច្ឆត្រ ព្រមទាំងកម្រាលលើខ្នងដ៏ល្អ ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សា ជាយានដ៏ប្រសើរ ជារាជពាហនៈ ដល់ពួកព្រាហ្មណ៍ ។

តស្ស មេ សិវយោ កុទ្ធា   បិតា ឧបហតោមនោ

អវរុទ្ធសិ មំ រាជា   វង្កំ គច្ឆាមិ បព្វតំ

និក្កាសិ សម្មា ជាតាជ   វនេ យត្ថ វសេម្ហសេ ។

[៦៨២] ស្វាគតន្តេ មហារាជ   អថោ តេ អទុរាគតំ

ឥស្សរោសិ អនុប្បត្តោ   យំ ឥធត្ថិ បវេទយ ។

សាកំ ភិសំ មធុំ មំសំ   សុទ្ធំ សាលីនមោទនំ

បរិភុញ្ជ មហារាជ   បាហុនោ នោសិ អាគតោ ។

[៦៨៣] បដិគ្គហិតំ យំ ទិន្នំ   សព្វស្ស អគ្ឃិយំ កតំ

អវរុទ្ធសិ មំ រាជា   វង្កំ គច្ឆាមិ បព្វតំ

និក្កាសិ សម្មា ជាតាជ   វនេ យត្ថ វសេម្ហសេ ។

[៦៨៤] ឥធេវ តាវ អច្ឆស្សុ   ទេវមេជ្ជ រាជសាក

យាវ នេតា គមិស្សន្តិ   រញ្ញោ សន្តិកេ យាចិតុំ ។

និជ្ឈាបេតុំ មហារាជំ   សិវីនំ រដ្ឋវឌ្ឍនំ ។





ព្រោះអំពើណានោះហើយ បានជាពួកអ្នកសិវិក្រោធនឹងខ្ញុំ ទាំងព្រះបិតា ក៏មានព្រះហឫទ័យកាក់អន់នឹងខ្ញុំ ព្រះរាជាទ្រង់ដេញខ្ញុំ ខ្ញុំនឹងទៅឯវង្កតបព៌ត នែសំឡាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹង នូវការសង់ទីនៅក្នុងព្រៃ ។

[៦៨២] (ពួកព្រះរាជាទេវៈ...) បពិត្រមហារាជ ព្រះអង្គទ្រង់យាងមក ស្រួលហើយ ព្រះអង្គមិនមែនយាងមកដោយអាក្រក់ទេ ព្រះអង្គ ជាធំទ្រង់ស្តេចមកដល់ហើយ សូមព្រះអង្គ មានព្រះបន្ទូលប្រាប់ របស់ដែលមានក្នុងទីនេះ ។ បពិត្រមហារាជ សូមព្រះអង្គទ្រង់ សោយអន្លក់ ក្រអៅឈូក ទឹកឃ្មុំ សាច់ និងបាយនៃអង្ករស្រូវ សាលីដ៏ស្អាត ព្រោះព្រះអង្គយាងមកហើយ ទុកជាភ្ញៀវរបស់ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ។

[៦៨៣] (ព្រះវេស្សន្តរ...) វត្ថុណា ដែលអ្នកទាំងអស់គ្នាឲ្យជារបស់ មានតម្លៃ បានឲ្យដល់ខ្ញុំ វត្ថុនោះ ខ្ញុំក៏បានទទួលហើយ (តែថា) ព្រះរាជាទ្រង់បណ្តេញខ្ញុំ ខ្ញុំនឹងទៅឯវង្កតបព៌ត នែសំឡាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹងនូវការសង់ទីនៅក្នុងព្រៃ ។

[៦៨៤] (ពួកព្រះរាជាទេវៈ...) បពិត្រព្រះអង្គដ៏ប្រសើរក្នុងរាជ សូមព្រះអង្គស្តេចគង់នៅ ត្រឹមដែលពួកនេះនាំគ្នាទៅ ទំរាំពួក ព្រះរាជាទេវៈ ទាំងនោះទៅកាន់សំណាក់ព្រះរាជា ដើម្បីទូលអង្វរ ។

តំ តំ ចេតា បុរក្ខិត្វា បតីតា លទ្ធបច្ចយា
បរិការេត្វាន គច្ឆន្តិ សិវី ជាតាហិ ទត្តិយ ។

(៤៨៥) មា ភេ ត្វិត្ត គមនំ រញ្ញោ សន្តិកា យាចិតុំ
និដ្ឋាបេតុំ មហាភជំ ភជាមិ ភត្តុ និស្សរេ ។
អក្កុទ្ធា ហិ សិវិយោ ពលគ្គា នេគមា ច យេ
តេ បដំសេតុមិច្ឆន្តិ ភជាមំ មម ការណា ។

(៤៨៦) សចេ បិតា បវត្តតុ រដ្ឋស្មា រដ្ឋវឌ្ឍន
សិវេ រដ្ឋំ ការេហិ ចេតេហិ បរិភារិតោ
ឥទ្ធំ ផីតញ្ចិត រដ្ឋំ ឥទ្ធោ ជនបទោ មហា
មតិ ការេហិ ត្វំ ទេវ រដ្ឋស្សមនុសាសិតុំ ។

(៤៨៧) ន មេ ជានោ មតិ អត្ថិ រដ្ឋស្សមនុសាសិតុំ
បព្វាជិតស្ស រដ្ឋស្មា ចេតបុត្តា សុណាថ មេ ។



ពួកព្រះរាជាចេតៈត្រេកអរបានទីពឹងហើយ ហែហមចោមរោមព្រះអង្គទៅ ដើម្បីញ៉ាំងមហាជន ដែលញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យខឹង ឲ្យលើកទោសទោល បពិត្រញាតិ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ។

(៤៨៥) (ព្រះបាទវេស្សន្តរ...) អ្នកទាំងឡាយ កុំពេញចិត្តនឹងការទៅកាន់សំណាក់ព្រះរាជា ដើម្បីទូលអង្វរមហាជន ឲ្យលើកទោសទោល ព្រោះព្រះរាជាមិនជាធំ ក្នុងការនោះទេ ។ ព្រោះពួកអ្នកសិវិរដ្ឋណា ជានាយពលក្តី ជាអ្នកនិគមក្តី សុទ្ធតែជាអ្នកខឹង ពួកអ្នកសិវិរដ្ឋនោះ ចង់បណ្តេញចាំងព្រះរាជា ព្រោះហេតុតែយើងផង ។

(៤៨៦) (ពួកព្រះរាជាចេតៈ...) បពិត្រព្រះអង្គអ្នកញ៉ាំងដែនឲ្យចំរើន បើដំណើរហ្នឹងមានក្នុងដែនខ្លួនមែន សូមព្រះអង្គដែលពួកព្រះរាជាចេតៈហែហមរោម ទ្រង់សោយរាជ្យក្នុងដែននេះចុះ ។ រីដែននេះ ជាដែនស្តុកស្តម្ភសប្បាយ ជនបទក៏ស្តុកស្តម្ភ បពិត្រព្រះទេវៈ សូមព្រះអង្គ ទ្រង់ធ្វើសេចក្តីពេញព្រះទ័យ ដើម្បីនឹងគ្រប់គ្រងរាជ្យ ។

(៤៨៧) (ព្រះបាទវេស្សន្តរ..) យើងដែលគេបណ្តេញ អំពីដែនហើយ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីពេញចិត្ត ដើម្បីនឹងគ្រប់គ្រងរាជ្យទេ ម្នាលពួកចេតបុត្រ អ្នកចូរស្តាប់ខ្ញុំ ។

អត្ថា សិវយោ អស្សុ   ពលគ្គា នេគមា ច យេ

បព្វាជិតស្ស រដ្ឋស្មា   នេក រដ្ឋិកសេចយិំ ។

អសម្មោទិយំ បិ វោ អស្ស   អច្ចន្តំ មម ការណា

សិវីហិ ភណ្ឌនញ្ចាបិ   វិគ្គហោ មេ ន រុច្ចតិ ។

អថស្ស ភណ្ឌនំ ឃោរំ   សម្បហារោ អនប្បកោ

ឯកស្ស ការណា មយ្ហំ   ហិំសេយ្យ ពហុកោ ជនោ ។

បដិគ្គហិតំ យំ ទិន្នំ   សព្វស្ស អគ្ឃិយំ កតំ

អវរុទ្ធសិ មំ រាជា   វង្កំ គច្ឆាមិ បព្វតំ

ឱកាសំ សម្បជានាថ   វនេ យត្ថ វសាមសេ ។

(៤៨៨) តក្យ នេ មយតក្ខាម   យថាបិ កុសលា តថា

រាជសី យត្ថ សន្តិ   រោហុតក្តី សមាហិតា ។

ឯស សេលោ មហារាជ   បព្វតោ គន្ធមាទនោ

យត្ថ ត្វំ សហ បុត្តេហិ   សហ ភរិយាយ វច្ឆសិ[១]

១ ឱ. វិច្ឆសិ ។



បើខ្ញុំព្រះរាជាទេវតាអភិសេកហើយ ដែលរាស្ត្របណ្ដេញចាកដែនកម្ព្ររហើយ ពួកអ្នកសិវិរដ្ឋណា ជាអាមាត្យក្តី ជាអ្នកនិគមក្តី ពួកអ្នកសិវិរដ្ឋនោះ មិនត្រេកអរទេ ។ ទាំងមិនមានសេចក្តីស្មោះស្ម័គ្រនឹងអ្នកទាំងឡាយ ព្រោះហេតុតែខ្ញុំជាដាច់ខាត ខ្ញុំមិនគាប់ចិត្តនឹងការប្រកួតប្រកាន់ទាស់ទែង ជាមួយពួកអ្នកសិវិរដ្ឋ ។ តទៅនឹងកើតមានការប្រកួតប្រកាន់ដ៏តន្ទឹក ការវាយដំគ្នាយ៉ាងសាហាវមុខជានឹងមានមិនខាន ជនជាច្រើនគប្បីបៀតបៀនគ្នា ព្រោះហេតុតែខ្ញុំម្នាក់ឯង ។ វត្ថុណាដែលអ្នកទាំងអស់គ្នាធ្វើឲ្យជារបស់មានតម្លៃ បានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំបានទទួលហើយ ព្រះរាជាទ្រង់បណ្ដេញខ្ញុំ ខ្ញុំនឹងទៅភ្នំវង្កត ម្នាលសំឡាញ់ទាំងឡាយ អ្នកទាំងឡាយ ចូរដឹងនូវឱកាសជាទីនៅក្នុងព្រៃ ។

(៤៨៨) (ក្រាបព្រះរាជទេវៈ...) ពួករាជបុត្តិក ជាអ្នកឈ្លាស ជាអ្នកប៉ុនប្រសប់ មានចិត្តតាំងមាំ តែងនាំទៅកាន់ទីណា ពួកខ្ញុំព្រះបង្គំជាខ្ញុំ នឹងក្រាបទូលដល់ព្រះអង្គនូវទីនោះ បពិត្រមហារាជ ព្រះអង្គនឹងទៅជាមួយព្រះរាជបុត្រ ព្រមទាំងព្រះអគ្គមហេសី នៅក្នុងទីណា ភ្នំនោះ ហៅថា ភ្នំគន្ធមាទន៍ ជាទីគួរនៅស្រួល ។

(៦៨៩) ឥតោ គន្ត្វា មហាព្រហ្មេ   ឧជុំ យេនុត្តរាមុខោ ។

អថ ទក្ខសិ ភទ្ទន្តេ   វេបុល្លំ នាម បព្វតំ

នានាទុមគណាកិណ្ណំ   សីតច្ឆាយំ មនោរមំ ។

តមតិក្កម្ម ភទ្ទន្តេ   អថ ទក្ខសិ អាបគំ

នទឹ កេតុមតឹ នាម   គម្ភីរំ គិរិគព្ភរំ ។

បុថុលោមមច្ឆាកិណ្ណំ   សុបតិត្ថំ មហោទកំ

តត្ថ ន្ហាត្វា បិវិត្វា ច   អស្សាសេត្វា សបុត្តកោ ។

អថ ទក្ខសិ ភទ្ទន្តេ   និគ្រោធំ មធុបិប្ផលំ

រម្មកេ សិខរេ ជាតំ   សីតច្ឆាយំ មនោរមំ ។

អថ ទក្ខសិ ភទ្ទន្តេ   នាឡិកំ នាម បព្វតំ

នានាទិជគណាកិណ្ណំ   សេលំ កិម្បុរិសាយុតំ ។

តស្ស ឧត្តរបុព្វេន   មុចលិន្ទោ នាម សោ សរោ

បុណ្ឌរីកេហិ សញ្ឆន្នោ   សេតសោគន្ធិកេហិ ច ។



(៦៨៩) ព្រះតាបសពោលថា កាលបើមានមុខទៅកាន់ទិសខាងជើង ពីក្រោយ ខ្ញុំនៅព្រះអាស្រមនេះ បពិត្រមហាព្រាហ្មណ៍ សូមព្រះអង្គទ្រង់យាងទៅកាន់ទិសនេះ សំដៅត្រង់ទៅទិសខាងជើង ។ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ ព្រះអង្គនឹងទតឃើញភ្នំឈ្មោះវេបុល្ល: ជាភ្នំដេរដាសដោយពួកឈើផ្សេងៗ មានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ។ បពិត្រព្រះអង្គដ៏ចំរើន លុះព្រះអង្គទ្រង់ផុតភ្នំនោះហើយ នឹងបានឃើញស្ទឹងមួយជាទីហូរទៅនៃទឹក ឈ្មោះកេតុមតី ជាស្ទឹងជ្រៅ ហូរចេញអំពីផ្នែកភ្នំ ។ ដេរដាសដោយហ្វូងត្រីច្រើន មានកំពង់ងូតស្រួល មានទឹកច្រើន ព្រះអង្គស្រង់ផង សោយផង ល្ហែលោមព្រះរាជបុត្ររបស់ព្រះអង្គក្នុងស្ទឹងនោះ ។ បពិត្រព្រះអង្គដ៏ចំរើន តទៅព្រះអង្គនឹងទតឃើញដើមជ្រៃ មានផ្លែផ្អែម ដុះនៅលើកំពូលភ្នំជាទីត្រេកអរ មានម្លប់ត្រជាក់ ជាទីគាប់នៃចិត្ត ។ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះព្រះអង្គនឹងទតឃើញភ្នំមួយ ឈ្មោះនាឡិក: ជាវិការៈនៃថ្ម ដេរដាសដោយពួកសត្វស្លាបផ្សេងៗ ក្រកដោយពួកកិន្នរ ។ នៅកាន់ខាងជើងទៀងខាងកើតនៃភ្នំនោះ មានស្រះឈ្មោះមុចលិន្ទ ដេរដាសដោយឈូកសផង ឧប្បលសផង ចង្កុលណីផង ។

សោ វំ មេឃសង្កាសំ ធុវំ ហរិតសទ្ទលំ

សីហោភិចិសបេក្ខិរ វនសណ្ឌំ វិគាហយ

បុប្ផរុក្ខេហិ សញ្ឆន្នំ ផលរុក្ខេហិ ចូភយំ ។

តត្ថ ពិន្ទុស្សរា វគ្គូ នានាវណ្ណា ពហូ ទិជា

កូជន្តមុបកូជន្តិ ឧតុសម្បុប្ផិតេ ទុមេ ។

គន្ត្វា គិរិវិទុគ្គានិ នទីនំ បភវានិ ច

សោ អទ្ទស បោក្ខរណឹ ករញ្ជកកុធាយុតំ ។

បុថុលោមមច្ឆាកិណ្ណំ សុបតិត្ថំ មហោទកំ

សមញ្ច ចតុរស្សញ្ច សាទុំ អប្បដិគន្ធិយំ ។

តស្សា ឧត្តរបុព្វេន បណ្ណសាលំ អមាបយ

បណ្ណសាលំ អមាបេត្វា ឧញ្ឆាចរិយាយ ឦហថ ។

វនប្បវេសនំ ចប់ ។

[៦៩០] អហុ ភាសី កលិង្គេសុ ជូជកោ នាម ព្រាហ្មណោ

តស្សាសិ ទហរា ភរិយា[១] នាមេនាមិត្តតាបនា ។

តា មំ តត្ថ គតាវេន្តំ នទីឧទកហារិយា

ថិយោ មំ បរិភាសិំសុ សមាគន្ត្វា កុតូហលា ។

---

១ ម. ចំយា ។



ព្រះអង្គចូលទៅកាន់ព្រៃដូចពពកខៀវ មានស្មៅខៀវខ្ចីស្រស់ ជានិច្ច ចូលទៅកាន់ដងព្រៃដែលដាសដោយឈើមានផ្កា និងឈើ មានផ្លែទាំងពីរ ដូចសីហៈត្រូវចំណី ។ ក្នុងព្រៃនោះ មានពពួក បក្សីជាច្រើនមានសម្បុរផ្សេងៗគ្នា មានសំឡេងមូល មានសំឡេងពីរោះ ស្រែកយំឆ្លើយឆ្លងគ្នាទៅមក លើដើមឈើមានផ្កាតែតាមរដូវ ។ ព្រះអង្គទ្រង់ស្ដេចទៅកាន់ដងភ្នំ និងកន្លែងជាកើតនៃស្ទឹងទាំងឡាយ និងបានទតឃើញស្រះបោក្ខរណីដែលដាសដោយដើមករញ្ជ ឬ ពាយជាប និងដើមចាប់ ។ ជាស្រះដែលដាសដោយពួកត្រីធំៗច្រើនមាន កំពង់ រាបស្មើល្អ មានទឹកច្រើន មានសណ្ឋានបួនជ្រុងស្មើ មានទឹកមាន រសឆ្ងាញ់ មានក្លិនមិនគួរខ្ពើម ។ សូមព្រះអង្គទ្រង់សាងបណ្ណ- សាលា ទ្រង់ទិសខាងជើងនៀងខាងកើត នៃស្រះបោក្ខរណីនោះ លុះទ្រង់បានសាងបណ្ណសាលាហើយ សូមទ្រង់ព្យាយាមត្រាច់ស្វែង រកផលាផលចិញ្ចឹមព្រះអង្គចុះ ។

ចប់ វនប្បវេសន៍ ។

(៦៩០) (អភិសម្ពុទ្ធគាថា) មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជក នៅក្នុងដែន កលិង្គៈ ឯភរិយារបស់គាត់នៅក្មេង ឈ្មោះនាងអមិត្តតាបនា ។ ពួក ស្រីៗដែលមកដងទឹកស្ទឹងក្នុងស្រុកនោះ បានទៅសួរចំពោះនាងអមិត្តតាបនា នោះ ផ្ដើមជេរប្រដៅតាមរកម លុះក្រោយមកនាងអមិត្តតាបនានោះ

អមិត្តា នូន តេ មាតា  អមិត្តោ នូន តេ បិតា
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។
អហិតំ វត តេ ញាតី  មន្តយិំសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។
ឧក្កដំ(១) វត តេ ញាតី  មន្តយិំសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។
បាបកំ វត តេ ញាតី  មន្តយិំសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។
អមនាបំ វត តេ ញាតី  មន្តយិំសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។
អមនាបវាសំ វស  ជិណ្ណេន បតិនា សហ
យា ត្វំ វសសិ ជិណ្ណស្ស  មតន្តេ ជីវិតា វរំ ។
ន ហិ នូន តុយ្ហំ កល្យាណី  បិតា មាតា ច សោភនេ
អញ្ញំ ភត្តារំ វិន្ទិំសុ
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។
ទុយិដ្ឋន្តេ នវមិយំ  អកតំ អគ្គិហុត្តកំ
យេ តំ ជិណ្ណស្ស បាទំសុ  ឯវំ ទហរិយំ សតិំ ។

---
១ ម. ទុក្កដំ ។





ថា ម្ដាយនាងជាសត្រូវពិត ឪពុកនាងជាសត្រូវពិត បានជាឲ្យនាង
ដែលនៅក្មេងក្រមុំយ៉ាងនេះដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់
នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ មិនជាប្រយោជន៍ដល់នាងពិតហើយ
បានជានាំគ្នាលើកនាង ដែលនៅក្មេងក្រមុំយ៉ាងនេះ ឲ្យដល់ព្រា-
ហ្មណ៍ចាស់ ។ ពួកញាតិរបស់នាង នាំគ្នាទៅប្រឹក្សា ក្នុងទីស្ងាត់ជា
ការអាក្រក់របស់នាងប្រាកដហើយ បានជានាំគ្នាលើកនាង ដែល
នៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំ
គ្នាទៅប្រឹក្សាក្នុងទីស្ងាត់ ជាការលាមករបស់នាងប្រាកដហើយ បាន
ជានាំគ្នាលើកនាង ដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។
ពួកញាតិរបស់នាង នាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ មិនជាទីគាប់ចិត្ត
របស់នាងពិតហើយ បានជានាំគ្នាលើកនាង ដែលនៅក្រមុំយ៉ាងនេះ
ឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងនៅទាំងមិនគាប់ចិត្តជាមួយនឹងប្ដី
ចាស់ ព្រោះនាងនៅក្នុងផ្ទះនៃប្ដីចាស់បែបនេះ នាងស្លាប់ទៅប្រសើរ
ជាងការរស់នៅ ។ នែនាងមានលំអយ៉ាងនេះ មាតាបិតារបស់
នាងរកជាគេប្ដីផ្សេងឲ្យនាងមិនបាន បានជានាំគ្នាលើកនាង ដែល
នៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងបានធ្វើការបូជាមិន
ល្អក្នុងថ្ងៃទី ៩ ពិតមិនបានធ្វើការបូជាព្រះអគ្គី បានជាពួកញាតិ
នាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះ ឲ្យដល់ព្រាហ្មណ៍ចាស់ ។

សមណេ ព្រាហ្មណេ ចេវ ព្រហ្មចរិយបរាយណេ
សាត្ថំ លោកេ អកំសុសំ(១) សីលវន្តេ ពហុស្សុតេ
យាត្វំ សេសិ ជិណ្ណស្ស ឃរំ ចរាមិ សតី ។
ន ទុក្ខំ អហិនា ទដ្ឋំ ន ទុក្ខំ សត្តិយា ហតំ
តញ្ច ទុក្ខញ្ច តិព្វញ្ច យំ បស្សេ ជិណ្ណកំ បតិំ ។
នត្ថិ ខិឌ្ឌា នត្ថិ រតិ ជិណ្ណេន បតិនា សហ
នត្ថិ អល្លាបសល្លាបោ ជគ្ឃិតម្បិ ន សោភតិ ។
យទា ច ទហរោ ទហរា មន្តយន្តិ រហោគតា
សព្វេ សោកា វិនស្សន្តិ យេ កេចិ ហទយស្សិតា
ទហរា ត្វំ រូបវតី បុរិសានំភិបត្ថិតា
គច្ឆ ញាតិកុលេ អច្ឆ កឹ ជិណ្ណោ រមយិស្សតិ ។
(៤៩៣) ន តេ ព្រាហ្មណ គច្ឆាមិ នទឹ ឧទកហារិយា
ថិយោ មំ បរិហាសន្តិ តយា ជិណ្ណេន ព្រាហ្មណ ។
(៤៩៤) មា មេ ត្វំ អការ កម្មំ មា មេ ឧទកមាហរិ
អហំ ឧទកមាហិស្សំ មា ភោតិ កុប្បិតា អហុ ។

១ ម. បរិស្សុំ ។



នាងជាក់ជាដែលបម្រើពួកសមណៈនិងព្រាហ្មណ៍ មានព្រហ្មចរិយៈប្រព្រឹត្តទៅខាងមុខ ជាអ្នកមានសីល មានការរៀនដឹងច្រើន ក្នុងលោក ឥឡូវជានាងដែលនៅគ្រប់យ៉ាងនេះនៅ (ក្នុងផ្ទះ) ព្រាហ្មណ៍ចាស់ ។ ពស់ចឹក មិនធ្ងន់ជាទុក្ខទេ ចាក់សំរែងមុត ក៏មិនធ្ងន់ជាទុក្ខដែរ ត្រង់នាងឃើញប្តីចាស់នោះ ទើបជាទុក្ខ ជាងជាគ្រឿងក្តៅក្រហាយ ។ ល្បែងមិនមាន ការត្រេកអរមិនមាន ការចរចាទៅមក ជាមួយនឹងប្តីចាស់មិនមាន ចាំងការសើច ក៏មិនសមល្អ ។ កាលណាប្តីក្មេង ប្រពន្ធក្មេង នៅប្រឹក្សាគ្នាក្នុងទីស្ងាត់ កាលណោះ សេចក្តីសោកទ្រូងយ៉ាងណាមួយ ដែលអាស្រ័យនៅហ្ឫទ័យ ក៏វិនាសបាត់ទៅ នាងក្មេង មានរូបល្អ ដែលជាទីប្រាថ្នានៃពួកបុរសណាស់ ចូរនាងវិលទៅនៅឯត្រកូលញាតិវិញទៅ ព្រាហ្មណ៍ចាស់ នឹងធ្វើនាងឲ្យត្រេកអរដូចម្តេចកើត ។

(៤៩៣) (នាងអមិត្តតាបនា ..) នែព្រាហ្មណ៍ ខ្ញុំមិនទៅដងទឹកស្ទឹងឲ្យអ្នកទេ នែព្រាហ្មណ៍ ពួកស្រីៗ ជេរប្រទេចខ្ញុំ ព្រោះតែអ្នកចាស់ ។

(៤៩៤) (ជូជក..) នាងកុំធ្វើកិច្ចការឲ្យអញឡើយ នាងកុំដងទឹកមកឲ្យអញឡើយ អញនឹងដងទឹក (ខ្លួនឯង) ម្នាលនាងដ៏ចំរើន នាងកុំក្រេវក្រោធឡើយ ។

(៥៩៣) នាហំ តម្ហិ កុលេ ជាតា យំ ត្វំ ឧទកមាហរេ

សច្ចំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមហំ ឃរេ ។

សចេ មេ ទាសំ ទាសឹ វា នានយិស្សសិ ព្រាហ្មណ

សច្ចំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមិ សន្តិកេ ។

(៥៩៤) នត្ថិ មេ សិប្បដ្ឋានំ វា ធនំ ធញ្ញញ្ច ព្រាហ្មណិ

កុតោហំ ទាសំ ទាសឹ វា អានយិស្សាមិ ភោតិយា

អហំ ភោតឹ ឧបដ្ឋិស្សំ មា ភោតី កុបិតា អហុ ។

(៥៩៥) ឯហិ តេ អហមក្ខិស្សំ យថា មេ វចនំ សុតំ

ឯស វេស្សន្តរោ រាជា វង្កេ វសតិ បព្វតេ ។

តំ ត្វំ គន្ត្វាន យាចស្សុ ទាសំ ទាសញ្ច ព្រាហ្មណ

សោ តេ ទស្សតិ យាចិតោ ទាសំ ទាសញ្ច ខត្តិយោ ។

(៥៩៦) ជិណ្ណោហមស្មិ ទុព្វលោ ទីឃោ ចទ្ធា សុទុគ្គមោ

មា ភោតី បរិទេវេសិ មា ភោតី វិមនា អហុ

អហំ ភោតឹ ឧបដ្ឋិស្សំ មា ភោតី កុបិតា អហុ ។



(៥៩៣) (នាហំ តម្ហិ កុលេ...) ខ្ញុំមិនមែនកើតក្នុងត្រកូល (ស្រីអ្នកបម្រើ) នោះទេ អ្នកដងទឹកណា (ខ្ញុំមិនត្រូវការទឹកនោះទេ) នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ។ នែព្រាហ្មណ៍ បើអ្នកមិននាំខ្ញុំប្រុស ឬខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំមិននៅក្នុងសំណាក់អ្នកទេ ។

(៥៩៤) (នត្ថិ...) ម្នាលនាងព្រាហ្មណី ហេតុជាទីតាំង នៃសិល្បៈក្ដី ទ្រព្យក្ដី ស្រូវក្ដី របស់អញមិនមានទេ អញនឹងនាំយកខ្ញុំប្រុស ឬខ្ញុំស្រីមកឲ្យនាងដ៏ចំរើន អំពីណាបាន អញនឹងបំរើនាងដ៏ចំរើន នាងដ៏ចំរើនកុំក្រេវក្រោធឡើយ ។

(៥៩៥) (ឯហិ តេ អហមក្ខិស្សំ...) អ្នកចូរមក ខ្ញុំនឹងប្រាប់អ្នក តាមពាក្យដែលខ្ញុំឮមកថា ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរនោះ ស្ដេចគង់នៅឯគិរីវង្កត ។ ម្នាលព្រាហ្មណ៍ អ្នកចូរទៅសុំខ្ញុំប្រុសខ្ញុំស្រីនឹងព្រះអង្គវេស្សន្តរនោះ ។ ក្សត្រនោះដែលអ្នកសុំហើយ មុខជាប្រទានខ្ញុំប្រុសខ្ញុំស្រីដល់អ្នកពុំខាន ។

(៥៩៦ (ជិណ្ណោ...) អញចាស់ហើយ មានកំឡាំងថយ ទាំងផ្លូវក៏ឆ្ងាយលំបាកទៅណាស់ នាងដ៏ចំរើនកុំយំយែកឡើយ នាងដ៏ចំរើន កុំអាក់អន់ចិត្តឡើយ អញនឹងបំរើនាងដ៏ចំរើន នាងដ៏ចំរើនកុំក្រេវក្រោធឡើយ ។

[៨៤៧] យថា អគ្គិ សន្តត្តំ អបេក្ខេ បភាវិតោ
ឯវមេវ តុវំ ព្រហ្មេ អគ្គីវ បភាវិតោ ។
សចេ មេ ទាសិំ ទាសំ វា នានយិស្សសិ ព្រាហ្មណ
ឯវំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមិហំ ឃរេ
អមនាបន្តេ ករិស្សាមិ តន្តេ ទុក្ខំ ភវិស្សតិ ។
នក្ខត្តេ ឧតុបុព្វេសុ យទា មំ ទក្ខសិលង្កតំ
អញ្ញេហិ សទ្ធឹ រមមានំ តន្តេ ទុក្ខំ ភវិស្សតិ ។
អទស្សនេន មយ្ហន្តេ ជិណ្ណស្ស បរិទេវតោ
ភិយ្យោ វង្កា ច បលិតា ពហូ ហេស្សន្តិ ព្រាហ្មណ ។

[៨៤៨] តតោ សោ ព្រាហ្មណោ ភីតោ ព្រាហ្មណិយា វសានុគោ
អដ្ដិតោ កាមរាគេន ព្រាហ្មណិំ ឯតទព្រវិ ។
បាទេយ្យំ មេ ករោហិ ត្វំ សង្កុល្យា សគុឡានិ[១] ច
មធុបិណ្ឌិកា ច សុកតាយោ សត្តុភត្តញ្ច ព្រាហ្មណិ ។
អានយិស្សំ មេថុនកេ ឧភោ ទាសកុមារកេ
តេ ច បរិចារិស្សន្តិ រត្តិន្ទិវមតន្ទិតា ។

១ ម. សង្កុល្យោ សគុឡានិ ។ ឱ. សង្កុល្យេ សាគលានិ ។





[៨៤៧] (នាងអមិត្តតាបនា...) តាហោនមិនទាន់ទៅឆេះស្រែម មិន ទាន់ឡើង ឆាញ់មុនទៅហើយ ម្នាលព្រាហ្មណ៍ អ្នកមិនទាន់ពាំងទៅ ផងតាញ់យ៉ាងនោះដែរ ។ នែព្រាហ្មណ៍ បើអ្នកមិននាំខ្ញុំប្រុសខ្ញុំស្រី មកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះ អ្នកទេ ខ្ញុំនឹងធ្វើអំពើមិនគាប់ចិត្តដល់អ្នក អំពើនោះនឹងជាទុក្ខដល់ អ្នកមិនខាន កាលណា អ្នកនឹងឃើញខ្ញុំតាក់តែង (ខ្លួន) ត្រេក ត្រេកអរជាមួយនឹងពួកប្រុសឯទៀត ក្នុងថ្ងៃនក្ខត្តឫក្ស ក្នុងកាលដើម រដូវទាំងឡាយ អំពើនោះនឹងជាទុក្ខ ដល់អ្នកក្នុងកាលនោះ ។ ម្នាលព្រាហ្មណ៍ កាលអ្នកជាបុគ្គលចាស់ខ្សោយកំរើបកប់ ព្រោះ តែមិនបានឃើញខ្ញុំ ខ្នងនឹងតែកោងទៅ សក់នឹងស្កូវច្រើនឡើង ។

[៨៤៨] (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រាហ្មណ៍នោះ ភិតភ័យ លុះ ក្នុងអំណាចនាងព្រាហ្មណី ត្រូវកាមរាគគ្របសង្កត់ បានពោលនឹង នាងព្រាហ្មណីយ៉ាងនេះថា ម្នាលនាងព្រាហ្មណី នាងចូរធ្វើ ព្រាបល្បផង ព្រាបលាជផង នំទឹកឃ្មុំដែលគេធ្វើល្អហើយផង ភក្ត សត្តុផង ឲ្យជាស្បៀងដល់អញ ។ អញនឹងនាំកុមារជាខ្ញុំពីរនាក់ មានជាតិគោត្រស្រគ្រួលនឹងប្រពន្ធ មើល្បីនាង កុមារទាំងនោះ នឹង បំរើនាង ទាំងយប់ទាំងថ្ងៃ មិនខ្ជិលច្រអូសឡើយ ។

(២៩៩) ឥទំ វត្វា ព្រហ្មពន្ធុ បដិមុញ្ចិ ឧបាហនំ
តតោ សោ មន្តយិត្វាន ភរិយំ កត្វា បទក្ខិណំ ។
បក្កាមិ សោ រុណ្ណមុខោ ព្រាហ្មណោ សហិតព្វតោ
សិវីនំ នគរំ ផីតំ ទាសបរិយេសនញ្ចរំ ។

(៣០០) សោ តត្ថ គន្ត្វា អវចាសិ យេ តត្ថាសុំ សមាគតា
កុហឹ វេស្សន្តរោ រាជា កត្ថ បស្សេមុ ខត្តិយំ ។
តេ ជនា តំ អវចិំសុ យេ តត្ថាសុំ សមាគតា
តុម្ហេហិ ព្រហ្មេ បកតោ អតិទានេន ខត្តិយោ
បព្វាជិតោ សកា រដ្ឋា វង្កេ វសតិ បព្វតេ ។
តុម្ហេហិ ព្រហ្មេ បកតោ អតិទានេន ខត្តិយោ
អាទាយ បុត្តទារញ្ច វង្កេ វសតិ បព្វតេ ។

(៣០១) សោ ចោទិតោ ព្រាហ្មណិយា ព្រាហ្មណោ កាមគិទ្ធិមា
អឃន្តំ បដិសេវិត្ថ
វនេ វាឡមិគាកិណ្ណេ ខគ្គទីបិនិសេវិតេ ។
អាទាយ វេឡុវំ ទណ្ឌំ អគ្គិហុត្តំ កមណ្ឌលុំ
សោ បាវិសិ ព្រហារញ្ញំ យត្ថ អស្សោសិ កាមទំ ។



(២៩៩) ជូជក ជាព្រហ្មពន្ធុ លុះពោលពាក្យនេះហើយ ក៏ពាក់ស្បែកជើង លំដាប់នោះ គាត់ធ្វើប្រទក្សិណភរិយាហើយប្រឹក្សា ចៀសចេញទៅព្រាហ្មណ៍នោះ មានមុខយំសស្រាក់ បានសមាទានវត្តគ្រប់ទៅកាន់នគរ របស់ពួកអ្នកសិវិរដ្ឋ ជានគរដ៏ធូលាយ ស្វែងរកខ្ញុំប្រុសខ្ញុំស្រី ។

(៣០០) ព្រាហ្មណ៍នោះ បានដើរទៅក្នុងនគរនោះ សាកសួរជនទាំងឡាយ ដែលប្រជុំគ្នាក្នុងនគរនោះថា ព្រះបាទវេស្សន្តរ ស្ដេចយាងទៅក្នុងទីណា យើងបានឃើញព្រះអង្គនោះក្នុងទីណា ។ ពួកជនដែលមកប្រជុំគ្នាក្នុងទីនោះ ។ បាននិយាយនឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នក ធ្វើឲ្យឃ្លាតឆ្ងាយទៅ ព្រោះអតិទាន (ទានប្រសើរ) ចេញចាកដែនរបស់ព្រះអង្គ ។ ទៅគង់នៅភ្នំវង្កត ។ ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នក ធ្វើឲ្យឃ្លាតឆ្ងាយទៅ ព្រោះអតិទាន ទ្រង់នាំព្រះបុត្រនិងព្រះទេវីទៅគង់នៅឯភ្នំវង្កត ។

(៣០១) ជូជកនោះ ដែលនាងព្រាហ្មណីដាស់តឿនហើយ ជាបុគ្គលមានសេចក្ដីជាប់ចំពាក់ក្នុងកាម ក៏ធ្វើទុក្ខក្នុងព្រៃដែលពាសពេញដោយម្រឹគសាហាវ ជាទីដែលពាសពេញដោយខ្លាដំបង តម្រែងទៅហើយ ។ ព្រាហ្មណ៍នោះ បានកាន់ដំបងដែលធ្វើពីឫស្សី និងគ្រឿងសម្រាប់បូជាភ្លើង ព្រមទាំងកុណ្ឌិ ចូលទៅកាន់ព្រៃធំ ដែលគាត់បានឮថា ជាទីដែលព្រះវេស្សន្តរ ព្រះអង្គឲ្យសេចក្ដីប្រាថ្នា (តទៅ) ។

តំ បវឌ្ឍិ ព្រហារញ្ញេ  កោកោ ធំ បរិភយេ
វិក្កន្តិ សោ វិបន្នផ្ទោ  ធុរេ បត្វា អបក្កមិ ៗ
ធរតោ សោ ព្រហ្មលោកគ្គា  កោកលុទ្ធោ អសញ្ញតោ
វិត្តិសេដ្ឋាហារណោ នថ្មោ  (សុនខេហិ បរិកិរិតោ
វិក្ខស្មិញ ឆិសិរេច្ឆោ ?)  ឥមា គាថា អភាសថ ៗ
(៣០៦) កោ ពជបុត្តំ ធំសកំ  ជយន្តមបរាជិតំ
កាយេ ទេវស្ស ធាតារំ  កោ មេ វេស្សន្តរំ វទេ ៗ
យោ យាចតំ បតិដ្ឋាសិ  គុន្នំ ធរណីរិវ
ធរណូបមំ មហារាជំ  កោ មេ វេស្សន្តរំ វទេ ៗ
យោ យាចតំ គតី អាសិ  សវន្តីនំ វ សាគរោ
ឧទធូបមំ(១) មហារាជំ  កោ មេ វេស្សន្តរំ វទេ ៗ
កល្យាណតិត្ថំ សុចិមំ(២)  សីតូទកំ មនោរមំ
បុណ្ឌរីកេហិ សញ្ឆន្នំ  យុត្តំ កិញ្ជក្ខរេណុនា
រហទូបមំ មហារាជំ  កោ មេ វេស្សន្តរំ វទេ ៗ
អស្សត្ថំ វ បថេ ជាតំ  សីតច្ឆាយំ មនោរមំ
សន្តានំ វិស្សមេតារំ(៣)  កិលន្តានំ បដិគ្គហំ
តថូបមំ មហារាជំ  កោ មេ វេស្សន្តរំ វទេ ៗ

---
១ ម. ឧទ្ធិមន្តំ ។ ២ ម. សុចិមំ ។ ឱ. សុចិន្តំ ។ ៣ ឱ. ម. វិសមេតារំ ។



ផ្ដាំទាំងឡាយ ចុះចោមរោមគាត់ កំពុងឈ្លបទៅកាន់ព្រៃធំនោះ គាត់វង្វេងផ្លូវ ស្រែកទ្រហោយំ ស្ទុះហ្វាតទៅក្នុងទីឆ្ងាយអំពីផ្លូវ (ដែលជាទីទៅកាន់គីរីវង្កត) ។ លុះដាច់នោះ ព្រាហ្មណ៍ដែលលោភក្នុងភោគៈ មិនសង្រួម ទៅវង្វេងទៅក្នុងផ្លូវដែលជាទីទៅកាន់គីរីវង្កត (ត្រូវឆ្កែព្រៃទាំងឡាយតាមខាំ ក៏ឡើងទៅអង្គុយនៅលើមែកឈើ) ប្អូនពោលគាថាទាំងនេះថា

(៣០៦) ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរ ដែលជារាជបុត្ត ដ៏ប្រសើរ ឈ្នះសត្រូវដែលគេញុំមិនចាលចាញ់ ជាអ្នកឲ្យសេចក្តីក្សេម ក្នុងកាលមានភ័យ ដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណា ជាទីពឹងនៃពួកអ្នកសូម ដូចជាផែនដីជាទីពឹងនៃពួកសត្វ ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចផែនដី ដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណា ជាទីទៅរបស់ពួកអ្នកសូម ដូចជាសាគរជាទីទៅ នៃស្ទឹងទាំងឡាយ ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាសមុទ្រ ដល់ខ្ញុំ ។ ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាអន្លង់ទឹកមានកំពង់ល្អ ស្អាត មានទឹកត្រជាក់ ជាទីមនោរម្យ ដេរដាស ដោយផ្កាឈូក-ស ប្រកបដោយលំអងផ្កា ដល់ខ្ញុំ ។

មហានិបាតេ ទសមស្ស វេស្សន្តរជាតកស្ស អដ្ឋកថា

និគ្រោធំ វនេ ជាតំ  សីតច្ឆាយំ មនោរមំ

សត្តានំ វិសមេតានំ  កាលត្តានំ បដិគ្គហំ

គជ្ជុបមំ មហាកដំ  កោ មេ វេស្សន្តរំ វិទូ ។

អម្ពំ ឥវ វនេ ជាតំ  សីតច្ឆាយំ មនោរមំ

សត្តានំ វិសមេតានំ  កាលត្តានំ បដិគ្គហំ

គជ្ជុបមំ មហាកដំ  កោ មេ វេស្សន្តរំ វិទូ ។

សាលំ ឥវ វនេ ជាតំ  សីតច្ឆាយំ មនោរមំ

សត្តានំ វិសមេតានំ  កាលត្តានំ បដិគ្គហំ

គជ្ជុបមំ មហាកដំ  កោ មេ វេស្សន្តរំ វិទូ ។

ជម្ពុំ ឥវ វនេ ជាតំ  សីតច្ឆាយំ មនោរមំ

សត្តានំ វិសមេតានំ  កាលត្តានំ បដិគ្គហំ

គជ្ជុបមំ មហាកដំ  កោ មេ វេស្សន្តរំ វិទូ ។

ឯវំ មេ វិលបតោ  បរិទ្ទេវស្ស ព្រហ្មណេ

អហំ ជានន្តិ យោ វជ្ជា  នន្ទិំ សោ ជនយេ មមំ ។



មហានិបាត វេស្សន្តរជាតក ទី ១០ ជូជកបព្វៈ

នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមពោធិ៍ធ្លាយ ដែលដុះលើក្បាលថ្ម មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាករបស់បុគ្គលនឿយហត់ ជាទីពឹងនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមជ្រៃ ដែលដុះលើក្បាលថ្ម មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពឹងនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមស្វាយ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពឹងនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមរាំងដែលដុះលើក្បាលថ្ម មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពឹងនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមឈើដែលដុះលើក្បាលថ្ម មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពឹងនាក់នៃបុគ្គលដែលលំបាក ដល់ខ្ញុំ ។ មួយវិញទៀត បុគ្គលណា និយាយប្រាប់ថា ខ្ញុំឯងស្គាល់កន្លែងនៅ នៃព្រះបាទវេស្សន្តរខ្លះ ដល់ខ្ញុំ ដែលចូលមកកាន់ព្រៃធំ កំពុងយំរៀបរាប់ យ៉ាងនេះ បុគ្គលនោះ ឈ្មោះថាញុំាងសេចក្តីត្រេកត្រអាលឲ្យកើត ដល់ខ្ញុំ ។

បញ្ញា មេ វិលបតោ  បរិទ្ធស្ស ព្រហ្មណេ
អហំ ជាតវេទ យោ វជ្ជា  វេស្សន្តរជិកិសតំ
តាយ សោ បតាភិធាយ បសវេ បុញ្ញំ អនប្បកំ ។
(៣០៣) តស្ស ទេវោ បដិស្សុណិ អភិញ្ញា លុទ្ទកោ ចរេ
កុម្ភិហំ ព្រហ្ម បការោ  អគ្គិនាទេន ខត្តិយោ
បញ្ជរោ សកា វេជ្ជា  វត្ថំ វសតិ បព្វតេ ។
កុម្ភិហំ ព្រហ្ម បការោ  អគ្គិនាទេន ខត្តិយោ
អាធាយ បុត្តទារញ្ច  វត្ថំ វសតិ បព្វតេ ។
អគ្គិហុត្តំ ជុហេតោ  វជ្ជា វិធមាតកោ
ភជបុត្តិ តបស្សន្តោ  ចតោ មជ្ឈិមកេ ជនោ ។
តស្ស ត្យាហំ ន ធស្សាមិ  ជីវិតំ ឥធ ព្រាហ្មណា
អយំ ហិតេ មយា មុឡ្ហ(១) សាកេ ជាតស្ស លោហិតំ ។
សិរោ តេ វជ្ឈយិត្វាន  ហទយំ ឆេត្វា សពន្ធនំ
បន្ថសកុណំ យជិស្សាមិ  តុយ្ហំ មំសេន ព្រាហ្មណា
តុយ្ហំ មំសេន មេទេន  មត្ថកេន ច ព្រាហ្មណា
អាហុតិំ បគ្គហេស្សាមិ  ឆេត្វាន ហទយំ តវ ។

១ ម. អយញ្ហិតេ មយា មុឡ្ហា ។



មួយទៀត បុគ្គលណា និយាយប្រាប់ថា ទ្រព្យនឹងទីលំនៅនៃព្រះបាទ វេស្សន្តរដូច្នេះ ដល់ខ្ញុំ ដែលចូលមកក្នុងព្រៃធំ កំពុងយំរៀបរាប់ យ៉ាងនេះ បុគ្គលនោះ រមែងប្រសព្វបុណ្យដ៏ច្រើន ព្រោះតែសំដី មួយម៉ាត់នោះឯង ។

(៣០៣) ពេលបុត្រព្រាននៃព្រៃ ឮគួរទៅក្នុងព្រៃ បានស្រដីតបទៅនឹង ជូជកព្រាហ្មណ៍នោះថា នែព្រាហ្មណ៍ ក្សត្រក្លៀវក្លាអ្នកធ្វើឲ្យខ្មាំង ភ្ជាត់ទៅព្រោះអគ្គិទាន ត្រូវគេបណ្ដេញចេញចាកដែន របស់ព្រះអង្គ ទៅគង់នៅភ្នំវង្កត ។ នែព្រាហ្មណ៍ ក្សត្រក្លៀវក្លាអ្នកធ្វើឲ្យខ្មាំងភ្ជាត់ ទៅព្រោះអគ្គិទាន ទ្រង់នាំព្រះរាជបុត្រនឹងព្រះទេវីទៅគង់នៅភ្នំវង្កត ។ អ្នកជាបុគ្គលឥតប្រាជ្ញា មិនធ្វើនូវកិច្ចការគួរ ចេញអំពីដែនចូល មកកាន់ព្រៃធំ ដើម្បីស្វែងរកព្រះរាជបុត្រ ដូចជាក្ងោកស្វែងរកត្រីក្នុង ទឹក ។ នែព្រាហ្មណ៍ យើងមុខជាមិនឲ្យជីវិត ដល់អ្នកនោះក្នុង ទីនេះទេ ព្រោះថា ព្រួញនេះដែលយើងបាញ់ សំដៅអ្នកហើយ មុខជាផឹកឈាមអ្នក ។ នែព្រាហ្មណ៍ យើងមុខជានឹងកាត់ ក្បាលអ្នក ហែកទ្រូងយកបេះដូង ព្រមទាំងទង ហើយបូជា បន្ថសកុណយញ្ញ (បូជាទេវតាក្នុងផ្លូវ) ដោយសាច់របស់អ្នក ។ នែព្រាហ្មណ៍ យើងនឹងកាត់យកបេះដូង របស់អ្នក រួចធ្វើ ការបូជា ដោយសាច់ ខ្លាញ់ខួរ និងក្បាល របស់អ្នក ។

កិំ មេ សុយិដ្ឋំ សុហុតំ តុយ្ហំ មីសេខ ព្រាហ្មណ

ឧ ច ត្វំ រាជបុត្តស្ស កាយំ ឥត្ថ ច ទេស្សសិ ។

(៣០៦) អវជ្ឈោ ព្រាហ្មណោ ទូតោ ចេតបុត្ត សុណោហិ មេ

តស្មា ហិ ទូតំ ន ហន្តិ ឯស ធម្មោ សនន្តនោ ។

និជ្ឈត្តា សិវយោ សព្វេ បិតា នំ ទដ្ឋុមិច្ឆតិ

មាតា ច ទុព្វលា តស្ស អចិរា ចក្ខូនិ ជីយរេ ។

តេសាហំ បហិតោ ទូតោ ចេតបុត្ត សុណោហិ មេ

រាជបុត្តំ នយិស្សាមិ យទិ ជានាសិ សំស មេ ។

(៣០៧) បិយស្ស មេ បិយោ ទូតោ បុណ្ណបត្តំ ទទាមិ តេ

ឥមញ្ច មធុនោ តុម្ពំ មិគសត្ថិញ្ច ព្រាហ្មណ

តញ្ច តេ ទេសមក្ខិស្សំ យត្ថ សម្មតិ កាមទោ ។

ជូជកបព្វំ នាម ។



ម្នាលព្រាហ្មណ៍ ការបូជានោះ ដោយសាច់របស់អ្នកនោះ ឈ្មោះថា យើងបូជាល្អហើយ មួយទៀត អ្នកនឹងនាំព្រះទេហ៍ នឹងព្រះរាជបុត្របុត្រីនៃព្រះរាជបុត្រមិនបានទេ ។

(៣០៦) (ជូជក...) នែចេតបុត្ត អ្នកចូរស្តាប់យើង ព្រាហ្មណ៍ជាទូតអ្នកមិនត្រូវសម្លាប់ទេ ព្រោះហេតុនោះឯង បានជាគេមិនសម្លាប់ទូតនេះ ជាធម៌មានមកយូរយារណាស់ហើយ ពួកអ្នកសិវិក្រុងទាំងអស់ បាត់ទីងហើយ ព្រះបិតាចង់ជួបព្រះបាទវេស្សន្តរនោះ ទាំងព្រះមាតាព្រះនេត្រក៏មានកំឡាំងថយ ពុំយូរឡើយ មុខជានឹងងងឹតព្រះនេត្រ (ដោយទ្រង់ព្រះពិលាប) ។ នែចេតបុត្ត អ្នកចូរស្តាប់ពាក្យយើង យើងជារាជទូតដែលក្សត្រទាំងនោះ បញ្ជូនមកហើយ យើងនឹងនាំទៅនូវព្រះរាជបុត្រ បើអ្នកដឹង អ្នកចូរប្រាប់យើង ។

(៣០៧) (ចេតបុត្ត...) នែព្រាហ្មណ៍ អ្នកជាទូតជាទីស្រឡាញ់នៃព្រះបាទវេស្សន្តរ ដែលជាទីស្រឡាញ់របស់យើង យើងនឹងឲ្យភាជន៍ដ៏ពេញដោយទឹកផង តុម្ពទឹកឃ្មុំនេះផង ភ្លៅម្រឹគ(ដែលចំអិនស្រេច)ផង ដល់អ្នក មួយទៀត ព្រះបាទវេស្សន្តរ ដែលជាអ្នកឲ្យវត្ថុជាទីប្រាថ្នា គង់នៅក្នុងប្រទេសណា យើងនឹងប្រាប់ប្រទេសនោះ ដល់អ្នក ។

ចប់ ជូជកបព្វៈ ។

(៣០៦) ឯសសេលោ មហាព្រហ្មេ បព្វតោ គន្ធមាទនោ

យត្ថ វេស្សន្តរោ រាជា   សហ បុត្តេហិ សម្មតិ ។
ធារេន្តោ ព្រាហ្មណវណ្ណំ   អាសទញ្ច[១] មសញ្ជដំ
ចម្មវាសី ឆមា សេតិ   ជាតវេទំ នមស្សតិ ។
ឯតេ នីលា បទិស្សន្តិ   នានាផលធរា ទុមា
ឧគ្គតា អព្ភកូដាវ   នីលា អញ្ជនបព្វតា ។
ធវស្សកណ្ណា ខទិរា   សាលា ផន្ទនមាលុវា
សម្បវេធន្តិ វាតេន   សកឹ បីតាវ មាណវា ។
ឧបរិ ទុមបរិយាយេសុ   សង្គីតិយោវ សុយ្យរេ
នជ្ជុហា កោកិលា សង្ឃា   សម្បតន្តិ ទុមា ទុមំ ។
អវ្ហយន្តេវ គច្ឆន្តំ   សាខាបត្តសមីរិតា
រមយន្តេវ អាគន្តុំ   មោទយន្តិ និវាសិនំ ។
យត្ថ វេស្សន្តរោ រាជា   សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ   អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ   ជាតវេទំ នមស្សតិ ។

១ ម. អាសតិញ្ច ។



(៣០៦) (អច្ចុត. .) នែមហាព្រាហ្មណ៍ នោះហ៎ ភ្នំគន្ធមាទន៍ ជាកន្លែង ដែលព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយនឹងព្រះរាជបុត្រទាំងព្រះអង្គ ។ ព្រះរាជាទ្រង់ទ្រទ្រង់ភេទអ្នកបួសដ៏ប្រសើរផង មានទំពក់ទឹកដែលសម្រាប់បូជាភ្លើង នឹងផ្នួងសក់ ទ្រង់ស្បៀកដណ្តប់ស្បែកខ្លា ផ្ទំលើផែនដី នមស្ការនូវភ្លើង ។ ឈើទាំងឡាយនុ៎ះ ដ៏ខៀវ ទ្រទ្រង់ផ្លែផ្សេងៗ ដ៏ខ្ពស់ដោយកំពូលទើសមេឃ ដ៏ខៀវដូចភ្នំអញ្ជន ។ មានដើមត្រៃបកព្រៃ ដើមក្រចៀកក្រើស ដើមគគីរ ដើមរាំង ដើមរាជ្រ នឹងដើមវល្លិ៍ ទោរទន់ទៅមក ដោយខ្យល់ ដូចជាមាណពដែលផឹក (ស្រា) ម្តង ។ នៅខាងលើមែកឈើទាំងឡាយ ឮសូរស័ព្ទដូចជាចម្រៀងទិព្វ (ពីរោះ) មានហ្វូងទំពាំលោកកនឹងតាវ៉ៅ ទុះពីឈើមួយទៅឈើមួយ ។ មែកឈើ នឹងស្លឹកឈើទាំងឡាយ ដែលខ្យល់បក់ប្រៀបហើយ ឮដូចជាហៅអ្នកដែលកំពុងដើរ ដូចជាកែកយ នឹងជនដែលមកដល់ ត្រេកត្រអាលនឹងជនដែលនៅអាស្រ័យ ។ អ្នកនឹងចូលទៅក្នុងអាស្រម ដែលជាកន្លែង ព្រះបាទវេស្សន្តរស្តេចគង់នៅ ជាមួយនឹងព្រះរាជបុត្រាបុត្រីទាំងឡាយ ស្តេចទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរ មានទំពក់ទឹកដែលសម្រាប់បូជា នឹងព្រះជដា ទ្រង់ស្បៀកស្បែកខ្លា ផ្ទំលើផែនដី នមស្ការភ្លើង ។

(៣០៧) អម្ពា កបិដ្ឋា បនសា សាលា ជម្ពូ វិភេទកា
ហរីតកី អាមលកា អស្សត្ថា ពទរានិ ច
ចារុតិម្ពរុកា ចេត្ថ និគ្រោធា ច កបិត្ថនា
មធុមធុកា ថេវន្តិ នីចេ បក្កា ចុទុម្ពរា
បារេវតា ភវេយ្យា ច មុទ្ទិកា ច មធុត្ថិកា
មធុំ អនេលកំ តត្ថ សកមាទាយ ភុញ្ជរេ ។
អញ្ញេត្ថ បុប្ផិតា អម្ពា អញ្ញេ តិដ្ឋន្តិ ទោវិលា
អញ្ញេ អាមា ច បក្កា ច ភេកវណ្ណា(១) តទូភយំ ។
អថេត្ថ ហេដ្ឋា បុរិសោ អម្ពបក្កានិ គណ្ហតិ
អាមានិ ចេវ បក្កានិ វណ្ណគន្ធរសុត្តមា ។
អតេវ(២) មេ អច្ឆរិយំ ហិង្ការោ បដិភាតិ មំ
ទេវានមិវ អាវាសោ សោភតិ នន្ទនូបមោ
វិភេទកា នាឡិកេរា ខជ្ជូរីនំ ព្រហាវនេ
មាលាវ គន្ថិតា ឋន្តិ ធជគ្គានេវ ទិស្សរេ ។
នានាវណ្ណេហិ បុប្ផេហិ នភំ តារាចិតាមិវ
កុដជី(៣) កុដ្ឋតគរា បាដលិយោ ច បុប្ផិតា
បុន្នាគា គិរិបុន្នាគា កោវិឡារា ច បុប្ផិតា ។

១ ម. ភាវណ្ណា ។ ២ ម. អតីវ ។ ៣ ម. កុដិជា ។



(៣០៧) ក្នុងទីនុ៎ះ មានដើមស្វាយ ខ្វិត ខ្នុរ រាំង ព្រីង សម៉ត់តេចក់ សម៉ក្តក កន្ទួតព្រៃ ពោធិ ពុទ្រា ទន្លាប់ពាស ល្វាផ្លែក្រសាំង ពាក់សាង មានផ្លែដ៏ផ្អែមល្ហើង ចំណែកឯមានផ្លែទុំ ដើមពពេល មានទេពកម្សាន្តក្នុង ទេពកម្សាន្តស្ងួន ទឹកឃ្មុំ មានផ្លែផ្អែមដូចទឹកឃ្មុំ នៅក្នុងរយឃ្មុំ ជនមកក្នុងទីនោះ យកជារបស់ខ្លួនហើយបរិភោគ ។ ក្នុងទីនុ៎ះ មានស្វាយខ្លះកំពុងផ្កា ស្វាយខ្លះទើបជាក្ដោបត្រួយ ស្វាយខ្លះមានផ្លែខ្ចីនិងទុំ ផ្លែទាំងពីរនោះមានសម្បុរដូចខ្នងកង្កែបញ្ញើរពក ។ ក្នុងទីនុ៎ះ បុរស(ឈរ)ខាងក្រោម បេះផ្លែស្វាយទុំទាំងឡាយ ស្វាយទាំងឡាយទាំងខ្ចីទាំងទុំ មានសម្បុរក្លិននិងរសដ៏ឧត្តម ។ ខ្ញុំគិតមានសេចក្ដីអស្ចារ្យក្រពេក ទាំងការលាន់ឮថាហឹងៗ គឺប្រាកដដល់ខ្ញុំ ប្រទេសនោះ ប្រមាណដូចនន្ទនវ័ន ល្អដូចជាទីនៅរបស់ពួកទេវតា ។ ត្នោត ដូងដុំខ្ទេះគា ក្នុងព្រៃល្មើងធំ ផ្កាទាំងឡាយ ដូចជាកម្រងដែលគេក្រងហើយ ឬប្រាកដដូចជាចុងទង់ជ័យ ។ ខ្ទឹងគង់ ក្តោកាដ ក្តិក្រឹស្នា ប្រមៀង បុន្នាគតូច បុន្នាគធំ និងស្លែស មានផ្កាពណ៌ផ្សេងៗ រីកស្គុះស្គាយ ដូចផ្កាយដែលភ្លឺព្រោងព្រាត លើអាកាស ។

ឧទ្ទាលកា សោមរុក្ខា អគរុភល្លិយា[១] ពហូ
បុត្តជីវា ច កក្កុធា[២] អសនា ចេត្ថ បុប្ផិតា ។
កុដជា សលឡា នីបា កោសម្ពលពុជា ធវា
សាលា ច បុប្ផិតា តត្ថ បលាលខលសន្និភា ។
តស្សាវិទូរេ បោក្ខរណី ភូមិភាគេ មនោរមេ
បទុមុប្បលសញ្ឆន្នា ទេវានមិវ នន្ទនេ ។
អថេត្ថ បុប្ផរសមត្តា កោកិលា មញ្ជុភាណិកា
អភិនាទេន្តិ បវនំ ឧតុសម្បុប្ផិតេ ទុមេ ។
ភស្សន្តិ មករន្ទេហិ បោក្ខរេ បោក្ខរេ មធូ
អថេត្ថ វាតា វាយន្តិ ទក្ខិណា អថ បច្ឆិមា ។
បទុមកិញ្ជក្ខរេណូហិ ឱកិណ្ណា ហោតិ អស្សមោ
ថូលា សិង្ឃាដកា ចេត្ថ សសាធិយា បសាធិយា[៣] ។
មច្ឆកច្ឆបព្យាវិទ្ធា ពហូ ចេត្ថ មុបយានកា
មធុំ ភិសេហិ សវតិ ខីរំ សប្បិ មុឡាលិភិ
សុរភិ តំ វនំ វាតិ នានាគន្ធសមេរិតំ ។

១. ម. អគ្គលុភល្លិយា ។ ២. ឱ. ម. កកុធា ។ ៣ ម. សំសាទិយា បសាទិយា ។



ករព្រឹក្ស ខ្ទុញ កំញាន កក់ម្ទៀ ព្រៃង ទន្លាប់ដុះជាច្រើន បាញ្ញាញផ្កាក្នុងទីនោះ ។ ខ្ទុំអង្គដ ស្រល់ ស្មាល សង្កែរ ទ្រសេម ត្រាចគៀត្រាចឆ្អឹងក៏ដុះ ត្រូវផ្កាក្នុងទីនោះ ដូចជាលាចអង្កាម ។ ក្នុងភូមិភាគជាទីរីករាយចិត្ត ជិតអាស្រមនោះ មានស្រះបោក្ខរណីដេរដាសដោយផ្កាឈូក និងផ្កាព្រលិត ដូចជាក្នុងឧទ្យាននន្ទនៈរបស់ពួកទេវតា ។ មួយទៀត ពួកតាវើហ៍ដែលស្រវឹងដោយរសផ្កា យំពីរោះ នៅលើឈើដែលមានផ្កាកើតតាមរដូវ ញុំាងព្រៃនោះឲ្យលាន់ឮរំពងឹង ។ លំអងដែលកោយកាយ ចេញអំពីកេសរ ដែលមាននៅត្រង់ស្លឹកឈូកមានសៅផ្ទុំ ហើយស្រក់ចាក់ជាតំណក់ ក្នុងទីអាស្រមនុ៎ះ អំពីទិសខាងត្បូងនិងទិសខាងលិច ។ អាស្រមក៏ដេរដាសដោយលំអងកេសរផ្កាឈូក ក្នុងស្រះបោក្ខរណីនុ៎ះ មានផ្លែក្រចាប់ធំៗ សាវ និងស្រូវសាលីដុះឯកឯងកោយកាយលើផែនដី ។ មួយទៀត មានត្រី អណ្តើក និងក្តាមច្រើនក្រៃ ហែលហាលទៅមកក្នុងស្រះនោះ សៅដែលហូរចេញអំពីក្រអៅឈូក មានរសជាតិដូចទឹកឃ្មុំ និងរសដែលហូរចេញអំពីមើមឈូក មានរសជាតិដូចទឹកដោះស្រស់និងទឹកដោះថ្លា ព្រៃនោះមានក្លិនក្រអូបផ្សេងៗ ផ្សព្វផ្សាយក្លិនឈ្ងុយឈ្ងប់ ។

សាម្មាធិកោ កមុទា បុប្ផសាខាហិ តំ វនំ
កទក បុប្ផកមុទ សមន្តាមភិកាសិតា ។
អថេត្ថ សកុណា សន្តិ នានាវណ្ណា ពហូ ទិជា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកូជិនោ ។
នទិកា ជីវបុត្តា ច ជីវបុត្តា បិយា ច នោ
បិយា បុត្តា បិយា នន្ទា ទិជា បោក្ខរណីឃរា ។
មាលាវ គន្ថិតា ឋន្តិ ធជគ្គានេវ ទិស្សរេ
នានាវណ្ណេហិ បុប្ផេហិ កុសលេហេវ សុគន្ថិតា ។
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ
ចីរវត្ថោ ព្រាហ្មណវណ្ណី អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ ។



ព្រៃនោះ ដូចជា (ញុំាងផែនដីផលមកដល់) ឲ្យរីករាយ ដោយក្លិន ដោយផ្កា និងផ្លែឈើ កន្លងទាំងឡាយ ក៏ញុំាងព្រៃឲ្យរីករាយ ដោយជុំវិញ ព្រោះតែក្លិនផ្កា ។ មិនតែប៉ុណ្ណោះសោត មានសត្វបក្សីទាំងជាតិជាច្រើន មានសម្បុរផ្សេង ៗ គ្នា ត្រេកត្រអាលជាមួយនឹងមេ យំរកគ្នាទៅវិញទៅមក ក្នុងស្រះនោះ ។ ពួកបក្សីដែលនៅក្នុងស្រះបោក្ខរណី គឺសត្វនន្ទិកា ១[1] សត្វជីវបុត្តា ១[2] សត្វជីវបុត្តាបិយាបតោ ១[3] សត្វបិយាបុត្តាបិយានន្ទា ១[4] ។ ផ្កាទាំងឡាយ ដូចជាកម្រងផ្កាដែលគេក្រងហើយ ប្រាកដដូចជាចុងទង់ជ័យ គ្រាន់តែដូចជាកម្រងផ្កា ដែលមាលាការដ៏ឈ្លាសក្រងហើយល្អ ដោយផ្កាមានពណ៌ផ្សេង ៗ ។ ក្នុងទីដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ជាមួយនឹងព្រះរាជបុត្រាបុត្រី ព្រះអង្គទ្រង់ភេទជាអ្នកបួសដ៏ប្រសើរ មានចំពាក់ និងរែកសម្រាប់ចូលជាក្តិងផង និងព្រះជដា ទ្រង់ស្លៀកស្បែកខ្លា ផ្ទំនៅលើផែនដី នមស្ការភ្លើង ។

---

១ ពួកសត្វនេះពោលថា បពិត្រព្រះវេស្សន្តរ ព្រះអង្គកាលគង់នៅក្នុងព្រៃនេះ ចូរត្រេកអរចុះ ។ ២ ពួកសត្វនេះពោលថា ព្រះមទ្ទី បុត្រាបុត្រីរបស់ព្រះមទ្ទី ចូររស់នៅសប្បាយចុះ ។ ៣ ពួកសត្វនេះពោលថា ព្រះមទ្ទី បុត្រាបុត្រីរបស់ព្រះមទ្ទី ដែលជាទីស្រឡាញ់ ចូររស់នៅចុះ ។ ៤ ពួកសត្វនេះពោលថា ព្រះមទ្ទី បុត្រាបុត្រីរបស់ព្រះមទ្ទី ដែលជាទីស្រឡាញ់ ចូរត្រេកអរ ។ អដ្ឋកថា ។

(៣០៨) ឥទញ្ច មេ សត្តុភត្តំ មធុនា បដិសំយុតំ
មធុបិណ្ឌិកា ច សុកតាយោ សត្តុភត្តំ ទទាមិ តេ ។

(៣០៩) តុយ្ហេវ សត្តុភស្តា ច ចាហំ ឥច្ឆាមិ សម្ភវំ
ឥតោបិ ព្រហ្មេ គណ្ហាហិ គច្ឆ ព្រហ្មេ យថាសុខំ ។
អយំ ឯកបទី រាជ ឧជុំ គច្ឆតិ អស្សមំ
ឥសីបិ អច្ចុតោ តត្ថ បង្កទន្តោ រជស្សិរោ
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ ។
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ
តំ ត្វំ គន្ត្វាន បុច្ឆស្សុ សោ តេ មគ្គំ បវក្ខតិ ។

(៣១០) ឥទំ សុត្វា ព្រហ្មពន្ធុ ចេតំ កត្វា បទក្ខិណំ
ឧទគ្គចិត្តោ បក្កាមិ យេនាសិ អច្ចុតោ ឥសិ ។

ចុល្លវនវណ្ណនា ។

(៣១១) គច្ឆន្តោ សោ ភារទ្វាជោ អទ្ទស អច្ចុតំ ឥសឹ
ទិស្វាន តំ ភារទ្វាជោ សម្មោទិ ឥសិនា សហ ។



(៣០៨) (ជូជក...) ភត្តគឺសត្តុនេះ ដែលលាយហើយដោយទឹកឃ្មុំ យើងនឹងឲ្យនូវទឹកឃ្មុំដែលយើងធ្វើល្អហើយផង នឹងភត្តគឺសត្តុផង ដល់អ្នក ។

(៣០៩) (ចេតបុត្ត...) ស្បៀងនុះនៅជារបស់អ្នកឯងចុះ យើងមិនត្រូវការស្បៀងទេ នែព្រាហ្មណ៍ អ្នកចូរយកស្បៀងអំពីនេះទៅ នែព្រាហ្មណ៍ អ្នកចូរទៅតាមស្រួលចុះ ។ ផ្លូវនេះជាផ្លូវដើរបានតែបុគ្គលម្នាក់ ត្រង់ទៅកាន់អាស្រម ក្នុងអាស្រមនោះ មានឥសីឈ្មោះអច្ចុតៈ មានធ្មេញប្រឡាក់ដោយមន្ទិល មានសក់ប្រឡាក់ដោយធូលី ទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរផង ចំពក់ផង វែកសម្រាប់បូជាភ្លើងផង ជដាផង ។ ឥសីឈ្មោះអច្ចុតៈនោះជាអ្នកស្លៀកស្បែកខ្លា ដេកនៅលើក្រាលស្លឹកឈើលើផែនដី នមស្ការភ្លើង អ្នកចូរទៅសួរលោកចុះ លោកនឹងប្រាប់ផ្លូវដល់អ្នកពុំខាន ។

(៣១០) ជូជកជាព្រហ្មពន្ធុ លុះបានឮពាក្យនេះហើយ ក៏មានចិត្តរីករាយ ប្រទក្សិណចេតបុត្តព្រានព្រៃ រួចដើរតម្រង់ទៅកាន់អច្ចុតឥសី ។

ចប់ ចុល្លវនវណ្ណនា ។

(៣១១) កាលជូជកព្រាហ្មណ៍នោះ ដើរទៅជួបឥសីឈ្មោះអច្ចុតៈ លុះជូជក បានឃើញឥសីនោះហើយ ក៏សំណេះសំណាលជាមួយនឹងឥសីជា

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច អប្បមេវ សរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតិ ។
[៣០២] កុសលញ្ចេវ នោ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ
អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។
អថោ ឌំសា មកសា ច អប្បមេវ សរីសបា
វនេ វាឡមិគាកិណ្ណេ ហឹសា មយ្ហំ ន វិជ្ជតិ ។
ពហូនិ វស្សបូគានិ អស្សមេ សម្មតំ មម
នាភិជានាមិ ឧប្បន្នំ អាពាធំ អមនោរមំ ។
ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទម្បិ បានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសិ ។



លោកដ៏ចំរើន សុខសប្បាយទេឬ លោកដ៏ចំរើន មិនមានរោគាពាធទេឬ លោកចិញ្ចឹមជីវិតដោយការស្វែងរក (ស្រូវ) ទេឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស ពស់មានតិចទេឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនមានការបៀតបៀនទេឬ ។

[៣០២] (តាបស...) ម្នាលព្រាហ្មណ៍ អាត្មាសុខសប្បាយទេ អាត្មាមិនមានរោគាពាធទេ មួយទៀត អាត្មាចិញ្ចឹមជីវិតដោយការស្វែងរក (ស្រូវ) ទេ ចំណែកមើមឈើផ្លែឈើ ក៏មានច្រើនដែរ ។ មួយវិញទៀត ពួករបោម មូស ពស់ មានតិចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនមានការបៀតបៀនអាត្មាទេ ។ អាត្មានៅក្នុងអាស្រមនេះ អស់ប្រមាណឆ្នាំជាច្រើន អាត្មាមិនដែលស្គាល់អាពាធមិនជាទីត្រេកអរនៃចិត្តកើតឡើយទេ ។ នែមហាព្រាហ្មណ៍ អ្នកមកល្អហើយ អ្នកមិនមែនមកអាក្រក់ទេ ម្នាលព្រាហ្មណ៍ដ៏ចំរើន អ្នកអញ្ជើញចូលមកខាងក្នុង អ្នកចូរលាងជើងទាំងឡាយរបស់អ្នកចុះ ។ នែព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែទន្លាប់ ផ្លែព្រីង ផ្លែមាក់សាង ផ្លែមាក់ម៉ោក មានរសឆ្ងាញ់ក៏សា ដូចជាទឹកឃ្មុំ ។ ចំណែកទឹកត្រជាក់នេះ អាត្មានាំមកអំពីជ្រោះភ្នំ នែមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនោះចុះប្រសិនបើអ្នកត្រូវការ ។

(៣១៨) អថេត្ថ ឧទកន្តស្មិំ ពហូ ជាតា ផណិជ្ជកា[១]
មុគ្គតិយោ ការតិយោ សេវាលំ សីសកំ ពហុំ[២] ៕
ឧទ្ធាបវត្តំ ឧល្លុង្គំ មក្ខិកា ហិង្គុជាលិកា
ទាសិមកញ្ជកោ ចេត្ថ ពហូ នីចេ កលម្ពកា
ឯឡម្ពកេហិ សញ្ឆន្នា រុក្ខា តិដ្ឋន្តិ ព្រាហ្មណ
សត្តាហំ ធារិយមានានំ គន្ធោ តេសំ ន ឆិជ្ជតិ ៕
ឧភតោ សរំ មុចលិន្ទំ បុប្ផា តិដ្ឋន្តិ សោភនា
ឥន្ទីវរេហិ សញ្ឆន្នំ វនន្តមុបសោភតិ
អឌ្ឍមាសំ ធារិយមានានំ គន្ធោ តេសំ ន ឆិជ្ជតិ ៕
នីលបុប្ផិ សេតវារី បុប្ផិតា គិរិកណ្ណិកា
កលេរុក្ខេហិ[៣] សញ្ឆន្នំ វនន្តំ តុលសីហិ ច ៕
សម្មោទតេវ គន្ធេន បុប្ផសាខាហិ តំ វនំ
ភមរា បុប្ផគន្ធេន សមន្តាមភិនាទិតា ៕
តីណិ កក្ការុជាតានិ[៤] តស្មឹ សរេ ព្រាហ្មណ
កុម្ភមត្តានិ ចេកានិ មុរមត្តានិ តេ ឧភោ ៕

---

១ ម. ពហុ ជាតា ផណិជ្ជកា ។ ២ ម. សេវាលសីសកា ពហូ ។ ៣ ម. កដេរុក្ខេហិ ។ ៤ ម. កក្ការុជាតានិ ។



(៣១៨) មួយទៀត មានតំណក់ស្លឹកគ្រៃ សណ្តែកបាយ សណ្តែកកង-
ហាសជាច្រើន សារាយ ទឹកក់តឹងគួយ ជាច្រើនដុះក្បែរទឹកមុច-
លិន្ទស្រះនុ៎ះ ។ (ទីនោះ) មានព្រៃផ្ចិតទំនប់ ត្រឡប់ចក់មក
រលកកំព្លាយខ្លះឡើង មានក្អកមេឃ្មុំ ឃុំដោយសំឡេងដំកោះ
រហើរត្រៀលក្ខាក់ តួម្ពលើមាន ម្ជូរ ស្វាស្វាច់ ស្វាង ក្នុងទំនាប
ទៀបមុចលិន្ទស្រះនោះ មានត្រកួនជាច្រើន ។ ម្នាលព្រាហ្មណ៍
ពួកព្រឹក្សសីងដឹងដោស ដោយពួកល្វីងឈ្មោះ ឯឡម្ពកៈ ផ្ទុះនៅ
ក្លិនរបស់ផ្កានៃល្វីងទាំងនោះ ដែលគេទ្រទ្រង់អស់ ៧ ថ្ងៃ មិនដាច់
បាត់ក្រអូបឡើយ ។ ពួកផ្កាដុះនៅ ក្នុងចំណោតកំពែងនៃមុចលិន្ទ
ស្រះ ព្រៃនោះដើរដោស ដោយពួកផ្កាល័ចន៍ ដុះស្មើរឿង ក្លិន
របស់ផ្កាទាំងនោះ ដែលគេទ្រទ្រង់អស់កន្លះខែ ក៏មិនដាច់បាត់ក្រអូប
ឡើយ ។ រីឯអញ្ចាន់ទៀត អញ្ចាន់-ស អញ្ចាន់ល្វៀង មានផ្កាកែស្ទះ
ស្វាយ ព្រៃនោះដើរដោសដោយម្ទេះក្រៀក ម្ទេះលោ ។ រីឯព្រៃនោះដូច
ជា (ញ៉ាំងជនដែលមកដល់) ឲ្យរីករាយដោយក្លិនផង ដោយមែក
មានផ្កាទាំងឡាយផង ឯពួកកន្ធេមានសម្លេងបញ្ចេញហើងកឹងកងជុំវិញ
ព្រោះក្លិនផ្កា ។ ម្នាលព្រាហ្មណ៍ ក្នុងមុចលិន្ទស្រះនោះ មានពួក
ត្រឡាចចម្អុទ អំពួយពួកផ្លែប៉ុនឆ្នាំង ពីរពួកទៀតផ្លែប៉ុនស្គរ ។

[៣១៣] បដិគ្គហិតំ យំ ទិន្នំ សព្វស្ស អគ្ឃិយំ កតំ
សញ្ជយស្ស សកំ បុត្តំ សិវីហិ វិប្បវាសិតំ
តមហំ ទស្សនមាគតោ យទិ ជានាសិ សំស មេ ។

[៣១៤] ន ភវំ ឯតិ បុញ្ញត្ថំ សិវិរាជស្ស ទស្សនំ
មញ្ញេ ភវំ បត្ថយតិ រញ្ញោ ភរិយំ បតិព្វតំ ។
មញ្ញេ កណ្ហាជិនំ ទាសឹ ជាលឹ ទាសញ្ច ឥច្ឆសិ
អថវា តយោ មាតាបុត្តេ អរញ្ញា នេតុមាគតោ
ន តស្ស ភោគា វិជ្ជន្តិ ធនំ ធញ្ញញ្ច ព្រាហ្មណ ។

[៣១៥] អក្រុទ្ធរូបោហំ ភោតោ នាហំ យាចិតុមាគតោ
សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ ។
អទិដ្ឋបុព្វោ សិវិរាជា សិវីហិ វិប្បវាសិតោ
តមហំ ទស្សនមាគតោ យទិ ជានាសិ សំស មេ ។

[៣១៦] ឯស សេលោ មហាព្រហ្មេ បព្វតោ គន្ធមាទនោ
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ ។



[៣១៣] (ជូជក...) វត្ថុដែលលោកបានឲ្យ ខ្ញុំបានទទួលយកហើយ ដែលលោកបានធ្វើឲ្យជាវត្ថុមានតម្លៃដល់ខ្ញុំទាំងអស់ ខ្ញុំមកដើម្បីចង់ជួបនឹងព្រះរាជបុត្របង្កើត របស់ព្រះបាទសញ្ជ័យ ដែលពួកអ្នកសិវិរដ្ឋបំបរបង់ហើយនោះ ប្រសិនបើលោកជ្រាប សូមប្រាប់ខ្ញុំផង ។

[៣១៤] (តាបស...) អ្នកមិនមែនមកគាល់ព្រះបាទសិវិ ដើម្បីបុណ្យទេ អ្នកចង់បានជាចង់បានព្រះទេវីរបស់ព្រះរាជា ដែលជាស្ត្រីប្រតិបត្តិក្នុងភស្តា ។ អ្នកចង់បានជាចង់បានកុមារីឈ្មោះកណ្ហាជិនា ធ្វើជាទាសី និងកុមារឈ្មោះជាលីធ្វើជាទាសៈ ឬក៏អ្នកមកដើម្បីនាំយកជនទាំង ៣នាក់ គឺមាតានិងបុត្រីបុត្រា ទៅកាន់ព្រៃ នែព្រាហ្មណ៍ ឯព្រះបាទវេស្សន្តរនោះ មិនមានភោគៈ មិនមានទ្រព្យ មិនមានធញ្ញជាតិទេ ។

[៣១៥] (ជូជក...) ខ្ញុំមិនមែនមានសភាពជាអ្នកខឹងនឹងលោកទេ ខ្ញុំមិនមែនមកដើម្បីសូមទេ ការចួបប្រទះនឹងពួកលោកដ៏ប្រសើរ ជាការល្អ ការនៅរួម នាំមកនូវសេចក្តីសុខសព្វកាល ។ ព្រះបាទសិវិ ដែលពួកអ្នកសិវិរដ្ឋបំបរបង់ហើយ ខ្ញុំមិនដែលបានឃើញ បានជាខ្ញុំមកគាល់ព្រះអង្គ ប្រសិនបើលោកជ្រាប សូមប្រាប់ខ្ញុំផង ។

[៣១៦] (តាបស...) នែមហាព្រាហ្មណ៍ នុ៎ះហ្ន៎ភ្នំគន្ធមាទន៍ ជាកោះនៃថ្ម ដែលព្រះបាទវេស្សន្តរស្តេចគង់នៅ ជាមួយព្រះរាជបុត្រនឹងព្រះទេវី

ធារេន្តោ ព្រាហ្មណវណ្ណំ  អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ  ជាតវេទំ នមស្សតិ ។
ឯតេ នីលា បទិស្សន្តិ  នានាផលធរា ទុមា
ឧគ្គតា អព្ភកូដាវ  នីលា អញ្ជនបព្វតា
ធវស្សកណ្ណា ខទិរា  សាលា ផន្ទនមាលុវា
សម្បវេធន្តិ វាតេន  សកឹ បីតាវ មាណវា ។
ឧបរិ ទុមបរិយាយេសុ  សង្គីតិយោវ សុយ្យរេ
នជ្ជុហា កោកិលាសង្ឃា  សម្បតន្តិ ទុមា ទុមំ ។
អវ្ហយន្តេវ គច្ឆន្តំ  សាខាបត្តសមីរិតា
រមយន្តេវ អាគន្តុំ  មោទយន្តិ និវាសិនំ ។
យត្ថ វេស្សន្តរោ រាជា  សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ  អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ  ជាតវេទំ នមស្សតិ ។



ព្រះរាជាទ្រង់ទ្រទ្រង់ភេទនៃបព្វជិតដ៏ប្រសើរ មានដំពក់នឹងកែសប្រោះបូជាភ្លើង សក់គណ្ដាញ់ ស្លៀកដណ្ដប់ស្បែកខ្លា ផ្ទំលើផែនដី នមស្ការភ្លើង ។ ពួកឈើដែលមើលទៅឃើញខៀវ ជាឈើមានពណ៌ខៀវ ទ្រទ្រង់ផ្លែផ្សេង ៗ ខ្ពស់មានចុងស្មើនឹងកំពូលពពក មានពណ៌ខៀវដូចភ្នំថ្មអញ្ជន ដើមក្រែងបែកព្រៃ ត្រាចក្របើស គគីរ កំពីរ កញ្ច្រឹងនិងជ្រៃ ញាប់ញ័រទៅតាមខ្យល់ ដូចពួកមាណពទើបផឹក (ស្រា)ម្ដង ៗ (សំឡេងរបស់ពួកសត្វស្លាបផ្សេង ៗ) លើមែកឈើតាំងឡាយលាន់ឮដូចចម្រៀង (ទិក្ក) ពួកសត្វទុំលោកោក សត្វតាវៅ តាំងហ្វូងហើរឆ្លៀលឆ្លាត់ ពីដើមឈើមួយ ទៅកាន់ដើមឈើមួយ ៗ អស់តាំងមែកឈើមានស្លឹក ដែលត្រូវខ្យល់បក់មក គឺហាក់ដូចជាដង្ហោយហៅជនដែលកំពុងដើរ ដូចជាត្រេកអរនឹងជនដែលមកដល់ តែកាយនឹងជនដែលនៅអាស្រ័យ ៗ (ត្រេកនឹងឃើញសម្បត្តិនៃអាស្រមបទ) ក្នុងអាស្រម ដែលព្រះបាទវេស្សន្តរស្ដេចគង់នៅ ជាមួយព្រះរាជបុត្រនឹងព្រះទេវី ព្រះអង្គទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរ មានដំពក់នឹងកែសប្រោះបូជាភ្លើង នឹងសក់គណ្ដាញ់ស្លៀកដណ្ដប់ស្បែកខ្លា ផ្ទំលើផែនដី នមស្ការភ្លើង ។

តាំបេរីមាលា វិតតា ភូមិភាគេ មនោរមេ
សណ្ហា ហរិតា ភូមិ ន តត្ថុទ្ធំសតេ រជោ ។
មយូរគីវសង្កាសា តូលផស្សសមូបមា
តិណានិ នាតិវត្តន្តិ សមន្តា ចតុរង្គុលា ។
អម្ពា ជម្ពូ កបិត្ថា ច នីចេ បក្កា ចទុម្ពរា
បរិភោគេហិ រុក្ខេហិ វនំ តំ រតិវឌ្ឍនំ ។
វេឡុរិយវណ្ណសន្និភំ មច្ឆគុម្ពនិសេវិតំ
សុចិំ សុគន្ធំ សលិលំ អាបោ តត្ថបិ សន្ទតិ ។
តស្សាវិទូរេ បោក្ខរណី ភូមិភាគេ មនោរមេ
បទុមុប្បលសញ្ឆន្នា ទេវានមិវ នន្ទនេ ។
តីណិ ឧប្បលជាតានិ តស្មិំ សរសិ ព្រាហ្មណ
វិចិត្រនីលានេកានិ សេតា លោហិតកានិ ច ។

(៣០៧) ខោមាវ តត្ថ បទុមា សេតសោគន្ធិយេហិ ច
កលម្ពកេហិ សញ្ឆន្នោ មុចលិន្ទោ នាម សោ សរោ ។
អថេត្ថ បទុមា ផុល្លា អបរិយន្តាវ ទិស្សរេ
គិម្ហា ហេមន្តិកា ផុល្លា ជណ្ណុតគ្ឃា ឧបត្ថរា ។



មានផ្កាចង្កោមព្រះកេយកាយ ដេរដាសលើភូមិភាគ ជាទីត្រេកអរនៃចិត្ត ពាំនៃផ្លូវផែនដីក៏មានពណ៌ខៀវស្រងាត់ ដោយស្មៅចាំក្បៀន ឥតមានធូលីហុយក្នុងទីនោះឡើយ ។ ពាំនស្មៅនោះក៏មានពណ៌ដូចជាកក-កនៃក្ងោក មានទន់ផាស្មើដោយសម្ផស្សនៃសំឡី មិនហួសកំពស់៤ធ្នាប់ដោយជុំវិញ ។ មានស្វាយ ព្រីង ក្ងុត ល្វាមានផ្លែទុំក្នុងទីទាប ព្រៃនោះសម្រាប់ញ៉ាំងតម្រេកឲ្យចំរើន ដោយពួកឈើសម្រាប់បរិភោគ ។ ទឹកស្អាត មានក្លិនក្រអូប មានសម្បុរប្រៀបពាលភ្លឺនៃពណ៌នៃកែវពិទូរ្យ កុះករដោយហ្វូងត្រី រមែងហូរទៅក្នុងព្រៃនោះ ។ ក្នុងទីជិតនៃអាស្រមបទនោះ មានស្រះបោក្ខរណីដ៏ដេរដាសដោយឈូកនិងឧប្បលក្នុងភូមិភាគ ជាទីត្រេកអរនៃចិត្តដូចជាក្នុងនន្ទនវ័ននៃពួកទេវតា ។ ម្នាលព្រាហ្មណ៍ ក្នុងស្រះនោះសឹងដុះដាសដោយឧប្បលជាតបី (ទេះ) គឺឧប្បលខៀវ ឧប្បល-សនិងឧប្បលក្រហម ។

(៣០៧) ក្នុងស្រះនោះ (ស) ដូចជាសំពត់សម្បកឈើ ស្រះនោះឈ្មោះមុចលិន្ទស្រះ ដេរដាសដោយព្រលិតនិងស្គុនទាំងឡាយផង ដោយក្រអូបទាំងឡាយផង ។ មួយទៀត ផ្កាឈូកក្នុងស្រះនោះ រីកស្គុះស្គាយ ឃើញហាក់ដូចជាគ្មានទីបំផុត ទូរក៏រីកក្នុងគិម្ហរដូវ ទូរក៏ក្នុងហេមន្តរដូវ បិតនៅក្នុងទឹកត្រឹមជង្គង់ ។

សុរភី សម្បវាយន្តិ វិចិត្រា បុប្ផសន្ថតា
កមក បុប្ផគេរុន សមន្តាមភិតាធិតា ។
(៣១៨) អថេត្ថ ឧទកន្តស្មឹ រុក្ខា តិដ្ឋន្តិ ព្រាហ្មណ
កទម្ពា បាដលី ផុល្លា កោវិឡារា ច បុប្ផិតា ។
អង្កោលា កច្ឆិការា ច បារិជញ្ញា ច បុប្ផិតា
វារណា វយ្ហតា រុក្ខា មុចលិន្ទមុភតោ សរំ ។
សិរីសា សេតបារិសា សាធុ វាយន្តិ បទ្មកា
និគ្គុណ្ឌី សរនិគ្គុណ្ឌី អសនា ចេត្ថ បុប្ផិតា ។
បង្គុរា ពហុលា សេលា សោភញ្ជនា ច បុប្ផិតា
កេតកា កណិការា ច កណវេរា ច បុប្ផិតា ។
អជ្ជុនា អជ្ជុកណ្ណា ច មហានាមា ច បុប្ផិតា
សម្បុប្ផិតគ្គា តិដ្ឋន្តិ បជ្ជលន្តេវ កិំសុកា ។
សេតបណ្ណិ សត្តបណ្ណា កទលិយោ កុសុម្ភរា
ធនុតក្ការិ បុប្ផេហិ សីសបាវរណានិ ច ។
អច្ឆិវា សល្លវា រុក្ខា សល្លកិយោ ច បុប្ផិតា
សេតគេរុតគរា មំសិកោដ្ឋកុលាវរា ។
ទហរា រុក្ខា វុឌ្ឍា ច អកុដិលា ចេត្ថ បុប្ផិតា
អស្សមំ ឧភតោ ឋន្តិ អគ្យាគារំ សមន្តតោ ។



ផ្ទៃដីនោះសឹងវិចិត្រល្អ ដ៏ដេរដាសដោយផ្កា មានក្លិនក្រអូបឈ្ងុយ
ឈ្ងប់បក់ផ្សាយទៅ ក្តួលមេឃាំកន្ទង់ខ្ទេរលើទិសទីកន្លងជុំវិញព្រោះក្លិនផ្កា ។
(៣១៨) ម្នាលព្រាហ្មណ៍ មួយទៀត មានពួកដើមឈើ ឋិតនៅ ច្រាំងនៃទឹង
រលួសផ្អុំ មានផ្កាពីកស្គុះស្គាយ ដុះក្បែរមាត់ទឹកមុចលិន្ទស្រះទាំង ។
មានទាំងដើមព្រូស ផ្ទូស ស្ពាន ខ្នុំ មានផ្កាពីក អមសងខាង
មុចលិន្ទស្រះ ។ មានពួកដីវេខ្មៅ ដីវ:ស ល្ហុកក្រាញ់ តណ្ហាំ:ស
តណ្ហាំខ្មៅ ផង់ ចាញ្ញញផ្កា ក្បែរមុចលិន្ទស្រះទាំង មានក្លិនក្រអូប
បក់ផ្សាយទៅ ។ មានពួកដើមស្រក់ ផ្តៅ កញ្ចុលដួ ព្រុំ មាន
ផ្កាពីក ពួកដើមកេតក: កណិការ ញ្ញាវេស មានផ្កាពីក ។ ពួក
ផ្គាំង:ស ផ្គាំងខ្មៅ ផ្ទាន់ផៃ មានផ្កាពីក មានត្រួយរីកល្អ ដុះនៅ
ព្រោះរន្ធាលផ្ទួកផ្កាតារ ។ ពួកដើមសត្វ:ស សត្វខ្មៅ ដើម
ចេកពាល ដើមផ្គត់ (ព្រៃនោះដុះហ្វ្រឹង) ដោយផ្កាពីកដោយទៅ
ទីនុតថ្ងូងន៍ ដោយផ្កាទួន៍ ទីនុខ្នុង ។ ដើមផ្គាំង កេ
កំពោរព្រៃ អត្ថិសេដ្ឋី ព្រឹង ត្រញូន៍ កេដ្ឋ-ស កេដ្ឋខ្មៅ មាន
ផ្កាពីក ។ ព្រឹក្សា(ទាំងនោះ) ពេរនូ សឹងមានដើមជីត្រង់ មាន
ផ្កាពីក ក្បែរមុចលិន្ទស្រះទាំង ដុះនៅទាំងសងខាងការស្រម (ក៏ទុក៏ទូ)
ជុំវិញរោងភ្លើង ។

(៣៦០) អថេត្ថ សាសបោ ពហុកោ នាទិយោ(១) ហរិតាយុតោ
អសី តាលាវ តិដ្ឋន្តិ ឆេជ្ជា ឥន្ទីវរា ពហូ ។
អម្ពាដា សុរិយវល្លី ច កាឡេរិយា(២) ធនុកទ្ធិយា
អសោកា មុទយន្តិ ច វល្លិកោ ទុទ្ធុប្បិយោ ។
កោរណ្ឌកា អនោជា ច ពុប្ផិតា តគរមល្លិកា(៣)
រុក្ខមារុយ្ហ តិដ្ឋន្តិ ផុល្លា កឹសុកវល្លិយោ ។
កដេរុហា ច វាសន្តី យោធិកា មធុគន្ធិយា
និលិយា សុមនា ភណ្ឌី សោភតិ បទុមុត្តរោ ។
បាដលី សមុទ្ទកប្បាសី កណិការា ច ពុប្ផិតា
ហេមជាលាវ ទិស្សន្តិ រុចិរា អគ្គិសិខូបមា ។
យានិ តានិ ច បុប្ផានិ ថលជានុទកានិ ច
សព្វានិ តត្ថ ទិស្សន្តិ ឯវំ រម្មោ មហោទធិ ។
(៣៦១) អថេត្ថ ពោក្ខរណិយា ពហុកា វារិគោចរា
រោហិតា នឡបី សិង្គូ កុម្ភិលា មករា សុសូ ។
មធុ ច មធុលដ្ឋិ ច តាលិយា(៤) ច បិយង្គុកា
កុដជា ភទ្ទមុដ្ឋា ច(៥) សត្តបុប្ផា(៦) ច លោលុបា ។

---

១ ម. នាទិយា ។ ២ ម. កោវិឡារា ។ ៣ ម. តគរល្លិកា ។ ៤ ម. តាលីសា ។ ៥ ម. កុដជា ភទ្ទមុត្តា ។ ៦ ម. សេតបុប្ផា ។





(៧៦០) មួយទៀត មានស្ពៃដ៏ច្រើន នឹងខ្ទឹម-ស លាយជាមួយខ្ទឹមក្រហម ជាច្រើន ដើមរកាទាំងឡាយ ដុះនៅដូចជាដើមត្នោត មានទាំងផ្កាលំចង់ដ៏ច្រើន ដែលគេគប្បីកាច់ ដុះនៅក្បែរមុចលិន្ទស្រះធំ ។ មានវល្លិ៍ម្ទេះព្រៃ ម្ទេះលា ក្រាំងពាក់ ឈើឯម ពួកអសោកព្រឹក្ស នឹងដើមទៀនព្រៃ ឈ្នួ វល្លិ៍ផ្ទាំង ។ ស្មៅកន្ទុយដំរី រតោងព្រៃ ដើមខ្ទឹម ដើមម្លិះសើងដ៏មានផ្កាកស្ទុះស្វាយ វល្លិ៍ពារ មានផ្កាកែ ដុះព័ទ្ធព័ន្ធដើមឈើ ។ ពួកឈើតានខ្លួន មៀនព្រៃ យុថ្កា មានក្លិនដូចជាទឹកឃ្មុំ ម្លិះវល្លិ៍ ម្លិះប្រេងក្រែ ខ្ចា បទុមុត្តរព្រឹក្ស សើងដ៏រុងរឿងល្អ ។ ពួកច្រទៀន កប្បាសសមុទ្រ កណិការសើងដ៏មានផ្កាកស្ទុះស្វាយ ប្រាកដដូចជាបណ្ដាញមាស សើងដ៏រុងរឿងល្អ ដូចជាអណ្ដាតភ្លើង ។ ពួកផ្កាណា កើតលើគោកនឹងកើតក្នុងទឹក ពួកផ្កាទាំងអស់នោះ ប្រាកដក្នុងមុចលិន្ទស្រះនោះ មុចលិន្ទស្រះប្រកបដោយទឹកច្រើន គួរឲ្យត្រេកអរ យ៉ាងនេះឯង ។

(៧៦១) មួយទៀត ក្នុងស្រះបោក្ខរណីនោះ មានពួកសត្វដែលក្រាប់ទៅក្នុងទឹក ជាច្រើន គឺត្រីឆ្កោ ត្រីរស់ ត្រីកណ្ដុង ក្រពើ មករ ក្ដាម ។ មានទាំងទឹកឃ្មុំ ឈើឯម ទ្រាំពូ ប្រយង្គុ ស្មៅក្រវាញជ្រូក ស្មៅមាត់ក្អែក ដើមសត្តបុស្ស សម្បូរល្អង ។

សុរភិមុត្តកា(១)  ពហុកា កុដ្ឋវច្ឆិយោ(២)
បទ្មកា ចារជា កោដ្ឋា  ឈាមកា ច ហរេណុកា ។
ហលិទ្ទកា គន្ធសេលា  ហិរិវេរា ច គុគ្គុលា
វិភេទកា ចោរកោដ្ឋា  កប្បូរា ច កាលិយកា ។
(៣៦៦)អថេត្ថ សីហា ព្យគ្ឃា ច  បុរិសាលូ ច ហត្ថិយោ
ឯណេយ្យា បសទា ចេវ  រោហិតា សរភា មិគា ។
កោដ្ឋសុណា សុណោបិ ច  តុលិយា នឡសន្និភា
ចាមរី ចលនី លង្ឃី  ឈាបិតា មក្កដា បិចុ ។
កក្កដា កដមាយា ច  ឥក្កា គោណសិរា ពហូ
ខគ្គា វរាហា នកុលា  កាឡកេត្ថ ពហូតសោ ។
មហិសា សោណា សិគាលា  បម្បកា ច សមន្តតោ
អាកុច្ឆា បចលាកា ច  ចិត្រកា ចាបិ ទីបិយោ ។
បេលកា ច វិឃាសាទា  សីហា គោគណិសាទកា
អដ្ឋបាទា ច មោរា ច  ភស្សរា ច កុក្កុដ្ឋកា ។
ចង្កោរា កុក្កុដា នាគា  អញ្ញមញ្ញំ បកូជិនោ
ពកា ពលាកា នជ្ជុហា  ទិន្ទិភា កោញ្ចវាទិកា

១ ម. សុរភី ច ព្រហ្មកា ។ ឱ. សុរភិមុត្តកា ។ ២ ម. កុដ្ឋវច្ឆកា ។ ឱ. កុដ្ឋវច្ឆិកា ។



ដើមកុំសែន ដើមថ្កូលសាមសិប គ្រឹស្នា ល្វីងណ្ដើស្វា ល្អកក្រាញ់ ក្រវាន់ កោដ្ឋ ប្រហូត បាយម៉ាត់ ។ ពួកម្រៀត ហរតាល យ៉ាន់ណា ហរិវេរត្រឹក ក្រើល សម៉ិកតចក់ ប្ញោស កប្បូរ រង្គក្រហម ។
(៣៦៦) មួយទៀត ក្នុងព្រៃមហាព្រៃនោះ មានពួករាជសីហ៍ ខ្លាធំ យក្ខិនី មានមុខដូចជាមុខមនុស្ស ដំរី ព្រាយ ស្មាន ទន្សោង សរភច្រើន ។ ហ្វូងចចក ទន្សាយ ឆ្មា ឆ្កែព្រៃ មានសម្បុរដូចជាផ្កាបបុស ចាមរី គោព ឈ្លូស ស្វាក្រោម ស្វាក្រៀស ស្វាពោល ។ ខ្នុរន៍ ទ្វីន ខ្លាឃ្មុំ គោព្រៃ ជាច្រើន ហ្វូងមាស ជ្រូកព្រៃ ស្កា កន្ធែន ជាច្រើន ក្សែមុខលិខ្នស្រែងុំ ។ មានចាំងញ្ញ្រក្រប៊ី ឆ្កែព្រៃ ចចក មានស្បាប់ដូសរៀតព្ទតសំដុំៗញកស្រមបខ ខ្សឿន បចលាកច្រើន រិចក្ខច្រើន ខ្លាដំបង ។ ហ្វូងទន្សាយ ក្ងាកគេសរសើរ ; គោគនិសាទកច្រើន សាកៈ ក្ងោក ក្ងាន មាន់ព្រៃក្ទើង ។ ពួកមាន់ទឹក មាន់ព្រៃ ដំរី ស្រែកយំឆ្លើយឆ្លងគ្នាទៅវិញទៅមក ពួកកុកសាប់ កុកព្រៃ ទ្រោលកាក ត្រដេវ ក្រៀល ទោល ។

ព្យគ្ឃិនសា លោហបិដ្ឋា   បម្បកា ជីវជីវកា

កបិញ្ជរា តិត្តិរាយោ   កុលា ច បដិកុដ្ឋកា ។

មណ្ឌាលកា ចេលកេដុ(១) ភណ្ឌុតិត្តិរនាមកា

ចេលាវកា បិង្គលាយោ   គោដកា អង្គហេតុកា ។

ករវិយា ច សគ្គា ច   ឧហុង្ការា ច កុក្កុហា

នានាទិជគណាកិណ្ណា   នានាសរនិកូជិតា ។

(៣២៣) អថេត្ថ សកុណា សន្តិ នីលកា(២) មញ្ជុភាណិកា

មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកូជិនោ ។

អថេត្ថ សកុណា សន្តិ ទិជា មញ្ជុស្សរា សិតា

សេតច្ឆិកូដា ភទ្រក្ខា អណ្ឌជា ចិត្របេក្ខុណា ។

អថេត្ថ សកុណា សន្តិ ទិជា មញ្ជុស្សរា សិតា

សិខណ្ឌី នីលគីវាហិ អញ្ញមញ្ញំ បកូជិនោ ។

កុកុត្ថកា កុឡីរកា   កោដ្ឋា បោក្ខរសាតកា

កាលាមេយ្យា ពលិយក្ខា កទម្ពា សុវសាលិកា ។

ហលិទ្ទា លោហិតា សេតា អថេត្ថ នលកា ពហូ

វារណា ភិង្គរាជា ច   កទម្ពា សុវកោកិលា ។

ឧក្កុសា កុររា ហំសា   អាដា បរិវទេន្តិកា

បាកហំសា(៣) អតិពលា នជ្ជុហា ជីវជីវកា ។

១ ម. ចេលកេតុ ។ ឱ. ចេលាវកេតុ ។ ២ ម. សាលិកា ។ ៣ ម. ឱ. បាកហំសា ។



ពួកខ្វែង ប្រមង់ ពន្លៀលខ្សឹង តាមស្រុក ចចាត ទទា ខ្វែក តាគូក ។ ពួកចចាតតង់ ប្រវាឡ ក្រួច ទទា តាមស្រុក តាមព្រៃ សាលិកា កែកេត ត្រល័តត្រលាច ។ ពួកករវិកផង ត្រចៀកកាំផង មៀមផង អកផង (មុចលិន្ទស្រះនោះ) កុះករដោយពួកបក្សីផ្សេងៗ ជាទីគ្រហឹងគឹកកងដោយសំឡេងផ្សេងៗ ។

(៣២៣) មួយទៀត ក្បែរមុចលិន្ទស្រះនោះ មានសត្វស្លាបទាំងឡាយ គឺពួកសាលិកាកែវ មានសម្លេងពីរោះ ស្រែកយំឆ្លើយឆ្លងនឹងគ្នាទៅវិញទៅមក រីករាយជាមួយនឹងញី (របស់ខ្លួន) ។ មួយទៀត ក្បែរមុចលិន្ទស្រះនោះ មានពួកសត្វស្លាបកើតពីពង មានសំឡេងពីរោះ មានត្របកភ្នែកស មានភ្នែកល្អ កើតក្នុងពង មានស្លាបវិចិត្រ ។ មួយទៀត ក្បែរមុចលិន្ទស្រះនោះ មានពួកបក្សី មានសំឡេងពីរោះ គឺក្ងោក មានកខៀវ ស្រែកយំឆ្លើយឆ្លងគ្នាទៅវិញទៅមក ។ សត្វគក្អឹង មាន់ព្រៃ គោដ្ឋបក្សីពាក់ ត្រចៀកកាំសមុទ្រ ខ្វែងជ្រក បក្សីប្រវឹក សេកនិងសាលិកា ។ មួយទៀត ក្បែរមុចលិន្ទស្រះនោះ មានពួកហង្សច្រើន មានសម្បុរលឿង ក្រហម-ស សត្វហត្ថលិង្គ សម្បុកត្រពាំង ប្រវឹក សេកនិងតាវ៉ៅ ។ ពួកអក្ខិតខ្មៅ អក្ខិតស ហង្សរាជ ក្ងួនស្រាក ពាកហង្ស កុកត្រាន ចោលតោក តាមស្រុក ។

តាវេត រវិបាំសា ធាតកភិតា ឆដិតក
ភិរណាកុំរុណា រម្មា ខេមា កាលុបក្ខជិនោ ។
អត្ថេត្ថ សកុណា សន្តិ នានាវណ្ណា ពហូ ទិជា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកូជិនោ ។
អត្ថេត្ថ សកុណា សន្តិ នានាវណ្ណា ពហូ ទិជា
សរេ មញ្ជូ និកូជន្តិ មុចលិន្ទមុភតោ សរំ ។
អត្ថេត្ថ សកុណា សន្តិ ករវីកា នាម តេ ទិជា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកូជិនោ ។
អត្ថេត្ថ សកុណា សន្តិ ករវីកា នាម តេ ទិជា
សរេ មញ្ជូ និកូជន្តិ មុចលិន្ទមុភតោ សរំ ។
ឯណេយ្យបសទាកិណ្ណំ នាគសំសេវិតំ វនំ
នានាលតាហិ សញ្ឆន្នំ កទលីមិគសេវិតំ ។
អត្ថេត្ថ សាមា[១] ពហុកា និភាវេ វរកោ ពហុ
សាលិ អកដ្ឋបាកោ ច ឧច្ឆុ តត្ថ អនប្បកោ ។

១ ម. សាសបា ពហុកា ។



ហ្វូងព្រាប ត្រៀលនិងកែក ចាក្រពាក ក្អែកទឹក ភារណបក្សី មានសំឡេងគួរឲ្យត្រេកអរ ស្រែកយំហៅគ្នាក្នុងកាលទាំងពីរ គឺព្រឹកល្ងាច ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបកើតពីដើម មានសម្បុរផ្សេងៗជាច្រើន ស្រែកយំឆ្លើយឆ្លងនឹងគ្នាទៅវិញទៅមក រីករាយជាមួយនឹងញី ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបមានកំណើតពីដើម មានសម្បុរផ្សេងៗជាច្រើន សុទ្ធតែមានសំឡេងពីរោះ ស្រែកស័ក្កសិទក្រញ៉ំនៅទាំងសងខាងមុចលិន្ទស្រះ ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកករវិក សត្វទាំងនោះមានកំណើតពីដើម រមែងស្រែកហៅគ្នា រីករាយជាមួយនឹងញី ។ មួយទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានពួកករវិក សត្វទាំងនោះមានកំណើតពីដើម សុទ្ធតែមានសំឡេងពីរោះ ស្រែកស័ក្កសិទក្រញ៉ំនៅទាំងសងខាងមុចលិន្ទស្រះ ។ ព្រៃ(ពិតស្រះមុចលិន្ទណោះ) ដែលពួកអីកេស្រ័យនៅហើយ សឹងពីក្របកដោយព្រាយ ស្វាន ទាំងដេរដាសដោយវល្លិផ្សេងៗ ដែលពួកសត្វឈ្លូសតែងស្រ័យនៅហើយ ។ មួយយ៉ាងទៀត ក្បែរមុចលិន្ទស្រះនុ៎ះ មានស្រូវផែច្រើន ស្គួយច្រើន គោតច្រើន ស្រូវសាលីដុះឯង មិនបាច់មានអ្នកណាភ្ជួររាស់ឡើយ ទាំងអំពៅសាគ៌ក៏មានច្រើន ដុះក្បែរមុចលិន្ទស្រះនុ៎ះ ។

អយំ ឯកបទី ឯតិ ឧជុំ គច្ឆតិ អស្សមំ
ខុទំ បិបាសំ អរតឹ តត្ថ បត្តោ ន វិន្ទតិ ។
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ ។
(៣៦៦) ឥទំ សុត្វា ព្រហ្មពន្ធុ ឥសឹ កត្វា បទក្ខិណំ
ឧទគ្គចិត្តោ បក្កាមិ យត្ថ វេស្សន្តរោ អហុ ។

មហាវនវណ្ណនា ។

(៣៦៧) ឧដ្ឋេហិ ជាលិ បតិដ្ឋ បោរាណំ វិយ ទិស្សតិ
ព្រាហ្មណំ វិយ បស្សាមិ នន្ទិយោ មាភិកីររេ ។
(៣៦៨) អហម្បិ តាត បស្សាមិ យោ សោ ព្រហ្មាវ ទិស្សតិ
អទ្ធិកោ វិយ អាយាតិ អតិថី នោ ភវិស្សតិ ។
(៣៦៩) កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។



ផ្លូវដើរនេះចុះតែជើងមួយ បុគ្គលដើរទៅត្រង់អាស្រម ដល់ទៅទីនោះហើយ ក៏មិនបានស្រេក ឃ្លាន និងសេចក្ដីអផ្សុកឡើយ ។ ជាអាស្រមដែលព្រះបាទវេស្សន្តរគង់នៅ ព្រមទាំងព្រះរាជបុត្រ និងព្រះរាជធីតា ព្រះអង្គទ្រង់ទ្រង់ភេទបព្វជិតដ៏ប្រសើរ មានដងកាន់និង វែកសម្រាប់បូជាភ្លើង និងសក់កណ្ដាញ់ ទ្រង់ស្បែកខ្លា ផ្ទុំលើផែនដី នមស្ការភ្លើង ។

(៣៦៦) (អភិសម្ពុទ្ធគាថា) ជូជកជាផៅពង្សនៃព្រាហ្មណ៍ ឮពាក្យនេះហើយ ក៏ធ្វើប្រទក្សិណឥសី មានចិត្តត្រេកអរ ក៏ដើរចេញទៅសំដៅទៅអាស្រម ដែលព្រះបាទវេស្សន្តរគង់នៅ ។

ចប់ មហាវនវណ្ណនា ។

(៣៦៧)(ព្រះវេស្សន្តរ..) ម្នាលជាលី អ្នកចូរក្រោកឈរឡើង (ដំណើរមករបស់ស្នូម) ព្រាហ្មណ៍ដូចជាដំណើរមកអំពីមុនៗ ពុកមើលទៅឃើញដូចជាព្រាហ្មណ៍ សេចក្ដីរីករាយ ក៏មកស្រោចស្រពលើចិត្ត ។

(៣៦៨)ជាលីកុមារ...) បពិត្រព្រះវរបិតា ខ្ញុំម្ចាស់មើលទៅ ឃើញបុគ្គលដូចជាព្រាហ្មណ៍ ដូចជាមានអ្នកដំណើរមក នឹងជាភ្ញៀវរបស់យើង ។

(៣៦៩) (ជូជក...) ព្រះអង្គបានសេចក្ដីសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គចិញ្ចឹមជីវិត ដោយការស្វែងរក (ស្រូវ) ទេឬ មើមឈើ និងផ្លែឈើ មានច្រើនឬ ។

កច្ចិ ឌំសា មកសា ច អប្បមេវ សរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតិ ។
(៣៤៨) កុសលញ្ចេវ តោ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ
អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។
អថោ ឌំសា មកសា ច អប្បមេវ សរីសបា
វនេ វាឡមិគាកិណ្ណេ ហឹសា មយ្ហំ ន វិជ្ជតិ ។
សត្ត នោ មាសេ វសតំ អរញ្ញេ ជីវសោកិនំ
ឥមំបិ បឋមំ បស្សាម ព្រាហ្មណំ ទេវវណ្ណិនំ
អាទាយ វេឡុវំ ទណ្ឌំ អគ្គិហុត្តំ កមណ្ឌលុំ ។
ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទំបិ បានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសិ ។
អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
អនុប្បត្តោ ព្រហារញ្ញំ តំ មេ អក្ខាហិ បុច្ឆិតោ ។



ពួករបោម មូស ពស់ មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនព្រះអង្គទេឬ ។

(៣៤៨) (ព្រះពោធិសត្វ..) ម្នាលព្រាហ្មណ៍ យើងបានសេចក្តីសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មួយទៀត យើងមិនមានរោគាពាធទេ យើងចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេ ទាំងមើមឈើនិងផ្លែឈើ ក៏មានច្រើនផង ។ មួយវិញទៀត ពួករបោម មូស ពស់ ក៏មានតិចទេ ក្នុងព្រៃដ៏កុះករ ដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនយើងទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែហើយ រស់នៅទាំងទុក្ខសោក ទើបតែនឹងបានឃើញព្រាហ្មណ៍ឯងជាដំបូង មានភេទដ៏ប្រសើរ កាន់ឈើច្រត់ មានសម្បុរដូចផ្ទះភ្លឺ មានវែកសម្រាប់បូជាភ្លើងនឹងកុណ្ឌី ។ ម្នាលមហាព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀត អ្នកមិនមែនមកអាក្រក់ទេ អ្នកចូរចូលមកខាងក្នុង សេចក្តីចំរើន(ចូរមាន)ដល់អ្នក អ្នកចូរលាងជើងរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែឈើដ៏ឆ្ងាញ់ពិសាដូចទឹកឃ្មុំ គឺផ្លែទន្លាប់ ផ្លែព្រីង ផ្លែមាក់ប្រាង ផ្លែមាក់ម៉េក ។ ទឹកដ៏ត្រជាក់នេះឯង ដែលយើងយកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ បើអ្នកប្រាថ្នាចង់ផឹក ចូរដងយកអំពីពេងទឹកនោះហើយផឹកចុះ ។ អ្នកមកដល់ព្រៃធំដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច យើងសួរហើយ អ្នកចូរប្រាប់ហេតុនោះ ។

(៣២៩) យថា ភិន្នោ ឃដោ សព្វកាលំ ន ទីយតិ
ឯវន្តំ យាចិតាកញ្ញំ បុត្តេ មេ ទេហិ យាចិតោ
(៣៣០) ទទាមិ ន វិកម្បាមិ ឥស្សរោ នយ ព្រាហ្មណ
មាតា គតា ភត្តិបុត្តី សាយំ ឧញ្ឆាតោ ឯហិតិ[១]
ឯករត្តឹ វសិត្វាន បាតោ គច្ឆសិ ព្រាហ្មណ ។
តស្សា ន្ហាតោ ឧបគ្ឃាតេ អថ នេ មាលធារិនេ
ឯករត្តឹ វសិត្វាន បាតោ គច្ឆសិ ព្រាហ្មណ ។
នានាបុប្ផេហិ សញ្ឆន្នេ នានាគន្ធេហិ ភូសិតេ
នានាមូលផលាកិណ្ណេ គច្ឆស្សាទាយ ព្រាហ្មណ ។
(៣៣១) ន វាសមភិរោចាមិ គមនំ មយ្ហំ រុច្ចតិ
អន្តរាយោបិ មេ អស្ស គច្ឆញ្ញេវ រថេសភ ។

១ ម. ឃ្រាយិតេ ។





(៣២៩) (ជូជក...) ដូចទឹក (មានទឹកក្នុងឆ្នាំងជាដើម) ដ៏ពេញប្រៀប មិនបានអស់ទៅសព្វកាល យ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំមកដើម្បីសូមទានព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមហើយ សូមទ្រង់ទានព្រះរាជបុត្រទាំងពីរ ក៏យ៉ាងនោះដែរ ។

(៣៣០) (ព្រះមហាសត្វ...) ម្នាលព្រាហ្មណ៍ យើងឲ្យ យើងមិនញាប់ញ័រទេ អ្នកជាម្ចាស់ (នៃពួកបុត្ររបស់យើង) ចូរនាំយកទៅចុះ កដ-បុត្រី (ជាមាតានៃបុត្រទាំងពីរនុ៎ះ) បានចេញទៅរកផលានុផលតាំងពីព្រឹក នាងនឹងត្រឡប់មកអំពីការស្វែងរកក្នុងវេលាល្ងាច ម្នាលព្រាហ្មណ៍ អ្នកចូរឈប់សម្រាកតែមួយយប់សិន លុះព្រឹកឡើងសឹមទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកឈប់សម្រាកតែមួយយប់ លុះព្រឹកឡើង (សឹមនាំយក) កុមារទាំងពីរនោះ ដែលមាតាគេនោះដុសក្បាលហើយ ប្រដាប់ដោយផ្កាកម្រង ហើយទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកចូរនាំយក (កុមារទាំងពីរនោះ) ដែលតាក់តែងដោយផ្កាផ្សេង ៗ ស្អិតស្អាងដោយគ្រឿងក្រអូបផ្សេង ៗ សម្បូណ៌ដោយមើមឈើនិងផ្លែឈើផ្សេង ៗ ហើយទៅចុះ ។

(៣៣១) (ជូជក...) បពិត្រព្រះអង្គប្រសើរក្នុងរថ ទូលព្រះបង្គំ មិនគាប់ចិត្តនឹងការនៅទេ គាប់ចិត្តនឹងការទៅ ក្រែងអន្តរាយមានដល់ទូលព្រះបង្គំ ឯទូលព្រះបង្គំ នឹងទៅ ឥឡូវនេះ ។

ន ហេតា យាចយោគី នំ អជ្ជកស្ស ភារិយា

ឥត្ថិកា មន្តំ ជានន្តិ សព្វំ គណ្ហន្តិ ភាសតោ ។

សព្វាយ តាតំ ឧបេតោ មា សមនត្តំ តាតរំ

អជ្ជកយំបិ សា កាយិក គច្ឆាញ្ញំ រជេសក ។

អាមន្តយស្សុ តេ បុត្តេ មា តេ តាតាមនុស្សុ

សព្វាយ តាតំ ឧបេតោ បរិ បុញ្ញំ បវស្សតិ ។

អាមន្តយស្សុ តេ បុត្តេ មា តេ តាតាមនុស្សុ

មាតិសស្ស ឧបំ ឧត្វា កាជ សក្កំ គមិស្សសិ ។

(៣៣៤) សចេ ត្វំ បព្វជស្សេ ឧបដ្ឋំ មម ភរិយំ បតិត្វំ

អយ្យកស្សុបមេនេហិ ជាលី កណ្ហាជិនំ កុមារេ ។

ឥមេ កុមារេ ទិស្វាន មញ្ញោ បិយកណាវេ

បតីតោ សុមនោ វិត្តោ ពហុំ ធនំ ទស្សតិ តេ ធនំ ។



នម្ភាក្មួកស្រីនុះមិនមែនជាអ្នកសូមរបស់ស្វាមីទេ តែងធ្វើសេចក្តីអន្តរាយ ពួកស្រីតែងដេរកិច្ចកលមាយា តែងកាន់យកកិច្ចការទាំងពួង ដោយការរំភូត ។ បពិត្រព្រះអង្គប្រសើរក្នុងនរជ ការបើព្រះអង្គប្រទាន ដោយសទ្ធា សូមកុំឲ្យ (ខ្ញុំព្រះបង្គំជាខ្ញុំ) ជួបនឹងព្រះមាតា (របស់កុមារទាំងនោះឡើយ) ព្រោះព្រះនាងនោះ ធ្វើសេចក្តីអន្តរាយ ខ្ញុំព្រះបង្គំនឹងទៅ តាមកុំបាន ។ សូមព្រះអង្គត្រាស់ហៅបុត្រទាំងពួងរបស់ព្រះអង្គមក កុំឲ្យបុត្រទាំងនោះបានឃើញព្រះមាតាឡើយ ការបើព្រះអង្គប្រទាន ដោយសទ្ធា បុណ្យតែងចំរើនល្អតលាស់យ៉ាងនេះ ។ សូមព្រះអង្គត្រាស់ហៅបុត្រទាំងពួងរបស់ព្រះអង្គមក កុំឲ្យបុត្រទាំងនោះបានឃើញព្រះមាតាឡើយ បពិត្រព្រះរាជា លុះព្រះអង្គប្រទានព្រះរាជទ្រព្យ ដល់បុគ្គលប្រាកដដូចជាខ្ញុំហើយ ព្រះអង្គនឹងយាងទៅកាន់ឋានសួគ៌ ។

(៣៣៤) ព្រះវេស្សន្តរ...) បើអ្នកមិនប្រាថ្នាចង់ជួបនឹងភរិយារបស់យើង ដែលជាស្រីមានកិច្ចស្មោះ អ្នកចូរនាំកុមារទាំងពីរ គឺជាលីនឹងកណ្ហាជិនានេះ ដល់ព្រះអយ្យកោចុះ ។ ព្រះអយ្យកោនោះ ទ្រង់ទតឃើញកុមារទាំងនេះ ដែលមានសំដីពីរោះ និយាយភាសាជាទីស្រឡាញ់ហើយ ទ្រង់សប្បាយរីករាយត្រេកអរ នឹងប្រទានទ្រព្យច្រើនដល់អ្នក ។

(៣៣៣) អយ្យកស្ស យាចាមិ រាជបុត្ត សុណោហិ មេ

រាជធញ្ញាយ មំ ឥច្ឆា វិត្តិំ លោយ្យំ មហេយ្យក

ទិន្នា ធនញ្ច ទាសេ ច ការយ្ហស្ស ព្រហ្មពន្ធុយា ។

(៣៣៤) ឥមេ កុមារេ ទិស្វាន មញ្ជុកេ បិយភាណិនេ

ឥច្ឆេ បិតា មហារាជា សិវីនំ រដ្ឋវឌ្ឍនោ

កត្វា បីតិសោមនស្សំ ពហុំ ទស្សតិ តេ ធនំ ។

(៣៣៥) នាហន្តំ បេ ការិស្សាមិ យំ មំ ត្វំ អនុសាសសិ

ទារកេ អហំ នេស្សំ ព្រាហ្មណិយា បរិចារកេ ។

(៣៣៦) តតោ កុមារា ព្យថិតា សុត្វា លុទ្ទស្ស ភាសិតំ

តេន តេន បធាវឹសុ ជាលី កណ្ហាជិនា ឧភោ ។

(៣៣៧) ឯហិ តាត បិយបុត្ត បូរេថ មម បារមី

ហទយំ មេភិសិញ្ចេថ ករោថ វចនំ មម ។



(៣៣៣) (ជូជក...) បពិត្រព្រះរាជបុត្រ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ (ពាក្យ) របស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនាំទៅក្រុងព្រះអយ្យកា ដល់ក្ដីមយក (ព្រះរាជកុមារ) ព្រះអយ្យកានឹងប្រទានខ្ញុំព្រះអង្គ (ដល់ពួកទាសា) ដើម្បីព្រះរាជទ្រព្យ ឬពេកក៏ដោយ តែនោះសោត នឹងសំឡាប់កុំពាន ខ្ញុំព្រះអង្គមុខជានឹងដាច់ពាក្យទ្រព្យផង ពាក ពួកទាសៈផង ត្រូវនាងព្រាហ្មណីតិះដៀលផង ។

(៣៣៤) (ព្រះវេស្សន្តរ...) ព្រះមហារាជទ្រង់បិតានៅក្នុងធម៌ ញុំាងពួកអ្នកសិវិក្រុងឲ្យចំរើន ទ្រង់ទតឃើញកុមារទាំងនេះ ដែលមានសំដីពីរោះ និយាយពាក្យផ្ទាំទីស្រឡាញ់ ទ្រង់បានបីតិនឹងសោមនស្ស នឹងព្រះរាជទានព្រះរាជទ្រព្យជាច្រើនដល់អ្នក ។

(៣៣៥) (ជូជក...) ខ្ញុំព្រះអង្គមិនធ្វើតាមព្រះបន្ទូលដែលទ្រង់បន្ទាប់នោះទេ ខ្ញុំព្រះអង្គសូមនាំយកទារកទាំងពីរទៅឲ្យបំរើនាងព្រាហ្មណី ។

(៣៣៦) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះរាជកុមារទាំងពីរ គឺជាលីនឹងកណ្ហាជិនា លុះឮសំដីព្រាហ្មណ៍ឃោរឃៅហើយ ក៏តក់ស្លុត នាំគ្នារត់ទៅតាមទីនោះ ៗ ។

(៣៣៧) (ព្រះមហាសត្វ...) ហៃពុធ ជាកូនសំណព្វស្រឡាញ់ កូនចូរមកតាម ចូរបំពេញបារមី របស់ពុក កូនចូរស្រោចស្រប់ហឫទ័យ របស់ពុក កូនចូរធ្វើតាមពាក្យ របស់ពុក ។

យានុការី ភវេ បោស អចលា អកោសកោ
ជាតិមារំ តរិស្សាមិ សព្ពាបស្សំ សទេវកោ ។
សចេ អន្នំ បិយា ជីវា បិយា មេ ធាតុធារមិ
មាតយំ មេតិសំពេទ្ធ ការេថ ពលំ មម ។
យានុការី ភវេ បោស អចលា អកោសកោ
ជាតិមារំ តរិស្សាមិ ទុគ្គតិស្សំ សទេវកោ ។

(៣៣៨) គតោ កុមារោ អាជាយ ជាលី កណ្ហាជិនំ ចុភោ
ព្រាហ្មណស្ស អជា ធានំ សំវីនំ វជ្ជវិឡារោ ។
គតោ កុមារោ អាជាយ ជាលី កណ្ហាជិនំ ចុភោ
ព្រាហ្មណស្ស អជា ចំត្តោ បុត្តកោ ធានមុត្តមំ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
យំ កុមារេ បទិន្នម្ហិ មេទនី សមកម្បថ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
យំ បញ្ជលីកតោ រាជា កុមារេ សុខវច្ឆិតេ
ព្រាហ្មណស្ស អជា ធានំ សំវីនំ វជ្ជវិឡារោ ។



កូនប្រុសជាយានុការ របស់ពុក ឲ្យនឹងថ្កល់ក្នុងសាលាកិត្តិ បិតានឹងឆ្លងនូវការកើតនិងជាតិ នឹងចម្លងនូវមនុស្ស ព្រមទាំងទេវតា (ទៅកាន់ត្រើយ គឺព្រះនិព្វាន) ។ ហេតុតែសេចក្តីស្រឡាញ់(ទុក) នាំផ្លូវមក ព្រោះតែធម៌ ជាសេចក្ដីស្រឡាញ់របស់ពុក នាំផ្លូវ ស្រោចស្រប់ហ្ឫទ័យ របស់ពុក ចូរធ្វើតាមពាក្យ របស់ពុក ។ នាំផ្លូវផ្លូវជាយានុការ របស់ពុក ឲ្យនឹងថ្កល់ក្នុងសាលាកិត្តិ ពុកនឹងឆ្លងនូវការកើតនិងជាតិ នឹងចម្លងនូវពួកមនុស្សព្រមទាំងទេវតា ។

(៣៣៨) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះបរមពោធិសត្វញ៉ាំងពួកអ្នកសិវិក្រុងឲ្យចំរើន ទ្រង់តាំងយកកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនា ហើយទ្រង់ប្រទានដល់ព្រាហ្មណ៍ ។ ក្នុងលំដាប់នោះ ព្រះរាជាទ្រង់មានព្រះហ្ឫទ័យរីករាយតាំងយកកុមារទាំងពីរ គឺជាលីនិងកណ្ហា-ជិនា ជាបុត្រឲ្យជាទានដ៏ឧត្តមដល់ព្រាហ្មណ៍ ។ ហេតុដែលគួរឲ្យស្ញប់ស្ញែង ក៏កើតមានក្នុងកាលនោះ សេចក្តីព្រឺព្រួចរោម ក៏កើតមានក្នុងកាលនោះ កាលដែលព្រះរាជាប្រទានកុមារទាំងពីរហើយ ផែនដីក៏កក្រើកញាប់ញ័រ ។ ហេតុដែលគួរឲ្យស្ញប់ស្ញែងក៏កើតមានក្នុងកាលនោះ សេចក្តីព្រឺព្រួចរោម ក៏កើតមានក្នុងកាលនោះ ព្រោះព្រះរាជា ញ៉ាំងពួកអ្នកសិវិក្រុងឲ្យចំរើន ទ្រង់ផ្គងអញ្ជលីប្រទានកុមារទាំងពីរ ដ៏ចំរើនដោយសេចក្តីសុខ ឲ្យជាទានដល់ព្រាហ្មណ៍ ។

(៣៥៩) តតោ សោ ព្រាហ្មណោ លុទ្ធោ លតំ ទន្តេហិ ឆិន្ទិយ

លតាយ ហត្ថេ ពន្ធិត្វា លតាយ អនុមជ្ជថ ។

តតោ សោ រជ្ជុមាទាយ ទណ្ឌញ្ចាទាយ ព្រាហ្មណោ

អាកោដយន្តោ តេ នេតិ សិវិរាជស្ស បេក្ខតោ ។

(៣៦០) តតោ កុមារា បក្កាមុំ ព្រាហ្មណស្ស បមុញ្ចិយ

អស្សុបុណ្ណេហិ នេត្តេហិ បិតរំ សោ ឧទិក្ខតិ ។

វេធមស្សត្ថបត្តំវ បិតុ បាទានិ វន្ទតិ

បិតុ បាទានិ វន្ទិត្វា ឥទំ វចនមព្រវិ ។

អម្មា ច តាត និក្ខន្តា ត្វញ្ច នោ តាត ទស្សសិ

យាវ អម្មំបិ បស្សេមុ អថ នោ តាត ទស្សសិ ។

អម្មា ច តាត និក្ខន្តា ត្វញ្ច នោ តាត ទស្សសិ

មា នោ ត្វំ តាត អទទា យាវ អម្មាបិ ឯតុ នោ ។

តទាយំ ព្រាហ្មណោ កាមំ វិក្កិណាតុ ហនាតុ វា

ពលវត្តាហោ អច្ចុនតោ អះជា ទុព្ពុបិណ្ឌិកោ



(៣៥៩) លំដាប់នោះ ព្រាហ្មណ៍ ជាអ្នកលោភនោះ បានកាត់វល្លិ៍
ដោយធ្មេញទាំងឡាយ ហើយចងដៃទាំងឡាយដោយវល្លិ៍ ហើយ
យកវល្លិ៍វាយបណ្តើរ ។ លំដាប់តពីនោះមក ព្រាហ្មណ៍នោះ កាន់
ខ្សែផង កាន់ឈើច្រត់ផង វាយកុមារទាំងពីរនោះ នាំបណ្តើរទៅ
(ក្នុងទី) ចំពោះព្រះភក្ត្រនៃព្រះបាទសិវី (វេស្សន្តរ) ។
(៣៦០) ក្នុងកាលដែលព្រាហ្មណ៍នាំទៅនោះ កុមារទាំងពីររួចខ្លួន
(អំពីចំណង) នៃព្រាហ្មណ៍ ហើយរត់គេចចេញទៅ កុមារនោះ
មាននេត្រទាំងពីរពេញដោយទឹកភ្នែក ក្រឡេកមើលព្រះបិតា ។
កុមារក៏ញាប់ញ័រប្រៀបដូចជាស្លឹកពោធិ៍ ថ្វាយបង្គំព្រះបាទទាំងគូ
របស់ព្រះបិតា លុះថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះបិតាហើយ
បានពោលពាក្យនេះថា បពិត្រព្រះបិតា ព្រះមាតាចេញទៅព្រៃ
ហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រព្រះបិតា ចាំ
យើងខ្ញុំជួបនឹងព្រះមាតាសិន សឹមព្រះអង្គប្រទានយើងខ្ញុំ ។ បពិត្រ
ព្រះបិតា ព្រះមាតាចេញទៅព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គ
ប្រទានយើងខ្ញុំ បពិត្រព្រះបិតា ព្រះអង្គកុំទាន់ប្រទានយើងខ្ញុំឡើយ
ទាល់តែព្រះមាតារបស់យើងខ្ញុំត្រឡប់មកសិន ។ ក្នុងវេលានោះព្រាហ្ម-
ណ៍នេះ ចង់លក់ឬចង់សម្លាប់ក៏តាមប្រាថ្នាចុះ (ដ្បិតព្រាហ្មណ៍
នេះ) មានជើងក្រញ៉ាំង ក្រចកស្អុយ មួយទៀត មានដុំសាច់យារ

និយោត្តកេដ្ឋោ ចបលោ  កឡារោ ភគ្គនាសកោ ។
កុព្ភុនកេ ភគ្គុបង្គី  អជោ វិសមចក្ខុកោ
លោមមស្សុ ហរិតកេសោ  វលីនំ តិលកាហតោ ។
បិង្គលោ ច វិនតោ ច  វិកដោ ច ព្រហា ខរោ
អជិនានិ ច សន្នទ្ធោ  អមនុស្សោ ភយានកោ ។
មនុស្សោ ឧទាហុ យក្ខោ  មំសលោហិតភោជនោ
គាមា អរញ្ញមាគម្ម  ធនំ តំ តាត យាចតិ ។
នីយមានេ បិសាចេន  កឹ នុ តាត ឧទិក្ខសិ
អស្មា នូន តេ ហទយំ  អយសា ទឡ្ហពន្ធនំ ។
យោ នោ ពទ្ធេ ន ជានាសិ  ព្រាហ្មណេន ធនេសិនា
អច្ចាយិកេន លុទ្ទេន  យោ នោ គាវោវ សុម្ភតិ ។
ឥធេវ អច្ឆតំ កណ្ហា  ន សា ជានាតិ កិញ្ចិ
មិគីវ ខីរសម្មត្តា  យូថា ហីនា បកន្ទតិ ។



បបូរមាត់ខាងលើវែង មានទឹកមាត់ហៀរចេញស្រញស្រួញ(ដូចក្ដាយជ្រូក) ច្រមុះបាក់ ១ មានគោរងធំកំប៉ុង ខ្នងកោង ភ្នែកស្រលៀង ពុកមាត់ពុកចង្កាក្រហម សក់លឿង ស្បែកជ្រួញជ្រីវ ខ្ទុះអាយកាចម៍រុយ ១ មានភ្នែកលៀនក្រហាក (ដូចភ្នែកឆ្មា) ចង្កេះ ខ្នងកង្វៀច សន្លាក់ឆ្អឹងលាតព្រលែស ១ ធំធេង ឈ្លានពាន ទុកជាស្លៀកដណ្ដប់ស្បែកខ្លា ក៏ដូចជាអមនុស្ស គួរស្ញើម ១ បពិត្រព្រះបិតា (ព្រាហ្មណ៍នេះ)ជាមនុស្ស ឬជាយក្ស ជាអ្នកស៊ីសាច់និងឈាម ចេញអំពីស្រុកមកកាន់ព្រៃ សូមទ្រព្យនឹងខ្លួន ពីព្រះបិតាឯង ១ បពិត្រព្រះបិតា យើងខ្ញុំត្រូវបិសាចកំពុងនាំទៅ ព្រះបិតាទ្រង់ទតឃើញម្ដេច ព្រះហឫទ័យរបស់ព្រះបិតា (ធ្ងន់ដូចថ្ម) ឬដូចជាដំណាប់ដែករឹងមាំ ព្រះអង្គមិនជ្រាបយើងខ្ញុំ ដែលព្រាហ្មណ៍ជាអ្នកស្វែងរកទ្រព្យឈ្លើយឈ្លោកហួសប្រមាណ ចាប់ចងហើយវាយយើងខ្ញុំ ដូចជាគេវាយគោ ១ នាងកណ្ហាជិនាចូរនៅក្នុងទីនេះចុះ ព្រោះនាងមិនទាន់ដឹងក្ដីនៅឡើយ រមែងយំកន្ទក់កន្ទេញ ដូចជាកូនម្រឹគនៅបៅដោះហើយព្រាត់ច្រាសចាកហ្វូង ១

[៣៤៣] ន មេ ឥទំ តថា ទុក្ខំ លព្ភា ហិ បុមុនា ឥទំ
យញ្ច អម្មំ ន បស្សាមិ តំ មេ ទុក្ខតរំ ឥតោ ។
ន មេ ឥទំ តថា ទុក្ខំ លព្ភា ហិ បុមុនា ឥទំ
យញ្ច តាតំ ន បស្សាមិ តំ មេ ទុក្ខតរំ ឥតោ ។
សា នូន កបណា អម្មា ចិររត្តាយ រុច្ឆតិ
កណ្ហាជិនំ អបស្សន្តី កុមារិំ ចារុទស្សនិំ ។
សោ នូន កបណោ តាតោ ចិររត្តាយ រុច្ឆតិ
កណ្ហាជិនំ អបស្សន្តោ កុមារិំ ចារុទស្សនិំ ។
សា នូន កបណា អម្មា ចិរំ រុច្ឆតិ អស្សមេ
កណ្ហាជិនំ អបស្សន្តី កុមារិំ ចារុទស្សនិំ ។
សោ នូន កបណោ តាតោ ចិរំ រុច្ឆតិ អស្សមេ
កណ្ហាជិនំ អបស្សន្តោ កុមារិំ ចារុទស្សនិំ ។



៣៤១] ទុក្ខដូច្នោះនេះមិនមែនជាទុក្ខដល់អញទេ ព្រោះទុក្ខនេះ បុរស (ដែលគេគាត់ទៅក្នុងគុក) ត្រូវបាន អញមិនឃើញព្រះមាតាណា ការមិនឃើញព្រះមាតានោះ ជាសេចក្តីទុក្ខក្រៃលែង របស់អញ ជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ទុក្ខដូច្នោះ នេះ មិនមែនជាទុក្ខដល់អញទេ ព្រោះទុក្ខនេះ បុរសត្រូវបាន អញមិនឃើញព្រះមាតាណា ការមិនឃើញព្រះមាតានោះ ជាសេចក្តីទុក្ខក្រៃលែង របស់អញ ជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ព្រះមាតានោះ ជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះបិតានោះជាមនុស្សកំព្រាដោយពិត កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះមាតានោះ ជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែង ក្នុងអាស្រម អស់កាលយូរ ។ ព្រះបិតានោះ ជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារី ឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែង ក្នុងអាស្រម អស់កាលយូរ ។

សា នូន កបណា អម្មា ចិរំ រត្តាយ រុច្ឆតិ
អឌ្ឍរត្តេ វ រត្តេ វា នទីវ អវសុស្សតិ ។
សោ នូន កបណោ តាតោ ចិរំ រត្តាយ រុច្ឆតិ
អឌ្ឍរត្តេ វ រត្តេ វា នទីវ អវសុស្សតិ ។
ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារកា
វិវិធានិ រុក្ខជាតានិ តានិ អជ្ជ ជហាមសេ ។
អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិត្ថនា
វិវិធានិ ផលជាតានិ តានិ អជ្ជ ជហាមសេ ។
ឥមេ តិដ្ឋន្តិ អារាមា អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡាម តានិ អជ្ជ ជហាមសេ ។
វិវិធានិ បុប្ផជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ធារេម តានិ អជ្ជ ជហាមសេ ។
វិវិធានិ ផលជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ភុញ្ជាម តានិ អជ្ជ ជហាមសេ ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ទា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡាម តានិ អជ្ជ ជហាមសេ ។



ព្រះមាតានោះ ជាមនុស្សកំព្រាពិត (ព្រោះកូនយើង) ក្នុងពាក់កណ្តាលអធ្រាត្រ ឬក្នុងរាត្រីទាំងមូល គឺនឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចស្ទឹង ។ ព្រះបិតានោះ ជាមនុស្សកំព្រាដោយពិត (ព្រោះកូនយើង) ក្នុងកណ្តាលអធ្រាត្រ ឬក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួត ដូចជាស្ទឹង ។ រុក្ខជាតិផ្សេងៗទាំងនេះ គឺដើមព្រីង ឈើតាលទ្រូង មានមែកក្រស៊ុំក្រសាយ ថ្ងៃនេះ យើងនឹងបោះបង់នូវរុក្ខជាតិទាំងនោះចោលហើយ ។ ពួកផលជាតិផ្សេងៗទាំងនេះ គឺពោធិ៍ ខ្នុរ ផ្លែ ក្រសាំង ថ្ងៃនេះ យើងនឹងបោះបង់ផលជាតិទាំងនោះចោលហើយ ។ នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើមយើងលេងក្នុងទីណា ថ្ងៃនេះ យើងនឹងបោះបង់ទីទាំងនោះ ។ ពីដើមពួកយើងទ្រទ្រង់ផ្កាណាច្រើនយ៉ាង លើភ្នំនេះ ថ្ងៃនេះ យើងនឹងបោះបង់ផ្កាទាំងនោះ ។ ពីដើមពួកយើងបរិភោគផ្លែឈើណាច្រើនយ៉ាង លើភ្នំនេះ ថ្ងៃនេះ យើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ នេះហ្វូងដំរី ហ្វូងសេះរបស់យើង នេះហ្វូងគោរបស់យើង ពីដើមយើងលេងដោយហ្វូងណា ថ្ងៃនេះ យើងនឹងបោះបង់ហ្វូងទាំងនោះ ។

(៣៤២) ធីយមានា កុមារកេ បិតរំ ឯតទព្រវុំ
អម្មំ អារោគ្យំ វជ្ជាសិ ត្វញ្ច តាត សុខី ភវ ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ទា ច នោ ឥមេ
តានិ អម្មាយ ទជ្ជាសិ សោកំ តេហិ វិនេស្សតិ ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ទា ច នោ ឥមេ
តានិ អម្មា ឧទិក្ខន្តី សោកំ បដិវិនេស្សតិ ។

(៣៤៣) តតោ វេស្សន្តរោ រាជា ទានំ ទត្វាន ខត្តិយោ
បណ្ណសាលំ បវិសិត្វា កលុណំ បរិទេវយិ ។
កន្វជ្ជ ឆាតា តសិតា ឧបរុជ្ជន្តិ ទារកា
សាយំ សំវេសនាកាលេ កោ នេ ទស្សតិ ភោជនំ ។
កន្វជ្ជ ឆាតា តសិតា ឧបរុជ្ជន្តិ ទារកា
សាយំ សំវេសនាកាលេ អម្មា ឆាតម្ហ ទេថ នោ ។



(៣៤២) កុមារទាំងនោះ កាលដែលព្រាហ្មណ៍កំពុងនាំទៅ បាននោល នឹងព្រះបិតាដូច្នេះថា បពិត្រព្រះបិតា សូមព្រះអង្គប្រាប់នូវការ (របស់ យើងខ្ញុំ) ថាបុត្រមិនមានរោគដល់ព្រះមាតាផង ចំណែកព្រះអង្គសោត ក៏សូមឲ្យបានសេចក្ដីសុខ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះ រូបគោរបស់យើងខ្ញុំ សូមព្រះអង្គប្រគល់រូបទាំងនោះដល់ព្រះមាតា នឹងបន្ទោបង់សោក ព្រោះរូបទាំងនោះ ។ នេះរូបដំរី រូបសេះ របស់យើងខ្ញុំ នេះរូបគោរបស់យើងខ្ញុំ ព្រះមាតាកាលបើក្រឡេក ឃើញរូបទាំងនោះហើយ នឹងបន្ទោបង់សោកចេញបាន ។

(៣៤៣) លំដាប់នោះ ព្រះបាទវេស្សន្តរជាក្សត្រិយ៍ ទ្រង់ដាក់ទានរួច ហើយ ក៏យាងចូលទៅកាន់បណ្ណសាលា ហើយខ្សឹកខ្សួល គួរឲ្យ ករុណាចលាចល ។ (ព្រះមហាសត្វទ្រង់ព្រះពិលាបថា) ក្នុងថ្ងៃ នេះ ទារកទាំងពីរ មានសេចក្ដីស្រេកឃ្លាន ហើយយំទារនឹង អ្នកណាហ្ន៎ នឹងឲ្យភោជន ដល់ទារកទាំងពីរនោះ ក្នុងកាលជាទី អត្តាស (អាហារ) ក្នុងវេលាល្ងាច ។ ក្នុងថ្ងៃនេះ ទារកទាំងពីរ មានសេចក្ដីស្រេកឃ្លាន ហើយយំទារនឹងថា បពិត្រព្រះមាតា យើង ខ្ញុំមានសេចក្ដីស្រេកឃ្លានហើយ សូមព្រះមាតាប្រទានភោជនដល់ យើងខ្ញុំ ក្នុងកាលជាទីអត្តាស (អាហារ) ក្នុងវេលាល្ងាច ។

កាមន្តុ ឋថំ គច្ឆន្តិ   បត្តិកា អនុតាហតា

សព្វា សុរោណំ តាឡេហិ   កោ ទេ ចាគ្គេ គហេស្សតិ ។

កាមន្តុ សោ អលង្កេយ្យ   សន្ធា បហំ ឆម

អនុស្សកានំ ពុត្តានំ   អលង្ខំ វត ព្រាហ្មណោ ។

យោ បិទេ តាសីតាសស្ស   វញ្ញោ កិបន ទេសំយោ

គស្សាបិ សុវីហ៊ិនស្ស   កោ លង្ខំ ឧតាវិស្សតិ ។

ភវិជស្សេវ ទេ សាតោ   តព្វស្ស កុមិយោ ឪទេ

អញ្ញាសតំ បហារតិ   ឋិយេ ពុត្តេ អបស្សតោ ។

(៣៦៦) អាគ្គុ(១) តានំ គហោត្វាន   ខត្តំ គច្ឆិយ កិឋកោ

អាធិស្សាមិ សកេ ពុត្តេ   ពុត្តានំ ហិ វិតោ ធុវញ្ញា ។

អត្ថានមេតំ ធុក្ខរូបំ   យំ កុមារា វិហញ្ញរ

សតញ្ច ធម្មញ្ញាយ   កោ ឆត្តា អនុតប្បតិ ។

(៣៦៧) សព្វំ គំហេមាហិស្ស   ធន ឃតគច្ឆិយា ឥធ

យស្ស ឆត្តំ សគា មាតា   យថា(២) ឆត្តំ គះជំរសោ ។

---

១ ម. ផត្ថុ ។ ២ ម. បិតា អត្ថិ ។



តាកេទាំងពីរដើរទៅដោយជើងទទេ មិនមានស្បែកជើង ឡើយ ហត់ នាងជើងទាំងពីរដ៏ក្រៀមក្រំ ទៅកាន់ផ្លូវ ដូចម្ដេចបាន អ្នកណាទឹងដឹកនាំតាកេទាំងនោះទៅ ។ កោតកែព្រាហ្មណ៍នោះហើយ ក៏យកកូនទាំងពីររបស់អញ ជាអ្នកមិនមានកំហុស ក្នុងទីចំពោះមុខ មិនអៀនខ្មាស ព្រាហ្មណ៍នេះហៅពេញជាមនុស្សថោកអៀនខ្មាស ។ អ្នកណាមានសេចក្ដីអៀនខ្មាស នឹងក៏យកកូនដែន ស្ទើរជាខ្ញុំស្រីខ្ញុំប្រុស ឬជាអ្នកបម្រើផ្ទៃរបស់អញ ដែលលទ្ធើរហើយនោះ ។ ព្រាហ្មណ៍ហិនទេវ ហិនតក់យកកូនសំឡាញ់របស់អញ ដែលកំពុងមើលឃើញ ដូចជាត្រីដែលជាប់នៅក្នុងមងក៏លប ។

(៣៦៦) អញនឹងកាន់យកធ្នូ ស្ពាយប្រដាប់លើស្មាកន់ខ្សែ ហើយ នាំយកកូនទាំងពីររបស់ខ្លួនមកវិញ ព្រោះជាការដែលគេក៏យដំកូនទាំងពីរ នាំមកនូវសេចក្ដីទុក្ខ ។ កូនទាំងពីរ គប្បីលំបាកដោយហេតុណា ហេតុនុ៎ះ មិនមែនជាទីកាន់នាងសកាគជាទុក្ខទេ នរណាយល់ធម៌របស់ពួកសប្បុរស ហើយឲ្យតាន ក៏មិនក្ដៅក្រហាយឡើយ ។ ។

(៣៦៧) (ជាលីកុមារ ...) ឧបានពួតា ដែនពួកខ្ញុំ គឺដំណាក់នេះ ឮនរពាលពាក្យពិត យ៉ាងនេះថា បុគ្គលណា មិនមានមាតាបាន៉ិត បុគ្គលនោះ ឈ្មោះថា មិនមានបិតា ដូចគ្នាដែរ ។

ឯហិ កណ្ហេ មរិស្សាម នត្ថត្ថោ ជីវិតេន នោ
ទិន្នម្ហាសេ ជនិន្ទេន ព្រាហ្មណស្ស ធនេសិនោ
អច្ចាយិកស្ស លុទ្ទស្ស យោ នោ គាវោវ សុម្ភតិ
ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារកា
វិវិធានិ រុក្ខជាតានិ តានិ កណ្ហេ ជហាមសេ ។
អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិត្ថនា
វិវិធានិ ផលជាតានិ តានិ កណ្ហេ ជហាមសេ ។
ឥមេ តិដ្ឋន្តិ អារាមា អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡាម តានិ កណ្ហេ ជហាមសេ ។
វិវិធានិ បុប្ផជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ធារេម តានិ កណ្ហេ ជហាមសេ ។
វិវិធានិ ផលជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ភុញ្ជាម តានិ កណ្ហេ ជហាមសេ ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ទា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡាម តានិ កណ្ហេ ជហាមសេ ។
(៣៤៦) នីយមានា កុមារា តេ ព្រាហ្មណស្ស បមុញ្ចិយ
តេន តេន បធាវិំសុ ជាលី កណ្ហាជិនា ចុភោ ។



ឱនាងកណ្ហាប្អូន នាងចូរមក យើងមុខជាមិនស្លាប់ យើងមិនមានសេចក្តីត្រូវការដោយជីវិតទេ ដោយយើងត្រូវព្រះជនិន្ទប្រទានដល់ព្រាហ្មណ៍អ្នកស្វែងរកទ្រព្យ ជាមនុស្សគំរោចលើសលប់ វាយដំយើងដូចជាគេវាយហ្វូងគោ ។ ឱនាងកណ្ហា ពួករុក្ខជាតិផ្សេងៗនេះ គឺដើមព្រីង ឈើពាលខ្ពស់ មានមែកត្រសុំត្រសាយ យើងនឹងលះបង់រុក្ខជាតិទាំងនោះ ឱនាងកណ្ហា ពួកផលជាតិផ្សេងៗនេះ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង យើងនឹងលះបង់ផលជាតិទាំងនោះ ។ ឱនាងកណ្ហា នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ កាលដើមយើងលេងក្នុងទីណា យើងនឹងលះបង់ទីទាំងនោះ ឱនាងកណ្ហា កាលដើមយើងទ្រទ្រង់ផ្កាទាំងឡាយណាផ្សេងៗ លើភ្នំនេះ យើងនឹងលះបង់ផ្កាទាំងនោះ ។ ឱនាងកណ្ហា កាលដើមយើងបរិភោគផ្លែឈើផ្សេងៗទាំងឡាយណា យើងនឹងលះបង់ផ្លែឈើទាំងនោះ ។ ឱនាងកណ្ហា នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់យើង ជារូបដែលយើងធ្លាប់លេង យើងនឹងលះបង់រូបនោះ ។

[៣៤៦] (អភិសម្ពុទ្ធគាថា) កុមារទាំងពីរនោះ គឺជាលីនិងកណ្ហាជិនា កាលដែលព្រាហ្មណ៍កំពុងនាំទៅ ក៏ស្ទុះចេញ (អំពីចំណង) ហើយនាំគ្នាស្ទុះទៅក្នុងទីនោះៗ ក្នុងខណៈនោះ ។

(៣៤៧) តតោ សោ រជ្ជុមាទាយ ទណ្ឌញ្ច ទាយ ព្រាហ្មណោ
អាកោដយន្តោ តេ នេតិ សិវិរាជស្ស បេក្ខតោ ។

(៣៤៨) តំ តំ កណ្ហាជិនាវោច អយំ មំ តាត ព្រាហ្មណោ
លដ្ឋិយា បដិកោដេតិ ឃរេ ជាតំវ ទាសិយំ ។
ន ចាយំ ព្រាហ្មណោ តាត ធម្មិកា ហោន្តិ ព្រាហ្មណា
យក្ខោ ព្រាហ្មណវណ្ណេន ខាទិតុំ តាត នេតិ នោ
នីយមានេ បិសាចេន កិន្នុ តាត ឧទិក្ខសិ ។

(៣៤៩) ឥមេ នោ បាទកា ទុក្ខា ទីឃោ ចទ្ធា សុទុគ្គមោ
នីចេ ចោលម្ពតេ សុរិយោ ព្រាហ្មណោ ច តុរេតិ នោ ។
ឱក្កន្តាម្ហសេ ភូតានិ បព្វតានិ វនានិ ច
សរស្ស សិរសា វន្ទាម សុបតិត្ថេ ច អាបកេ ។
តិណលតានិ ឱសធ្យោ បព្វតានិ វនានិ ច



(៣៤៧) លំដាប់នោះ ជូជកព្រាហ្មណ៍នោះ កាន់យកខ្សែ និងឈើច្រត់ វាយដំកុមារទាំងពីរនោះ ហើយនាំទៅក្នុងទីចំពោះព្រះភក្ត្រ នៃព្រះបាទសិវិ (វេស្សន្តរ) ។

(៣៤៨) នាងកណ្ហាជិនា បានពោលនឹងព្រះបិតានោះថា បពិត្រព្រះបិតា ព្រាហ្មណ៍នេះ វាយខ្ញុំម្ចាស់ដោយឈើច្រត់ ដូចជាទាសីដែលកើតក្នុងផ្ទះ ។ បពិត្រព្រះបិតា នេះមិនមែនជាព្រាហ្មណ៍ទេ ព្រោះពួកព្រាហ្មណ៍ជាអ្នកប្រកបដោយធម៌ បពិត្រព្រះបិតា យក្សក្លែងភេទជាព្រាហ្មណ៍នាំយើងខ្ញុំយកទៅស៊ីទេដឹង បពិត្រព្រះបិតា យើងខ្ញុំត្រូវបិសាចកំពុងនាំទៅ ហេតុអ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ ។

(៣៤៩) ជើងទាំងពីរ របស់យើងខ្ញុំនេះ ក៏សែនលំបាក ផ្លូវសោតក៏ឆ្ងាយដាច់ស្រយាល លំបាកនឹងដើរទៅណាស់ ព្រះសុរិយាក៏កាន់តែទន់ទាប ផងឥតស្លន់ណាស់ហើយ ព្រាហ្មណ៍ក៏នាំយើងខ្ញុំទៅប្រញាប់ប្រញាល់ ។ យើងខ្ញុំ សូមថ្វាយបង្គំ នូវពួកភូតដែលនៅអាស្រ័យលើភ្នំនិងព្រៃ សូមថ្វាយបង្គំដោយសិរសា នូវពួកទេវតាដែលរក្សាស្រះ និងទេវតាដែលនៅអាស្រ័យក្នុងស្ទឹងមានកំពង់ដ៏ល្អ ។ (យើងខ្ញុំ សូមថ្វាយបង្គំ) នូវពួកទេវតាដែលនៅអាស្រ័យលើស្មៅ និងវល្លិ៍ និងឈើឱសថ និងភ្នំ និងព្រៃ

អម្មំ អារោគ្យំ វជ្ជាសិ អយំ នោ នេតិ ព្រាហ្មណោ ។
វជ្ជេថ ភោន្តោ អម្មញ្ច មទ្ទឹ អស្មាក មាតរំ
សចេ អនុបតិតុកាមា ខិប្បំ អនុបតេយ្យ នោ ។
អយំ ឯកបទី ឯតិ ឧជុំ វដ្ដតិ អស្សមំ
តមេវានុបតេយ្យាសិ អបិ បស្សេសិ នោ លហុំ ។
អហោ វត រេ ជដិនី វនមូលផលហារិយា
សុញ្ញំ ទិស្វាន អស្សមំ តន្តេ ទុក្ខំ ភវិស្សតិ ។
អតិវេលំ នុ អម្មាយ ឧញ្ឆា លទ្ធំ អនប្បកំ
យា នោ ពទ្ធេ ន ជានាតិ ព្រាហ្មណេន ធនេសិនា ។
អច្ចាយិកេន លុទ្ទេន យោ នោ គាវោវ សុម្ភតិ
អបជ្ជ អម្មំ បស្សេមុ សាយំ ឧញ្ឆាតោ អាគតំ ។
ទជ្ជា អម្មា ព្រាហ្មណស្ស ផលំ ខុទ្ទេន មិស្សិតំ
តទាយំ អសិតោ ធាតោ[១] ន ពាឡ្ហំ ធារយេយ្យ នោ ។
សុណា ច វត នោ បាទា ពាឡ្ហំ វារេតិ ព្រាហ្មណោ
ឥតិ តត្ថ វិលបិំសុ កុមារា មាតុគិទ្ធិនោ ។

កុមារបព្វំ នាម ។

១ ម. ឃាតោ ។



សូមទេវតាទាំងឡាយ ទូលព្រះមាតានូវការរបស់យើងខ្ញុំជាអ្នកមិនមានរោគ ដ្បិតព្រាហ្មណ៍នេះកំពុងនាំយកយើងខ្ញុំទៅ ។ សូមពួកលោកដ៏ចំរើន ទូលដល់ព្រះមេម៉្រីជាព្រះមាតារបស់យើងខ្ញុំថា បើលោកចង់អញ្ជើញមកតាមយើងខ្ញុំ គប្បីអញ្ជើញមកឲ្យឆាប់ ។ ផ្លូវនេះ ដើរចុះតែដើរមួយ ត្រង់ទៅកាន់អាស្រម ព្រះមាតាគប្បីស្តេចអញ្ជើញមកតាមផ្លូវនោះឯង មុខជានឹងឃើញយើងខ្ញុំភ្លាម ។ បពិត្រព្រះមាតា ដ៏មានផ្នួងសក់ ទុក្ខនោះនឹងមានដល់លោក ដែលនាំមើមឈើ និងផ្លែឈើអំពីព្រៃមក ព្រោះឃើញអាស្រមស្ងាត់ជ្រងំ ។ ព្រះមាតាបាន (មើមឈើនិងផ្លែឈើអំពីព្រៃនឹងចំណី) ច្រើន ហើយមកស្វែងរកក្នុងវេលា មិនប្រទះយើងខ្ញុំដែលព្រាហ្មណ៍ អ្នកស្វែងរកទ្រព្យ កំណាចលើសលប់ ចងវាយដំយើងខ្ញុំ ដូចជាគោ វាយហ្វូងគោ ម្យ៉ាងទៀត យើងខ្ញុំសូមជួបនឹងព្រះមាតា ដែលអញ្ជើញមកអំពីការស្វែងរកផ្លែឈើ ក្នុងវេលាល្ងាច ។ ព្រះមាតាគប្បីប្រទាន ផ្លែឈើលាយដោយទឹកឃ្មុំ ដល់ព្រាហ្មណ៍ ។ នេះបានបរិភោគផ្លែឈើនោះឆ្អែតហើយ មុខជាមិនបង្ខំនាំយើងខ្ញុំទៅ ។ កុមារទាំងពីរ មានសេចក្ដីជាប់ចិត្តនឹងព្រះមាតា ពិលាបក្នុងកាលនោះថា ទៀត ជើងទាំងឡាយរបស់យើងពុះពងអស់ហើយ ព្រាហ្មណ៍ដឹកនាំយើងទៅប្រញាប់ប្រញាល់ខ្លាំងណាស់ ។

ចប់ កុមារបព្វ ។

(៣៨០) តេសំ លាលប្បិតំ សុត្វា តយោ វាឡា វនេ មិគា
សីហោ ព្យគ្ឃោ ច ទីបិ ច ឥទំ វចនមព្រវុំ ។
មា ហេវ នោ រាជបុត្តី សាយំ ឧញ្ឆាតោ អាគមា
មា ហេវម្ហាកំ វិជិតេ ហេឋយិត្ថ វនេ មិគា ។
សីហោ ចេ នំ វិហេឋេយ្យ ព្យគ្ឃោ ទីបិ ច លក្ខណំ
នេវ ជាលីកុមារស្ស កុតោ កណ្ហាជិនា សិយា
ឧភយេនេវ ជីយេថ បតិំ បុត្តេ ច លក្ខណា ។
(៣៨១) ខណិត្តិកំ មេ បតិតំ ទក្ខិណក្ខិ ច ផន្ទតិ
អផលា ផលិនោ រុក្ខា សព្វា មុយ្ហន្តិ មេ ទិសា ។
តស្សា សាយណ្ហកាលស្មិំ អស្សមាគមនំ បតិ
អត្ថង្គតម្ហិ សុរិយេ វាឡា បន្ថេ ឧបដ្ឋហុំ ។
នីចេ ចោលម្ពតេ សុរិយោ ទូរេ ច វត អស្សមោ
យញ្ច នេសំ ឥតោ ហស្សំ តន្តេ ភុញ្ជេយ្យុ ភោជនំ ។



(៣៨០) (អភិសម្ពុទ្ធគាថា) ពួកទេវតាបានឮពិលាបនៃកុមារទាំងពីរនោះ ហើយ បានពោលពាក្យនេះថា អ្នកទាំងឡាយ ចូរធ្វើជាម្រឹគសាហាវក្នុងព្រៃ គឺសីហៈ១ ខ្លាធំ១ ខ្លារខិន១ ។ កុំឲ្យព្រះរាជបុត្រីមកអំពីការស្វែងរកផ្លែឈើ ក្នុងវេលារសៀលឡើយ កុំឲ្យពួកម្រឹគក្នុងព្រៃ ជាដែនរបស់យើង បៀតបៀនឡើយ ។ ប្រសិនបើ សីហៈក្តី ខ្លាធំក្តី ខ្លារខិនក្តី បៀតបៀននាងមទ្រី ដែលប្រកបដោយលក្ខណៈនោះហើយ ជាលិកុមារនឹងនាងកណ្ហាជិនា នឹងរស់នៅដូចម្តេចបាន នាងមទ្រី ដែលប្រកបដោយលក្ខណៈ នឹងព្រាត់ប្រាសចាកចំណែកទាំងពីរ គឺភស្តានឹងបុត្រទាំងពីរ ។

(៣៨១) (ព្រះនាងមទ្រី...) ជន្លីក ធ្លាក់ចុះ (អំពីដៃ) របស់ខ្ញុំ ភ្នែកស្តាំក៏ករព្រើក ទាំងដើមឈើមានផ្លែ ក៏ប្រែជាមិនមានផ្លែ ខ្ញុំវង្វេងទិសទាំងអស់ ។ កាលដែលខ្ញុំនោះ មកកាន់អាស្រម ក្នុងវេលាល្ងាច ក្នុងពេលដែលព្រះអាទិត្យអស្តង្គតហើយ ក៏មានពួកម្រឹគសាហាវ មកឈរកំដរផ្លូវ កាលបើព្រះអាទិត្យទៀបអស្តង្គតហើយ អាស្រមក៏នៅឆ្ងាយណាស់ ខ្ញុំនឹងនាំយកមើមឈើនិងផ្លែឈើណា អំពីទីនេះ ដើម្បីជនទាំងនោះ ជនទាំងនោះ គប្បីចាំញ៉ាបរិភោគនូវមើមឈើនិងផ្លែឈើនោះ ជាភោជន ។

សោ នូន ខត្តិយោ ឯកោ  បណ្ណសាលាយ អច្ឆតិ
តោសេន្តោ ទារកេ ឆាតេ  មមំ ទិស្វា អនាយតឹ ៗ
តេ នូន បុត្តកា មយ្ហំ  កបណាយ វរាកិយា
សាយំ សំវេសនាកាលេ  ខីរបីតាវ អច្ឆរេ ៗ
តេ នូន បុត្តកា មយ្ហំ  កបណាយ វរាកិយា
សាយំ សំវេសនាកាលេ  វារិបីតាវ អច្ឆរេ ៗ
តេ នូន បុត្តកា មយ្ហំ  កបណាយ វរាកិយា
បច្ចុគ្គតា មំ តិដ្ឋន្តិ  វច្ឆា ពាលាវ មាតរំ ៗ
តេ នូន បុត្តកា មយ្ហំ  កបណាយ វរាកិយា
បច្ចុគ្គតា មំ តិដ្ឋន្តិ  ហំសាវុបរិបល្លលេ ៗ
តេ នូន បុត្តកា មយ្ហំ  កបណាយ វរាកិយា
បច្ចុគ្គតា មំ តិដ្ឋន្តិ  អស្សមស្សាវិទូរតោ ៗ
ឯកាយនោ ឯកបថោ  សរា សោព្ភា ច បស្សតោ
អញ្ញំ មគ្គំ ន បស្សាមិ  យេន គច្ឆេយ្យ អស្សមំ ៗ
មិគា នមត្ថុ រាជានោ  កាននស្មឹ មហព្វលា
ធម្មេន ភាតរោ ហោថ  មគ្គំ មេ ទេថ យាចិតា ៗ





ក្សត្រិយ៍នោះនឹងនៅតែមួយអង្គឯងក្នុងបណ្ណសាលាពិត ម្ល៉េះសម ឃើញអាត្មាអញដែលមិនទាន់មកដល់ ក៏ទ្រង់លួងលោមទារកទាំងពីរ ដែលមានសេចក្ដីស្រេកឃ្លាន ៗ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រា កំសត់ វេទនាពិត នៅអង្គុយ (ចាំមើលផ្លូវ) ដូចកូនម្រឹគ នៅបៅទឹកដោះ ក្នុងវេលាល្ងាច ក្នុងវេលាដែលចូលដេក ៗ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រា កំសត់ វេទនាពិត នៅអង្គុយ (ចាំមើលផ្លូវ) ដូចកូនម្រឹគប្រាថ្នាទឹកផឹក ក្នុងវេលាល្ងាច ក្នុងវេលាដែលចូលដេក ៗ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រា កំសត់ វេទនាពិត នាំគ្នាឈរចាំទទួលអញ ដូចជាកូនគោតូចឈរចាំទទួលមេ ៗ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រា កំសត់ វេទនាពិត នាំគ្នាឈរចាំទទួលអញដូចជាកូនហង្សឈរនៅលើភក់ ៗ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រាកំសត់ វេទនាពិត នាំគ្នាឈរចាំទទួលអញ ក្នុងទីមិនឆ្ងាយអំពីអាស្រម ៗ ផ្លូវតែមួយ ចុះបានតែដើរនៃបុគ្គលម្នាក់ ក្បែរខាងផ្លូវមានស្រះ មានជ្រោះ អញមិនឃើញផ្លូវដទៃ សម្រាប់ទៅកាន់អាស្រមបានទេ ៗ បពិត្រម្រឹគទាំងឡាយ ខ្ញុំសូមថ្វាយបង្គំលោកទាំងឡាយ ជាស្ដេច មានកំឡាំងច្រើន ក្នុងព្រៃធំ សូមលោកជាបងប្អូននឹងខ្ញុំដោយធម៌ លោកទាំងឡាយ កាលបើខ្ញុំអង្វរហើយ ក៏សូមឲ្យផ្លូវដល់ខ្ញុំ ៗ

អយ្យកស្សាហំ ភរិយា រាជបុត្តស្ស សិរីមតោ
តញ្ចាហំ នាតិមញ្ញាមិ រាមំ សីតាវនុព្វតា ។
តុម្ហេ ច បុត្តេ បស្សេថ សាយំ សំវេសនំ បតិ
អហញ្ច បុត្តេ បស្សេយ្យំ ជាលី កណ្ហាជិនំ ចុភោ ។
ពហុញ្ចិទំ មូលផលំ ភក្ខោ ចាយំ អនប្បកោ
តតោ ឧបឌ្ឍំ ទស្សាមិ មគ្គំ មេ ទេថ យាចិតា ។
រាជបុត្តី ច នោ មាតា រាជបុត្តោ ច នោ បិតា
តស្មេន ភាតរោ ហោថ មគ្គំ មេ ទេថ យាចិតា ។
(៣៩២) តស្សា លាលប្បមានាយ ពហុំ ការុញ្ញសញ្ហិតំ
សុត្វា នេលបតី ភិចំ ភិន្នា បព្ហា អបក្កមុំ ។
(៣៩៣) ឥមម្ហិ នំ បទេសម្ហិ បុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តិដ្ឋន្តិ វច្ឆា ពាលាវ មាតរំ ។
ឥមម្ហិ នំ បទេសម្ហិ បុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តិដ្ឋន្តិ ហំសាវុបរិបល្លលេ ។





ខ្ញុំជាភរិយារបស់ព្រះរាជបុត្រដ៏មានសិរី ដែលគេនិរទេស ខ្ញុំមិនហ៊ានមើលងាយព្រះរាជស្វាមីនោះ ដូចនាងសីតា ជាស្ត្រីមានតែមិនហ៊ានមើលងាយព្រះរាម ។ លោកទាំងឡាយ ចូរឃើញបុត្រទាំងឡាយចុះ ចំណែកខ្ញុំសូមឃើញស្វាមីនឹងបុត្តទាំងពីរ គឺជាលីនឹងកណ្ហាជិនា ក្នុងវេលាល្ងាច គឺកាលជាទីចូលដំណេក ។ មួយទៀតនឹងផ្លែឈើនេះលោកក៏ច្រើន ចំណីនេះមិនមែនតិចទេ ខ្ញុំនឹងចែកចំណីនោះពាក់កណ្តាលជូន លោកទាំងឡាយ កាលបើខ្ញុំអង្វរហើយ សូមឲ្យផ្លូវខ្ញុំ ។ ព្រះមាតារបស់យើង ជាព្រះរាជបុត្រី ព្រះបិតារបស់យើង ជាព្រះរាជបុត្រ លោកទាំងឡាយចូរជាបងប្អូនដោយធម៌ លោកទាំងឡាយ កាលបើខ្ញុំអង្វរហើយ សូមឲ្យផ្លូវខ្ញុំ ។

(៣៩២) (អភិសម្ពុទ្ធគាថា) ពួកម្រឹគសាហាវ បានស្តាប់ពាក្យពិលាបរបស់នាង ជាពាក្យប្រកបដោយសេចក្តីករុណាច្រើន របស់នាងមទ្រីនោះ ដែលកំពុងលួងលោមហើយ ក៏នាំគ្នាថយចេញអំពីផ្លូវចុះទៅ ។

(៣៩៣) (ព្រះនាងមទ្រី...) កូនតូចទាំងពីរ ប្រឡាក់ដោយធូលីដី តែងតែឈរនៅទទួលអញក្នុងប្រទេសនេះ ដូចជាកូនគោ ឈរនៅទទួលមេ ។ កូនតូចទាំងពីរប្រឡាក់ដោយធូលីដី តែងតែឈរចាំទទួលអញក្នុងប្រទេសនេះ ដូចជាកូនហង្សឈរនៅលើកក់ ។

ឥមម្ហិ នំ បទេសម្ហិ បុត្តកា បំសុកុណ្ឋិតា

បច្ចុគ្គតា មំ តិដ្ឋន្តិ អស្សមស្សាវិទូរតោ ។

តេ[១] មត្តា វិយ ឧក្កណ្ណា សមន្តា មភិធាវិនោ

អានន្ទិនោ បមុទិតា វគ្គមានាវ កម្បរេ

ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។

ឆគលីវ[២] មិគី ឆាបំ បក្ខី មុត្តាវ បញ្ជរា

ឱហាយ បុត្តេ និក្ខម្ម សីហីវាមិសគិទ្ធិនី

ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។

ឥទំ នេសំ បទក្កន្តំ នាគានមិវ បព្វតេ

ចិត្តកា បរិកិណ្ណាយោ អស្សមស្សាវិទូរតោ

ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។

វាលុកាយបិ ឱកិណ្ណា បុត្តកា បំសុកុណ្ឋិតា

សមន្តា មភិធាវន្តិ ន តេ បស្សាមិ ទារកេ ។

យេ មំ បុរេ បច្ចុដេន្តិ អរញ្ញា ទូរមាយតឹ

ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។

---

១ ម. ទេ ។ ២ ម. ឆកលី ។ ឱ. ឆគលី ។



កូនតូចទាំងពីរ ប្រឡាក់ដោយធូលីដី រមែងឈរចាំទទួលអញ ក្នុងប្រទេសនេះ ក្នុងទីជិតអាស្រម ។ កូនតូចទាំងនោះ ធ្លាប់តែស្ទុះមកទទួលវិញ មានសេចក្តីត្រេកអរ រីករាយ ចាំគ្នាលោតមក ហាក់ដូចជា (ញ៉ាំងត្រចៀកឲ្យយេរបស់តាត) ឲ្យកំរើក ដូចកូនម្រឹគទាំងពីរ ឡាយ (ឃើញមេ) ហើយដំឡើងស្លឹកត្រចៀក (រើក-កម្រើកទៅជិតមេ រីករាយត្រេកអរស្ទុះទៅទទួលវិញ) ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ អញលះបង់កូនទាំងពីរ ហើយចេញទៅ ដូចមេពពែឬមេម្រឹគ លះបង់កូន ដូចមេបក្សីចេញអំពី (សំបុក) ឬដូចមេសីហៈប្រាថ្នាសាច់ (លះបង់កូនរបស់ខ្លួនដើរចេញទៅរកចំណី) ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរ គឺជាលី និងនាងកណ្ហាជិនានោះ ។ នេះស្នាមជើងនៃកូនទាំងនោះ ដូច(ស្នាមជើង) នៃពួកដំរីភ្នំ គំនូតខ្សាច់ដែលកូនទាំងពីរនាំគ្នាកូស កំផ្លាក់ផ្លាយ ក្នុងទីជិតនៃអាស្រម ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនតូចទាំងពីរ រាយកាយ ដោយខ្សាច់ ប្រឡាក់ ដោយធូលីដី រមែងស្ទុះមកទទួលវិញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើម កូនទាំងពីរណា ទទួលអញដែលមកអំពីព្រៃឆ្ងាយ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរនោះ គឺជាលីនិងនាងកណ្ហាជិនា ។

ឧត្ថលិង្គំ មិគំ ជាតា    បច្ចុគ្គន្ត្វាន មាតរំ
ទូរេ មំ បដិកិលោកេន្តិ    តេ ន បស្សាមិ ទារកេ ។
ឥទញ្ច តេសំ កីឡនំ    បតិតំ បណ្ឌុវេលុវំ
ត្យជ្ជ បុត្តេ ន បស្សាមិ    ជាលី កណ្ហាជិនំ ចុភោ ។
ថនា ច មយ្ហិមេ បូរា    ឧរោ ច សម្បទាលតិ
ត្យជ្ជ បុត្តេ ន បស្សាមិ    ជាលី កណ្ហាជិនំ ចុភោ ។
ឧច្ឆង្គេ(១) មេកា(២) វិចិនតិ    ថនមេកាវលម្ពតិ
ត្យជ្ជ បុត្តេ ន បស្សាមិ    ជាលី កណ្ហាជិនំ ចុភោ ។
យស្សុ សាយណ្ហសមយំ    បុត្តកា បំសុកុណ្ឋិតា
ឧច្ឆង្គេ មេ វិវត្តន្តិ    តេ ន បស្សាមិ ទារកេ ។
អយំ សោ អស្សមោ បុព្វេ    សមជ្ជោ បដិភាតិ មំ
ត្យជ្ជ បុត្តេ អបស្សន្ត្យា    ភមតេ វិយ អស្សមោ ។
កិមិទំ អប្បសទ្ទោវ    អស្សមោ បដិភាតិ មំ
កាកោលាបិ ន វស្សន្តិ    មតា មេ នូន ទារកា ។
កិមិទំ អប្បសទ្ទោវ    អស្សមោ បដិភាតិ មំ
សកុណាបិ ន វស្សន្តិ    មតា មេ នូន ទារកា ។

---

១ ម. ឱ. ឧច្ឆង្គ ។ ២ ម. ចេលាវក្ខិ ។



ទារកទាំងពីរ តែងមើលមើលផ្លូវអញ ក្នុងទីឆ្ងាយ ដូចកូនម្រឹគ ទទួលមេកពៃ ឬម្រឹគជាមេ ។ ផ្លែព្នៅលឿងទុំ ដែលជ្រុះមកនេះឯង ជាល្បែងរបស់ទារកទាំងនោះ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ ស្តនរបស់អញទាំងពីរនេះពេញ(ដោយទឹកដោះ)ទាំងទ្រូងសោតក៏ស្ទើរតែបែកធ្លាយ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនមួយ ករកៅផ្ទាល់ក្នុងចង្កេះរបស់អញ កូនមួយ តោងដោះទាំងគូរបស់អញ ថ្ងៃនេះ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ វេលាថ្ងៃល្ងាច កូនតូចទាំងពីរ ប្រឡាក់ដោយភក់ដី នៀលលើភ្លៅរបស់អញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើម អាស្រមនេះ ប្រាកដដល់អញ (ដូចជា) កន្លែងមហោស្រព ថ្ងៃនេះ អាស្រមហាក់ដូចវិលដល់អញ ដែលមិនបានឃើញកូនទាំងនោះ ។ ហេតុដូចម្តេច បានជាអាស្រមនេះ ហាក់ដូចជាស្ងាត់សូន្យឈឹង ប្រាកដដល់អញ សូម្បីពួកក្អែកព្រៃ ក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់អញ ប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្តេច បានជាអាស្រមនេះ ហាក់ដូចជាស្ងាត់សូន្យឈឹង ប្រាកដដល់អញ សូម្បីពួកសត្វហើរ ក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់អញ ប្រាកដជាស្លាប់ហើយ ។

(៣៨៦) កិមិទំ តុណ្ហីភូតោសិ អបិ រត្តេវ មេ មនោ

កាកោលាបិ ន វស្សន្តិ មតា មេ នូន ទារកា ។

កិមិទំ តុណ្ហីភូតោសិ អបិ រត្តេវ មេ មនោ

សកុណាបិ ន វស្សន្តិ មតា មេ នូន ទារកា ។

កច្ចិ នុ មេ អយ្យបុត្ត មិគា ខាទឹសុ ទារកេ

អរញ្ញេ ឥរិណេ វិវនេ កេន នីតា មេ ទារកា ។

អទុ តេ បហិតា ទូតា អទុ សុត្តា បិយំវទា

អទុ ពហិ នោ និក្ខន្តា ខិឌ្ឌាសុ បសុតា នុ តេ ។

នេវាសំ កេសា ទិស្សន្តិ ហត្ថបាទា ច ជាលិនោ

សកុណានញ្ច ឱបាតោ កេន នីតា មេ ទារកា ។

(៣៨៧) ឥទំ តតោ ទុក្ខតរំ សល្លវិទ្ធោ យថា វណោ

យម្បិ បុត្តេ ន បស្សាមិ ជាលី កណ្ហាជិនំ ចុភោ ។



(៣៨៦) ហេតុនេះដូចម្តេច បានជាព្រះអង្គគង់ស្ងៀម ចិត្តរបស់ខ្ញុំម្ចាស់ហាក់ដូច(យល់សប្តិ)ក្នុងរាត្រី សូម្បីពួកក្អែកព្រៃក៏មិនគាព្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្តេច បានជាព្រះអង្គគង់ស្ងៀម ចិត្តរបស់ខ្ញុំម្ចាស់ហាក់ដូចជា (យល់សប្តិ) ក្នុងរាត្រី សូម្បីពួកសត្វបក្សីក៏មិនគាព្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះអយ្យបុត្រ ពួកម្រឹគស៊ីទារកទាំងពីររបស់ខ្ញុំម្ចាស់ហើយទេដឹង ឬមនុស្សណានាំយកទារក របស់ខ្ញុំម្ចាស់ទៅក្នុងព្រៃ ដ៏ស្ងាត់ឥតជាតិទៅ ។ ព្រះអង្គធ្វើទារកទាំងនោះឲ្យជាទូតហើយប្រើទៅឬ ឬក៏ទារកទាំងនោះ ជាអ្នកពោលពាក្យពីរោះ ដេកលក់អស់ហើយ ឬទារកទាំងនោះខ្វល់ខ្វាយ ក្នុងល្បែងទាំងឡាយ ហើយនាំគ្នាចេញទៅខាងក្រៅ ។ សក់ទាំងឡាយក្តី ដៃជើងទាំងឡាយក្តី ដ៏វិចិត្រដោយបណ្តាញរបស់ទារកទាំងនោះ ក៏មិនឃើញសោះ ព្រោះពួកបក្សីចាប់នាំយកទៅទេដឹង ឬមនុស្សណានាំយកទារក របស់ខ្ញុំម្ចាស់ទៅ ។

(៣៨៧) ការដែលព្រះអង្គមិនមានព្រះបន្ទូលនេះ ជាទុក្ខក្រៃលែងជាងទុក្ខរបស់ខ្ញុំម្ចាស់ ដែលមិនឃើញកូនទាំងពីរ គឺជាលីនិងកណ្ហាជិនានោះ ដូចជាដំបៅ ដែលមុត ដោយព្រួញ ។

ឥទំ ទុតិយំ សល្លំ  កម្បេតិ ហទយំ មម

យញ្ច បុត្តេ ន បស្សាមិ  ត្វញ្ច មំ នាភិភាសសិ ។

អជ្ជ ចេ មេ ឥមំ រត្តឹ  រាជបុត្ត ន សំសសិ

មញ្ញេ ឱក្កន្តសន្តំ មំ  បាតោ ទក្ខសិ នោ មតំ ។

(៣៩៦) នូន មទ្ទី វរារោហា  រាជបុត្តី យសស្សិនី

បាតោ គតាសិ ឧញ្ឆាយ  កិមិទំ សាយមាគតា ។

(៣៩៧) ននុ ត្វំ សទ្ទមស្សោសិ  យេ សរំ បាតុមាគតា

សីហស្ស វិនទន្តស្ស  ព្យគ្ឃស្ស ច និកុជ្ជិតំ ។

អហុ បុព្វនិមិត្តំ មេ  វិចរន្ត្យា ព្រហាវនេ

ខណិត្តោ មេ ហត្ថា បតិតោ  ឧគ្គីវញ្ចាបិ អំសតោ ។

តទាហំ ព្យថិតា ភីតា  បុថុំ កត្វាន អញ្ជលឹ

សព្វទិសា នមស្សិស្សំ  អបិ សោត្ថិ ឥតោ សិយា ។



នេះជាព្រួញទីពីរ គឺត្រង់ដែលខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីរ ១ ដែលព្រះអង្គមិនត្រាស់ប្រាប់ខ្ញុំម្ចាស់ ១ ធ្វើឲ្យកំរើកហឫទ័យរបស់ខ្ញុំម្ចាស់ ។ បពិត្រព្រះរាជបុត្រ បើព្រះអង្គមិនត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់ អស់រាត្រីនេះ ក្នុងថ្ងៃនេះ ព្រះអង្គមុខជានឹងឃើញខ្ញុំម្ចាស់អស់ជីវិតស្លាប់ក្នុងវេលាព្រឹកមិនខាន ។

(៣៩៦) (ព្រះមហាសត្វ...) ក្រែងនាងមទ្រី មានកំពស់នឹងទំហំដ៏ប្រសើរ ជារាជបុត្រី មានយសស្ស ទាំងទៅដើម្បីស្វែងរក (ផ្លែឈើតូច-ធំ) តាំងពីពេលព្រឹក ហេតុដូចម្តេច បានជាដល់ពេលល្ងាចហើយ ទើបមក ។

(៣៩៧) (ព្រះនាងមទ្រី...) ក្រែងព្រះអង្គទ្រង់ព្រះសណ្តាប់សំឡេងទ្រហឹងនៃសីហៈនឹងខ្លា ដែលស្រែកបន្លឺឡើង (ព្រមទាំងម្រឹគដទៃមានដំរីជាដើម) ដែលមកកាន់ស្រះ (នេះ) ដើម្បីផឹកទឹកដែរឬទេ ។ បុព្វនិមិត្តបានកើតឡើងដល់ខ្ញុំម្ចាស់ ដែលដើរត្រាច់ក្នុងព្រៃធំ ជន្លក់ក៏ធ្លាក់ចាកដៃរបស់ខ្ញុំម្ចាស់ ទាំងកញ្ច្រែង ដែលលើលើចុងស្មាក៏ធ្លាក់ពីស្មា ។ ក្នុងវេលានោះ ខ្ញុំម្ចាស់មានសេចក្តីតក់ស្លុតភ័យព្រឺព្រួច ក៏ប្រណម្យអញ្ជលី នមស្ការគ្រប់ទិសផ្សេងៗ សូមឲ្យសួស្តីកើតមាន ព្រោះការនមស្ការនេះ ។

មា ហេវ នោ រាជបុត្តា យាតោ សីហេន ទីបិនា
ទារកា វា បរាមដ្ឋា អច្ឆកោកតរច្ឆិភិ ។
សីហោ ព្យគ្ឃោ ច ទីបិ ច តយោ វាឡា វនេ មិគា
តេ មំ បរិយាវរុំ មគ្គំ តេន សាយម្ហិ អាគតា ។
(៣៩៨) អហំ បតិញ្ច បុត្តេ ច អាចរិយមិវ មាណវោ
អនុដ្ឋិតា ទិវារត្តឹ ជដិនី ព្រហ្មចារិនី ។
អជិនានិ បរិទហិត្វា វនមូលផលហារិយា
វិចរាមិ ទិវារត្តឹ តុម្ហំ កាមា ហិ បុត្តកា ។
ឥទំ(១) សុវណ្ណហាលិទ្ទំ អាភតំ បណ្ឌុវេឡុវំ
រុក្ខបក្កានិ នានាសិ ឥមេ វោ បុត្តកីឡនា ។
ឥទំ មុឡាលិវត្តកំ សាលុកំ ជិញ្ជុរោទកំ(២)
ភុញ្ជ ខុទ្ទេហិ សំយុត្តំ សហ បុត្តេហិ ខត្តិយ ។
បទុមំ ជាលិនោ ទេហិ កុមុទំ ច កុមារិយា
មាលិនេ បស្ស នច្ចន្តេ សិវិបុត្តានិ អវ្ហយ ។

---

១ ម. ឥហំ ។ ២ ម. ចិញ្ជុរោទកំ ។ ម. ពិញ្ចុរោទកំ ។



សូមកុំឲ្យសីហៈនិងខ្លាដំបង មៀតមៀនព្រះរាជបុត្ររបស់យើងបាន មួយទៀត សូមកុំឲ្យខ្លាឃ្មុំ ឆ្កែព្រៃ និងខ្លារខិនចាប់កូនៗរបស់ខ្ញុំ ក៏បាន ។ ពួកសាហាវម្រឹគទាំងបីក្នុងព្រៃ គឺសីហៈមួយ ខ្លាធំមួយ ខ្លាដំបងមួយ ក៏រវាំងផ្លូវខ្ញុំម្ចាស់ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់មកក្នុងវេលាល្ងាច ។

(៣៩៨) ខ្ញុំម្ចាស់មានសក់កណ្ដាញ់ ប្រព្រឹត្តធម៌ដ៏ប្រសើរ ស្រាក់ស្រាវទញ (ផ្គត់ផ្គង់) ប្ដីផង បុត្រទាំងពីរផង អស់ថ្ងៃនិងយប់ ដូចជាមាណព (ផ្គត់ផ្គង់) អាចារ្យ ។ វៃតាបុត្រកំសត់ទាំងពីរ មាតាស្លៀកដណ្ដប់ស្បែកខ្លា ទៅស្វែងរកមើមឈើនិងផ្លែឈើក្នុងព្រៃ ទាំងថ្ងៃ ទាំងយប់ ព្រោះតែសេចក្ដីស្រឡាញ់កូនឯងទាំងពីរ ។ រមៀតមានពណ៌ដូចជាមាសនិងផ្លែព្នៅនេះ មាតាបាននាំមកដល់ហើយ មាតាបាននាំទាំងផ្លែឈើទាំងឡាយ (ឯទៀតផង) វៃតាបុត្រកំសត់ទាំងពីរ ផ្លែឈើទាំងនេះ ជាល្បែងរបស់កូនឯងទាំងពីរ ។ មើមឈូក ក្រអៅ ខ្ជុល ក្រចាប់នេះ បពិត្រក្សត្រិយ៍ សូមព្រះអង្គព្រមទាំងបុត្រទាំងពីរសោយ (វត្ថុទាំងនោះ) ដែលលាយជាមួយទឹកឃ្មុំចុះ ។ បពិត្រព្រះបាទសិវិ សូមព្រះអង្គប្រទានផ្កាឈូកដល់ជាលី សូមព្រះអង្គប្រទានផ្កាកុមុទដល់នាងកុមារី សូមទត (កូនទាំងពីរ) ដែលប្រដាប់ដោយកម្រងផ្កាហើយរាំ សូមព្រះអង្គត្រាស់ហៅបុត្រទាំងពីរមក ។

គតោ កណ្ហាជិនា យាចិ និសាមេហិ រថេសភ
ខញ្ញុស្សុកយ វត្តុយា អស្សមំ ឧបគច្ឆិយា
សមាគសុខទុក្ខេហា រដ្ឋា បព្វាជិតា ឧភោ
អថ សិវិបុត្តេ បស្សេសិ ជាលី កណ្ហាជិនំ ចុភោ។
សមណោ ព្រាហ្មណោ វុធ ព្រហ្មចរិយបរាយណេ
អហំ លោកេ អភិសស្សំ សីលវន្តេ ពហុស្សុតេ
យជ្ជ បុត្តេ ន បស្សាមិ ជាលី កណ្ហាជិនំ ចុភោ។
(៣៨៩) ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារិកា
វិវិធានិ រុក្ខជាតានិ តេ កុមារា ន ទិស្សរេ។
អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិត្ថនា
វិវិធានិ ផលជាតានិ តេ កុមារា ន ទិស្សរេ។
ឥមេ តិដ្ឋន្តិ អារាមា អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេ។
វិវិធានិ បុប្ផជាតានិ អស្មឹ ឧបរិបព្វតេ
យានស្សុ បុព្វេ ធារឹសុ តេ កុមារា ន ទិស្សរេ។
វិវិធានិ ផលជាតានិ អស្មឹ ឧបរិបព្វតេ
យានស្សុ បុព្វេ ភុញ្ជឹសុ តេ កុមារា ន ទិស្សរេ។



បពិត្រព្រះអង្គ ជាម្ចាស់ថ្លៃ បណ្តាបុត្រទាំងពីរនោះ បុត្រីឈ្មោះ កណ្ហាជិនា រៀមរៀប សូមព្រះអង្គទ្រង់ព្រះសណ្តាប់ (សំឡេង) របស់កំផែលពីរកេះ គួរពាប់ចិត្តការក្បាកេះ ចូលទៅកាន់អាស្រម ។ បពិត្រព្រះបាទសិវិ បើនាងទាំងពីរនាក់ ត្រូវគេនិរទេសចាកដែន ហើយជាអ្នករួមសុខទុក្ខជាមួយគ្នា ព្រះអង្គឃើញបុត្រទាំងពីរ គឺ ជាលីនឹងកណ្ហាជិនាដែរឬ ។ ខ្ញុំម្ចាស់បានដើរប្រទេចពួកស្រមណ៍ នឹងព្រាហ្មណ៍ ក្នុងលោក មានព្រហ្មចរិយធម៌ប្រព្រឹត្តទៅខាងមុខ មានសីល ជាពហុស្សូតដោយគិត បានជាខ្ញុំម្ចាស់មិនឃើញបុត្រ ទាំងពីរ គឺជាលី នឹងកណ្ហាជិនានោះ ក្នុងថ្ងៃនេះ ។

(៣៨៩) នេះព្រីងជាតិផ្សេងៗ គឺព្រីង ឈើតាលទ្រុល មានផ្លែក្រុសុំ ក្រសាយ កុមារទាំងនោះ អញមិនបានឃើញ ។ នេះផលជាតិ ផ្សេងៗ គឺពោធិ៍ ខ្នុរ ផ្លែព្រៃ ក្រសាំង កុមារទាំងនោះអញមិន បានឃើញ ។ នេះសួនច្បារទាំងឡាយ នេះស្ទឹងមានទឹក ត្រជាក់ ជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញ មិនបានឃើញ ។ ផ្កាឈើច្រើនយ៉ាង លើភ្នំនេះ ជាផ្កា ដែលកុមារទាំងពីរធ្លាប់ទ្រទ្រង់ កុមារទាំងនោះ អញមិនបាន ឃើញ ។ ផ្លែឈើច្រើនយ៉ាងលើភ្នំនេះ ជាផ្លែដែលកុមារទាំង ពីរធ្លាប់បរិភោគ កុមារទាំងនោះ អញមិនបានឃើញសោះ ។

ឥមេ តេ ហត្ថិកា អស្សា ពលិពទ្ទា ច តេ ឥមេ
យេហិស្សុ បុព្វេ កីឡិំសុ តេ កុមារា ន ទិស្សរេ ។

(៣៦០) ឥមេ សាមា សសោលូកា(១) ពហុកា កទលីមិគា
យេហិស្សុ បុព្វេ កីឡិំសុ តេ កុមារា ន ទិស្សរេ ។
ឥមេ ហំសា ច កោញ្ចា ច មយូរា ចិត្របេខុណា
យេហិស្សុ បុព្វេ កីឡិំសុ តេ កុមារា ន ទិស្សរេ ។

(៣៦១) ឥមា តា វនគុម្ពាយោ បុប្ផិតា សព្វកាលិកា
យត្ថស្សុ បុព្វេ កីឡិំសុ តេ កុមារា ន ទិស្សរេ ។
ឥមា តា បោក្ខរណី រម្មា ចក្កវាកូបកូជិតា
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
យត្ថស្សុ បុព្វេ កីឡិំសុ តេ កុមារា ន ទិស្សរេ ។

(៣៦២) ន តេ កដ្ឋានិ ភិន្នានិ ន តេ ឧទកមាហដំ
អគ្គិបិ តេ ន ហាបិតោ កិន្នុ មន្ទោវ ឈាយសិ ។
បិយោ បិយេន សង្គម្ម សមោ មេ ព្យបហញ្ញតិ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។

---

១ ម. សសោលូកា ។





រូបដំរី រូបសេះទាំងនេះក្តី រូបគោទាំងនេះក្តី ជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះ អញមិនបានឃើញ ។

(៣៦០) រូបម្រឹគមានសម្បុរកព្រុស រូបទន្សាយ រូបមៀម រូបម្រឹគល្អុសជាច្រើនទាំងនេះ ជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះ អញមិនបានឃើញ ។ រូបហង្ស រូបក្រៀល រូបក្ងោក មានស្លាបដ៏វិចិត្រ ជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះ អញមិនបានឃើញ ។

(៣៦១) គុម្ពឈើទាំងនេះ មានផ្កាគ្រប់កាល ជាផ្កាដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះ អញមិនបានឃើញ ។ ស្រះបោក្ខរណីទាំងនេះ គួរជាទីត្រេកអរ ច្រហឹងតឹងកង ដោយសត្វចាក្រពាក ដេរដាសដោយផ្កាមណ្ឌាលកៈផង ដោយផ្កាឈូកនិងផ្កាឧប្បលផង ជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។

(៣៦២) អុសទាំងឡាយព្រះអង្គមិនកាប់ ទឹកព្រះអង្គមិនដង ភ្លើងព្រះអង្គមិនបង្កាត់ ហេតុអ្វីបានជាព្រះអង្គសញ្ជប់សញ្ជឹង ដូចមនុស្សខ្លៅ ។ (ព្រះវេស្សន្តរ) ជាទីស្រឡាញ់ (របស់ខ្ញុំម្ចាស់) សេចក្តីព្រួយតែងសោយ ព្រោះបានជួបជុំដោយព្រះអង្គជាទីស្រឡាញ់ ក្នុងថ្ងៃនេះ ខ្ញុំម្ចាស់មិនឃើញបុត្រទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។

(៣៦៣) ន ខោហំ តេ បស្សាមិ យេន តេ នីហតា មតា
កាកោលាបិ ន វស្សន្តិ មតា មេ ទ្វេ ច ទារកា ។
ន ខោហំ តេ បស្សាមិ យេន តេ នីហតា មតា
សកុណាបិ ន វស្សន្តិ មតា មេ ទ្វេ ច ទារកា ។

(៣៦៤) សា តត្ថ បរិទេវិត្វា បព្ពតានិ វនានិ ច
បុនទេវស្សមំ គន្ត្វា រោទិ សាមិកសន្តិកេ ។
ន ខោហំ តេ បស្សាមិ យេន តេ នីហតា មតា
កាកោលាបិ ន វស្សន្តិ មតា មេ ទ្វេ ច ទារកា ។
ន ខោហំ តេ បស្សាមិ យេន តេ នីហតា មតា
សកុណាបិ ន វស្សន្តិ មតា មេ ទ្វេ ច ទារកា ។



(៣៦៣) បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្ររបស់យើងទាំងពីរនោះ ខ្ញុំម្ចាស់មិនដឹងថា (អ្នកណា) នាំយកបុត្រទាំងពីរនោះទៅ ទាំងពួកក្អែកព្រៃសោក ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្ររបស់យើងទាំងពីរនោះ ខ្ញុំម្ចាស់មិនដឹងថា (អ្នកណា) នាំយកបុត្រទាំងពីរនោះទៅ ទាំងពួកសត្វស្លាបសោក ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។

(៣៦៤) (អគ្គមហេសីព្រះនាម) មទ្រីនោះ (បានត្រាច់ទៅ) កាន់ភ្នំនិងព្រៃទាំងឡាយក្នុងទីនោះ ហើយត្រឡប់មកកាន់អាស្រមវិញ ក៏ទ្រង់ព្រះកន្សែងក្នុងសំណាក់ព្រះរាជស្វាមីថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ (បុត្រទាំងពីរ) របស់យើងនោះ ខ្ញុំម្ចាស់មិនដឹងថា (អ្នកណា) នាំយកបុត្រទាំងពីរនោះទៅ ទាំងពួកក្អែកព្រៃសោក ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ (បុត្រទាំងពីរ) របស់យើងនោះ ខ្ញុំម្ចាស់មិនដឹងថា (អ្នកណា) នាំយកបុត្រទាំងពីរនោះទៅ ទាំងពួកសត្វស្លាបសោក ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។

ន ខោ នោ ទេវ បស្សាមិ យេន តេ និហតា មតា

វិចរន្តិ រុក្ខមូលេសុ បព្វតេសុ គុហាសុ ច ។

ឥតិ មទ្ទី វរារោហា រាជបុត្តី យសស្សិនី

ពាហា បគ្គយ្ហ កន្ទិត្វា តត្ថេវ បតិតា ឆមា ។

(៣២៨) តមជ្ឈបត្តំ រាជបុត្តឹ ឧទកេនាភិសិញ្ចថ

អស្សត្ថំ នំ វិទិត្វាន អថ នំ ឯតទព្រវិ ។

អាទិយេនេវ តេ មទ្ទិ ទុក្ខំ នក្ខាតុមិច្ឆិសំ

ទលិទ្ទោ យាចកោ វុឌ្ឍោ ព្រាហ្មណោ ឃរមាគតោ ។

តស្ស ទិន្នា មយា បុត្តា មទ្ទិ មា ភាយិ អស្សស

មំ បស្ស មទ្ទិ មា បុត្តេ មា ពាឡ្ហំ បរិទេវយិ

លច្ឆាម បុត្តេ ជីវន្តា អរោគា ច ភវាមសេ ។

បុត្តេ បសុញ្ច ធញ្ញញ្ច យញ្ច អញ្ញំ ឃរេ ធនំ

ទជ្ជា សប្បុរិសោ ទានំ ទិស្វា យាចកមាគតេ

អនុមោទាហិ មេ មទ្ទិ បុត្តកេ ទានមុត្តមំ ។



បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ (បុត្រទាំងពីរ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងថា (អ្នកណា) នាំយកបុត្រទាំងនោះទៅ ម្នាលក៏ក្តីទាំងឡាយ នាងមទ្រីត្រាច់ទៅក្រោមម្លប់ឈើនឹងភ្នំនិងគុហា ។ នាងមទ្រីមានកំពស់ដ៏ល្អប្រសើរ ជារាជបុត្រីមានយស ក៏ផ្គងដើមដៃទាំងពីរកន្ទក់កន្ទេញយំនៅទីនោះហើយ ក៏ដួលទៅលើផែនដីក្នុងទីនោះ ។

(៣២៨) ព្រះបាទវេស្សន្តរ ទ្រង់ស្រោចស្រប់ព្រះរាជបុត្រីនោះ ដែលបានមកដល់សំណាក់ព្រះអង្គ បន្ទាប់អំពីនោះមក ព្រះអង្គជ្រាបព្រះរាជបុត្រីនោះ ដែលស្រួលចិត្តហើយ ទើបបានត្រាស់នឹងព្រះរាជបុត្រីនោះយ៉ាងនេះថា ម្នាលនាងមទ្រី អញមិនចង់ប្រាប់សេចក្តីទុក្ខដល់នាងអំពីដំបូងទេ មានព្រាហ្មណ៍ចាស់កំសត់ជាស្មូម បានមកកាន់លំនៅ ។ ម្នាលនាងមទ្រី អញបានឲ្យបុត្រទាំងពីរដល់ព្រាហ្មណ៍នោះហើយ នាងកុំភិតភ័យអ្វី នាងចូរស្រួលចិត្តចុះ ម្នាលនាងមទ្រី នាងចូរមើលមកអញ កុំមើលបុត្រទាំងពីរ កុំខ្សឹកខ្សួលខ្លាំងឡើយ កាលបើយើងរស់នៅបានសុខសប្បាយ គឺគង់បាន (ជួបប្រទះ) នឹងបុត្រវិញ ។ សប្បុរសបានឃើញអ្នកស្មូមមកហើយ គប្បីឲ្យបុត្រ សត្វចិញ្ចឹម ធញ្ញជាតិ នឹងទ្រព្យឯទៀតដែលមានក្នុងផ្ទះជាទាន ម្នាលនាងមទ្រី នាងចូរត្រេកអរតាម នូវការឲ្យបុត្រដ៏ខ្ពង់ខ្ពស់របស់អញ ។

(៣៦៦) អនុមោទាមិ តេ ទេវ បុត្តកេ ទានមុត្តមំ
ចត្វា ចិត្តំ បសាទេហិ ភិយ្យោ ទានំ ទទោ ភវ ។
យោ ត្វំ មច្ឆេរភូតេសុ មនុស្សេសុ ជនាធិប
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោ ។

(៣៦៧) វិន្នាទិតា តេ បឋវី សទ្ទោ តេ តិទិវង្គតោ
សមន្តា វិជ្ជុតា អាគុំ គិរីនំវ បតិស្សុតា ។

(៣៦៨) តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ច ព្រហ្មា ច បជាបតី ច
សោមោ យមោ វេស្សវណោ ច រាជា
សព្វេ ទេវានុមោទន្តិ តាវតឹសា សឥន្ទកា ។
ឥតិ មទ្ទី វរារោហា កុលបុត្តី យសស្សិនី
វេស្សន្តរស្ស អនុមោទិ បុត្តកេ ទានមុត្តមំ ។

មទ្ទីបព្វំ ចប់ ។



(៣៦៦) (ព្រះនាងមទ្រី...) បពិត្រព្រះទេវៈ ខ្ញុំម្ចាស់សូមរីករាយតាម នូវអំណោយបុត្រដ៏ឧត្តមរបស់ព្រះអង្គ ព្រះអង្គប្រទានហើយ សូមធ្វើព្រះហឫទ័យឲ្យជ្រះថ្លាចុះ សូមព្រះអង្គទ្រង់ឲ្យទានជាភិយ្យោភាពចុះ ។ បពិត្រព្រះជនាធិបៈ កាលដែលពួកមនុស្ស កំពុងមានសេចក្ដីកំណាញ់ ព្រះអង្គជាអ្នកញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យចំរើន ទ្រង់បានដាក់ទានដល់ព្រាហ្មណ៍ ។

(៣៦៧) ព្រះអង្គបានញ៉ាំងផែនដី ឲ្យរន្ធឺរន្ធាំ កិត្តិសព្ទរបស់ព្រះអង្គទៅដល់ទេវលោក ផ្លេកបន្ទោរក៏ភ្លឺឆ្វាលឆ្វាច់ជុំវិញព្រៃហិមពាន្ត ដូចជាសំឡេងលាន់នៃភ្នំទាំងឡាយ ។

(៣៦៨) ពួកទេវតាទាំងពីរក្រុម គឺនារទៈនិងបព្វតៈ ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម និងបជាបតិទេវបុត្រ សោមទេវបុត្រ ព្រះបាទយមៈនិងព្រះបាទវេស្សវ័ណ ក៏នាំគ្នារីករាយតាមព្រះអង្គនោះ ពួកទេវតាទាំងអស់ដែលកើតក្នុងឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រក៏រីករាយតាម ។ (ព្រះសាស្ដាបានត្រាស់គាថានេះថា) ព្រះនាងមទ្រី ដ៏មានកំពស់និងទំហំដ៏ប្រសើរ ជាកុលបុត្រីមានយស បានរីករាយតាមនូវអំណោយបុត្រដ៏ឧត្តម របស់ព្រះបាទវេស្សន្តរ ដោយប្រការដូច្នេះ ។

ចប់ មទ្ទីបព្វ ។

(៣៦៩) តតោ រត្យា វិវសានេ សុរិយស្សុគ្គមនំ(១) បតិ

សក្កោ ព្រាហ្មណវណ្ណេន បាតោ តេសំ អទិស្សថ ។

(៣៧០) កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ

កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។

កច្ចិ ឌំសា មកសា ច អប្បមេវ សិរីសបា

វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតិ ។

(៣៧១) កុសលញ្ចេវ នោ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ

អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។

អថោ ឌំសា មកសា ច អប្បមេវ សិរីសបា

វនេ វាឡមិគាកិណ្ណេ ហឹសា មយ្ហំ ន វិជ្ជតិ ។

សត្តនោ មាសេ វសតំ អរញ្ញេ ជីវសោកិនំ

ឥទម្បិ បឋមំ បស្សាម ព្រាហ្មណំ ទេវវណ្ណិនំ

អាទាយ វេឡុវំ ទណ្ឌំ ធារេន្តំ អជិនក្ខិបំ ។

ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ

---

១ ម. សុរិយុគ្គមនំ ។



(៣៦៩) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ក្នុងកាលដែលរាត្រីកន្លងទៅ ហើយ ព្រះអាទិត្យក៏រះឡើង សក្កទេវរាជ មានភេទជាព្រាហ្មណ៍ ប្រាកដ ដល់ក្សត្រទាំងពីរនោះក្នុងវេលាព្រឹក ។

(៣៧០) (សក្កទេវរាជ...) ព្រះអង្គសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយការស្វែងរកស្រូវទេឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស និងតស់ មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនទេឬ ។

(៣៧១) (ព្រះមហាសត្វ...) ម្នាលព្រាហ្មណ៍ ពួកយើងសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មិនមានរោគាពាធទេ មួយទៀត យើងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយការស្វែងរកស្រូវទេ មើមឈើនិងផ្លែឈើទាំងឡាយដ៏បរិបូណ៌ដែរទេ ។ ទាំងពួករបោម មូសនិងតស់មានតិចទេ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនយើងទេ ។ យើងនៅក្នុងព្រៃអស់៧ខែ រស់នៅទាំងសោក ទើបឃើញព្រាហ្មណ៍ជាទីបំផុតនេះ មានភេទដ៏ប្រសើរ កាន់ឈើច្រត់មានពណ៌ដូចផ្លែព្នៅ ទ្រទ្រង់នូវស្បែកខ្លាទាំងក្រចក ។ នែមហា-ព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀត អ្នកមិនមែនមកអាក្រក់ទេ

អន្តោ បវិស ភទ្ទន្តេ បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទម្បិ បានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសិ ។
អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
អនុប្បត្តោសិ ព្រហារញ្ញំ តំ មេ អក្ខាហិ បុច្ឆិតោ ។
(៣៧២) យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគច្ឆិំ ភរិយំ មេ ទេហិ យាចិតោ ។
(៣៧៣) ទទាមិ ន វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ នប្បដិគុយ្ហាមិ ទានេ មេ រមតេ មនោ ។
(៣៧៤) មទ្ទី ហត្ថេ គហេត្វាន ឧទកស្ស កមណ្ឌលុំ
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
មទ្ទឹ បរិច្ចជន្តស្ស មេទនី សម្បកម្បថ ។



អញ្ជើញអ្នកចូលទៅខាងក្នុង សេចក្តីចំរើន (ចូរមាន) ដល់អ្នក អ្នកចូរលាងជើងទាំងឡាយរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នកចូររើសបរិភោគផ្លែឈើយ៉ាងឆ្ញាញ់ៗ ដូចទឹកឃ្មុំ គឺផ្លែទន្លាប់ ព្រីង ពក់ព្រាង ម៉ាក់ផោក ។ ទឹកត្រជាក់នេះ ដែលនាំមកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនេះចុះ បើអ្នកប្រាថ្នាចង់ផឹក ។ យើងសូមសួរអ្នក អ្នកបានមកដល់ព្រៃធំ ដោយរឿងដូចម្តេច ឬដោយហេតុដូចម្តេច អ្នកកាលបើយើងសួរហើយ ចូរប្រាប់រឿងនោះ ។

(៣៧២) (សក្កទេវិន្ទ...) ផ្លូវទឹកដ៏ពេញប្រៀប មិនអស់ទៅសព្វកាល យ៉ាងណាមិញ ខ្ញុំបង្គំជាខ្ញុំ មកដើម្បីសូមទានព្រះអង្គ ខ្ញុំបង្គំជាខ្ញុំសូមហើយ សូមព្រះអង្គប្រទានភរិយា ក៏យ៉ាងនោះដែរ ។

(៣៧៣) (ព្រះមហាសត្វ...) ម្នាលព្រាហ្មណ៍ យើងឲ្យរបស់ដែលអ្នកសូមនឹងយើង យើងមិនរញ្ញាក់ យើងមិនលាក់លៀមរបស់ដែលមាន ចិត្តរបស់យើងត្រេកអរក្នុងទាន ។

(៣៧៤) (អភិសម្ពុទ្ធគាថា) ព្រះបាទវេស្សន្តរ ជាអ្នកញុំាងដែនអ្នកសិវិរដ្ឋឲ្យចំរើន ចាប់ដៃនាងមទ្រីនឹងកុណ្ឌីទឹក ហើយបានដាក់ទានដល់ព្រាហ្មណ៍ ។ កាលដែលព្រះវេស្សន្តរប្រគល់នូវព្រះនាងមទ្រី ហេតុដែលគួរស្ញប់ស្ញែង ក៏កើតមាន ក្នុងកាលនោះ សេចក្តីព្រឺរោមក៏កើតមាន ក្នុងកាលនោះ ផែនដីក៏ញាប់ញ័រ ។

នេវស្ស មទ្ទី ភកុដិ ន សន្ធិយតិ ន រោទតិ
បេក្ខតេវស្ស តុណ្ហិយា ឯស ជានាតិ យំ វរំ ។

(៣៧៥) ជាលី កណ្ហាជិនំ ធីតំ មទ្ទី ទេវី បតិព្វតំ
ចជ្ជមានោ ន ចិន្តេសិំ ពោធិយាយេវ ការណា ។
ន មេ ទេស្សា ឧភោ បុត្តា មទ្ទី ទេវី ន អប្បិយា
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា បិយេ អទាសហំ[១] ។

(៣៧៦) កោមារី យស្សាហំ ភរិយា សាមិកោ មម ឥស្សរោ
យស្សិច្ឆេ តស្ស មំ ទជ្ជា វិក្កិណេយ្យ ហនេយ្យ វា ។

(៣៧៧) តេសំ សង្កប្បមញ្ញាយ ទេវិន្ទោ ឯតទព្រវិ
សព្វេ ជិតា តេ បច្ចូហា យេ ទិព្វា យេ ច មានុសា
និន្នាទិតា តេ បថវី សទ្ទោ តេ តិទិវង្គតោ

---

១ ម. ជាលី កណ្ហាជិនំ ធីតំ មទ្ទី ទេវី បតិព្វតំ
ចជ្ជមានោ ន ចិន្តេសិំ ពោធិយាយេវ ការណា ។
ន មេ ទេស្សា ឧភោ បុត្តា មទ្ទី ទេវី ន អប្បិយា
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា បិយេ អទាសហន្តិ
ឥតិ បាឋោ ទិស្សតិ ។



ព្រះនាងមទ្រី មិនមានមុខក្រញូវ មិនរអៀន មិនយំ ព្រះនាងស្ងៀម សំឡឹង (ព្រះភក្ត្រ) របស់ព្រះបាទវេស្សន្តរនោះ (ដោយគិតថា) ព្រះរាជានេះ ជ្រាបហេតុដ៏ប្រសើរ ។

(៣៧៥) អាត្មាអាត្មាកាលដែលលះបង់បុត្រាឈ្មោះជាលី បុត្រីឈ្មោះ កណ្ហាជិនា និងនាងទេវីឈ្មោះមទ្រី ដែលមានតែជាស្ត្រីគង់ត្រង់ មិនគិត (ស្តាយ) ព្រោះហេតុតែពោធិញ្ញាណតែម្យ៉ាងគត់ ។ បុត្រទាំងពីរមិនមែនជាទីស្អប់របស់អាត្មាទេ នាងទេវីឈ្មោះមទ្រី មិនមែនមិនជាទីស្រឡាញ់របស់អាត្មាទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់អាត្មា ព្រោះហេតុនោះ បានជាអាត្មាឲ្យទានទាំងឡាយជាទីស្រឡាញ់ (ដល់ព្រាហ្មណ៍) ។

(៣៧៦) (ព្រះនាងមទ្រី...) ខ្ញុំម្ចាស់ជាភរិយារបស់ព្រះអង្គក៏ព្រោះព្រះអង្គជាស្វាមី ជាឥស្សរៈរបស់ខ្ញុំម្ចាស់ស្រាប់ហើយ ចង់ឲ្យខ្ញុំម្ចាស់ដល់អ្នកណា គប្បីឲ្យដល់អ្នកនោះចុះ ចង់លក់ឬចង់សំឡាប់ (ក៏បាន) ។

(៣៧៧) (អភិសម្ពុទ្ធគាថា) ព្រះឥន្ទ្រ ជាធំជាងទេវតា ជ្រាបសេចក្តីត្រិះរិះ របស់ជនទាំងនោះហើយ ក៏បានពោលថ្លែងថា ពួកសត្រូវទាំងអស់ ដែលឃាត់ឃាំងទិព្វសម្បត្តិ និងមនុស្សសម្បត្តិ ព្រះអង្គ ក៏បានឈ្នះហើយ ព្រះអង្គបានញ៉ាំងផែនដីឲ្យរំពង កិត្តិសព្ទរបស់ព្រះអង្គ ផ្សាយទៅ ដល់ទេវលោក

សមណា វិជ្ជតា អាក្ខ  គិរិរិវំ បដិស្សុតា ។

តស្ស តេ អនុមោទន្តិ  ឧភោ នារទបព្វតា

ឥន្ទោ ច ព្រហ្មា ច បជាបតី ច

សោមោ យមោ វេស្សវណោ ច រាជា

សព្វេ តេ អនុមោទន្តិ  ទុក្ករំ ហិ ករោតិ សោ

ទុទ្ទទំ ទទមានានំ  ទុក្ករំ កម្មកុព្វតំ

អសន្តោ នានុកុព្វន្តិ  សតំ ធម្មោ ទុរន្វយោ ។

តស្មា សតញ្ច អសតញ្ច  នានា ហោតិ ឥតោ គតី

អសន្តោ និរយំ យន្តិ  សន្តោ សគ្គបរាយណា ។

យមេតំ កុមារេ អទា  ភរិយំ អទា វនេ វសំ

ព្រហ្មយានមនោក្កម្ម  សគ្គេ តេ តំ វិបច្ចតុ ។

(៣៩៨) ទទាមិ ភោតោ ភរិយំ  មទ្ទិំ សព្វង្គសោភនំ

ត្វញ្ចេវ មទ្ទិយា ឆន្នោ  មទ្ទី ច បតិនា សហ ។



ផ្គររន្ទះក៏ដាលប្រែកជុំវិញ ដូចជាសំឡេងលាន់នៃផ្គរលាន់ឡើង ពួកទេវតាទាំងពីរក្រុម គឺទេវៈនិងពួក: ទាំងព្រះឥន្ទ្រ ព្រះព្រហ្ម និងបជាបតិទេវបុត្រ សោមទេវបុត្រ ព្រះបាទយមៈ និងព្រះបាទវេស្សវ័ណ រីករាយតាមព្រះអង្គនោះ ពួកទេវតាទាំងអស់ ក៏រីករាយតាម (យ៉ាងនេះថា) ថែមពិត ព្រះបាទវេស្សន្តរនោះ ធ្វើអំពើដែលគេធ្វើបានដោយកម្រ ។ កាលដែលពួកជនកំពុងឲ្យនូវវត្ថុដែលគេឲ្យបានដោយកម្រ កំពុងធ្វើអំពើដែលគេធ្វើបានដោយកម្រ ពួកអសប្បុរស រមែងមិនធ្វើតាម (អំពើនោះ) ឡើយ ធម៌របស់ពួកសប្បុរស គឺគេដើរតាមបានដោយក្រ ។ ព្រោះហេតុនោះ ដំណើរទៅអំពីលោកនេះ (ទៅកាន់បរលោក) នៃពួកសប្បុរស និងពួកអសប្បុ-រស ជាដំណើរផ្សេងគ្នា ពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ។ ព្រះអង្គកាលដែលនៅក្នុងព្រៃ បានប្រទានកុមារទាំងពីរ ទាំងបានប្រទានភរិយា មានទាំងពីរនោះឈ្មោះថាជាយានដ៏ប្រសើរ មិនធ្លាក់ចុះទៅ (កាន់អបាយភូមិ) ទេ យានដ៏ប្រសើរនោះ សូមសម្រេចដល់ព្រះអង្គក្នុងឋានសួគ៌ ។

(៣៧៨) (សក្កទេវរាជ...) ខ្ញុំសូមថ្វាយនាងមទ្រី ជាស្ត្រីមានសព្វាង្គដ៏ល្អ ជាភរិយារបស់ព្រះអង្គវិញ ព្រះអង្គសមគួរនឹងនាងមទ្រីដោយពិត នាងមទ្រីក៏សមគួរនឹងព្រះអង្គ ដែលជាភស្តាដែរ ។

យថា បយោ ច សង្ខោ ច ឧភោ សមានវណ្ណិនោ

ឯវំ តុវញ្ច មទ្ទី ច សមានមនចេតសា ។

អវុត្ថ អរញ្ញស្មិំ ឧភោ សម្មថ អស្សមេ

ខត្តិយា គោត្តសម្បន្នា សុជាតា មាតុបេត្តិតោ

យថា បុញ្ញានិ កយិរាថ ទទន្តា អបរាបរំ ។

(៣៧៩) សក្កោហមស្មិ ទេវិន្ទោ អាគតោស្មិ តវន្តិកេ

វរំ វរស្សុ រាជិសិ វរេ អដ្ឋ ទទាមិ តេ ។

(៣៨០) វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ

បិតា មំ អនុមោទេយ្យ ឥតោ បត្តំ សកំ ឃរំ

អាសនេន និមន្តេយ្យ បឋមេតំ វរំ វរេ ។

បុរិសស្ស វធំ ន រោចេយ្យំ អបិ កិព្ពិសការកំ

វជ្ឈំ វធា មោចេយ្យំ ទុតិយេតំ វរំ វរេ ។

យេ វុឌ្ឍា យេ ច ទហរា យេ ច មជ្ឈិមបោរិសា

មមេវ ឧបជីវេយ្យុំ តតិយេតំ វរំ វរេ ។

បរទារំ ន គច្ឆេយ្យំ សទារបសុតោ សិយំ

ថីនំ វសំ ន គច្ឆេយ្យំ ចតុត្ថេតំ វរំ វរេ ។



ផ្គុំគ្នាទាំងពីរ គឺទឹកដោះស្រស់មួយ ស័ង្ខមួយ មានសម្បុរស្មើគ្នា យ៉ាងណាមិញ ព្រះអង្គនិងនាងមទ្រី មានព្រះហឫទ័យស្មើគ្នា ក៏យ៉ាងនោះដែរ ។ ព្រះអង្គទាំងពីរ ជាក្សត្រិយ៍បរិបូណ៌ដោយគោត្រ បានព្រះជាតិល្អខាងមាតានិងបិតា ត្រេកអរនឹងទេស មកគង់នៅក្នុងអាស្រមក្នុងព្រៃនេះ ព្រះអង្គគប្បីធ្វើបុណ្យឲ្យបានតាមសមគួរតទៅ ។

(៣៧៩) ខ្ញុំជាទេវិន្ទ ឈ្មោះសក្កៈ បានមកក្នុងសំណាក់ព្រះអង្គ បពិត្រព្រះរាជឥសី សូមព្រះអង្គទទួលយកពរចុះ ខ្ញុំសូមថ្វាយពរ ៨ យ៉ាង ចំពោះព្រះអង្គ ។

(៣៨០) (ព្រះពោធិសត្វ...) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់ខ្ញុំ (ខ្ញុំ) សូមព្រះបិតាស្រុះស្រួលទទួលខ្ញុំដែលទៅអំពីព្រៃនេះ ដល់នូវលំនៅរបស់ខ្លួន សូមអញ្ជើញខ្ញុំដោយអាសនៈ (រាជសម្បត្តិ) ខ្ញុំសូមពរទី១នេះ ។ ខ្ញុំសូមមិនចូលចិត្តនឹងការសម្លាប់បុរស ខ្ញុំសូមដោះលែងអំពីការសម្លាប់នូវមនុស្សដែលគេត្រូវសម្លាប់ សូម្បីមនុស្សនោះធ្វើអំពើអាក្រក់ (មានកំហុសក្នុងព្រះរាជា) ក៏ដោយ ខ្ញុំសូមពរទី២នេះ ។ សូមឲ្យពួកបុរសចាស់ ពួកបុរសក្មេង ពួកកណ្ដាល រស់នៅអាស្រ័យនឹងខ្ញុំ ខ្ញុំសូមពរទី៣នេះ ។ ខ្ញុំសូមមិនគប់រកប្រពន្ធអ្នកដទៃ ខ្ញុំសូមជាអ្នកខ្វល់ខ្វាយចំពោះតែប្រពន្ធរបស់ខ្លួន ខ្ញុំសូមមិនលុះក្នុងអំណាចពួកស្ត្រី ខ្ញុំសូមពរទី៤នេះ ។

បុត្តោ មេ សក្ក ជាយេថ សោ ច ទីឃាយុកោ សិយា
ធម្មេន ជិនេ បឋវឹ បញ្ចមេតំ វរំ វរេ ។
តតោ រត្យា វិវសានេ សុរិយស្សុគ្គមនំ បតិ
ទិព្វា ភក្ខា បាតុភវេយ្យុំ ឆដ្ឋមេតំ វរំ វរេ ។
ទទតោ មេ ន ខីយេថ ទត្វា នានុតប្បេយ្យហំ
ទទំ ចិត្តំ បសាទេយ្យំ សត្តមេតំ វរំ វរេ ។
ឥតោ វិមុច្ចមានាហំ សគ្គគាមី វិសេសគូ
អនិវត្តី តតោ អស្សំ អដ្ឋមេតំ វរំ វរេ ។
[៣៨៥] តស្ស តំ វចនំ សុត្វា ទេវិន្ទោ ឯតទព្រវិ
អចិរំ វត តេ តាតោ បិតា តំ ទដ្ឋុមេស្សតិ ។
ឥទំ វត្វាន មឃវា ទេវរាជា សុជម្បតិ
វេស្សន្តរេ វរំ ទត្វា សគ្គកាយំ អបក្កមិ ។

សក្កបព្វំ ចប់ ។

(៣៨៦) កស្សេតំ មុខមាភាតិ ហេមំវុត្តត្តមគ្គិនា
និក្ខំវ ជាតរូបស្ស ឧក្កាមុខបហំសិតំ ។



បពិត្រសក្កៈ បុត្ររបស់ខ្ញុំកើតហើយ សូមឲ្យបុត្រនោះមានអាយុវែង សូមឲ្យបានគ្រងក្រៅផែនដីដោយធម៌ ខ្ញុំសូមពរទី ៥ នេះ ។ តពីនោះមក ក្នុងកាលរាត្រីកន្លងទៅ ព្រះអាទិត្យរះឡើង សូមចំណីជាទិព្វទាំងឡាយ មានប្រាកដ ខ្ញុំសូមពរទី ៦ នេះ ។ កាលបើខ្ញុំកំពុងឲ្យ សូម(ទេយ្យធម៌)កុំបីអស់ទៅ លុះខ្ញុំឲ្យហើយ សូមកុំឲ្យក្ដៅក្រហាយស្ដាយក្រោយ ខ្ញុំកំពុងឲ្យ សូមឲ្យចិត្តជ្រះថ្លា ខ្ញុំសូមពរទី ៧ នេះ ។ កាលបើខ្ញុំរួចចាកអត្តភាពនេះ សូមឲ្យបានទៅកាន់ឋានសួគ៌ ដល់នូវឋានដ៏វិសេស គឺកើតក្នុងតុសិតបុរី (កាលបើខ្ញុំរួចចាកតុសិត-ភពនោះមក) សូមកុំឲ្យកើត (ក្នុងភពដទៃទៀត) ខ្ញុំសូមពរទី ៨ នេះ ។

(៣៨៥) (អភិសម្ពុទ្ធគាថា) ព្រះឥន្ទ្រ ជាធំជាងទេវតា បានទ្រង់ព្រះសណ្ដាប់ព្រះបន្ទូលព្រះបាទវេស្សន្តរនោះហើយ ក៏ពោលពាក្យយ៉ាងនេះថា ព្រះបិតាបង្កើតរបស់ព្រះអង្គមិនយូរទេ នឹងមកទតព្រះអង្គ ។ មឃទេវរាជ ជាម្ចាស់នៃនាងសុជាតា លុះត្រាស់ព្រះតម្រាស់នេះហើយ ប្រទានពរដល់ព្រះបាទវេស្សន្តរ ហើយក៏ចៀសចេញទៅកាន់ពួកទេវតាក្នុងឋានសួគ៌ ។

ចប់ សក្កបព្វៈ ។

(៣៨៦) (ព្រះបាទសញ្ជ័យ...) មុខអ្នកណានុ៎ះ ភ្លឺដូចមាសដែលគេរំលាយដោយភ្លើង ឬដូចមាសនេក្ខ ក្នុងចង្ក្រានដែលគេដុតក្ដៅ ។

ឧភោ សទិសបច្ចង្គា ឧភោ សទិសលក្ខណា

ជាលិស្ស សទិសោ ឯកោ ឯកា កណ្ហាជិនា យថា ។

សីហា ពិលាវ និក្ខន្តា ឧភោ សម្បតិរូបកា

ជាតរូបមយាយេវ ឥមេ ទិស្សន្តិ ទារកា ។

(៣៨៣) កុតោ នុ ភវំ ភារទ្វាជ ឥមេ អានេសិ ទារកេ

អជ្ជ រដ្ឋមនុប្បត្តោ កុតោ(១) គច្ឆសិ ព្រាហ្មណ ។

(៣៨៤) មយ្ហន្តេ ទារកា ទេវ ទិន្នា វិត្តេន សញ្ជយ

អជ្ជ បណ្ណរសា រត្តិ យតោ លទ្ធា មេ ទារកា ។

(៣៨៥) កេន វា វាចបេយ្យេន សម្មាញាយេន សទ្ទហេ

កោ តេ តំ ទានមទទា បុត្តកេ ទានមុត្តមំ ។

(៣៨៦) យោ យាចតំ បតិដ្ឋាសិ ភូតានំ ធរណីរិវ

សោ មេ វេស្សន្តរោ រាជា បុត្តេទាសិ វនេ វសំ ។

---

១ ម. កុហឹ គច្ឆសិ ។





កុមារទាំងពីរ មានអវយវៈស្រដៀងគ្នា កុមារទាំងពីរមានលក្ខណៈស្រដៀងគ្នា កុមារម្នាក់ស្រដៀងនឹងជាលី កុមារីម្នាក់ដូចនាងកណ្ហាជិនា ។ កុមារទាំងពីរបរិបូណ៌ ដោយរូបសម្បត្តិ ដូចជាកូនសីហៈ ដែលចេញអំពីរូង ទារកទាំងនេះ ប្រាកដដូចរូបជាវិការៈនៃមាស ។

(៣៨៣) ម្នាលភារទ្វាជៈ អ្នកនាំទារកទាំងពីរនេះមកអំពីទីណាហ្ន៎ ម្នាលព្រាហ្មណ៍ អ្នកមកដល់ដែនក្នុងថ្ងៃនេះ តើអ្នកមកអំពីទីណា ។

(៣៨៤) (ជូជក...) បពិត្រព្រះទេវៈ ទ្រង់ព្រះនាមសញ្ជ័យ ព្រះបាទវេស្សន្តរ ទ្រង់មានព្រះហឫទ័យត្រេកអរ បានប្រទានទារកទាំងនោះដល់ខ្ញុំព្រះបង្គំជាខ្ញុំ តាំងពីថ្ងៃដែលខ្ញុំព្រះបង្គំជាខ្ញុំ បានទារកមក ១៥ រាត្រី គិតត្រឹមថ្ងៃនេះហើយ ។

(៣៨៥) (ព្រះបាទសញ្ជ័យ...) អ្នកឯងនឹងធ្វើឲ្យយើងជឿដោយពាក្យជាទីស្រឡាញ់ តាមហេតុត្រឹមត្រូវដូចម្ដេចបាន នរណាហ្ន៎លើកបុត្រទាំងពីរនេះជាទានដ៏ឧត្តម ហើយឲ្យដល់អ្នក ។

(៣៨៦) (ជូជក...) ព្រះបាទវេស្សន្តរណា ជាទីពឹងរបស់ពួកស្មូម ដូចជាព្រះធរណីជាទីពឹងរបស់ពួកសត្វ ព្រះបាទវេស្សន្តរនោះ ទ្រង់គង់នៅក្នុងព្រៃ បានប្រទានបុត្រទាំងពីរដល់ខ្ញុំព្រះបង្គំជាខ្ញុំ ។

យោ យាចតំ គតិ អាសិ  សវន្តីនំ សាគរោ

សោ មេ វេស្សន្តរោ កថា  បុត្តេ ទាសិ វន វសំ ។

(៣៨៧) ឧក្កដ្ឋេ វត ភោ វញ្ញោ  សាទ្ធេន យាវមសំ ធា

កាជិ ទុ បុត្តកោ ឧត្វា  អរញ្ញេ អវរុទ្ធកោ ។

ឥមំ ភោន្តោ និសាមេថ  យាវន្តេត្ថ សមាគតា

កាជិ វេស្សន្តរោ កថា  បុត្តេ ទាសិ វន វសំ ។

ដាសំ ដាសិញ្ច សោ ឧត្វា  អស្សំ ចស្សតរីរថំ

ហត្ថិញ្ច កុញ្ជរំ ឧត្វា  កាជិ សោ ឧជ្ជ ដារកេ ។

(៣៨៨) យស្ស ដាស្ស ឃរេ ដាសោ  អស្សោ ចស្សតរីរថោ

ហត្ថិ ច កុញ្ជរោ ដាគោ  កឹ សោ ឧត្វា ទិតាមហា ។

(៣៨៩) ដានមស្ស បសំសាម  នានិន្ទាម ពោតកា

កាជិ ទុ ហានយំ អាសិ  តុម្ហេ ឧត្វា វនិព្វកេ ។



ព្រះវេស្សន្តរណា ជាទីប្រព្រឹត្តទៅនៃពួកស្មូម ដូចសាគរជាទីប្រព្រឹត្ត
ទៅនៃស្ទឹងទាំងឡាយ ព្រះបាទវេស្សន្តរនោះ ទ្រង់គង់នៅក្នុងព្រៃ
បានប្រទានបុត្រទាំងពីរ ដល់ខ្ញុំព្រះបង្គំជាខ្ញុំ ។

(៣៨៧) (ឧក្កដ្ឋេ...) ម្នាលម្ចាស់យើង ព្រះរាជាកាលទ្រង់គង់នៅក្នុង
ព្រះរាជដំណាក់ ទ្រង់មានសទ្ធា ធ្វើការក្រៃលែងណាស់ ព្រះបាទវេស្សន្តរ
ត្រូវគេនិរទេសទៅគង់នៅក្នុងព្រៃហើយ ម្ដេចក៏នៅតែប្រទានបុត្រ
ទាំងពីរទៀត ។ នៃអ្នកដ៏ចំរើនទាំងឡាយ អ្នកទាំងពុំស្មានឆាក់
ដែលបានមកជួបជុំគ្នាក្នុងទីនេះ ចូរស្ដាប់រឿងនេះចុះ ហេតុដូចម្ដេច
បានជាព្រះបាទវេស្សន្តរ ទៅគង់នៅក្នុងព្រៃហើយ ក៏ប្រទានបុត្រ
ទាំងពីរ ។ ព្រះអង្គទ្រង់ប្រទានទាសា ទាសី សេះ រថ ដែលទឹម
ដោយសេះអស្សតរផង ឬប្រទានដំរីកុញ្ជរផង ហេតុដូចម្ដេច
បានជា ដាក់ទានទារកទាំងពីរទៀត ។

(៣៨៨) (ជាលីកុមារ...) បពិត្រព្រះអយ្យកោ ទាសៈ សេះ ឬរថ ដែល
ទឹមដោយសេះអស្សតរ នឹងដំរីកុញ្ជរ មិនមានក្នុងផ្ទះនៃបុគ្គលណា
បុគ្គលនោះ នឹងឲ្យដូចម្ដេចកើត ។

(៣៨៩) (ព្រះបាទសញ្ជ័យ...) នែចៅ យើងសរសើរទានបិតារបស់អ្នក
យើងមិនតិះដៀលបន្តិចបន្តួចទេ ចុះហឫទ័យ (នៃបិតារបស់ចៅ) ទើបដូចម្ដេច
បានជាឲ្យចៅទាំងពីរដល់ស្មូម ។

(៣៨០) (បិតា មយ្ហំ មហារាជ តុម្ហេ ទត្វា វនិព្វកេ
សុត្វាន ករុណំ គិរំ អដ្ឋកថាយ ភាសិតំ)[១] ។

(៣៨១) ទុក្ខស្ស ហទយំ អាសិ អថោ ឧណ្ហំបិ អស្សសិ
រោហិណីហេវ តម្ពក្ខី បិតា អស្សូនិ វត្តយិ ។

(៣៨២) យន្តំ កណ្ហាជិនាវោច អយំ មំ តាត ព្រាហ្មណោ
លដ្ឋិយា បដិកោដេតិ ឃរេ ជាតំវ ទាសិយំ ។
ន ចាយំ ព្រាហ្មណោ តាត ធម្មិកា ហោន្តិ ព្រាហ្មណា
យក្ខោ ព្រាហ្មណវណ្ណេន ខាទិតុំ តាត នេតិ នោ
នីយមានេ បិសាចេន កិន្នុ តាត ឧទិក្ខសិ ។

(៣៨៣) រាជបុត្តី ច វោ មាតា រាជបុត្តោ ច វោ បិតា
បុព្វេ មេ អង្គមារុយ្ហ កិន្នុ តិដ្ឋថ អារកា ។

(៣៨៤) រាជបុត្តី ច នោ មាតា រាជបុត្តោ ច នោ បិតា

---

១ ឧ. អយំ គាថា ន ទិស្សតិ ។



(៣៨០) (ជាលីកុមារ...) បពិត្រមហារាជ (ការណ៍ដែល) ព្រះបិតារបស់ខ្ញុំព្រះបង្គំជាខ្ញុំ ទ្រង់ប្រទានយើងខ្ញុំដល់ស្មូម(នោះ) សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ នូវពាក្យឲ្យអាណោចអាធ័ម ដែលនាងកណ្ហាជិនាជាប្អូនពោលចុះ ។

(៣៨១) ហ្ឫទ័យនៃព្រះបិតា របស់ខ្ញុំព្រះបង្គំជាខ្ញុំនោះ ជាទុក្ខ ទាំងទ្រង់មានអស្សាសបស្សាសៈដ៏ក្ដៅ ព្រះបិតាមានព្រះនេត្រក្រហមដូចជាផ្កាយរោហិណី ទ្រង់សម្រក់ទឹកព្រះនេត្រ ។

(៣៨២) នាងកណ្ហាជិនា បានពោលនឹងព្រះបិតានោះ ថា បពិត្រព្រះបិតា ព្រាហ្មណ៍នេះវាយខ្ញុំម្ចាស់ ដោយឈើច្រត់ ដូច(ខ្ញុំម្ចាស់) ជាទាសីដែលកើតក្នុងផ្ទះ ។ បពិត្រព្រះបិតា អ្នកនេះមិនមែនជាព្រាហ្មណ៍ទេ ព្រោះពួកព្រាហ្មណ៍តែងជាអ្នកប្រព្រឹត្តធម៌ បពិត្រព្រះបិតា យក្សក្លែងភេទជាព្រាហ្មណ៍ នាំពួកយើងខ្ញុំយកទៅស៊ី ទេដឹង ។ បពិត្រព្រះបិតា យើងខ្ញុំកាលបិសាចនាំយកទៅ ហេតុអ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ ។

(៣៨៣) (ព្រះបាទសញ្ជ័យ...) មាតារបស់អ្នកជាព្រះរាជបុត្រី បិតារបស់អ្នក ជាព្រះរាជបុត្រ ក្នុងកាលពីដើម ចៅទាំងពីរ ឡើងកាន់ភ្លៅរបស់អញ ចុះហេតុអ្វីបានជាចៅទាំងពីរ ឋិតនៅក្នុងទីឆ្ងាយ ។

(៣៨៤) (ជាលីកុមារ...) ព្រះមាតារបស់ពួកខ្ញុំព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រី ព្រះបិតារបស់ពួកខ្ញុំព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រ

ទាសា មយិ ព្រាហ្មណស្ស តស្មា តិដ្ឋាម អាវកា ។

(៣៩៥) មា សម្មេវំ អវចុត្ថ ទុយ្ហតេ ហទយំ មម

ចិតកាយំវ មេ កាយោ អាសនេ ន សុខំ លភេ ។

(៣៩៦) មា សម្មេវំ អវចុត្ថ ភិយ្យោ សោកំ ជនេថ មំ

និក្កិណិស្សាមិ ធនេន ន វោ ទាសា ភវិស្សថ ។

កិំនគ្ឃិយំ ហិ វោ តាត ព្រាហ្មណស្ស បិតា អទា

យថាភូតំ មេ អក្ខាថ បដិបាទេន្តុ ព្រាហ្មណំ ។

(៣៩៧) សហស្សគ្ឃំ ហិ មំ តាត ព្រាហ្មណស្ស បិតា អទា

អច្ឆិំ កណ្ហាជិនំ កញ្ញំ ហត្ថិអាទិសតេន ច ។

(៣៩៨) ឧដ្ឋេហិ កត្តេ តរមានោ ព្រាហ្មណស្ស អវាករ

ទាសិសតំ ទាសសតំ គវំ ហត្ថុសភំ សតំ



ខ្ញុំព្រះបង្គំជាខ្ញុំតាំងពីដើម ជាទាសារបស់ព្រាហ្មណ៍ ហេតុនោះ បានជាខ្ញុំព្រះបង្គំជាខ្ញុំឈរនៅក្នុងទីឆ្ងាយ ។

(៣៩៥) (ព្រះបាទសញ្ជ័យ...) នែចៅសំឡាញ់ទាំងពីរ ចៅទាំងពីរ កុំពោលយ៉ាងនេះឡើយ ចិត្តក្តៅក្រហាយរបស់ជីតាណាស់ កាយរបស់ជីតា ហាក់ដូចជា (គេលើកដាក់) លើជើងថ្ករ ជីតាមិនបានសុខលើអាសនៈទេ ។

(៣៩៦) នែចៅសំឡាញ់ទាំងពីរ ចៅទាំងពីរ កុំពោលយ៉ាងនេះឡើយ ចៅទាំងពីរនឹងតែញ៉ាំងសេចក្តីសោកឲ្យកើតដល់ជីតា ជីតានឹងលោះដោះសាបានដោយទ្រព្យ មិនឲ្យបានទៅជាទាសាទេ ។ នែចៅ បិតារបស់ចៅ បានកាត់ថ្លៃប៉ុន្មាន ហើយបានឲ្យចៅទាំងពីរដល់ព្រាហ្មណ៍ ចូរប្រាប់ដល់ជីតាឲ្យត្រង់ តាមពាក្យ ចូរញ៉ាំងព្រាហ្មណ៍ឲ្យទទួលទ្រព្យ ។

(៣៩៧) (ជាលីកុមារ...) បពិត្រព្រះអយ្យកា ព្រះបិតាបានប្រទានខ្ញុំព្រះបង្គំជាខ្ញុំ ដល់ព្រាហ្មណ៍ ដោយកាត់ថ្លៃមួយពាន់និក្ខៈ ប្រទានកញ្ញាឈ្មោះកណ្ហាជិនាជាប្អូនស្រី ដោយកាត់ថ្លៃមួយរយនៃគ្រឿងគ្រប់មុខ មានដំរីជាដើម ។

(៣៩៨) (ព្រះបាទសញ្ជ័យ...) នែពួកអាមាត្យ អ្នកចូរក្រោកឲ្យឆាប់ ហើយចូរឲ្យទាសី១០០ ទាសា១០០ គោ១០០ ដំរី១០០ គោបា១០០

ជាតរូបសហស្សញ្ច    តាតោ ជាលិំ និក្ខយិ ។

(៧៩៩) ឥតោ កក្ក តរមានោ    ព្រាហ្មណស្ស អភិតារិ

ទាសីសតំ ទាសសតំ    គវំ ហត្ថុសភំ សតំ

ជាតរូបសហស្សញ្ច    តាតានំទាសិ និក្ខយិ ។

(៨០០) (ទាសីសតំ ទាសសតំ    គវំ ហត្ថុសភំ សតំ

អស្សតរីរថញ្ចេវ    សព្វលោកេ សតំ សតំ

ជាតរូបសហស្សញ្ច    ព្រាហ្មណស្ស ធនេសិនោ

មក្ខាយិតស្ស លុទ្ធស្ស    តាតានំទាសិ និក្ខយិ)[១] ។

(៨០១) និក្កិណិត្វា នហាបេត្វា    ភោជយិត្វាន ទារកេ

សមលង្កិត្វា ភណ្ឌេហិ    ឧច្ឆង្គេ ឧបវេសយុំ ។

សីសំ ន្ហាតេ សុចិវត្ថេ    សព្វាភរណភូសិតេ

រាជា អង្កេ ករិត្វាន    អយ្យកោ បរិបុច្ឆថ ។

---

១ ម. អយំ គាថា នត្ថិ ។





(សេះ១០០ ឧសភៈ១០០) និងមាស១០០០ដំឡឹង ដល់ព្រាហ្មណ៍ ឲ្យជាដំឡៃលោះយកចៅទាំងពីរ ។

(៧៩៩) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ពួកអាមាត្យក៏ប្រញាប់ប្រញាល់ ឲ្យទាសី១០០ ទាសា១០០ គោ១០០ ដំរី១០០ គោឧសភ១០០ (សេះ១០០ ឧសភៈ១០០) និងមាស១០០០ដំឡឹង ដល់ព្រាហ្មណ៍ ឲ្យជាដំឡៃលោះយកព្រះរាជនត្តាទាំងពីរ ។

(៨០០) (តាមគាថា) ចូរឲ្យប្រគល់តាំងសន្និយាយៗ គឺទាសី១០០ ទាសា១០០ គោ១០០ ដំរី១០០ គោឧសភ១០០ រថទឹមដោយសេះ១០០ និងមាស១០០០ដំឡឹង ដល់ព្រាហ្មណ៍ ជាអ្នកស្វែងរកទ្រព្យ ជាមនុស្សល្មោភកាមលើសលប់ ឲ្យជាដំឡៃលោះយកព្រះរាជនត្តាទាំងពីរ ។

(៨០១) ពួកគ្រួតាំងពីព្រះអង្គ ចុះលោះចៅទាំងពីរ ហើយផ្ងូតទឹក ឲ្យបរិភោគភោជន ប្រដាប់ដោយគ្រឿងប្រដាប់តាំងឡាយ រួចឲ្យគង់លើភ្លៅ ។ ព្រះរាជាជាព្រះអយ្យកោ ដាក់ជាលីកុមារលើភ្លៅ ហើយសាកសួរចៅទាំងពីរ ដែលកក់សីសៈហើយ មានសំពត់ស្អាត ស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង ។

កុណ្ឌលេ ឃុសិតេ មាលេ សព្វាលង្ការភូសិតេ

ភជា អន្តេ ការិក្ខាន ឥទំ វចនមព្រវិ ។

កច្ចិ នុ ភោ អរោគា តេ ជាលិ មាតាបិតា តវ

កច្ចិ ឧញ្ឆេន យាបេន្តិ កច្ចិ មូលផលា ពហូ ។

កច្ចិ ឌំសា មកសា ច អប្បមេវ សរីសបា

វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតិ ។

(៦០២) អថោ នុ ភោ អរោគា តេ ទេវ មាតាបិតា មម

អថោ ឧញ្ឆេន យាបេន្តិ អថោ មូលផលា ពហូ

អថោ ឌំសា មកសា ច អប្បមេវ សរីសបា

វនេ វាឡមិគាកិណ្ណេ ហឹសា នេសំ ន វិជ្ជតិ ។

ខណន្តាលុកលម្ពានិ ពិឡានិ តក្កលានិ ច

កោលំ ភល្លាតកំ ពេលំ សា នោ អាហត្វ បោសតិ ។



ព្រះរាជា បានដាក់លើភ្លៅ នូវកុមារទាំងពីរដែលមានកុណ្ឌល ក្រវិល គីកកង មានផ្កាកម្រង ស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង ហើយត្រាស់ព្រះរាជតម្រាស់នេះថា នែជាលី មាតាបិតារបស់ចៅ ទាំងពីរនោះ សុខសប្បាយទេឬ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរក (ផលាផល) ស្រួលទេឬ ទាំងមើមឈើនិងផ្លែឈើ មានច្រើនដែរឬ ពួករបោម មូស និងពស់ មានតិចតួចទេឬ ក្នុងព្រៃដ៏កុះករ ដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនទេឬ ។

(៦០២) (ជាលីកុមារ...) បពិត្រព្រះទេវៈ មាតាបិតារបស់ខ្ញុំព្រះអង្គទាំងពីរនោះ សុខសប្បាយជាទេ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរក(ផលាផល)ស្រួលទេ មើមឈើនិងផ្លែឈើមានច្រើន ។ ឯពួករបោម មូស និងពស់មានតិចទេ ក្នុងព្រៃដ៏កុះករ ដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនព្រះអង្គទេ ។ ព្រះមាតានោះ ជីកយកមើមដំឡូងសព្វ ដំឡូងដូង ដំឡូងនិងក្ខា ដំឡូងខៀន ទាំងបាននាំយក ផ្លែពុទ្រា ផ្លែកន្ទួត ផ្លែព្នៅ មកចិញ្ចឹមយើងខ្ញុំផង ។

យញ្ចេត្ថ សា អាហរតិ វនមូលផលហារិយា
តំ នោ សព្វេ សមាគន្ត្វា រត្តឹ ភុញ្ជាម នោ ទិវា ។
អម្មាវ នោ កិសា បណ្ឌុ អាហរន្តី ទុមប្ផលំ
វាតាតបេន សុខុមាលី បទុមំ ហត្ថគតមិវ ។
អម្មាយ បតនូកេសា វិចរន្ត្យា ព្រហាវនេ
វនេ វាឡមិគាកិណ្ណេ ខគ្គទីបិនិសេវិតេ ។
កេសេសុ ជដំ ពន្ធិត្វា កច្ឆេ ជល្លមធារយិ
(ធារេន្តា ព្រាហ្មណាវណ្ណំ អាសនេតុ មសញ្ជដំ)
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ ។
(៦០៣) បុត្តា បិយា មនុស្សានំ លោកស្មឹ ឧទបជ្ជិសុំ
ន ហិ នូនម្ហាកំ អយ្យស្ស បុត្តេ សិនេហោ អជាយថ ។
(៦០៤) ទុក្កដញ្ច ហិ នោ តាត ភូនហច្ចំ កតំ មយា
យោហំ សិវីនំ វចនា បព្វាជេសឹ អទូសកំ ។



បើព្រះមាតានោះនាំគ្នាតាំងយកមើមឈើនិងផ្លែឈើក្នុងព្រៃ នាំយកវត្ថុណាមកយើងខ្ញុំទាំងអស់គ្នាក៏មកជុំគ្នាបរិភោគវត្ថុនោះនៅតែក្នុងវេលាយប់មិនបានបរិភោគក្នុងវេលាថ្ងៃទេ ។ ព្រះមាតារបស់យើងខ្ញុំជាស្រីបាច់សុខស្រួល ទំនាំយកផ្លែឈើមក ក៏ទៅជាមានកាយស្គមស្លេកស្លាំងដោយត្រូវខ្យល់និងកំដៅថ្ងៃ ដូចជាផ្កាឈូកដែលគេល្មើដោយដៃ ។ ព្រះកេសាទាំងឡាយ របស់ព្រះមាតាក៏ជ្រុះ ព្រោះត្រាច់ទៅក្នុងព្រៃធំ ជាព្រៃដ៏កុះករដោយម្រឹគសាហាវ ជាទីដែលអាសនឹងខ្លាដំបងនៅអាស្រ័យហើយ ។ ព្រះមាតាចងនូវសក់ទាំងឡាយខ្ចើខ្ចូនាំញើសក្លៀកបង្ហៀក (ខ្ចើខ្ចូនាំគេទាំងឡាយមិនធ្វើសក់ខ្ចើខ្ចូនីដាក់ ស្លាបព្រា សម្រាប់បូជាភ្លើងនឹងផង) ស្លៀកដណ្ដប់ស្បែកខ្លា ដេកលើផែនដី នមស្ការភ្លើង ។

(៦០៣) បុត្រជាទីស្រឡាញ់ នៃមនុស្សក្នុងលោក ចាំស្មើតែសេចក្តីស្នេហាក្នុងបុត្រ មិនកើតដល់ព្រះអយ្យកោ របស់យើងខ្ញុំដោយពិត ។

(៦០៤) (ព្រះបាទសញ្ជ័យ...) នែរ៉េ អំពើតាក្រក់យើងបានធ្វើហើយ ទាំងអំពើដែលបង្ខូចសេចក្តីចំរើន យើងក៏បានធ្វើហើយ ព្រោះអីតាបានបំបរបង់បុត្រដែលឥតទោស តាមពាក្យ នៃពួកអ្នកសិវិរដ្ឋ ។

យំ មេ កិញ្ចិ ឥធ អត្ថិ ធនំ ធញ្ញញ្ច វិជ្ជតិ
ឯតុ វេស្សន្តរោ រាជា សិវិរដ្ឋេ បសាសតុ ។
(៦០៨) ន ទេវ មយ្ហំ វចនា នាគតោ សិវិសុន្ទរោ
សយមេវ ទេវ គន្ត្វាន សិញ្ច ភោគេហិ អត្រជំ ។
(៦០៩) តតោ សេនាបតឹ រាជា សញ្ជយោ អជ្ឈភាសថ
ហត្ថី អស្សា រថា បត្តី សេនា សន្នាហយន្តុ នំ
នេគមា ច មំ អន្វេន្តុ ព្រាហ្មណា ច បុរោហិតា
តតោ សដ្ឋី សហស្សានិ យោធិនោ ចារុទស្សនា
ខិប្បមាយន្តុ សន្នទ្ធា នានាវណ្ណេហិលង្កតា ។
នីលវត្ថធរានេកេ បីតានេកេ និវាសិតា
អញ្ញេ លោហិតឧណ្ហីសា សុទ្ធានេកេ និវាសិតា
ខិប្បមាយន្តុ សន្នទ្ធា នានាវណ្ណេហិលង្កតា ។
ហិមវា យថា គន្ធរោ បព្វតោ គន្ធមាទនោ
នានារុក្ខេហិ សញ្ឆន្នោ មហាភូតគណាលយោ ។



វត្ថុណាមួយរបស់យើង មានក្នុងទីនេះ ទាំងទ្រព្យនឹងធញ្ញជាតិ (ជីតាកំណត់ទីនឹងវត្ថុនោះ ដល់បិតារបស់ចៅ) សូមវេស្សន្តរទ្រង់មក ចូរជាព្រះរាជាគ្រងក្រុងសិវិចុះ ។

(៦០៨) (ជាលីកុមារ...) បពិត្រព្រះសម្មតិទេព ព្រះរាជាដ៏ឧត្តមរបស់អ្នកសិវិក្រុង នឹងមិនយាងមកតាមពាក្យ របស់ទូលព្រះបង្គំទេ សូមព្រះសម្មតិទេព ទ្រង់ស្តេចយាងទៅដោយព្រះអង្គឯងវិញ ហើយស្រោចស្រប់ព្រះរាជបុត្រ ដោយភោគៈទាំងឡាយ ។

(៦០៩) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះរាជាព្រះនាមសញ្ជ័យ មានព្រះបន្ទូលនឹងសេនាបតីថា ពួកសេនាដំរី សេនាសេះ សេនារថ សេនាថ្មើរជើង ចូរសៀត(កាន់អាវុធទាំងឡាយ)ពួកអ្នកនិគម ព្រាហ្មណ៍បុរោហិត តាមខ្ញុំ ៦០.០០០ នឹងពួកទាហាន ដ៏ល្អមើល ចង់គ្រឿងក្រោះ ប្រដាប់ដោយគ្រឿងប្រដាប់ មានពណ៌ផ្សេងៗ ចូរទាំងគ្នាមកឲ្យឆាប់ ជូនអញទៅ ។ ពួកទាហានខ្លះ ស្លៀកពាក់សំពត់ខៀវ ពួកទាហានខ្លះ ស្លៀកពាក់សំពត់លឿង ពួកទាហានដទៃពាក់ឈ្នួតក្រហម ពួកទាហានខ្លះ ស្លៀកពាក់សំពត់ស ចង់គ្រឿងក្រោះ ប្រដាប់ដោយគ្រឿងប្រដាប់មានពណ៌ផ្សេងៗ ចូរទាំងគ្នាមកឲ្យឆាប់ ។ ភ្នំហិមពាន្តនឹងភ្នំគន្ធមាទន៍ ដ៏ទ្រទ្រង់ក្លិន ដ៏ដេរដាសដោយពួកឈើផ្សេងៗ ជាលំនៅនៃពួកភូតដ៏ច្រើន

និសេធេហិ ច ធំពេហិ ធំសា កាតំ ឋភតិ ៤
ទិព្វមាយន្តុ សន្នទ្ធា ធំសា កន្តុ ឋត្ថុ ៤ ។
ឥតោ នាគសហស្សានិ យោជយន្តុ ចតុទ្ទស
សុវណ្ណកច្ឆេ មាតង្គេ ហេមកប្បនវាសសេ ។
អារូឡ្ហេ គាមណីយេហិ តោមរង្កុសបាណិភិ
ទិព្វមាយន្តុ សន្នទ្ធា ហត្ថិក្ខន្ធេហិ ទស្សិតា ។
ឥតោ អស្សសហស្សានិ យោជយន្តុ ចតុទ្ទស
អាជានិយេវ ជាតិយា សិន្ធវេ សីឃវាហនេ ។
អារូឡ្ហេ គាមណីយេហិ ឥល្លិយាចាបធារិភិ
ទិព្វមាយន្តុ សន្នទ្ធា អស្សបិដ្ឋេ អលង្កតា ។
ឥតោ រថសហស្សានិ យោជយន្តុ ចតុទ្ទស
អយោសុកតនេមិយោ សុវណ្ណចិត្របក្ខរេ ។
អារោបេន្តុ ធជេ តត្ថ ចម្មានិ កវចានិ ច
វិប្បាលេន្តុ ច ចាបានិ ទឡ្ហធម្មា បហារិនោ
ទិព្វមាយន្តុ សន្នទ្ធា រថេសុ រថជីវិនោ ។



ញ៉ាំងទិសទាំងឡាយឲ្យភ្លឺ ផ្សាយទៅដោយទេសទាំងឡាយ ជាទិព្វ យ៉ាងណា ពួកទាហានទាំងឡាយដ៏ក្លៀវក្លា ចូរមកឲ្យឆាប់ ចូរញ៉ាំងទិសទាំងឡាយ ឲ្យភ្លឺរុងរឿងផ្សាយទៅ យ៉ាងនោះដែរ ។ ពួកអ្នកជិះដំរី ចូររៀបចំដំរី ១៤ ពាន់ ជាសត្វមានសរីរៈធំ មានខ្សែរង្គុំជាវិការៈនៃមាស មានសរីរៈស្រោប ដោយគ្រឿងតែងក្បជាវិការៈនៃមាស ។ ពួកអ្នកបង្ហាត់ដំរី មានដៃកាន់ដែកចំពុះទុង និងកង្វេរ មានគ្រឿងស្អិតស្អាងប្រាកដហើយ ពាក់គ្រឿងក្រោះហើយ ចូរនាំគ្នាឡើងជិះកដំរីទាំងឡាយបរមកឲ្យឆាប់ ។ ពួកអ្នកជិះសេះ ចូររៀបចំសេះ ទាំង ១៤ ពាន់ ជាជាតិសេះសិន្ធពអាជានេយ្យ មានសន្ទុះដ៏លឿន ។ ពួកអ្នកបង្កើតសេះ ប្រុងប្រៀបសឹងធ្នូ ចងគ្រឿងក្រោះ ប្រដាប់លើខ្នងសេះ ហើយចូរឡើងជិះបរមកឲ្យឆាប់ ។ លំដាប់ពីនោះមក ពួកអ្នកបររថ ចូររៀបចំរថទាំង ១៤ ពាន់ ជារថមានខ្នងកង់ធ្វើពីដែកដ៏ល្អ មានខ្នងរំលេចដោយមាស ។ ពួកទាហានជំនាញស្ទាត់ក្នុងការប្រហារ ពួកជិះរថ ចូរនាំគ្នាលើកទង់ជ័យ រៀបចំគ្រឿងក្រោះទាំងឡាយ ក្នុងរថទាំងនោះ ចូរដំឡើងធ្នូ ពាក់គ្រឿងក្រោះ ហើយចូរបររថទាំងឡាយមកឲ្យឆាប់ ។

(២០៧) ឡាជា ឱលោកិយា(១) បុប្ផា មាលាគន្ធវិលេបនា
អគ្ឃិយានិ ច តិដ្ឋន្តុ យេន មគ្គេន ឯហិតិ ។
គាមេ គាមេ សតំ កុម្ភា មេរយស្ស សុរាយ ច
មគ្គម្ហិ បតិតា ឋន្តុ យេន មគ្គេន ឯហិតិ ។
មំសា បូវា ច សង្កុល្យា កុម្មាសា មច្ឆសំយុតា
មគ្គម្ហិ បតិតា ឋន្តុ យេន មគ្គេន ឯហិតិ ។
សប្បិ តេលំ ទធិ ខីរំ កង្គុពីជា(២) ពហូ សុរា
មគ្គម្ហិ បតិតា ឋន្តុ យេន មគ្គេន ឯហិតិ ។
អាឡារិកា ច សូទា ច នដនដ្ដកគាយិនោ
បាណិស្សរា កុម្ភថូណិយោ មន្ទកា សោកជ្ឈាយិកា ។
អាហញ្ញន្តុ សព្ពវីណា ភេរិយោ ទិន្ទិមានិ ច
ខរមុខានិ ធមន្តុ នទន្តុ ឯកបោក្ខរា ។
មុទិង្គា បណវា សង្ខា គោធា បរិវទន្តិកា
ទិន្ទិមានិ ច ហញ្ញន្តុ កុតុម្ពា ទិន្ទិមានិ ច ។
(២០៨) សា សេនា មហតី អាសិ ឧយ្យុត្តា សិវិវាហិនី
ជាលិនា មគ្គនាយេន វង្កំ បាយាសិ បព្វតំ ។

១ ឱ. ឱលោកិកា ។ ២ ឱ. កង្គុបិដ្ឋា ។



(២០៧) ផ្កាទាំងឡាយ ចូរកាត់តែងផ្កាទាំងឡាយ (មានឈើផាត់របប់) និងផ្កាសម្រាប់កោយកាយ គម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបស្រឡាប និងផ្កាដ៏មានដំឡៃទាំងឡាយ ចូរឋិតនៅត្រង់ផ្លូវ ដែលបុត្ររបស់អញមក ។ គ្រប់ក្លាស្រុក ចូរតាក់តែងតាំងទុកថងទឹកមេរ័យ និងសុរាច្រើន ត្រង់ផ្លូវដែលបុត្ររបស់អញមក ។ ចូរតាក់តែងតាំងទុក សាច់ នំព្រោបល្វ នំកុម្មាសដែលលាយសាច់ត្រី ត្រង់ផ្លូវដែលបុត្ររបស់អញមក ។ ចូរតាក់តែងតាំងទុកទឹកដោះរាវ ប្រេង ទឹកដោះជូរ ទឹកដោះស្រស់ និងសុរាដ៏ច្រើន ដែលធ្វើដោយស្រូវផ្ដៅ ត្រង់ផ្លូវដែលបុត្ររបស់អញមក ។ ពួកអ្នកធ្វើម្ហូប អ្នកធ្វើបាយ អ្នករាំនិងអ្នកច្រៀង អ្នកច្រៀងដំរាំង អ្នកវាយស្គរ អ្នកច្រៀងដោយសំឡេងដ៏ស្រទន់ និងពួកអ្នកលេងកុំហុក ។ ពួកជនចូរផ្ញើពិណគ្រប់បែប ចូរវាយស្គរ និងមហោរីកទាំងឡាយ ចូរផ្លុំសង្ខ និងវាយស្គរទាំងឡាយ ។ ជនទាំងឡាយចូរវាយសំភោរ វាយស្គរធំ ផ្លុំសង្ខ ដេញតាក់ខេ ដេញពិណវៀល វាយមហោរីក វាយស្គរខនីដែង វាយស្គរមន្ទីល ។

(២០៨) សេនាដ៏ច្រើននោះ ជាកងទ័ពក្សត្រដែនសិវិ លើកចេញទៅ មានជាលីកុមារជាមគ្គនាយក បានដើរសំដៅទៅកាន់វង្កបព៌ត ។

កោញ្ចា នទន្តិ មាតង្គា កុញ្ជរា សដ្ឋិហាយនា
កុញ្ជរាយ ពន្ធមានាយ កោញ្ចា នទន្តិ ភេរវា ។
អជាជិយោ មាសិយន្តិ ធេនាយោសោ អជាយថ
ឆតិ(១) រវោ អតាធេសិ ទុយុត្តា សរិកវាលិធ ។
សារសេចាមតិតិ កវសិ ទុយុត្តា មារីមារិណី
ជាលិតា ទត្តាយេន វក្កិ តាយាសិ បត្តំ ។
តេ តារីសុ ត្រូមាវត្ថុំ ពហុសាទំ ទាហោឆតំ
បុប្ផំ គោត្រីហិ សញ្ឆន្នំ ផលព្រោក្ខាហិ ចូកយំ ។
តត្ថ វិទូស្សក វត្ថ តាតាវណ្ណា តហុ ធិជា
កុជន្តុ ឧបកុជន្តិ ឧតុសំបុប្ផិតេ ទុមេ ។
តេ តត្ថា ធីយទត្តាធំ អហោវត្តាឧទដ្ឋយេ
បទេសន្តិ ទុវាគត្ថុំ យត្ថ វេស្សន្តរោ អហុ ។

មហាវនបព្វំ ចប់ ។

(៦០៩) តេសំ សុត្វាន និគ្ឃោសំ ភីតោ វេស្សន្តរោ អហុ
បព្វតំ អភិរូហិត្វា ភីតោ សេនំ ឧទិក្ខតិ ។

១ ម. អត្ថិ ។



ដំរីញីប្រាសីឆ្នាំមានអាយុ៦០ឆ្នាំ បន្លឺកញ្ជ្រៀវ ដំរីកាលបើមានខ្សែជន្លន់ជាប់នៅហើយ ក៏បន្លឺកញ្ជ្រៀវ ។ សេះគាជាទ័យតាំងព្រះយាយស្រែកក៏វែង សំឡេងអឺកកងនៃខ្ទង់ ក៏កើតមានក្នុងកាលនោះ ទូលីក៏ហុយចាំងដូចពពក កងទ័ពក្នុងដែនសិវិបានលើកចេញទៅ ។ សេនាដ៏ច្រើនរោះគាចនាំយករបស់ដែលគួរនាំយកទៅបាន លើកចេញទៅ មានជាលីកុមារជាមគ្គនាយក បានដើរសំដៅទៅកាន់វង្កតបព៌ត ។ កងទ័ពទាំងនោះ បានចូលទៅកាន់ព្រៃធំ មានមែកឈើច្រើន មានទឹកច្រើន ដេរដាសដោយឈើមានផ្កា និងឈើមានផ្លែផ្ដាំងសង់ទាំងផ្កា ។ ពួកសត្វស្លាបដ៏ច្រើនក្នុងព្រៃធំនោះ មានសំឡេងផ្អូល មានសំឡេងពីរោះ មានព្រគួលផ្សេងៗ ស្រែកហៅសត្វស្លាប ដែលកំពុងស្រែក លើដើមឈើដែលផ្កាតាមរដូវ ។ កងទ័ពទាំងនោះ ទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ក្នុងកាលកន្លងទៅនៃថ្ងៃនិងយប់ បានចូលទៅដល់ប្រទេស ដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ។

ចប់ មហាវនបព្វ ។

(៦០៩) (អភិសម្ពុទ្ធគាថា) ព្រះបាទវេស្សន្តរ ទ្រង់ឮសំឡេងគឹកកងនៃកងទ័ពទាំងនោះហើយ ក៏ភិតភ័យ ទ្រង់ឡើងទៅលើភ្នំ ហើយទ្រង់ទតមើល នូវពួកសេនា ទាំងភិតភ័យ មានបន្ទូលថា

ឥង្ឃ មទ្ទិ និសាមេហិ និគ្ឃោសោ យាទិសោ វនេ

អាជានិយា ហសិយន្តិ ធជគ្គានេវ ទិស្សរេ ។

ឥមេ នូន អរញ្ញស្មឹ មិគសង្ឃានិ លុទ្ទកា

វាគុរាហិ បរិក្ខិប្ប សោព្ភំ បាតេត្វា តាវទេ

វិក្កោសមានា តិព្វាហិ ហន្តិ នេសំ វរំ វរំ ។

យថា មយំ អទូសកា អរញ្ញេ អវរុទ្ធកា

អមិត្តហត្ថត្តំ គតា បស្ស ទុព្វលឃាតកំ ។

(៦១០) អមិត្តា នប្បសហេយ្យុំ អគ្គីវ ឧទកណ្ណវេ

តទេវ ត្វំ វិចិន្តេហិ អបិ សោត្ថិ ឥតោ សិយា ។

(៦១១) តតោ វេស្សន្តរោ រាជា ឱរុហិត្វាន បព្វតា

និសីទិ បណ្ណសាលាយំ ទឡ្ហំ កត្វាន មានសំ ។

(៦១២) និវត្តយិត្វាន រថំ វុដ្ឋាបេត្វាន សេនិយោ

ឯកំ អរញ្ញេ វិហរន្តំ បិតា បុត្តំ ឧបាគមិ ។



នែនាងមទ្រី នាងចូរពិចារណាមើល សំឡេងគឹកកង ក្នុងព្រៃ យ៉ាងនេះ មានតែសេះអាជានេយ្យស្រែកកញ្ចែង តែចុងទង់ជ័យ កំពុងឃើញ ។ ជនទាំងនេះ ដូចជាព្រានព្រៃតាមព័ទ្ធហ្វូងម្រឹគ ក្នុងព្រៃដោយបណ្តាញទាំងឡាយ ដេញចំណាក់ក្នុងរណ្តៅ ហើយចាក់កាប់សំឡាប់ ពួនយកតែសាច់ល្អៗ នៃម្រឹគទាំងនោះ ដោយកាំបិតដ៏មុត ដោយពិត ។ ពួកយើងមិនមានទោស ត្រូវគេនិរទេសមកនៅក្នុងព្រៃ ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃសត្រូវ ក៏ដូចជាម្រឹគយ៉ាងនោះដែរ នាងចូរមើលនូវការសម្លាប់បុគ្គលខ្សោយ ។

(៦១០) (ព្រះនាងមទ្រី..) ពួកសត្រូវមិនអាចគ្របសង្កត់(ព្រះអង្គ)បានទេ ដូចជាភ្លើង មិនអាចគ្របសង្កត់ទឹកសមុទ្របាន សូមព្រះអង្គទ្រង់ព្រះចិន្តាដល់ពាក្យ ដែលសត្វទៅកាន់ពាលហើយនោះឯង ទំនងជាសួស្តីនឹងមានដល់ព្រះអង្គ ព្រោះហេតុពលនេះ ។

(៦១១) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះបាទវេស្សន្តរ យាងចុះអំពីភ្នំ ទ្រង់ធ្វើព្រះហឫទ័យឲ្យមាំ ហើយគង់នៅក្នុងបណ្ណសាលា ។

(៦១២) ព្រះបិតាទ្រង់ឲ្យបញ្ឈប់រថ ទ្រង់ឲ្យពួកសេនាត្រៀមចាំ ហើយទ្រង់ស្តេចចូលទៅជួបនឹងព្រះរាជបុត្រ ដែលគង់នៅក្នុងព្រៃតែម្នាក់ឯង ។

ហត្ថិក្ខន្ធតោ ឱរុយ្ហ ឯកំសោ បញ្ជលីកតោ
បរិកិណ្ណោ អមច្ចេហិ បុត្តំ សិញ្ចិ សមាគមំ ។
តត្ថទ្ទស កុមារំ សោ រម្មរូបំ សមាហិតំ
និសិន្នំ បណ្ណសាលាយំ ឈាយន្តំ អកុតោភយំ ។
(៤១៣) តញ្ច ទិស្វាន អាយន្តំ បិតរំ បុត្តគិទ្ធិនំ
វេស្សន្តរោ ច មទ្ទី ច បច្ចុគ្គន្ត្វា អវន្ទិសុំ ។
មទ្ទី ច សិរសា បាទេ សស្សុរស្សាភិវាទយិ
មទ្ទី អហញ្ហិ តេ ទេវ បាទេ វន្ទាមិ តេ សុសា[1]
តេសុ តត្ថ បលិស្សជ្ជ បាណិនា បរិមជ្ជថ ។
(៤១៤) កច្ចិ វោ កុសលំ បុត្ត កច្ចិ បុត្ត អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច អប្បមេវ សរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហិំសា ន វិជ្ជតិ ។

១ ម. តេ សុណ្ហា ។





លុះព្រះបិតាយាងចុះអំពី-កដំរី ហើយទ្រង់ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ផ្គងអញ្ជលី មានពួកអាមាត្យហែហម បានចូលទៅដើម្បីអភិសេកបុត្រ ។ ព្រះអង្គបានទតឃើញកុមារមានរូបគួរឱ្យត្រេកអរ ស្រួលព្រះហឫទ័យ កំពុងតែត្រិះរិះ មិនមានភ័យអំពីទីណាមួយ ដែលគង់នៅក្នុងបណ្ណសាលានោះ ។

(៤១៣) ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រី បានទតឃើញព្រះបិតានោះ មានសេចក្តីជាប់ព្រះហឫទ័យ ក្នុងបុត្រ កំពុងយាងមក ក៏ក្រោកទៅទទួល ថ្វាយបង្គំ ។ ចំណែកព្រះនាងមទ្រី ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសស្សុរៈដោយព្រះសិរ្ស (ហើយក្រាបទូលថា) បពិត្រព្រះសម្មតិទេព ខ្ញុំឈ្មោះមទ្រី ជាសុណ្ហារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះអង្គ ព្រះបិតាទ្រង់ឱបរឹតផងទាំងពីរនោះ ហើយបាបោសអង្អែលដោយព្រះហស្ត ។

(៤១៤) (ព្រះរាជា...) នែបុត្រ អ្នកទាំងពីរសុខសប្បាយទេឬ នែបុត្រ អ្នកទាំងពីរ មិនមានជម្ងឺផ្កាត់ទេឬ អ្នកទាំងពីរ ចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេឬ មើមឈើនិងផ្លែឈើមានច្រើនឬទេ ។ ពួករបោមមូស ពស់ មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង់ មិនមានការបៀតបៀនទេឬ ។

(២១៥) អត្ថិ នោ ជីវិកា ទេវ សា ច យាទិសិកីទិសា
កាសិក ជីវិកា ហោម ឧញ្ឆាចរិយាយ ជីវិតំ ។
អនិដ្ឋំ មហារាជ ឥមេត្យស្សំ សារថិ
ត្យម្ហា មិដ្ឋិកា ឆន្ទា អសមិទ្ធិ ឥមេតិ នោ ។
អបិ នោ កីសានំ មំសានំ បិតុ មាតុ អនស្សតា
អវុទ្ធានំ មហារាជ អរញ្ញេ ជីវិសោកិនំ ។

(២១៦) យេ បិ តេ សិរិសេដ្ឋស្ស ឆាយាឧបច្ចត្តមានសា
ជាលី កណ្ហាជិនា ឧភោ ព្រាហ្មណស្ស សោទុតា
អច្ចាយិកស្ស លុទ្ទស្ស យោ នេ គាវោ សុម្ភតិ ។
តេ រាជបុត្តិយា បុត្តេ យទិ ជានាថ សំសថ
បរិយាបុណាថ នោ ខិប្បំ សប្បទដ្ឋំវ មាណវំ ។

(២១៧) ឯតេ[១] កុមារា និក្ខន្តា ជាលី កណ្ហាជិនា ឧភោ
ព្រាហ្មណស្ស ធនំ ធត្វា បុត្ត មា ភាយិ អស្សស ។

---

១ ម. ឧភោ ។





(២១៥) (ព្រះមហាសត្វ...) បពិត្រព្រះសម្មតិទេព ការរស់នៅរបស់យើងខ្ញុំ ជាការរស់នៅផ្តេសផ្តាស យើងខ្ញុំជាអ្នករស់នៅ ត្រដាបត្រដួស ព្រោះការរស់នៅដោយការស្វែងរក (ផលាផល) ។ បពិត្រមហារាជ (សេចក្ដីទុរគត)របស់យើងខ្ញុំនោះ (ក្រសកំសត់) ដូចជាកាយសារថីខ្ទេចខ្ទាំ យើងខ្ញុំតាំងនៅ ជាបុគ្គលមានសេចក្ដីទុក្ខគ្រប់ខាងហើយ សេចក្ដីទុក្ខទោសរបស់យើងខ្ញុំ ។ បពិត្រមហារាជ យើងខ្ញុំស្គាំស្គម និងកំសត់ហើយ មានសេចក្ដីសោកនៅក្នុងព្រៃ តាំងសាច់ឈាមខ្សៀតសោកក៏ស្ងំស្ងួម ព្រោះមិនបានឃើញព្រះមាតាបិតា ។

(២១៦) កុមារទាំងពីរ គឺជាលី និងកណ្ហាជិនា ដែលជាចៅ (ព្រះកជន្តា) របស់ព្រះអង្គ ជាបុគ្គលប្រសើរបំផុតក្នុងផែនដី មាន បំណងមិនទាន់បានសម្រេចនៅឡើយ លុះតែណាបព្រាហ្មណ៍ ជា បុគ្គលឈ្លានពានលើសលប់ ដែលកុមារទាំងពីរ ដូចជាគោ ហ្វូងគោ ។ បើព្រះអង្គជ្រាបថា បុត្រទាំងពីររបស់រាជបុត្រី សូមប្រាប់ ដល់យើងខ្ញុំឱ្យឆាប់ ដូចជា (ពួកពេទ្យដែលព្យាបាល) នូវមាណព ត្រូវពស់ចឹក ។

(២១៧) (ព្រះរាជា...) កុមារទាំងពីរ គឺជាលី និងកណ្ហាជិនានេះ ចៅបាន ប្រគល់ទ្រព្យឱ្យដល់ព្រាហ្មណ៍ ហើយរួចមកហើយ ចៅកុំភ័យឡើយ ចូរស្រួលចិត្តចុះ ។

(៦៥៨) កច្ចិ នុ តាត កុសលំ កច្ចិ តាត អនាមយំ
កច្ចិ នុ តាត មេ មាតុ ចក្ខុំ ន បរិហាយតិ ។

(៦៥៩) កុសលញ្ចេវ មេ បុត្ត អថោ បុត្ត អនាមយំ
អថោ ច បុត្ត តេ មាតុ ចក្ខុំ ន បរិហាយតិ ។

(៦៦០) កច្ចិ អរោគំ យោគ្គន្តេ កច្ចិ វហតិ វាហនំ
កច្ចិ ផីតោ ជនបទោ កច្ចិ វុដ្ឋិ ន ឆិជ្ជតិ ។

(៦៦១) អថោ អរោគំ យោគ្គម្មេ អថោ វហតិ វាហនំ
អថោ ផីតោ ជនបទោ អថោ វុដ្ឋិ ន ឆិជ្ជតិ ។

(៦៦២) ឥច្ចេវំ មន្តយន្តានំ មាតា នេសំ អទិស្សថ
រាជបុត្តី គិរិទ្វារេ បត្តិកា អនុបាហនា ។
តញ្ច ទិស្វាន អាយន្តឹ មាតរំ បុត្តគិទ្ធិនឹ
វេស្សន្តរោ ច មទ្ទី ច បច្ចុគ្គន្ត្វា អវន្ទិសុំ ។
មទ្ទី ច សិរសា បាទេ សស្សុយា អភិវាទយិ
មទ្ទី អហញ្ហិ តេ អយ្យេ បាទេ វន្ទាមិ តេ សុណិសា[១] ។

---
១ ម. តេ សុណ្ហា ។



(៦៥៨) (ព្រះមហាសត្វ...) បពិត្រព្រះបិតា ព្រះអង្គសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានរោគាពាធទេឬ បពិត្រព្រះបិតា ព្រះនេត្រ របស់ព្រះមាតានៃខ្ញុំព្រះអង្គ មិនទាន់ងងឹតទេឬ ។

(៦៥៩) (ព្រះរាជា...) នែបុត្រ យើងសុខសប្បាយទេ នែបុត្រ យើងមិនមានជម្ងឺដង្កាត់ទេ នែបុត្រ ចក្ខុមាតារបស់ឯង មិនទាន់ងងឹតទេ ។

(៦៦០) (ព្រះមហាសត្វ...) យានរបស់ព្រះអង្គមិនទាន់ចាស់ទេឬ វាហនៈ រមែងនាំទៅបានទេឬ ជនបទសម្បូរដែរឬ ភ្លៀងមិនដាច់ទេឬ ។

(៦៦១) (ព្រះរាជា...) យានរបស់យើងមិនទាន់ចាស់ទេ ទាំងវាហនៈក៏នាំទៅបាន ជនបទក៏សម្បូរ ទាំងភ្លៀងក៏មិនដាច់ទេ ។

(៦៦២) (អភិសម្ពុទ្ធគាថា) កាលដែលក្សត្រិយ៍ទាំងពីរអង្គ កំពុងចរចា យ៉ាងនេះឯង ព្រះរាជបុត្រី ជាព្រះមាតា ស្តេចមកដោយព្រះបាទា ឥតមានស្បែកបាទ ប្រាកដដល់ក្សត្រិយ៍ទាំងនោះទៀបទ្វារភ្នំ ។ ឯព្រះបាទវេស្សន្តរ នឹងព្រះនាងមទ្រី បានឃើញព្រះមាតានោះ ដែលមានព្រះហឫទ័យជាប់ក្នុងបុត្រ កំពុងយាងមក ក៏ក្រោកទទួល ហើយថ្វាយបង្គំ ។ ចំណែកខាងព្រះនាងមទ្រី ថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមាតាក្មេកដោយព្រះសិរ្ស (ហើយក្រាបបង្គំទូលថា) បពិត្រព្រះមេម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនាងមទ្រី ជាព្រះសុណិសារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមេ ។

(៦៦៣) មទ្ទិញ្ច បុត្តកា ទិស្វា ទូរតោ សោត្ថិមាគតា
កន្ទន្តា អភិធាវិំសុ វច្ឆា ពាលាវ មាតរំ ។
មទ្ទី ច បុត្តកេ ទិស្វា ទូរតោ សោត្ថិមាគតេ
វារុណីវ បវេធន្តី ថនធារាភិសិញ្ចថ ។

(៦៦៤) សមាគតានំ ញាតីនំ មហាឃោសោ អជាយថ
បព្វតា សមនាទិំសុ[1] មហី អកម្បិតា អហុ ។
វុដ្ឋិធារំ បវត្តេន្តោ ទេវោ បាវស្សិ តាវទេ
អថ វេស្សន្តរោ រាជា ញាតីហិ សមគញ្ឆថ ។
នត្តារោ សុណិសា បុត្តោ រាជា ទេវី ច ឯកតោ
យទា សមាគតា អាសុំ តទាសិ លោមហំសនំ ។
បញ្ជលិកា តស្ស យាចន្តិ រោទន្តា ភេរវេ វនេ
វេស្សន្តរញ្ច មទ្ទិញ្ច សព្វេ រដ្ឋា សមាគតា
ត្វំ នោសិ ឥស្សរោ រាជា រជ្ជំ ការេថ នោ ឧភោ ។

ឆក្ខត្តិយបព្វំ ៣ម ។

១ ឱ សុំនាទិំសុ ។



(៦៦៣) ចំណែកខាងព្រះរាជបុត្រទាំងពីរ ដែលមកអំពីទីឆ្ងាយដោយសួស្តី បានឃើញព្រះនាងមទ្រីហើយ ក៏ស្រែកព្រះកន្សែងស្ទួលគាក់ទាំងគ្នាស្ទុះចូលទៅរក ដូចកូនគោតូច ស្ទុះទៅរកមេ ។ ឯព្រះនាងមទ្រី បានឃើញបុត្រទាំងពីរ ដែលមកពីទីឆ្ងាយដោយសួស្តី ក៏ញាប់ញ័រដូចជាស្រវឹងមក ទាំងទឹកដោះក៏ហូរចេញមក ។

(៦៦៤) កាលពួកព្រះញាតិជួបជុំគ្នាហើយ សំឡេងកងរំពង ក៏កើតឡើង ភ្នំទាំងឡាយក៏បន្លឺឡើង ផែនដីផងសុធា ក៏កក្រើកញាប់ញ័រ ។ ភ្លៀងក៏ធ្លាក់ធ្លាទឹកឲ្យធ្លាក់ក្នុងខណៈនោះ ព្រះបាទវេស្សន្តរ ក៏បានជួបនឹងញាតិទាំងឡាយក្នុងខណៈនោះ ។ ព្រះនត្តាទាំងពីរ ព្រះសុណិសា ព្រះរាជបុត្រ ព្រះរាជានឹងព្រះទេវី បានជួបក្នុងទីជាមួយគ្នាក្នុងកាលណា សេចក្តីព្រឺព្រួចរោមក៏មានក្នុងកាលនោះ ពួកអ្នកនគរទាំងអស់ បានផ្គងអញ្ជលី ចំពោះព្រះបាទវេស្សន្តរនោះ នាំគ្នាយំក្នុងព្រៃ មានសូរឲ្យស្ញប់ស្ញែង ទូលអង្វរថា ។ ពួករាស្ត្រទាំងអស់ជួបជុំគ្នា (បានពោល) នឹងព្រះបាទវេស្សន្តរផង នឹងព្រះនាងមទ្រីផងថា ព្រះអង្គជាព្រះរាជាជាឥស្សរៈរបស់ពួកយើង សូមព្រះអង្គទាំងពីរព្រះអង្គសោយរាជសម្បត្តិ ។

ចប់ ឆក្ខត្តិយបព្វៈ ។

(៦៦៤) ធម្មេន រដ្ឋំ ការេន្តំ រដ្ឋា បព្វាជយិត្ថ មំ
កុទ្ធា ជានបទា ចេវ នេគមា ច សមាគតា ។

(៦៦៥) ទុក្កដញ្ច ហិ នោ បុត្ត ភូនហច្ចំ កតំ មយា
យោហំ សិវីនំ វចនា បព្វាជេសិំ អទូសកំ ។

(៦៦៦) យេន កេនចិ វណ្ណេន បិតុ ទុក្ខំ ឧទព្វហេ
មាតុយា ភគិនិយាបិ អបិ បាណេហិ អត្តនោ
(ន្ហាណកាលោ មហារាជ រជោជល្លំ បវាហយ) ។

(៦៦៧) តតោ វេស្សន្តរោ រាជា រជោជល្លំ បវាហយិ
រជោជល្លំ បវាហេត្វា សង្ខវណ្ណំ អធារយិ ។

(៦៦៨) សីសំ ន្ហាតោ សុចិវត្ថោ សព្វាភរណភូសិតោ
បច្ចយំ នាគមារុយ្ហ ខគ្គំ ពន្ធិ បរន្តបំ ។
តតោ សដ្ឋី សហស្សានិ យោធិនោ ចារុទស្សនា
សហជាតា បរិកិរុំ នន្ទយន្តា រថេសភំ ។



(៦៦៤) (ព្រះមហាសត្វ...) ព្រះអង្គទ្រង់ពួកអ្នកជនបទ អ្នកនិគម បានព្រមព្រៀងគ្នានិរទេសខ្ញុំព្រះអង្គ ដែលកំពុងសោយរាជ្យ តាមធម៌ ចាកដែនហើយ ។

(៦៦៥) (ព្រះរាជា...) ម្នាលបុត្រ (នេះ) ពិតជាកំហុសរបស់យើង យើងបានធ្វើអំពើបំផ្លិចបំផ្លាញសេចក្ដីចំរើន បាននិរទេសបាដែលមិនមានកំហុស ព្រោះតាមពាក្យពួកអ្នកសីវិរដ្ឋ ។

(៦៦៦) (កូន) គួរដោះទុក្ខរបស់បិតាមាតា ឬរបស់បងប្អូនស្រី ដោយហេតុណាមួយ សូម្បីដោយជីវិតរបស់ខ្លួន ។ (ពួកអាមាត្យបានពោលថា បពិត្រមហារាជ កាលនេះជាកាលគួរស្រង់ទឹក សូមទ្រង់ផុសជម្រះព្រះរជោជលៈ) ។

(៦៦៧) (អភិសម្ពុទ្ធគាថា) គ្រានោះ ព្រះបាទវេស្សន្តរក៏ផុសជម្រះធូលី លុះផុសជម្រះធូលីហើយ បានទ្រង់ទ្រង់ព្រះពស្ត្រមានពណ៌ដូចស័ង្ខ ។

(៦៦៨) ព្រះបាទវេស្សន្តរ ទ្រង់កក់ព្រះសិរ្ស មានព្រះពស្ត្រស្អាត ស្អិតស្អាងដោយគ្រឿងអាភរណៈគ្រប់យ៉ាង ទ្រង់សៀតព្រះខាន់ដែលដុតកំដៅសត្រូវ ហើយទ្រង់ឡើងគង់លើដំរីប្រសើរ ឈ្មោះបច្ច័យ ។ កាលនោះ ពួកទាហាន ៦០.០០០នាក់ កើតក្នុងថ្ងៃជាមួយគ្នា គួររមិលមើល ញ៉ាំងព្រះរាជាជាធំក្នុងរថឲ្យរីករាយ ហោមរោម ។

តតោ មទ្ទិម្បិ ន្ហាបេសុំ សិវិកញ្ញា សមាគតា

វេស្សន្តរោ ច បាលេតុ ជាលី កណ្ហាជិនា ចុភោ

អថោបិ តំ មហារាជា សញ្ជយោ អភិរក្ខតុ ។

(៦៣០) ឥទញ្ច បច្ចយំ លទ្ធា បុព្វេ ក្លេសមត្តនោ[១]

អានន្ទិយំ អចារិសុំ រមណីយេ គិរិព្វជេ ។

ឥទញ្ច បច្ចយំ លទ្ធា បុព្វេ ក្លេសមត្តនោ

អានន្ទចិត្តា សុមនា បុត្តេ សង្គម្ម លក្ខណា ។

ឥទញ្ច បច្ចយំ លទ្ធា បុព្វេ ក្លេសមត្តនោ

អានន្ទចិត្តា បតីតា សហ បុត្តេហិ លក្ខណា ។

(៦៣១) ឯកភត្តា បុរេ អាសឹ និច្ចំ ថណ្ឌិលសាយិនី

ឥតិ មេតំ វតំ អាសិ តុម្ហំ កាមា ហិ បុត្តកា

---

១ ម. បុព្វេ សល្លេខមត្តនោ ។



កាលនោះពួកកញ្ញារបស់ព្រះបាទសិវី បានជួបជុំគ្នា ហើយញ៉ាំងព្រះនាងមទ្រីឲ្យស្រង់ទឹក (ហើយពោលថា) សូមព្រះបាទវេស្សន្តរ នឹងជាលីកណ្ហាជិនាទាំងពីរ បីបាច់ថែរក្សាព្រះនាង ទាំងមហារាជព្រះនាមសញ្ជ័យ ក៏សូមឲ្យថែរក្សាព្រះនាងផង ។

(៦៣០) ព្រះបាទវេស្សន្តរនឹងព្រះនាងមទ្រី បាននូវទីពឹងនេះ (បាននឹកដល់ក្តីកង្វល់សម្បត្តិ ហើយក្តុករឭក) នូវសេចក្តីសៅហ្មងរបស់ព្រះអង្គ (ដែលទ្រង់ធ្លាប់នៅក្នុងព្រៃពីដើម) ក៏ទ្រង់ឲ្យធ្វើការនន្ទិយភេរីក្រាប់ ទៅទៀបភ្នំក្តុក ដែលគួរជាទីរីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈ បានទីពឹងនេះហើយ (ក៏ក្តុករឭក) នូវសេចក្តីសៅហ្មងរបស់ព្រះនាង ដែលធ្លាប់នៅក្នុងព្រៃពីដើម បានជួបនឹងបុត្រទាំងពីរ ហើយក៏ត្រេកអររីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈ បានទីពឹងនេះហើយ ក៏មានព្រះហឫទ័យក្តុករឭកសេចក្តីសៅហ្មង របស់ព្រះនាង ដែលធ្លាប់នៅក្នុងព្រៃពីដើម មានចិត្តត្រេកអររីករាយជាមួយនឹងបុត្រទាំងពីរ ។

(៦៣១) (ព្រះនាងមទ្រី...) នែបុត្រទាំងពីរ កាលពីដើម មាតាជាអ្នកបរិភោគភត្តតែមួយពេល ដេកផ្ទាល់នឹងផែនដីជានិច្ច នេះជាវត្តរបស់មាតាផ្ទាល់ ព្រោះសេចក្តីប្រាថ្នាចង់ (ជួប) នឹងបុត្រទាំងពីរ

តំ មេ វតំ សមិទ្ធជ្ជ    តុម្ហេ សង្គម្ម បុត្តកេ

មាតុជំបិ តំ បាលេតុ    បិតុជំបិ ច បុត្តកា

អជោបិ តំ មហារាជា    សញ្ជយោ អភិរក្ខតុ ។

យង្កិញ្ចិត្ថិ កតំ បុញ្ញំ    មយ្ហញ្ចេវ បិតុច្ច តេ

សព្វេន តេន កុសលេន    អជរោ អមរោ ភវ ។

(៤៣៦) កប្បាសិកញ្ច កោសេយ្យំ ខោមកោទុម្ពរានិ ច

សស្សុ សុណ្ហាយ បាហេសិ    យេហិ មទ្ទី អសោភថ ។

តតោ ហេមញ្ច កាយូរំ    គីវេយ្យំ រតនាមយំ

សស្សុ សុណ្ហាយ បាហេសិ    យេហិ មទ្ទី អសោភថ ។

តតោ ហេមញ្ច(១) កាយូរំ    អង្គទំ មណិមេខលំ

សស្សុ សុណ្ហាយ បាហេសិ    យេហិ មទ្ទី អសោភថ ។

ឧណ្ណតំ មុខផុល្លញ្ច    នានារត្តេ ច មាណិយេ

សស្សុ សុណ្ហាយ បាហេសិ    យេហិ មទ្ទី អសោភថ ។

១ ឱ. ហេមញ្ច ។



ម្នាលបុត្រទាំងពីរ វត្តនោះ សម្រេចដល់មាតា ក្នុងថ្ងៃនេះហើយ ព្រោះបានជួបនឹងបុត្រទាំងពីរ ម្នាលបុត្រទាំងពីរ សូមឲ្យបុណ្យ ដែលកើតអំពីមាតា នឹងកើតអំពីបិតារក្សាបា ទាំងមហារាជ ព្រះនាមសញ្ជ័យ ក៏សូមឲ្យរក្សាបា ។ បុណ្យណាមួយ ដែលមាតាក្តី បិតាក្តី របស់បាបានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមបា កុំចាស់ កុំស្លាប់ឡើយ ។

(៤៣៦) (អភិសម្ពុទ្ធគាថា) ព្រះសស្សុ បានបញ្ជូនកប្បាសិកវត្ថ្រ កោសេយ្យវត្ថ្រ ខោមវត្ថ្រ នឹងកោទុម្ពរវត្ថ្រ ទៅថ្វាយព្រះសុណ្ហា ដែលជាសំពត់ សម្រាប់លំអព្រះនាងមទ្រី ។ លំដាប់តមក ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសុវណ្ណ ជាវិការៈនៃមាស នឹងគ្រឿងប្រដាប់ព្រះសុវណ្ណ ជាវិការៈនៃកែវ ទៅថ្វាយព្រះសុណ្ហា ដែលជាគ្រឿងប្រដាប់សម្រាប់លំអរបស់ព្រះនាងមទ្រី ។ លំដាប់តមកទៀត ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសុវណ្ណ ជាវិការៈនៃមាស នឹងកងដៃនឹងខ្សែក្រវាត់ ជាវិការៈនៃកែវមណី ទៅថ្វាយព្រះសុណ្ហាដែលជាគ្រឿងប្រដាប់លំអរបស់ព្រះនាងមទ្រី ។ ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ថ្ងាស ជាគ្រឿងប្រដាប់ សម្រាប់ព្រះភក្ត្រ ទាក់ណាំផ្សេងៗ ដែលជាវិការៈនៃកែវមណី ទៅថ្វាយព្រះសុណ្ហា ដែលជាគ្រឿងប្រដាប់លំអ របស់ព្រះនាងមទ្រី ។

ឧក្កដ្ឋិ តិដ្ឋមានំ    មេខលី ជជិតាធុតំ
សស្សុ សុណ្ហាយ តាមោសិ យេហិ មទ្ទី អសោកដេ ។
សុត្តញ្ច សុត្តវជ្ជញ្ច    ឧបធិញ្ញយ សេយ្យសំ
អសោកដេ ភជន្តី    ទេវកញ្ញាវ នន្ទនេ ។
សីសណ្ហាតា សុចិវត្ថា    សព្វាភរណភូសិតា
អសោកដេ ភជន្តី    តាវត្តឹសាវ អច្ឆរា ។
កទលីវ វាតច្ឆុបិតា    ជាតា ចិត្តលតាវនេ
ទន្តាវរណសម្បន្នា    ភជន្តី អសោកដេ ។
សកុណី មានុសិនីវ    ជាតា ចិត្តបត្តា បតិ
និគ្រោធបក្កពិម្ពោដ្ឋី    ភជន្តី អសោកដេ ។
(៤៣៣)តស្សា ច នាគមានេសុំ នាតិវុឌ្ឍំ កុញ្ជរំ
សត្តិក្ខមំ សរក្ខមំ    ឦសាទន្តំ ឧរូឡ្ហវំ ។
សា មទ្ទី នាគមារុហិ    នាតិវុឌ្ឍំ កុញ្ជរំ
សត្តិក្ខមំ សរក្ខមំ    ឦសាទន្តំ ឧរូឡ្ហវំ ។





ព្រះសស្សុបានបញ្ជូន ឲ្យគ្រឿងប្រដាប់សម្រាប់ព្រះស្នុស គឺគ្រឿងប្រដាប់ស្មា គឺខ្សែក្រវាត់ កងជើង ទៅថ្វាយព្រះសុណ្ហា ដែលជាគ្រឿងប្រដាប់លំអព្រះមទ្រី ។ ព្រះរាជបុត្រីជាស្រីប្រសើរ បានតែងអង្គមើលគ្រឿងប្រដាប់ល្អិតដោយគំនោរ គឺគ្រឿងប្រដាប់រៀបតាមគំនោរ ដ៏ល្អក្រពេក ហាក់ដូចទេវកញ្ញាក្នុងនន្ទនវ័ន ។ ព្រះរាជបុត្រី កក់ព្រះសិរ្ស មានព្រះពស្ត្រដ៏ស្អាត ស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង ដ៏ល្អក្រពេក ហាក់ដូចស្ត្រីអប្សរក្នុងឋានត្រៃត្រិង្ស ។ ព្រះរាជបុត្រីចាប់ផ្ដើមដោយរបៀបនៃចង្កេះញាប់ញ័រ ល្អក្រពេក ហាក់ដូចដើមចេក ដែលកើតក្នុងចិត្តលតាវ័ន ត្រូវខ្យល់បក់បោកហើយ ។ ព្រះរាជបុត្រី មានបបូរមាត់ដូចផ្លែជ្រៃទុំ គឺផ្លែជ្រៃទុំ ល្អក្រពេក ហាក់ដូចបក្សី មានសរីរៈសព្វគ្រប់ ដូចជាសរីរៈនៃមនុស្ស មានស្លាបដ៏វិចិត្រ (ហើរក្នុងអាកាស) ។

(៤៣៣) ពួកអាមាត្យនាំដំរីដ៏ប្រសើរ មិនចាស់ពេក អត់ទ្រាំលំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុក-ដ៏ទន្ទាំ កាចតាស់រំលើងសត្រូវបាន មកថ្វាយព្រះនាងមទ្រីនោះ ។ ព្រះនាងមទ្រីនោះឡើងកាន់ដំរីដ៏ប្រសើរ មិនចាស់ពេក អត់ទ្រាំលំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុក-ដ៏ទន្ទាំ កាចតាស់រំលើងសត្រូវបាន ។

(៦៣៦) សព្វស្មិំ តំ អរញ្ញស្មិំ យាវន្តេត្ថ មិគា អហុ
វេស្សន្តរស្ស តេជេន នាញ្ញមញ្ញំ វិហេឋយុំ ។
សព្វស្មិំ តំ អរញ្ញស្មិំ យាវន្តេត្ថ ទិជា អហុ
វេស្សន្តរស្ស តេជេន នាញ្ញមញ្ញំ វិហេឋយុំ ។
សព្វស្មិំ តំ អរញ្ញស្មិំ យាវន្តេត្ថ មិគា អហុ
ឯកជ្ឈំ សន្និបាតឹសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សព្វស្មិំ តំ អរញ្ញស្មិំ យាវន្តេត្ថ ទិជា អហុ
ឯកជ្ឈំ សន្និបាតឹសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សព្វស្មិំ តំ អរញ្ញស្មិំ យាវន្តេត្ថ មិគា អហុ
នាស្សុ មញ្ជុំ និកូជឹសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សព្វស្មិំ តំ អរញ្ញស្មិំ យាវន្តេត្ថ ទិជា អហុ
នាស្សុ មញ្ជុំ និកូជឹសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។



(៦៣៦) ពួកម្រឹគទាំងប៉ុន្មាន ដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ មិនបៀតបៀនគ្នានឹងគ្នា ដោយតេជះនៃព្រះបាទវេស្សន្តរ ។ ពួកបក្សីទាំងប៉ុន្មាន ដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ មិនបៀតបៀនគ្នានឹងគ្នា ដោយតេជះនៃព្រះបាទវេស្សន្តរ ។ កាលព្រះបាទវេស្សន្តរ ញុំាងដែនអ្នកសីវិរដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីព្រៃ) ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ បានមកប្រជុំក្នុងទីជាមួយគ្នា ។ កាលព្រះបាទវេស្សន្តរ ញុំាងដែនអ្នកសីវិរដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីព្រៃ) ពួកបក្សីទាំងប៉ុន្មាន ដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ បានមកប្រជុំក្នុងទីជាមួយគ្នា ។ កាលព្រះបាទវេស្សន្តរ ញុំាងដែនអ្នកសីវិរដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីព្រៃ) ពួកម្រឹគទាំងប៉ុន្មាន ដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ លែងបន្លឺសំឡេងពីរោះ ។ កាលព្រះបាទវេស្សន្តរ ញុំាងដែនអ្នកសីវិរដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីព្រៃ) ពួកបក្សីទាំងប៉ុន្មាន ដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ លែងបន្លឺសំឡេងពីរោះ ។

(៦៣៩) បដិយត្តា រាជមគ្គា វិចិត្តា បុប្ផសន្ថតា
វសិ វេស្សន្តរោ រាជា យត្ថ យាតិ ជេតុត្តរា ។
ឥតោ សដ្ឋី សហស្សានិ យោធិនោ ចារុទស្សនា
សមន្តា បរិកិរីសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ឥត្ថាគារា ច កុមារា ច វេសិយានា ច ព្រាហ្មណា
សមន្តា បរិកិរីសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
សមន្តា បរិកិរីសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សមាគតា ជានបទា នេគមា ច សមាគតា
សមន្តា បរិកិរីសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ករោដិយា ចម្មធរា ខគ្គហត្ថា សុវម្មិកា
បុរតោ បដិបជ្ជិំសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។



(៦៣៩) ក្នុងកាលមាគ៌ាបានរៀបចំរាជមាគ៌ា ឲ្យក្រាលទន្ទោស ត្រៀបត្រាដោយល្អ គឺផ្កាវិចិត្រ ដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ហេតុដល់ក្រុងជេតុត្តរ ។ លំដាប់នោះ កាលព្រះបាទវេស្សន្តរ ញុំាងអ្នកសិវិករដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីក្រុង) ពួកយោធាចំនួន ៦០,០០០ ល្អមើល បាននាំគ្នាហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរ ញុំាងពួកអ្នកសិវិករដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីក្រុង) ពួកស្រីស្នំផង ពួករាជកុមារផង ពួកអ្នកជំនួញផង ពួកព្រាហ្មណ៍ផង ហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរ ញុំាងពួកអ្នកសិវិករដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីក្រុង) ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរ ញុំាងពួកអ្នកសិវិករដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីក្រុង) ពួកអ្នកជនបទ ក៏បានមកជួបជុំគ្នា និងអ្នកនិគម ក៏បានមកជួបជុំគ្នា ហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរ ញុំាងពួកអ្នកសិវិករដ្ឋឲ្យចំរើន ទ្រង់យាងចេញ (អំពីក្រុង) ពួកទាហានពាក់មួក ទ្រទ្រង់ខែល កាន់ដាវ ចងគ្រឿងក្រោះដ៏ល្អ ដើរហែខាងមុខ ។

(៨៣៦) តេ បាវិសុំ បុរំ រម្មំ មហាបាការតោរណំ
ឧបេតំ អន្នបានេហិ នច្ចគីតេហិ ចូភយំ ។
វិត្តា ជានបទា អាសុំ នេគមា ច សមាគតា
អនុប្បត្តេ កុមារម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ចេលុក្ខេបោ អវត្តិត្ថ អាគតេ ធនទាយកេ
នន្ទិប្បវេសិ នគរេ ពន្ធនា មោក្ខោ អឃោសថ ។
(៨៣៧) ជាតរូបមយំ វស្សំ ទេវោ បាវស្សិ តាវទេ
វេស្សន្តរេ បវិដ្ឋម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
តតោ វេស្សន្តរោ រាជា ទានំ ទត្វាន ខត្តិយោ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជថាតិ ។

នគរកណ្ឌំ តេរស ។

មហាវេស្សន្តរជាតកំ ទសមំ ។

មហានិបាតំ និដ្ឋិតំ ។

---





(៨៣៦) ក្សត្រិយ៍ទាំងនោះ បានយាងចូលទៅកាន់បុរី ជាក្រុងគួរឲ្យត្រេកអរ មានកំពែងនិងទ្វារខាងក្រៅធំច្រើន ប្រកបដោយគ្រឿងស៊ីនិងគ្រឿងផឹក មានទាំងល្បែងពីរយ៉ាង គឺរាំនិងច្រៀង ។

កាលកុមារ ញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យចំរើន ស្តេចមកដល់ ពួកអ្នកជនបទ និងពួកអ្នកនិគម បានមកជួបជុំគ្នា ត្រេកអរ ។

កាលព្រះមហាក្សត្រិយ៍ ជាអ្នកប្រទានព្រះរាជទ្រព្យ ស្តេចមកដល់ហើយ ពួកមហាជន ក៏នាំគ្នាលើកទង់ជ័យ ទូង[illegible] ហើយ ចូលទៅក្នុងនគរ ព្រះបាទវេស្សន្តរ ក៏ទ្រង់ឲ្យឃោសនា ដើម្បីឲ្យដោះលែងសព្វសត្វ ចាកចំណង ។

(៨៣៧) កាលព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរដ្ឋឲ្យចំរើន ស្តេចចូលមកដល់ សក្កទេវតាដែលជាឧបបត្តិទេព បានបង្អុរភ្លៀងជាវិការៈនៃមាស ។ លំដាប់នោះ ព្រះបាទវេស្សន្តរជាក្សត្រិយ៍ប្រកបដោយប្រាជ្ញា ទ្រង់ឲ្យទាន លុះបែកធ្លាយរាងកាយទៅ ក៏បានស្តេចទៅកើតក្នុងឋានសួគ៌ទេវលោក ។

ចប់ នគរកណ្ឌ ។

ចប់ មហាវេស្សន្តរជាតក ទី ១០ ។

ចប់ មហានិបាត ។